# រាជរដ្ឋាភិបាលកម្ពុជា
# គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ




# វេទិកាជាតិលើកទី៣
# ស្តីពីការប្រែប្រួលអាកាសធាតុ

# របាយការណ៍

ថ្ងៃទី០៥ ដល់ ០៧ ខែវិច្ឆិកា ឆ្នាំ២០១៣

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**រៀបចំដោយ៖**

ក្រសួងបរិស្ថាន

**ឧបត្ថម្ភដោយ៖**

CAMBODIA CLIMATE CHANGE ALLIANCE

Implemented by: Supported by:

Ministry of Environment · European Union · UNDP · Danida · SWEDEN · UNEP · christian aid · The NGO Forum on Cambodia · CCCN

# របាយការណ៍ វេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ

ថ្ងៃទី០៥ ដល់ ០៧ ខែវិច្ឆិកា ឆ្នាំ២០១៣
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**បោះពុម្ពដោយ ៖**
ក្រសួងបរិស្ថាន
រាជធានីភ្នំពេញ កម្ពុជា

**© ក្របមុខ និងរូបថត ៖ កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា**

**សេចក្តីបដិសេធ ៖**

ក្រសួងបរិស្ថាន និងម្ចាស់ជំនួយមិនទទួលខុសត្រូវចំពោះការបញ្ចេញមតិ និងទស្សនៈទាំងឡាយដែលបានសរសេរ និងលើកឡើងដោយវាគ្មិន នៅក្នុងឯកសារបោះពុម្ពផ្សាយនេះទេ។ ក្រសួងបរិស្ថាន និងម្ចាស់ជំនួយមិនបានព្រមព្រៀង លើកទឹកចិត្ត ឬណែនាំនូវការបង្ហាញស្លាកសញ្ញាពាណិជ្ជកម្ម ឬផលិតករណាមួយ ដែលអាចមាននៅក្នុងឯកសារបោះពុម្ពផ្សាយនេះឡើយ។

© រក្សាសិទ្ធិគ្រប់យ៉ាងដោយក្រសួងបរិស្ថាន
បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា

# អារម្ភកថា

បន្ទាប់ពីវេទិកាជាតិលើកទី១ និងលើកទី២ បានកន្លងផុតទៅ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (គ.ជ.គ.ប.អ.) ដែលមាននាយកដ្ឋានប្រែប្រួលអាកាសធាតុ (CCD) នៃក្រសួងបរិស្ថាន (MoE) ជាលេខាធិការដ្ឋាន បានរៀបចំវេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ (3rd National Forum on Climate Change: 3rd NFCC) នៅរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី០៥ ដល់ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៣ ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹង និងចែករំលែកចំណេះដឹង ក៏ដូចជាបទពិសោធន៍អំពីការប្រែប្រួលអាកាសធាតុ ដែលជាបញ្ហាអន្តរវិស័យ ហើយតម្រូវការឱ្យមានការចូលរួមដោះស្រាយពីស្ថាប័នរាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធនានា រួមទាំង វិស័យឯកជន ស្ថាប័នសិក្សាស្រាវជ្រាវ អង្គការមិនមែនរដ្ឋាភិបាល (NGOs) និងសង្គមស៊ីវិល (CSOs)។

ភាគីពាក់ព័ន្ធជាច្រើនបានចុះឈ្មោះ និងចូលរួមនៅក្នុងវគ្គផ្សេងៗនៃវេទិកាជាតិនេះ រួមទាំងមន្ត្រីរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់នៃក្រសួង-ស្ថាប័នពាក់ព័ន្ធនានា។ វេទិកាជាតិនេះ មានកិត្តិយសដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានអញ្ជើញមកថ្លែងសុន្ទរកថាក្នុងពិធីបើក។ នៅថ្ងៃទី១ ទី២ និងទី៣ នៃអង្គវេទិកាជាតិ ឥស្សរជនជាតិ និងអន្តរជាតិសំខាន់ៗមួយចំនួន បានចូលរួមថ្លែងសុន្ទរកថាស្វាគមន៍ រួមមាន **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន **ឯកឧត្តម ខៀវ មុត** រដ្ឋលេខាធិការ ក្រសួងបរិស្ថាន លោកស្រី **Claire Van der Vaeren** មន្ត្រីសម្របសម្រួលនៃអង្គការសហប្រជាជាតិប្រចាំកម្ពុជា **ឯកឧត្តម ប៉ាន ប៊ុនធឿន** រដ្ឋលេខាធិការ ក្រសួងផែនការ **ឯកឧត្តម Jean-François Cautain** ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំកម្ពុជា **ឯកឧត្តម រស់ សីលវ៉ា** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលោក **Peter Brimble** នាយករងប្រចាំប្រទេសនៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។

វេទិកាជាតិនេះ បាននាំមកនូវលទ្ធផលជាផ្លែផ្កា តាមរយៈបទបង្ហាញ និងកិច្ចពិភាក្សា ហើយបានចែករំលែកនូវព័ត៌មាន បទពិសោធន៍ ព្រមទាំងបង្ហាញពីការប្តេជ្ញាចិត្តរបស់ភាគីពាក់ព័ន្ធទាំងអស់ក្នុងកិច្ចសហការរួមគ្នាដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។ វេទិកានេះមិនត្រឹមតែផ្តល់ការយល់ដឹងជាមូលដ្ឋានអំពីការប្រែប្រួលអាកាសធាតុ ដែលជាបញ្ហាអន្តរវិស័យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបញ្ជ្រាប និងពង្រឹងទស្សនទាននានាដល់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសបណ្តាក្រសួង-ស្ថាប័ននានា ឱ្យយកចិត្តទុកដាក់លើបញ្ហាប្រែប្រួលអាកាសធាតុ និងចាត់ទុកបញ្ហានេះជាអាទិភាពនៅក្នុងការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុប្រកបដោយប្រសិទ្ធភាព។ ព័ត៌មានពីវេទិកាជាតិនេះ មានសារៈសំខាន់ណាស់សម្រាប់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីលើកយកទៅពិភាក្សានៅក្នុងសន្និសីទបណ្តាភាគីលើកទី១៩ (COP 19) នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)។

ឯកសារនេះរួមមាន សេចក្តីសង្ខេបនៃរបាយការណ៍ពិស្តារ កិច្ចពិភាក្សាសំខាន់ៗ និងសេចក្តីសន្និដ្ឋានជាគន្លឹះ ដែលជាលទ្ធផលរបស់វេទិកាជាតិនេះ។ យើងសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា

កិច្ចពិភាក្សាដែលបានរៀបចំនៅក្នុងវេទិកាជាតិនេះ នឹងជួយជំរុញកិច្ចពិភាក្សាអំពីគោលនយោបាយ ការធ្វើសេចក្តីសម្រេចចិត្ត និងសកម្មភាពពាក់ព័ន្ធនានា ដែលកំពុងដំណើរការ ដើម្បីឱ្យប្រទេសកម្ពុជា ពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងសេដ្ឋកិច្ចដែលបញ្ចេញកាបូនតិច ហើយប្រើប្រាស់ឱកាសនិងការគាំទ្រដែលអាចទទួលបានក្នុងកិច្ចខិតខំឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់កាត់បន្ថយភាពក្រីក្រ តាមរយៈការគ្រប់គ្រងហានិភ័យអាកាសធាតុ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

សាយ សំអាល់

# មាតិកា

**អារម្ភកថា** ERROR! BOOKMARK NOT DEFINED.
**សេចក្តីថ្លែងអំណរគុណ** IV
**មាតិកា** V
**បញ្ជីអក្សរកាត់** VII
**សេចក្តីសង្ខេបប្រតិបត្តិ** 1
**សាវតា** 4
សនិទានភាព 4
គោលបំណង 5
**អ្នកចូលរួម** 6
**កម្មវិធី** 7
**សេចក្តីសង្ខេបលទ្ធផលសំខាន់ៗ៖ "ធ្វើសកម្មភាពឆ្ពោះទៅការអភិវឌ្ឍប្រកបដោយចីរភាពក្នុងបរិបទប្រែប្រួលអាកាសធាតុ** 12
វិទ្យាសាស្ត្រនៃការប្រែប្រួលអាកាសធាតុ វឌ្ឍនភាពនៃការអនុវត្ត និងផែនការយុទ្ធសាស្ត្រ 12
*បច្ចុប្បន្នភាពនៃព័ត៌មានវិទ្យាសាស្ត្រប្រែប្រួលអាកាសធាតុ៖ មូលហេតុ និងផលប៉ះពាល់* *12*
*ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុក្នុងប្រទេសកម្ពុជា និងតំបន់អាស៊ីអាគ្នេយ៍* *13*
*បច្ចុប្បន្នភាពការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជាដោយផ្តោតលើសកម្មភាពបន្តនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ* *15*
*ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា* *16*
យុទ្ធសាស្ត្រជាតិឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ៖ បទពិសោធន៍ទទួលបាន និងដំណើរឆ្ពោះទៅមុខ 17
*ការអប់រំការប្រែប្រួលអាកាសធាតុ ទំទាក់ទំនង និងយេនឌ័រ៖* *18*
*ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម និងធារាសាស្ត្រ* *21*
*ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត* *23*
*ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យសុខភាព អនាម័យ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ* *25*
*ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យព្រៃឈើ ជលផល និងស្ថានប្រព័ន្ធ* *27*
*ការកាត់បន្ថយការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យឧស្សាហកម្ម និងថាមពល* *29*
*ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងការគ្រប់គ្រងគ្រោះមហន្តរាយ* *30*
*ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ នៅក្នុងតំបន់ឆ្នេរ និងវិស័យទេសចរណ៍* *32*
*វឌ្ឍនភាពរបស់កម្ពុជាក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងដំណើរឆ្ពោះទៅកាន់សកម្មភាពជាតិសមស្របសម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (NAMA)* *34*
កិច្ចសហប្រតិបត្តិការរបស់ប្រទេសកម្ពុជា និងអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ 36

**សេចក្តីសន្និដ្ឋាន** 39
**ឧបសម្ព័ន្ធ** 40
ឧបសម្ព័ន្ធទី ១៖ របៀបវារៈ 40
ឧបសម្ព័ន្ធទី២៖ បើកវេទិកា និងសុន្ទរកថាបិទ 49
ឧបសម្ព័ន្ធទី៣៖ ប្រវត្តិរូបសង្ខេប 87
ឧបសម្ព័ន្ធទី៤៖ បទបង្ហាញ 101
ឧបសម្ព័ន្ធទី ៥៖ បញ្ជីរាយនាមអ្នកចូលរួម 221
ឧបសម្ព័ន្ធទី៦៖ សេចក្តីប្រកាសព័ត៌មាន 237

# បញ្ជីអក្សរកាត់

| | |
|---|---|
| 3rd NFCC | វេទិកាជាតិលើកទី៣ ស្ដីពីការប្រែប្រួលអាកាសធាតុ |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AFOLU | វិស័យកសិកម្ម ព្រៃឈើ និងការប្រើប្រាស់ដីធ្លី |
| AusAID | ទីភ្នាក់ងារអូស្ត្រាលី ដើម្បីការអភិវឌ្ឍអន្តរជាតិ |
| CARD | ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ |
| CCAI | កិច្ចផ្តួចផ្តើមការប្រែប្រួលអាកាសធាតុ និងបន្សាំ |
| CCAP | ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ |
| CCCA | កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា |
| CCCN | បណ្ដាញប្រែប្រួលអាកាសធាតុកម្ពុជា |
| CCCSP | ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា |
| CCD | នាយកដ្ឋានប្រែប្រួលអាកាសធាតុ |
| CDM | យន្តការអភិវឌ្ឍន៍ស្អាត |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា |
| CNMC | គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា |
| $CO_2$ | ឧស្ម័នកាបូនិក |
| COP | សន្និសទបណ្តាភាគីនៃអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ |
| CSOs | អង្គការសង្គមស៊ីវិល |
| DANIDA | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសដាណឺម៉ាក |
| DCA/CA | អង្គការជំនួយរបស់វិហារដាណឺម៉ាក / ជំនួយគ្រីស្តបរិស័ទ |
| DPs | ដៃគូអភិវឌ្ឍន៍ |
| DRM | ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ |
| DRR | ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ |
| EBA | បន្សុាំនឹងការប្រែប្រួលអាកាសធាតុដោយផ្អែកលើស្ថានប្រព័ន្ធ |
| EU | សហភាពអឺរ៉ុប |
| FAO | អង្គការស្បៀង និងកសិកម្មសហប្រជាជាតិ |
| GDANCP | អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ |
| GDP | ផលិតផលក្នុងស្រុកសរុប |
| GEF | មូលនិធិបរិស្ថានពិភពលោក |

| | |
|---|---|
| **GHG** | ឧស្ម័នផ្ទះកញ្ចក់ |
| **GIZ** | កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ |
| **IFAD** | មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម |
| **IGES** | វិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានពិភពលោក |
| **IPCC** | ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ |
| **ITC** | វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា |
| **IUCN** | សម្ព័ន្ធភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ |
| **JCCI** | គំនិតផ្តួចផ្តើមរួមគ្នាចំពោះការប្រែប្រួលអាកាសធាតុ |
| **JICA** | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន |
| **KOICA** | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ |
| **MAFF** | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| **MEF** | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| **MIME** | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| **MLMUPC** | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| **MoE** | ក្រសួងបរិស្ថាន |
| **MoEYS** | ក្រសួងអប់រំ យុវជន និងកីឡា |
| **MoH** | ក្រសួងសុខាភិបាល |
| **MoI** | ក្រសួងមហាផ្ទៃ |
| **MoP** | ក្រសួងផែនការ |
| **MoPWT** | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| **MoT** | ក្រសួងទេសចរណ៍ |
| **MoWA** | ក្រសួងកិច្ចការនារី |
| **MoWRAM** | ក្រសួងធនធានទឹក និងឧតុនិយម |
| **MRC** | គណៈកម្មាធិការទន្លេមេគង្គ |
| **MRD** | ក្រសួងអភិវឌ្ឍន៍ជនបទ |
| **MRV** | ការវាស់វែង របាយការណ៍ និងផ្ទៀងផ្ទាត់ |
| **NAMAs** | សកម្មភាពជាតិសមស្របសម្រាប់ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ |
| **NAPA** | កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ |
| **NCCC** | គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (គ.ជ.គ.ប.អ.) |
| **NCDD-S** | លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (លេខាធិការដ្ឋាន គ.ជ.អ.ប.) |

| | |
|---|---|
| **NCDM** | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| **NGOs** | អង្គការមិនមែនរដ្ឋាភិបាល |
| **NSFSN** | យុទ្ធសាស្ត្រជាតិដើម្បីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ |
| **PES** | ការបង់ថ្លៃសេវាកម្មបរិស្ថាន |
| **PPCR** | កម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ |
| **REDD** | ការកាត់បន្ថយការបញ្ចេញ ឧស្ម័នពីការបាត់បង់ និងរេចរឹលព្រៃឈើ |
| **RGC** | រាជរដ្ឋាភិបាលកម្ពុជា |
| **RUA** | សាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| **RUPP** | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| **SIDA** | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសស៊ុយអែដ |
| **SNC** | របាយការណ៍ជាតិលើកទី២ |
| **SPCR** | កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ |
| **UNDP** | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| **UNEP** | កម្មវិធីបរិស្ថានសហប្រជាជាតិ |
| **UNFCCC** | អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |
| **UNIDO** | អង្គការអភិវឌ្ឍន៍ឧស្សាហកម្មសហប្រជាជាតិ |
| **USAID** | ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍអន្តរជាតិ |
| **WHO** | អង្គការសុខភាពពិភពលោក |
| **WWF** | អង្គការមូលនិធិពិភពលោកសម្រាប់ការអភិរក្សធម្មជាតិ |
| **YFC** | សហភាពសហព័ន្ធយុវជនកម្ពុជា |

# សេចក្ដីសង្ខេបប្រតិបត្តិ

វេទិកាជាតិលើកទី៣ ស្ដីពីការប្រែប្រួលអាកាសធាតុក្រោមប្រធានបទ "ធ្វើសកម្មភាពឆ្ពោះទៅការអភិវឌ្ឍប្រកបដោយចីរភាពក្នុងបរិបទប្រែប្រួលអាកាសធាតុ" បានរៀបចំឡើងចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ វេទិកាជាតិនេះមានគោលបំណងផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រ ចែករំលែកបទពិសោធន៍ និងចំណេះដឹងនានា ដើម្បីឆ្លើយតបការប្រែប្រួលអាកាសធាតុប្រកបដោយប្រសិទ្ធភាពក្នុងប្រទេសកម្ពុជា។ វេទិកាជាតិនេះ បានរៀបចំដោយគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (គ.ជ.គ.ប.អ.) ក្រោមការសម្របសម្រួលរបស់ក្រសួងបរិស្ថាន និងមានការគាំទ្រពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) ដែលជាកិច្ចផ្តួចផ្តើមរបស់សហភាពអឺរ៉ុប (EU) កម្មវិធិអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសដាណឹម៉ាក (DANIDA) និងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសស៊ុយអែដ (SIDA)។ ដៃគូ និងអ្នកគាំទ្រផ្សេងទៀត រួមមាន សហភាពសហព័ន្ធយុវជនកម្ពុជា (YFC) កម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP) អង្គការជំនួយរបស់វិហារដាណឺម៉ាក/ជំនួយគ្រីស្ទបរិស័ទ (DCA/CA) វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជា (The NGO Forum on Cambodia) និងបណ្តាញប្រែប្រួលអាកាសធាតុកម្ពុជា (CCCN)។ វេទិកាជាតិលើកទី៣នេះ បានប្រព្រឹត្តទៅរយៈពេល៣ថ្ងៃ តាមប្រធានបទសំខាន់ៗចំនួន៣ ដែលរួមមាន៖ ក) ព័ត៌មានអំពីវិទ្យាសាស្ត្រនៃការប្រែប្រួលអាកាសធាតុ វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ ខ) យុទ្ធសាស្ត្រជាតិឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ៖ បទពិសោធន៍ និងដំណើរឆ្ពោះទៅមុខ និង គ) ប្រទេសកម្ពុជា និងដំណើរការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុជាអន្តរជាតិ។ លទ្ធផលនានាដែលទទួលបានពីកិច្ចពិភាក្សានៅក្រោមប្រធានបទទាំងបីនេះ រួមមាន ៖

## ក. ព័ត៌មានវិទ្យាសាស្ត្រនៃការប្រែប្រួលអាកាសធាតុ វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ

- វេទិកាជាតិនេះ បានទទួលការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។
- ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ បានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ដោយ**សម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។
- ដៃគូអភិវឌ្ឍន៍រួមមានកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងសហភាពអឺរ៉ុប (EU) បានបង្ហាញពីឆន្ទៈដ៏មោះមុតក្នុងការបន្តជួយគាំទ្រប្រទេសកម្ពុជាក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។
- រាជរដ្ឋាភិបាលកម្ពុជា (RGC) បានបង្ហាញឆន្ទៈដ៏ខ្លាំងក្លាក្នុងការចាត់វិធានការជាបន្ទាន់ ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ រួមមានបន្សាំ និងការកាត់បន្ថយ។ រាជរដ្ឋាភិបាលនឹងពង្រឹងសកម្មភាពកៀរគរកញ្ចប់ថវិការួមគ្នាពីដៃគូអភិវឌ្ឍន៍ (DPs) និងលើកទឹកចិត្តដល់ការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រសម្រាប់អភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យា កសាងសមត្ថភាព និងលើកកម្ពស់ការយល់ដឹងជាសាធារណៈ។

- ជំរុញឱ្យមានកញ្ចប់ថវិកាជាតិសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដែលត្រូវអនុវត្ត ដោយក្រសួងពាក់ព័ន្ធ។ ថវិកាទាំងនោះត្រូវរៀបចំឡើងជាលក្ខណៈប្រព័ន្ធក្នុងទម្រង់ច្បាស់លាស់មួយ ដើម្បីបញ្ចៀសសកម្មភាពត្រួតគ្នា ដែលជាការខ្ជះខ្ជាយធនធាន។

- ជំរុញឱ្យក្រសួងពាក់ព័ន្ធត្រូវឈានជាបណ្តើរៗពីការរៀបចំផែនការទៅជាការអនុវត្ត និងពីគម្រោងសាកល្បង ទៅជាគម្រោងជាក់ស្តែងពេញលេញ ក្នុងគោលបំណងដោះស្រាយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុប្រកបដោយប្រសិទ្ធភាព ដោយសហការជាមួយដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងសហគមន៍ ក្នុងការអនុវត្តសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ។

## ខ. យុទ្ធសាស្ត្រជាតិឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

- អង្គវេទិកាបានកត់សំគាល់ថា មានក្រសួងចំនួន៩ បានរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យ និងបានត្រៀមខ្លួនជាស្រេច ដើម្បីបន្តការងារនេះដោយការប្តេជ្ញាចិត្តខ្ពស់។ ក្រសួងទាំងនោះរួមមាន៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) ក្រសួងធនធានទឹក និងឧតុនិយម (MoWRAM) ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) ក្រសួងសុខាភិបាល (MoH) ក្រសួងកិច្ចការនារី (MoWA) ក្រសួងសាធារណការ និងដឹកជញ្ជូន (MoPWT) និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (MIME) បានរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យ និងបានត្រៀមខ្លួនជាស្រេច ដើម្បីបន្តការងារនេះដោយការប្តេជ្ញាចិត្តខ្ពស់។

- លើកទឹកចិត្តឱ្យក្រសួងបរិស្ថាន (MoE) និងក្រសួងទេសចរណ៍ (MoT) ធ្វើការជាមួយគ្នា ដើម្បីដោះស្រាយផលប៉ះពាល់ដល់វិស័យទេសចរណ៍ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។

- ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ (CCAP) ត្រូវចាប់ផ្តើមអនុវត្តពីសហគមន៍ទាំងឡាយណាដែលងាយរងគ្រោះមុនគេ។

## គ. ប្រទេសកម្ពុជា និងដំណើរការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុជាអន្តរជាតិ

- អាស្រ័យដោយប្រទេសកម្ពុជានៅតែខ្វះខាតសមត្ថភាពផ្នែកបច្ចេកទេស ធនធាន និងថវិកា ដូច្នេះ ដើម្បីអនុវត្ត CCCSP ឱ្យបានជោគជ័យ ត្រូវមានកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍នានា ។

- ជំរុញ និងពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី ថ្នាក់តំបន់ និងសកលលោក ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដូចជា ជាមួយបណ្តាប្រទេសនានាក្នុងតំបន់អាងទន្លេមេគង្គ និងអាស៊ាន។ ប្រទេសជាសមាជិកក្នុងបណ្តាញនេះ គួរតែបញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

- មានការកត់សំគាល់ថា នៅកម្ពុជាមានគម្រោង និងគំនិតផ្តួចផ្តើមជាច្រើនសម្រាប់ការងារឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ប៉ុន្តែគម្រោង និងគំនិតផ្តួចផ្តើមទាំងនោះ ហាក់ដូចជាមិនត្រូវបានគ្រប់គ្រងចុះបញ្ជី និងផ្តល់ព័ត៌មានដល់ NCCC ឱ្យបានពេញលេញ។

- ជំរុញ និងការលើកទឹកចិត្តដល់ការវិនិយោគពីវិស័យឯកជនទាំងថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីចូលរួមកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងលើកកម្ពស់ការអភិវឌ្ឍបៃតង។ កិច្ចសហប្រតិបត្តិការ និងការពង្រឹងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពអាចធានាបាននូវការលើកទឹកចិត្តដល់វិស័យឯកជន។

- កត់សំគាល់ថា ការផ្តល់ថវិកាពីម្ចាស់ជំនួយអន្តរជាតិនៅមិនទាន់ច្បាស់លាស់ និងគ្មានតុល្យភាពរវាងកញ្ចប់ថវិកាប្រើប្រាស់សម្រាប់បន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ តូយ៉ាងដូចជា ប្រទេសកម្ពុជា ត្រូវការចរចាជាមួយម្ចាស់ជំនួយ ដើម្បីទទួលបានថវិកាបន្ថែមសម្រាប់បន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុដែលជាអាទិភាពរបស់ជាតិ។

- វេទិកាជាតិនេះ មិនស្វាគមន៍ប្រាក់កម្ចី ដើម្បីប្រើប្រាស់សម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុទេ។ ក៏ប៉ុន្តែ ប្រទេសកម្ពុជាពិតជាត្រូវការជំនួយ ដើម្បីដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុដែលកំពុងកើតឡើងក្នុងប្រទេស។

- ប្រទេសកម្ពុជា បានរៀបចំគោលជំហារដែលមានលក្ខណៈសមស្របជាមួយជំហាររបស់ក្រុមប្រទេសអភិវឌ្ឍន៍តិចតួច និងប្រទេស G77 បូកចិន សម្រាប់ចូលរួមក្នុង COP-19។

# ១. សាវតា

## ១.១ សនិទានភាព

ការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាប្រឈមដ៏គួរឱ្យព្រួយបារម្ភមួយ ដែលគំរាមកំហែងដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងអាចបង្អាក់រាល់ការអភិវឌ្ឍ ប្រសិនបើផលប៉ះពាល់របស់វានៅតែបន្តកើនឡើង។ សព្វថ្ងៃនេះ ការយល់ដឹងជាសាធារណៈ និងសមត្ថភាពការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅមានកម្រិតនៅឡើយ។ កត្តាទាំងនេះ បានធ្វើឱ្យប្រទេសកម្ពុជាកាន់តែងាយរងគ្រោះ ដោយសារការប្រែប្រួលអាកាសធាតុ។ យោងតាមហេតុផលទាំងនេះ ប្រទេសកម្ពុជាបានរៀបចំវេទិកាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុយ៉ាងទៀងទាត់ ដើម្បីចែករំលែកព័ត៌មាន បញ្ហាបការប្រែប្រួលអាកាសធាតុ និងពង្រឹងកិច្ចសហប្រតិបត្តិការ និងសម្របសម្រួលរវាងស្ថាប័នរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងវិស័យឯកជន ក្នុងគោលបំណងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុឱ្យមានប្រសិទ្ធភាពខ្ពស់។

វេទិកាជាតិលើកទី១ ស្តីពីការប្រែប្រួលអាកាសធាតុបានរៀបចំឡើយប្រកបដោយជោគជ័យនៅខែតុលា ឆ្នាំ២០០៩។ វេទិកានេះរៀបចំឡើង ដើម្បីលើកកម្ពស់ការយល់ដឹងស្តីពីការប្រែប្រួលអាកាសធាតុ ដែលជាការប្រឈមមួយនៅក្នុងការអភិវឌ្ឍ និងចងក្រងកំណើនចំនួនសកម្មភាពទាំងថ្នាក់ជាតិ និងថ្នាក់អន្តរជាតិសម្រាប់ជាគំនិតដល់អ្នកធ្វើសេចក្តីសម្រេចចិត្ត ម្ចាស់ជំនួយ និងប្រតិបត្តិករ។ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ចូលរួមបើកវេទិកាជាតិលើកទី១ ជាផ្លូវការហើយវេទិកាបានទទួលការគាំទ្រពីម្ចាស់ជំនួយជាច្រើន ព្រមទាំងមានសិក្ខាកាមមកពីវិស័យផ្សេងៗ រួមមានស្ថាប័នរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាលចូលរួមប្រមាណជាង ៧០០នាក់ នៅក្នុងវេទិកាបើកនាថ្ងៃទី១ និងប្រមាណជាង ៣០០នាក់ នៅថ្ងៃទី២ និងទី៣។

វេទិកាជាតិលើកទី២ ស្តីពីការប្រែប្រួលអាកាសធាតុបានរៀបចំនៅខែតុលា ឆ្នាំ២០១១ ដោយផ្តោតលើការពិភាក្សា ដើម្បីរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុឱ្យមានប្រសិទ្ធភាព។ វេទិកាជាតិនោះ មានគោលបំណងរួមលើកទឹកចិត្ត និងការគាំទ្ររបស់ គ.ជ.គ.ប.អ. និងក្រុមការងារបច្ចេកទេសអន្តរក្រសួងគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រែប្រួលអាកាសធាតុ។ វេទិកានេះ ក៏ជាឱកាសក្នុងការចែករំលែកផងដែរនូវសកម្មភាព និងគំនិតផ្តួចផ្តើមដែលបានអនុវត្តដោយស្ថាប័ននានា ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុទាំងនៅថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាន ដោយផ្តោតលើបទពិសោធន៍ និងបញ្ហាប្រឈមនានា។

វេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុបានរៀបចំឡើង នៅខែវិច្ឆិកា ឆ្នាំ២០១៣ ក្រោមប្រធានបទ ***"ធ្វើសកម្មភាពឆ្ពោះទៅការអភិវឌ្ឍប្រកបដោយចីរភាពក្នុងបរិបទប្រែប្រួលអាកាសធាតុ"***។ វេទិកាជាតិលើកទី៣ នេះ ប្រព្រឹត្តទៅដោយយោងទៅតាមលទ្ធផល និងការរំពឹងទុកពីវេទិកាជាតិលើកទី១ និងលើកទី២។ ដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ដោយមានការចូលរួម ពីសំណាក់ក្រសួងពាក់ព័ន្ធនានា និងបញ្ហាក់ភាពរីកចម្រើន ចាប់តាំងពីវេទិកាជាតិលើកទី២ មកម្លេះ។ បន្ថែមពីនេះទៅទៀត នាប៉ុន្មានឆ្នាំចុងក្រោយនេះ NGOs ក៏បានប្រឹងប្រែងអនុវត្តគម្រោងរបស់ខ្លួន ឱ្យសមស្របទៅនឹងផែន

ការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ និងបានបញ្ជាក់ពីការរំកិលឆ្ពោះទៅរកការអនុវត្តសកម្មភាពប្រែប្រួលអាកាសធាតុនេះផងដែរ។ អាស្រ័យហេតុនេះ វេទិកាជាតិលើកទី៣ បានក្លាយជាវេទិកា ដើម្បីចែករំលែក CCCSP និងឆ្លៀតយកឱកាសនេះ ដើម្បីភ្ជាប់អង្គការមិនមែនរដ្ឋាភិបាលនានា ដែលបានរៀបចំផែនការយុទ្ធសាស្ត្ររបស់ខ្លួន ដូចជាការកាត់បន្ថយហានិភ័យពីគ្រោះមហន្តរាយ (DRR) ការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ និងរេចរឹលព្រៃឈើ (REDD) បន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដើម្បីចែករំលែកលទ្ធផលពីសកម្មភាពរបស់ខ្លួន។ វេទិកាជាតិលើកទី៣នេះគឺជាឱកាសសម្រាប់ការពិភាក្សាពីការរៀបចំផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងបានបង្កើតឱកាសបញ្ចូលគ្នាផងដែររវាង ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាល (ឧទាហរណ៍៖ ផែនការសកម្មភាពតាមវិស័យ) និងគំនិតផ្តួចផ្តើមសំខាន់ៗនានា ដែលបានអនុវត្តដោយ NGOs នានា។

## ១.២ គោលបំណង

- បង្កើនការចូលរួមកាន់តែច្រើនឡើងពីសំណាក់អ្នកពាក់ព័ន្ធសំខាន់ៗនានា ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដូចជា រាជរដ្ឋាភិបាល ម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានសិក្សា យុវជន និងវិស័យឯកជន

- លើកកម្ពស់ការយល់ដឹងសាធារណៈអំពីគោលនយោបាយសំខាន់ៗនៃការប្រែប្រួលអាកាសធាតុ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពដល់អ្នកធ្វើសេចក្តីសម្រេចចិត្ត និងអ្នកពាក់ព័ន្ធសំខាន់ៗនានា

- ពង្រឹងការសម្របសម្រួល កិច្ចសហការ និងភាពជាដៃគូពីសំណាក់អ្នកពាក់ព័ន្ធនានា

- ពង្រឹងការចូលរួមក្នុងភាពជាអ្នកដឹកនាំរបស់ គ.ជ.គ.ប.អ. នៅក្នុងគោលនយោបាយ ការធ្វើផែនការ និងដំណើរការសម្របសម្រួលស្តីពីការប្រែប្រួលអាកាសធាតុ។

## ២. អ្នកចូលរួម

នៅក្នុងអំឡុងកម្មវិធីបើកវេទិកាជាតិលើកទី៣ មានអ្នកចូលរួមប្រមាណ ៨៥០នាក់ ដែលអញ្ជើញមកពីស្ថាប័នផ្សេងៗគ្នា រួមមាន សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា សមាជិករាជរដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់ វិស័យសិក្សាធិការ ស្ថានទូតនានា DPs និងបណ្តា NGOs ទាំងជាតិ និងអន្តរជាតិ វិស័យឯកជន និស្សិត និងសមាជិករបស់ YFC **(បញ្ជីរាយនាមអ្នកចូលរួមមាននៅក្នុងឧបសម្ព័ន្ធទី៥)**។




**អ្នកតំណាងនៃប្រធានវេទិកានៅក្នុងវេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ (ថតដោយ CCCA, 2013)**



**អ្នកចូលរួមនៅក្នុងវេទិកាជាតិលើកទី៣ស្តីពីការប្រែប្រួលអាកាសធាតុ (ថតដោយ CCCA, 2013)**

នៅក្នុងកំឡុងវេទិកាជាតិទាំងមូលនេះ មានប្រធានដឹកនាំចំនួន ១២រូប អ្នកធ្វើបទបង្ហាញចំនួន ៣០រូប និងវាគ្មិនចំនួន ៣៨រូប ដែលអញ្ជើញមកពីស្ថានប័នផ្សេងៗគ្នា **(បញ្ជីរាយនាមអ្នកចូលរួមមានក្នុងឧបសម្ព័ន្ធទី១ និងទី៥)** ។

## ៣. កម្មវិធី

វេទិកាជាតិនេះមានរយៈពេល៣ថ្ងៃ មានកម្មវិធី ដូចជា ការពិភាក្សាពេញអង្គ និងការពិភាក្សាជាក្រុមស្របគ្នា ចំនួន៣វគ្គ ការតាំងពិព័រណ៍រូបគំនូរ និងរូបភាព និងតាំងពិព័រណ៍សកម្មភាពការប្រែប្រួលអាកាសធាតុ **(សេចក្តីព្រាងកម្មវិធីនៅក្នុងឧបសម្ព័ន្ធ ១)។**

### កម្មវិធីថ្ងៃទី១៖ ព័ត៌មានវិទ្យាសាស្ត្រអំពីការប្រែប្រួលអាកាសធាតុ វឌ្ឍនភាពនៃការអនុវត្ត និងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (CCCSP)

ថ្ងៃទី១ រួមបញ្ចូលទាំងកម្មវិធីពេលព្រឹកមានសុន្ទរកថាស្វាគមន៍របស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធាន គ.ជ.គ.ប.អ. និងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងជាប្រធានកិត្តិយស គ.ជ.គ.ប.អ.។ ក្នុងពិធីបើកវេទិកាជាតិនេះ **សម្តេចនាយករដ្ឋមន្ត្រី** បានថ្លែងសុន្ទរកថា និងប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា២០១៤-២០២៣ ។



**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

*"...ក្នុងស្មារតីនេះ ខ្ញុំយល់ថាវេទិកាជាតិលើកទី៣នេះ នឹងផ្តល់នូវកាលានុវត្តភាពដ៏កម្រសម្រាប់ការពិភាក្សាលើបញ្ហាជាច្រើនដូចជាវិទ្យាសាស្ត្រប្រែប្រួលអាកាសធាតុ ការចរចាអន្តរជាតិ មេរៀនានាដែលទទួលបានមកទល់បច្ចុប្បន្ន យុទ្ធសាស្ត្ររបស់យើងសម្រាប់អនាគត ការគ្រប់គ្រងចំណេះដឹង ការស្រាវជ្រាវ និងការចាត់ចែងហិរញ្ញប្បទាន លើការងារគ្រប់គ្រងប្រែប្រួលអាកាសធាតុ។ ខ្ញុំសង្ឃឹមថា ឯកឧត្តម លោកជំទាវ លោក លោកស្រី ពិតជាទទួលបានអត្ថប្រយោជន៍ពីការពិភាក្សានានា ជាមួយប្រតិបត្តិករទាំងឡាយនៅក្នុងរយៈពេលប៉ុន្មានថ្ងៃខាងមុខនេះ ហើយខ្ញុំរំពឹងថា យើងនឹងទទួលបានអនុសាសន៍ជាច្រើនផងដែរពីវេទិកានេះ ដើម្បីជាប្រយោជន៍សម្រាប់គាំទ្រកម្ពុជាក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ឆ្ពោះទៅការកសាងសង្គមមួយដែលបៃតង បញ្ចេញកាបូនតិច ធន់នឹងការប្រែប្រួលអាកាសធាតុ មានសមធម៌ និងមានភាពសុខដុមរវាងការរស់នៅរបស់មនុស្ស និងបរិស្ថាន..."*



**ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធាន គ.ជ.គ.ប.អ.**

*"...ការជួបជុំគ្នានៅថ្ងៃនេះ គឺជាសក្ខីភាពបញ្ជាក់ឱ្យឃើញអំពីការយកចិត្តទុកដាក់ខ្ពស់ពីរាជរដ្ឋាភិបាលចំពោះបញ្ហាការប្រែប្រួលអាកាសធាតុ ក៏ដូចជាកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដើម្បីធានាបាននូវតុល្យភាពរវាងការអភិវឌ្ឍ និងការអភិរក្ស។ បញ្ហាការប្រែប្រួលអាកាសធាតុ ត្រូវបានដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដោយផ្តោតជាសំខាន់លើការកសាងភាពធន់ទ្រាំរបស់យើងចំពោះការប្រែប្រួលអាកាសធាតុ និងការលើកកម្ពស់ការអភិវឌ្ឍដែលបញ្ចេញកាបូនតិច។*

*ជាងនេះទៅទៀត ការប្រែប្រួលអាកាសធាតុក៏បានក្លាយជាកត្តាអាទិភាពនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម (NSDP) ២០០៩-២០១៣ ហើយបញ្ហានេះ ក៏ត្រូវបានរំពឹងទុកថាជាកិច្ចការដ៏ចម្បងមួយនៅក្នុង NSDP សម្រាប់រយៈពេលខាងមុខបន្តទៀត...”*

នៅពេលរសៀល គឺជាកម្មវិធីបើកវគ្គបច្ចេកទេស ដោយមានមតិស្វាគមន៍ពីលោកស្រី **Claire Van de Vaeren** មន្ត្រីសម្របសម្រួលនៃអង្គការសហប្រជាជាតិប្រចាំកម្ពុជា និង**ឯកឧត្តម ខៀវ មុត** រដ្ឋលេខាធិការ ក្រសួងបរិស្ថាន។ បន្ទាប់មក គឺវគ្គប្រជុំពេញអង្គដែលដឹកនាំ **ឯកឧត្តម ខៀវ មុត**។ ផ្នែកនេះបានបង្ហាញពីបច្ចុប្បន្នភាពព័ត៌មានវិទ្យាសាស្ត្រអំពីការប្រែប្រួលអាកាសធាតុនៅថ្នាក់សកលលោក ថ្នាក់តំបន់ និងថ្នាក់ជាតិ បច្ចុប្បន្នភាពនៃការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងបទបង្ហាញពីផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា និងដំណើរឆ្ពោះទៅមុខសម្រាប់ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។




**លោកស្រី Claire Van der Vaeren មន្ត្រីសម្របសម្រួល អង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា**

*“...ការប្រែប្រួលអាកាសធាតុ ត្រូវបានគេដឹងថាជាការគំរាមកំហែងធំជាងគេមួយ ដល់ការអភិវឌ្ឍដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ។ ប៉ុន្តែជាញឹកញាប់បំផុត ប្រការសំខាន់មួយត្រូវគេបំភ្លេចៈ ការដោះស្រាយការប្រែប្រួលអាកាសធាតុ គឺជាឱកាសមួយក្នុងចំណោមឱកាសធំបំផុតចំនួនបួនរបស់យើង។ ជំនាញខាងបច្ចេកវិទ្យាបញ្ចេញកាបូនតិច និងបន្សាំ គឺជាអ្វីដែលត្រូវការជាខ្លាំង។ ប្រទេសនានា ដែលវិនិយោគក្នុងដំណាក់កាលដំបូងលើវិស័យទាំងនេះនឹងស្ថិតក្នុងស្ថានភាពរឹងមាំនៅក្នុងទីផ្សារថ្មីនេះ។ ប្រការសំខាន់បំផុត គឺការរួមបញ្ចូលការប្រែប្រួលអាកាសធាតុនៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផ្តល់នូវឱកាសដើម្បីបង្កើតគំរូនៃកំណើនសេដ្ឋកិច្ចដោយចីរភាពសម្រាប់កម្ពុជា ស្របជាមួយតុល្យភាពដែលត្រូវការជាចាំបាច់រវាងអត្ថប្រយោជន៍ខាងសង្គម សេដ្ឋកិច្ច និងបរិស្ថាន...”*




**ឯកឧត្តម ខៀវ មុត រដ្ឋលេខាធិការ ក្រសួងបរិស្ថាន**

*“...ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជានេះ នឹងផ្តល់នូវក្របខ័ណ្ឌគោលនយោបាយជាយុទ្ធសាស្ត្រមួយ សម្រាប់តម្រង់ទិស និងគាំទ្រស្ថាប័នជាតិ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ក្នុងការគិតគូរអំពីវិធានការជាក់លាក់ និងសមស្របដែលទាក់ទងនឹងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (GHG) ការអភិវឌ្ឍបៃតង និងការអភិវឌ្ឍដែលបញ្ចេញកាបូនតិច ដែលគាំទ្រដល់សមិទ្ធផលនៃយុទ្ធសាស្ត្រចតុកោណ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា...”*

## កម្មវិធីថ្ងៃទី២៖ ការធ្វើផែនការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ៖ មេរៀនទទួលបាន និងដំណើរឆ្ពោះទៅមុខ

នៅថ្ងៃទី២ បន្ទាប់ពីបានស្តាប់របាយការណ៍សង្ខេបលទ្ធផលរបស់វេទិកានៅថ្ងៃទី១ **ឯកឧត្តម ប៉ាន ប៊ុនធឿន** រដ្ឋលេខាធិការ ក្រសួងផែនការ បានថ្លែងសុន្ទរកថាស្វាគមន៍ និងចំណាប់អារម្មណ៍រួមគ្នាជាមួយ **ឯកឧត្តម Jean-François Cautain** ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំកម្ពុជា។

បទបង្ហាញនានារបស់វាគ្មិន បានគូសបញ្ជាក់ពីវឌ្ឍនភាពនៃការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងទស្សនវិស័យពង្រឹងកិច្ចសហការរវាងដៃគូពាក់ព័ន្ធ។ សម្រាប់ថ្ងៃទី២ មានការពិភាក្សាតាមក្រុម លើប្រធានបទជាច្រើនពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។




**ឯកឧត្តម ប៉ាន ប៊ុនធឿន រដ្ឋលេខាធិការ ក្រសួងផែនការ**

*"...ក្រសួងផែនការ នឹងបន្តធានាឱ្យមានការដាក់បញ្ចូលសូចនាករណ៍នានាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុទៅក្នុងក្របខ័ណ្ឌពិនិត្យតាមដាន NSDP។ ដោយសហការជាមួយក្រសួងបរិស្ថាន យើងនឹងផ្តល់ការគាំទ្រដល់ក្រសួងពាក់ព័ន្ធ ដើម្បីរួមបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងឯកសារធាតុចូលរបស់ក្រសួងទាំងនោះសម្រាប់ NSDP នៅកម្រិតវិស័យ ថ្ងៃនេះយើងនឹងមានការពិភាក្សាអំពីការងារ ដែលក្រសួងពាក់ព័ន្ធចំនួនប្រាំបួនបានអនុវត្ត ដើម្បីបង្កើតផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់ខ្លួន ដែលជាការបង្ហាញពីកិច្ចប្រឹងប្រែងអនុវត្ត ដើម្បីដាក់បញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការកសាងផែនការជាប្រក្រតីរបស់ខ្លួន និងបញ្ជៀសការចាត់ទុកការប្រែប្រួលអាកាសធាតុថាជាផ្នែកមួយនៅដាច់តែឯង..."*




**ឯកឧត្តម Jean-François Cautain អគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំកម្ពុជា**

*"...នៅក្នុងបុព្វហេតុនេះ ខ្ញុំមានអារម្មណ៍រីករាយខ្លាំងណាស់ ដែលសហភាពអឺរ៉ុបរួមជាមួយនឹងរដ្ឋាភិបាលប្រទេសដាណឺម៉ាក ប្រទេសស៊ុយអែដ និង UNDP បានគាំទ្ររាជរដ្ឋាភិបាលកម្ពុជាក្នុងការបង្កើត CCCA។ CCCA គឺជាការរួមបញ្ចូលនូវកិច្ចការរួមគ្នា ដើម្បីគាំទ្រដល់ផែនការសកម្មភាពថ្នាក់សាមីក្រសួង ដើម្បីបញ្ជ្រាបការធ្វើផែនការ ការចំណាយ និងការអនុវត្តនៅថ្នាក់ក្រសួង..."*

កិច្ចពិភាក្សាមានចំនួន៣វគ្គស្របគ្នា ដែលវគ្គនីមួយៗមានបទបង្ហាញចំនួន ២ ឬ៣។ ក្រុមពិភាក្សាផ្សេងៗគ្នាបានអនុញ្ញាតឱ្យអ្នកពាក់ព័ន្ធសំខាន់ដែលធ្វើការលើវិស័យស្រដៀងគ្នាមានឱកាសចែករំលែកវឌ្ឍនភាពនៃការរៀបចំ និងអនុវត្តន៍គោលនយោបាយ និងសកម្មភាពនានាក៏ដូចជាបទពិសោធន៍ និងដំណើរឆ្ពោះទៅមុខ។ លទ្ធផលរំពឹងទុកចេញពីការពិភាក្សា គឺជាការចែករំលែកព័ត៌មាន និងលទ្ធភាពនៃការអនុវត្តសកម្មភាពរួមគ្នានាពេលអនាគត។

ក្រុមពិភាក្សានីមួយៗ បានដឹកនាំដោយប្រធានម្នាក់។ ដើម្បីចាប់ផ្តើមការពិភាក្សាមន្ត្រីតំណាងក្រសួងម្នាក់ ឬពីរនាក់ បានបង្ហាញពីបច្ចុប្បន្នកម្មនៃផែនការយុទ្ធសាស្ត្រ និងបទពិសោធន៍កន្លង ។ បន្ទាប់មក មានក្រុមវាគ្មិនពីបីទៅបួននាក់ដែលជាតំណាងមកពី (សង្គមស៊ីវិល ស្ថាប័នសិក្សាធិការ និងវិស័យឯកជន) បានចែករំលែកវឌ្ឍនភាពនៃសកម្មភាពរបស់ខ្លួនមុននឹងបន្តពិភាក្សារួមគ្នាពីដំណើរឆ្ពោះទៅមុខ។

## កម្មវិធីថ្ងៃទី៣៖ កម្ពុជា និងដំណើរការស្តីពីការប្រែប្រួលអាកាសធាតុអន្តរជាតិ

នៅថ្ងៃទី៣នៃអង្គវេទិកា **ឯកឧត្តម រស់ សីលវ៉ា** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង **លោក Peter Brimble** នាយករងប្រចាំប្រទេសនៃធនាគារអភិវឌ្ឍន៍អាស៊ី បានថ្លែងសុន្ទរកថាស្វាគមន៍ និងចំណាប់អារម្មណ៍រួមគ្នា។

សេចក្តីសង្ខេបពីលទ្ធផលនៃកិច្ចពិភាក្សាថ្ងៃទី២ និងរបៀបវារៈនៃថ្ងៃទី៣ បានរាយការណ៍ដោយអ្នកសម្របសម្រួលកម្មវិធី។ កម្មវិធីនៅថ្ងៃទី៣ គឺជាកិច្ចពិភាក្សាវគ្គពេញអង្គ ស្តីពីហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ កិច្ចសហប្រតិបត្តិការថ្នាក់តំបន់ និងគោលជំហររបស់ប្រទេសកម្ពុជាក្នុង COP ១៩។ វគ្គពេញអង្គអំពីហិរញ្ញប្បទានប្រែប្រួលអាកាសធាតុផ្តោតលើក្របខ័ណ្ឌហិរញ្ញប្បទានអាកាសធាតុអន្តរជាតិ ក៏ដូចជាការវិវត្តនៃក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុកម្ពុជា រាប់បញ្ចូលទាំងបទពិសោធន៍ពីកម្មវិធី CCCA និងយន្តការផ្សេងៗទៀត។ បន្ទាប់មកវគ្គពេញអង្គក៏បានចែករំលែកនូវវឌ្ឍនភាព និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ នៃការប្រែប្រួលអាកាសធាតុនៅក្នុងគណៈកម្មការទន្លេមេគង្គ (MRC) និងអាស៊ាន មុននឹងឈានដល់ការពិភាក្សាអំពីគោលជំហររបស់ប្រទេសកម្ពុជាក្នុងការចរចា COP ១៩ ដើម្បីទទួលបាននូវសេចក្តីព្រៀងកិច្ចព្រមព្រៀង ដើម្បីដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រីពិនិត្យ និងសម្រេច។




**ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

*"...បច្ចុប្បន្ន ហិរញ្ញប្បទានភាគច្រើន ត្រូវបានផ្តល់មកសម្រាប់តែដំណើរការគម្រោងមួយៗ ដាច់ដោយឡែកពីគ្នា។ នៅរយៈពេលពីរបីឆ្នាំទៅមុខទៀត យើងចង់ឱ្យមានការវិវត្ត ដោយធ្វើការផ្លាស់ប្តូរបន្តិចម្តងៗពីវិធីសាស្ត្រដែលមានមូលដ្ឋានលើគម្រោងមួយៗ ទៅជាវិធីសាស្ត្រដែលផ្តោតលើកម្មវិធី។ យើងចាំបាច់ត្រូវជំរុញយន្តការមូលនិធិបែបប្រមូលផ្តុំ ក៏ដូចជាការគាំទ្រថវិកាតាមវិស័យ។ តាមរបៀបនេះ វានឹងជួយយើងក្នុងការគ្រប់គ្រងកំណើនលំហូរធនធាន ដោយបញ្ចៀសការចំណាយលើប្រតិបត្តិការហួសកំណត់ ដែលកើតឡើងដោយសារតែកំណើនចំនួនគម្រោងយ៉ាងឆាប់រហ័ស ..."*




**លោក Peter Brimble នាយករងប្រចាំប្រទេសនៃ ADB**

*"...ទន្ទឹមគ្នានេះ ADB បានអនុម័តនូវយុទ្ធសាស្ត្រចម្រុះសម្រាប់បន្សាំ និងការកាត់បន្ថយការប្រែប្រួល*

*អាកាសធាតុ ដោយផ្តោតសំខាន់លើវិស័យជាអាទិភាពមួយចំនួន ដូចជា៖ (i) ការពង្រីកការប្រើប្រាស់ថាមពលស្អាត (ii) ការលើកទឹកចិត្តដល់ការដឹកជញ្ជូនប្រកបដោយចីរភាព និងការអភិវឌ្ឍទីក្រុង (iii) ការគ្រប់គ្រងការប្រើប្រាស់ដីធ្លី និងព្រៃឈើ ក្នុងការចាប់យកកាបូនតាមរយៈ REDD+ និង (iv) ការជំរុញការអភិវឌ្ឍដែលធន់នឹងអាកាសធាតុ...”*

នៅចុងបញ្ចប់នៃវេទិកាជាតិលើកទី៣ នេះ អ្នកសម្របសម្រួលកម្មវិធី បានរាយការណ៍អំពីសេចក្តីសង្ខេបរបស់វេទិការយៈពេល ៣ ថ្ងៃកន្លងមក។ បន្ទាប់មក **ឯកឧត្តម សាបូ អូហ្សាណូ** រដ្ឋលេខាធិការ ក្រសួងបរិស្ថាន បានថ្លែងសុន្ទរកថាបិទកម្មវិធី។




**ឯកឧត្តម សាបូ អូហ្សាណូ រដ្ឋលេខាធិការ ក្រសួងបរិស្ថាន**

*“...ជាទីបញ្ចប់ ជូនសមុខឱ្យ គ.ជ.គ.ប.អ. ថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការរបស់ក្រសួងបរិស្ថាន ខ្ញុំសូមថ្លែងអំណរគុណដល់សមាជិក សមាជិកានៃអង្គវេទិកាទាំងមូល ជាពិសេសចំពោះប្រធានដឹកនាំ វាគ្មិន និងអ្នកជំនាញការនានា ដែលបានចំណាយពេលវេលាដ៏មានតម្លៃ មកចូលរួមក្នុងវេទិកាជាតិនេះ ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍ ហើយចូលរួមចំណែកយ៉ាងសកម្មនៅក្នុងការពិភាក្សា និងការផ្តល់នូវយោបល់ដ៏មានតម្លៃ។ ខ្ញុំសូមអរគុណជាពិសេសដល់តំណាងវិស័យឯកជន អង្គការជាតិ និងអន្តរជាតិ និង NGOs ដែលបានមកចូលរួមនៅក្នុងការតាំងពិព័រណ៌ការប្រែប្រួលអាកាសធាតុនេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសមាជិក សមាជិកានៃគ.ជ.គ.ប.អ. ក៏ដូចជាគណៈកម្មការរៀបចំវេទិកាជាតិលើកទី៣ ចំពោះការខិតខំបំពេញភារកិច្ច រៀបចំដំណើរការវេទិការជាតិនេះ ឱ្យប្រព្រឹត្តទៅដោយជោគជ័យ និងទទួលលទ្ធផលជាផ្លែផ្កាតាមការរំពឹងទុក។ ជាចុងក្រោយ ខ្ញុំសូមអរគុណ ជាពិសេសដល់អ្នកឧបត្ថម្ភរបស់យើង រួមមាន EU UNDP SIDA DANIDA UNEP DCA/CA YFC CCCN និង The NGO Forum on Cambodia ចំពោះការគាំទ្រឧបត្ថម្ភផ្នែកហិរញ្ញវត្ថុសម្រាប់ដំណើរការវេទិការជាតិលើកទី៣ស្តីពីការប្រែប្រួលអាកាសធាតុ នេះ...”*

កម្មវិធីផ្សេងៗនៃវេទិកាជាតិនេះ ត្រូវបានរៀបចំនៅក្រៅបន្ទប់ពិភាក្សា ដែលរួម មានការតាំងពិពណ៌រូបថត និងខ្សែវីដេអូរអំពីការប្រែប្រួលអាកាសធាតុ។ កម្មវិធីនេះក៏រៀបចំរយៈពេលបីថ្ងៃពេញដែរ។ ការតាំងពិព័រណ៌អំពីការប្រែប្រួលអាកាសធាតុរួមមាន៖ ការបង្ហាញគម្រោងគំរូ និងសកម្មភាព ឬផលិតផលដែលអនុវត្តដោយវិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល និងក្រសួងនានា។

# ៤. សេចក្តីសង្ខេបលទ្ធផលសំខាន់ៗ៖ "ធ្វើសកម្មភាពឆ្ពោះទៅការអភិវឌ្ឍប្រកបដោយចីរភាពក្នុងបរិបទប្រែប្រួលអាកាសធាតុ"

## ៤.១ វិទ្យាសាស្ត្រនៃការប្រែប្រួលអាកាសធាតុ វឌ្ឍនភាពនៃការអនុវត្ត និងផែនការយុទ្ធសាស្ត្រ

### បច្ចុប្បន្នភាពនៃព័ត៌មានវិទ្យាសាស្ត្រប្រែប្រួលអាកាស-ធាតុ៖ មូលហេតុ និងផលប៉ះពាល់

អ្នកវិទ្យាសាស្ត្របានបញ្ជាក់ថាការប្រែប្រួលអាកាសធាតុបណ្តាលឱ្យមានការប្រែប្រួលសីតុណ្ហភាព ការប្រែប្រួលកម្ពស់ទឹកភ្លៀង និងកំណើនកម្ពស់ទឹកសមុទ្រ។ ការអង្កេតពីការប្រែប្រួលទាំងនោះបានបង្ហាញថា កំណើនសីតុណ្ហភាពសកលជាមធ្យម មានឥទ្ធិពលដល់កំណើនកម្ពស់ទឹកភ្លៀងនៅតំបន់ដែលមានរយៈកម្ពស់ខ្ពស់ និងថយចុះនៅតំបន់ដែលមានរយៈកម្ពស់ទាប។ លើសពីនេះទៅទៀត តាមការសិក្សាបានបញ្ជាក់ថា ក្នុងកំឡុងឆ្នាំ ១៩០១-២០១០ កំណើនកម្ពស់ទឹកសមុទ្រសកលជាមធ្យមគឺ 0,១៩ ម៉ែត្រ។ កត្តាមនុស្ស គឺជាជាមូលហេតុចម្បងដែលនាំឱ្យមានការប្រែប្រួលអាកាសធាតុ តាមរយៈសកម្មភាពអភិវឌ្ឍសេដ្ឋកិច្ច ដែលបានបញ្ចេញឧស្ម័នផ្ទះកញ្ចក់ជាច្រើនទៅក្នុងបរិយាកាស ។

ការប្រែប្រួលអាកាសធាតុ នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិចបានកើតឡើង ហើយនេះគឺជាការប្រឈមមួយយ៉ាងធំ។ ភស្តុតាងមួយចំនួនបានបញ្ជាក់ពីការប្រែប្រួលនៅក្នុងតំបន់ ដូចជានិន្នាការកំណើនសីតុណ្ហភាព និងបាតុភូតអាកាសធាតុមិនប្រក្រតីកាន់តែញឹកញាប់ និងកំណើនកំពស់ទឹកសមុទ្រ។ ផលប៉ះពាល់ជាច្រើនមានដូចជា ការរលាយទឹកកក កំណើនកម្ពស់ទឹកសមុទ្រ គ្រោះទឹកជំនន់ គ្រោះរាំងស្ងួត និងផលប៉ះពាល់ទៅលើធនធានធម្មជាតិដូចជា កង្វះខាតទឹក ការបាត់បង់ជីវៈចម្រុះ ការខូចខាតស្ពានប្រព័ន្ធ និងសេវាកម្ម។ ការប្រែប្រួលទាំងនោះនឹងនាំមកនូវផលប៉ះពាល់ជាអវិជ្ជមានដល់សុខភាពមនុស្ស និងជីវភាពរស់នៅ សន្តិសុខស្បៀង និងភាពក្រីក្រនៅក្នុងទំហំ និងប្រភេទខុសគ្នា។ ឥទ្ធិពលនោះអាចប្រែប្រួលទៅតាមប្រទេស និងតំបន់ ។

ទំនាក់ទំនងរវាងបន្សាំ និងការកាត់បន្ថយឧស្ម័ន ក៏ត្រូវបានលើកយកមកបង្ហាញផងដែរ។ គោលបំណងរួមនៃបន្សាំ គឺរក្សាមុខងាររបស់ផលិតផល ឬសម្ភារ និងធានាលទ្ធផលដដែល។ UNEP កំពុងធ្វើការងារក្នុងផ្នែកបន្សាំ និងការកាត់បន្ថយ និងជួយប្រទេសមួយចំនួននៅក្នុងតំបន់ ដូចជាកម្ពុជា។

ចំណុចពិភាក្សាសំខាន់ៗ នៅក្នុងប្រធានបទនេះ រួមមាន៖

- របៀបកាត់បន្ថយការប្រែប្រួលអាកាសធាតុនៅកម្ពុជាមានមួយចំនួន។ វិធីសាស្ត្រនានាសម្រាប់លើកមកពិចារណា មានដូចជា៖ ការលើកកម្ពស់ការយល់ដឹង និងលើកយកការប្រែប្រួលអាកាសធាតុ ទៅក្នុងកម្រិតគោលនយោបាយ ព្រមទាំងការបញ្ចូលដំណោះស្រាយបច្ចេកវិទ្យា ដោយសារបច្ចេកវិទ្យាបច្ចុប្បន្ន ប្រហែលមិនអាចផ្តល់នូវការផ្លាស់ប្តូរ ដូចដែលរំពឹងទុក ក្នុងការឆ្លើយតប

នឹងការបន្សាំ និងការកាត់បន្ថយឧស្ម័ននោះទេ។

- គ្មានចំណេះដឹងច្បាស់លាស់អំពីនិន្នាការនៃផលប៉ះពាល់ ព្រមទាំងគ្មានទិន្នន័យគោលពីនិន្នាការនៃផលប៉ះពាល់ទាំងបច្ចុប្បន្ន និងអនាគត។ វិស័យកសិកម្ម ជាវិស័យសំខាន់ក្នុងការឆ្លើយតបនឹងវិសមរូបអាកាសធាតុ។ របាយការណ៍របស់ IPCC ដែលនឹងចេញផ្សាយក្នុងខែមីនាខាងមុខនេះ នឹងបង្ហាញពីផលប៉ះពាល់នានាលើវិស័យផ្សេងៗ។ ប្រទេសនានា អាចប្រើប្រាស់វិធីសាស្ត្ររៀបចំបញ្ជីសារពើភ័ណ្ឌ GHG ដែលបានបោះពុម្ពផ្សាយនៅឆ្នាំ ១៩៩៦ ឬក៏នៅឆ្នាំ ២០០៦ ដោយឥតគិតថ្លៃ។

- ការសិក្សា និងគំហើញហានិភ័យ និងការផុតពូជនៃជីវៈចម្រុះបានបង្ហាញថា ផលប៉ះពាល់ដោយផ្ទាល់អាចនឹងមានហានិភ័យដល់ទិន្នផល និងផលិតភាពរបស់ដំណាំ។ ឧទាហរណ៍៖ ប្រសិនបើមានកំណើនសីតុណ្ហភាព ១℃ ទិន្នផលស្រូវនឹងថយចុះ ១០%។ មានតែព័ត៌មានដែលទាក់ទងនឹងជីវៈចម្រុះទូទៅ តែគ្មានទិន្នន័យចំពោះប្រភេទនីមួយៗទេ។ ចំពោះនិន្នាការលម្អិតពីផលប៉ះពាល់សកលលោក យើងត្រូវរង់ចាំរហូតដល់ក្រុមការងារបច្ចេកទេសរបស់ IPCC ចេញផ្សាយរបាយការណ៍បន្ទាប់របស់គេ។

- មិនទាន់មានការវាយតម្លៃ ឱ្យបានស៊ីជម្រៅពីការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់នៅឡើយទេ។ របាយការណ៍លើកទី ២ របស់ UNEP បានលើកឡើងពីគម្លាតនៃបន្សាំ។ គម្លាតបន្សាំមានដូចជា សមត្ថភាព ហិរញ្ញវត្ថុ និងបច្ចេកវិទ្យា គោលការណ៍គន្លឹះនៃសន្និសញ្ញាជីវៈចម្រុះ និងផលិតកម្មអាហារជាដើម។

- របាយការណ៍វាយតម្លៃលើកទី ៥ របស់ IPCC បានមើលពីសមត្ថភាពដែលមានដូចជា (i) សមត្ថភាព (ii) បច្ចេកវិទ្យាដែលមានស្រាប់ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ (iii) ការអនុវត្តបច្ចេកវិទ្យាទាំងនោះ មិនត្រឹមតែនៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងក្នុងបរិបទនៃការអភិវឌ្ឍទៀតផង។

## ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុក្នុងប្រទេសកម្ពុជា និងតំបន់អាស៊ីអាគ្នេយ៍

វេទិកាបានបង្ហាញជាថ្មីថា ប្រទេសកម្ពុជាគឺជាប្រទេសដែលងាយរងគ្រោះ ដោយសារអាកាសធាតុខ្លាំងជាងគេ នៅអាស៊ី ដោយសារតែសមត្ថភាពបន្សាំនៅមានកម្រិតទាប និងសេដ្ឋកិច្ច ពឹងអាស្រ័យទៅលើវិស័យកសិកម្ម និងធនធានទឹក។ ដើម្បីកសាងភាពធន់នឹងអាកាសធាតុ ក្រសួងបរិស្ថាន និងដៃគូអភិវឌ្ឍ បានចាប់ផ្តើមកម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ (PPCR) ចំនួនពីរដំណាក់កាល។ PPCR ដំណាក់កាលទី១ មានបំណងរៀបចំនូវកិច្ចការមូលដ្ឋានចាំបាច់ ដើម្បីបង្កើតកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR) ដែលដឹកនាំដោយប្រទេស និងមានភាពជាម្ចាស់។ PPCR ដំណាក់កាលទី២ ផ្តោតលើការអនុវត្តនូវជំនួយបច្ចេកទេស និងគម្រោងបណ្តាក់ទុន។ បទពិសោធន៍ទទួលបានពីកម្មវិធីទាំងពីរនេះ ក៏មានឧបសគ្គចំពោះកម្ពុជាដូចជា៖ ខ្វះខាតបទពិសោធន៍ និងទិន្នន័យរយៈពេលវែង ធនធានមានកំណត់ (ការប្រមូលទិន្នន័យការចងក្រងជារបាយការណ៍ ការប្រើប្រាស់របាយការណ៍ និងការវិភាគ (សមត្ថភាពបច្ចេកទេស និងការបែងចែកមូលនិធិសម្រាប់ការសិក្សាឱ្យបានលម្អិត។ ជារួម SPCR បានកសាងសមត្ថភាព និងសម្របសម្រួលចាប់តាំងពីមានតម្រូវការនៃបន្សាំនឹងការ

ប្រែប្រួលអាកាសធាតុ។ បញ្ហាយេនឌ័រក៏ស្រប នឹងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលផងដែរ។

MRC ក៏បាន និងកំពុងសហការជាមួយបណ្តាប្រទេសនៅអាងទន្លេមេគង្គក្រោម ដើម្បីផ្តួចផ្តើមកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ដែលហៅថា កិច្ចផ្តួចផ្តើមប្រែប្រួលអាកាសធាតុ និងការ បន្សាំ (CCAI) ដើម្បីរៀបចំការវិភាគ និងការវាយតម្លៃដោយមានការចូលរួម និងតាមបែបវិទ្យាសាស្ត្រ ដើម្បីបង្កើនការយល់ដឹង ស្តីពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងសកម្មភាពបន្សាំដែលសមស្រប។ កិច្ចផ្តួចផ្តើមនេះអាចរួមចំណែកដល់ការពង្រឹងសមត្ថភាពបន្សាំរបស់ប្រទេសជាសមាជិក និងតំបន់ទាំងមូល ក៏ដូចជាឆ្លើយតបនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

### កិច្ចពិភាក្សានៅក្នុងវគ្គនេះរួមមាន៖

- ថ្មីៗនេះ MRC បានវាយតម្លៃពីរបៀបដែលការប្រែប្រួលអាកាសធាតុជះឥទ្ធិពលទៅលើវារីអគ្គិសនី និងបង្កើតជាយុទ្ធសាស្ត្រថ្នាក់តំបន់ពីបន្សាំនឹងការប្រែប្រួលអាកាសធាតុ MRC ក៏មានយន្តការក្នុងការបញ្ចូលបណ្តាប្រទេសជាសមាជិកទៅក្នុងកិច្ចពិភាក្សាពីរបៀបអភិវឌ្ឍអាងទន្លេមេគង្គ។ នៅពេលពិចារណាអំពីការកាត់បន្ថយផលប៉ះពាល់ត្រូវក្រឡេកមើលយុទ្ធសាស្ត្របន្សាំ ពិសេសការអភិវឌ្ឍជនបទ និងកសិកម្ម សន្តិសុខស្បៀង ការកសាងសមត្ថភាព និងការលើកកម្ពស់ការយល់ដឹងដែលពាក់ព័ន្ធនឹងការបង្កើនការយល់ដឹងអំពីផលប៉ះពាល់ដែលអាចកើតមាន និងវិសមរូបអាកាសធាតុដែលជាបញ្ហាដំបូងត្រូវដោះស្រាយ។ ដើម្បីរៀបចំប្រទេស ឬប្រជាជននៅតំបន់ជនបទឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ត្រូវគិតទាំងបច្ចេកវិទ្យា ហិរញ្ញវត្ថុ ព្រមទាំងគោលនយោបាយផងដែរ។
- ការទទួលបានព័ត៌មានអាចទុកចិត្តបាន គឺជាការប្រឈមមួយ ដោយប្រភពព័ត៌មានខ្លះគ្មាន និងព័តមានខ្លះទៀត ត្រូវការពេលវេលាប្រហែលជា៥០ឆ្នាំ។ ដូចនេះគួរទស្សន៍ទាយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុក្នុងរយៈពេលខ្លី (ប្រហែលជា ៥ឆ្នាំ) ដោយសារការទស្សន៍ទាយរយៈពេលវែងមិនអាចទុកចិត្តបាន។
- បើយោងតាមអនុសាសន៍របស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន ការកសាងសមត្ថភាពគួរតែរៀបចំឱ្យបានទូលំទូលាយ ហើយគួរផ្តោតលើគ្រប់វិស័យដែលក្នុងនោះ រួមមានវិស័យសំខាន់ៗចំនួន៤ ដូចជា៖ កសិកម្ម ធនធានទឹក ការអភិវឌ្ឍជនបទ និងការផ្គត់ផ្គង់ទឹក។ លើសពីនេះទៅទៀត ត្រូវមានការចូលរួមពីអ្នកពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- MRC សហការយ៉ាងជិតស្និទ្ធ ជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្តល់នូវព័ត៌មាន ក៏ប៉ុន្តែការផ្តល់ព័ត៌មានទៅថ្នាក់មូលដ្ឋានជាការទទួលខុសត្រូវរបស់រដ្ឋាភិបាលជាតិ។
- ប្រទេសកម្ពុជា គឺជាប្រទេសដែលមានភាពងាយរងគ្រោះជាងគេ ទៅនឹងការប្រែប្រួលអាកាសធាតុនៅអាស៊ី ដោយសារសេដ្ឋកិច្ចជាតិភាគច្រើន ពឹងអាស្រ័យលើវិស័យកសិកម្ម និងកម្ពុជាគឺជាប្រទេសមួយដែលក្រីក្រជាងគេ នៅក្នុងចំណោមបណ្តាប្រទេសអាស៊ាន។ ដើម្បីអភិវឌ្ឍប្រទេស កម្ពុជាត្រូវយកចិត្តទុកដាក់ទៅលើដំណោះស្រាយចាប់ពីពេលនេះទៅ។

- ឯកឧត្តម ខៀវ មុត បានលើកឡើងអំពីការព្រួយបារម្ភ ចំពោះខេត្តដែលជាប់សមុទ្រទាំង៤របស់ប្រទេសកម្ពុជា ពាក់ព័ន្ធនឹងការប៉ាន់ស្មានតាមវិទ្យាសាស្ត្រ អំពីកំណើនកម្ពស់ទឹកសមុទ្រសកល។ ឯកឧត្តម បានស្នើសុំយោបល់ពីអ្នកស្រាវជ្រាវទាំងអស់ ដើម្បីការពារខេត្តទាំង៤ ពីការលិចលង់នាពេលអនាគត។ លោក Hans Guttman បានឆ្លើយតបថា តំបន់សមុទ្រ និងតំបន់ទំនាប គឺជាតំបន់ងាយរងគ្រោះជាងគេ។ តំបន់ទាំងនោះ មានសកម្មភាពសេដ្ឋកិច្ចច្រើន។ ដូចនេះដំណោះស្រាយសមស្របមួយ គឺពិចារណាពីការរំកិលសកម្មភាពសេដ្ឋកិច្ចទាំងនោះទៅតំបន់ផ្សេងទៀត។

## បច្ចុប្បន្នភាព ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា ដោយផ្ដោតលើសកម្មភាពបន្តនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ការប្រែប្រួលអាកាសធាតុ ត្រូវបានចាត់ទុកជាបញ្ហាអន្តរវិស័យនៅក្នុង NSDP (២០១៤-២០១៨) រាជរដ្ឋាភិបាលនឹងកៀរគរធនធាន ការគាំទ្រ និងហិរញ្ញប្បទាន ដើម្បីចូលរួមក្នុងកិច្ចប្រឹងប្រែងជាសកល លើការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ។ **សម្តេចនាយករដ្ឋមន្ត្រី**បានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការរួចហើយនូវផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (២០១៤-២០២៣) ទាក់ទងនឹងគោលនយោបាយប្រែប្រួលអាកាសធាតុ។ លើសពីនេះទៀត ស្ថាប័នពាក់ព័ន្ធកំពុងរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ។ ផែនការយុទ្ធសាស្ត្រ និងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង ក៏ត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការក្នុងខែមីនា ឆ្នាំដដែលនេះដែរ។

ប្រទេសកម្ពុជាមានកម្មវិធីចម្បងចំនួនពីរ អំពីភាពធន់នឹងអាកាសធាតុ។ CCCA ដែលមានថវិកាសរុបចំនួន ១១លានដុល្លារអាមេរិច ទទួលបានពី EU UNDP SIDA និង DANIDA សម្រាប់រយៈពេលពី ២០១១ ដល់ ២០១៤។ កម្មវិធីមួយទៀតគឺ PPCR ដែលមានមូលនិធិសរុបចំនួន ១.៥ លានដុល្លារអាមេរិក ទទួលបានពីធនាគារពិភពលោក និងរាជរដ្ឋាភិបាលកម្ពុជាគិតពីឆ្នាំ ២០១១ ដល់ ២០១៣។ PPCR ដំណាក់កាលទី២ សម្រាប់រយៈពេលពី ២០១៣ ដល់ ២០១៧ មានថវិកាសរុបចំនួន៥៥លានដុល្លារអាមេរិក និងអនុវត្តក្នុងវិស័យអាទិភាពមួយចំនួន ដូចជា៖ ធនធានទឹក កសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធ។ គម្រោងការប្រែប្រួលអាកាសធាតុមួយចំនួនទៀត ដែលមានការគាំទ្រថវិកាពីភ្នាក់ងារផ្សេងៗ ដូចជា UNEP មូលនិធិបន្សុាំ JICA ក្រសួងការបរទេសជប៉ុន FAO UNDP AusAID DANIDA Luxemburg SIDA IUCN និង IGES។ NGOs មួយចំនួនបាន និងក៏កំពុងអនុវត្តគម្រោងការប្រែប្រួលអាកាសធាតុផ្សេងៗ ទាំងបន្សុាំ និងការកាត់បន្ថយ។

កំឡុងពេល ៣-៤ឆ្នាំ កន្លងទៅនេះ ថវិកាប្រមាណ ២៥០លានដុល្លារអាមេរិក ត្រូវបានកៀរគរ សម្រាប់កម្មវិធីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (ភាគច្រើនលើការងារបន្សុាំនឹងការប្រែប្រួលអាកាសធាតុ)។ ការវិភាគថ្មីៗលើការចំណាយសាធារណៈបានបង្ហាញថា ប្រមាណ ៨៦% នៃការចំណាយសរុបលើកិច្ចការប្រែប្រួលអាកាសធាតុនៅកម្ពុជាមានប្រភពមកពីខាងក្រៅប្រទេស។ មានវិស័យចម្បងៗដែលទទួលបានគម្រោងការប្រែប្រួលអាកាសធាតុពេលបច្ចុប្បន្ន មាន កសិកម្ម ធនធានទឹក/ធារាសាស្ត្រ អភិវឌ្ឍន៍ជនបទ (ហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ផ្លូវជនបទ) ការអភិវឌ្ឍ និងធ្វើផែនការតំបន់ឆ្នេរ តំបន់ការពារ និងព្រៃឈើ អគ្គិសនីជនបទ និងផ្លូវថ្នល់។

ចំណុចគន្លឹះសម្រាប់ការពិភាក្សាក្នុងបទបង្ហាញនេះមានដូចជា៖

- បទពិសោធន៍ជាច្រើន ទទួលបានពីការអនុវត្តគម្រោង រាប់បញ្ចូលទាំងយុទ្ធសាស្ត្រ ប្តូរពីការអនុវត្តគម្រោងមកជាការអនុវត្តកម្មវិធី ការបង្កើនសមត្ថភាពជាតិ និងការបង្កើតយន្តការមូលនិធិរួមគ្នា។ កត្តាទាំងនេះបណ្តាលមកពី៖ [១]កំណើនការចាប់អារម្មណ៍នឹងការប្រែប្រួលអាកាសធាតុ [២]ការយល់ដឹងកាន់តែច្បាស់ពីទំនោរនៃការប្រែប្រួលអាកាសធាតុនិង[៣]ទាំងអ្នកអនុវត្តគម្រោងនិងម្ចាស់ជំនួយបានចាប់ផ្តើមផ្លាស់ប្តូរពីយុទ្ធសាស្ត្រអនុវត្តគម្រោងមកជាការអនុវត្តកម្មវិធី ដើម្បីធានាចីរភាពជំនួយ។

- រាជរដ្ឋាភិបាល កំពុងចរចាជាមួយម្ចាស់ជំនួយផ្សេងៗដូចជា UNDP SIDA DANIDA ជាដើម ក្នុងគោលបំណងបន្តជំនួយដូចករណីគម្រោងខាងលើ។ លើសពីនេះទៅទៀត រដ្ឋាភិបាលកម្ពុជា បានចាប់ផ្តើមកំណត់គោលបំណង និងពង្រឹងការអនុវត្ត CCCSP។

- វិធីលើកកម្ពស់តម្លាភាពមានពីរគឺ [១] សមត្ថភាពរបស់រដ្ឋាភិបាលក្នុងការសម្របសម្រួល និង[២]យុទ្ធសាស្ត្ររបស់ម្ចាស់ជំនួយ។ យុទ្ធសាស្ត្រទាំងពីរនេះគួរតែដាក់បញ្ចូលគ្នា ដើម្បីការអនុវត្តប្រកបដោយប្រសិទ្ធភាព។

## ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា

កម្ពុជាគួរតែបង្កើនសមត្ថភាពបន្សាំរបស់ខ្លួន ទៅនឹងហានិភ័យអាកាសធាតុបច្ចុប្បន្ន តាមរយៈការបង្កើនការគ្រប់គ្រងហានិភ័យអាកាសធាតុ និងការចិញ្ចឹមជីវិតរបស់សហគមន៍ ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់រយៈពេលខ្លី។ កម្ពុជាគួរតែបង្កើនប្រព័ន្ធភាពធន់នឹងហានិភ័យអាកាសធាតុនាពេលអនាគត តាមរយៈការបង្កើតគោលនយោបាយ និងការធ្វើផែនការរយៈពេលវែង ការរចនាឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ ដែលអាចប្រើប្រាស់បានយូរ ហើយធន់នឹងការប្រែប្រួលអាកាសធាតុជាងមុនសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរយៈពេលវែង។ ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ មានចក្ខុវិស័យជំរុញកម្ពុជាឆ្ពោះទៅរកសង្គមមួយដែលមានភាពបៃតង ធន់នឹងអាកាសធាតុ សមភាព ចីរភាព និងពឹងផ្អែកលើចំណេះដឹងជាគោល។ ផែនការយុទ្ធសាស្ត្រនេះ មានវត្ថុបំណងចំនួន ៨។

### ចំណុចពិភាក្សាសំខាន់ៗ នៅក្នុងផ្នែកនេះមានដូចខាងក្រោម៖

- ការរៀបចំ CCCSP នៅកម្ពុជាបានចំណាយពេលវេលាអស់ប្រហែលជាបីឆ្នាំ ហើយទទួលក៏បានការរួមចំណែកពីស្ថាប័នពាក់ព័ន្ធ ជំនាញការ និង គ.ជ.គ.ប.អ.។ បញ្ហាដែលលំបាក និងប្រើប្រាស់ពេលច្រើនជាងគេ គឺការបកប្រែទៅជាភាសាខ្មែរ។

- ការរៀបចំផែនការយុទ្ធសាស្ត្រនេះ បានប្រើប្រាស់ពេលវេលាអស់ប្រមាណជាពីរឆ្នាំ អាស្រ័យដោយផែនការយុទ្ធសាស្ត្រនេះ តម្រូវឱ្យប្រមូលយោបល់ និងការចូលរួមពិគ្រោះយោបល់ទាំងពីម្ចាស់ជំនួយ និងជំនាញការ ការបកប្រែត្រូវការពេលវេលាច្រើននៅក្នុងបណ្តាប្រទេសអាស៊ាន ដូចជាប្រទេសថៃ និងវៀតណាម ក៏បានបញ្ចប់ផែនការមេស្តីពីការប្រែប្រួលអាកាសធាតុរបស់គេដូចជាកម្ពុជាដែរ។ ជាទូទៅប្រទេសនីមួយៗ មានផែនការយុទ្ធសាស្ត្ររបស់ខ្លួន ក៏ប៉ុន្តែកម្រិតនៃភាពលម្អិតនោះខុសៗគ្នា។ នៅក្នុងកិច្ចប្រជុំបណ្តាប្រទេសអាស៊ាន

ប្រទេសកម្ពុជា បានចែករំលែកបទពិសោធន៍របស់ខ្លួន អំពីការប្រែប្រួលអាកាសធាតុ។ ឧទាហរណ៍ កម្ពុជាបានបង្ហាញពីការបង្កើតនាយកដ្ឋានប្រែប្រួលអាកាសធាតុ ហើយគណៈប្រតិភូមួយចំនួនក៏បានស្នើទៅរដ្ឋាភិបាលរបស់ខ្លួនឱ្យអនុវត្តដូចកម្ពុជាដែរ។

- រាជរដ្ឋាភិបាលកម្ពុជា មិនទាន់បានគ្រប់គ្រងលើគម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុទាំងអស់នៅក្នុងប្រទេសនៅឡើយទេ ហើយកម្ពុជាគ្មានបទបញ្ញា ឬគោលការណ៍ណាមួយ ដើម្បីជៀសវាងពីការអនុវត្តគម្រោងជាន់គ្នានោះដែរ។ ប៉ុន្តែរាជរដ្ឋាភិបាលបានព្យាយាមជៀសវាងនូវការអនុវត្តគម្រោងជាន់គ្នា ទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ។

នៅចុងបញ្ចប់នៃវគ្គនេះ ឯកឧត្តម ខៀវ មុត បានសរុបសេចក្តីថា យើងត្រូវសហការគ្នា ដើម្បីដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេស។ រាជរដ្ឋាភិបាល បានចាត់ទុកការប្រែប្រួលអាកាសធាតុ ជាសកម្មភាពអាទិភាពមួយ។ កម្ពុជាបានប្តេជ្ញាចិត្តរៀបចំ CCCSP ហើយបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការនៅវេលាព្រឹកថ្ងៃទី១ នៃវេទិកាជាតិដោយសម្តេចនាយករដ្ឋមន្ត្រី។ សកម្មភាពបន្ទាប់ទៀតគឺ ត្រូវបន្តកិច្ចសហប្រតិបត្តិការ និងរៀបចំ CCAP ដើម្បីឆ្ពោះទៅរកសង្គមកម្ពុជាដែលមានភាពបៃតង។

## ៤.២ យុទ្ធសាស្ត្រជាតិឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ៖ បទពិសោធន៍ទទួលបាន និងដំណើរឆ្ពោះទៅមុខ

ដំណើរការនៃកិច្ចរៀបចំផែនការ ព្រមទាំងកញ្ចប់ថវិកានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គឺជាគន្លឹះក្នុងការគាំទ្រដល់បន្សាំនឹងការប្រែប្រួលអាកាសធាតុ ក៏ដូចជាការបណ្តាក់ទុនពាក់ព័ន្ធនឹងអាកាសធាតុ។ ប្រទេសកម្ពុជាមានស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចយ៉ាងប្រសើរ ក្នុងអំឡុងទសវត្សរ៍ចុងក្រោយ ដែលជាសូចនាកររបស់កំណើនផលិតផលក្នុងស្រុកសរុប (GDP) កំណើនប្រាក់ចំណូលរបស់ប្រជាជន និងការកាត់បន្ថយអត្រាភាពក្រីក្រក្នុងប្រទេស។ ដោយយោងទៅតាមសុន្ទរកថារបស់ឯកឧត្តម ប៉ាន ប៊ុនធឿន រដ្ឋលេខាធិការក្រសួងផែនការ បានលើកឡើងថា "ទោះបីជាប្រទេសកម្ពុជា កំពុងតែមានកំណើនសេដ្ឋកិច្ចដ៏ល្អក៏ដោយ ប៉ុន្តែកំណើននេះនឹងត្រូវរាំងស្ទះ ដោយសារការប្រែប្រួលអាកាសធាតុនៅពេលខាងមុខយ៉ាងខ្លី ប្រសិនបើយើងមិនបានដាក់ចេញនូវ វិធានការឱ្យបានត្រឹមត្រូវសម្រាប់ដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនោះទេ"។

ការជួយសហគមន៍ជនបទ ឱ្យបន្សាំនឹងហានិភ័យនៃការប្រែប្រួលអាកាសធាតុ គឺជាអាទិភាពចម្បង ហើយរាជរដ្ឋាភិបាលកម្ពុជានឹងបញ្ចូលការប្រែប្រួលអាកាសធាតុ ជាបញ្ហាអន្តរវិស័យនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ NSDP។ ក្នុងន័យនេះ ឯកឧត្តម ប៉ាន ប៊ុនធឿន បានបន្ថែមថា "ការពិចារណាពីការប្រែប្រួលអាកាសធាតុ គឺជាការចាំបាច់បំផុត ដើម្បីធានាឱ្យទទួលបាននូវការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមទំហំល្បឿន និងយុទ្ធសាស្ត្រជាតិ" ។

ឯកឧត្តម **Jean-François Cautain** ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំកម្ពុជា បានកត់សម្គាល់ថា គោលនយោបាយ និងក្របខណ្ឌ បទបញ្ញារបស់ប្រទេសកម្ពុជាក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ បានជំរុញឱ្យមានការគាំទ្រពីបណ្តាស្ថាប័ន

អន្តរជាតិ ទាំងបច្ចេកទេស និងហិរញ្ញវត្ថុ។ ដោយឡែក EU បានបញ្ចូលហិរញ្ញវត្ថុអាកាសធាតុទៅក្នុងកញ្ចប់ថវិកា ដោយក្នុងនោះកញ្ចប់ថវិកាយ៉ាងហោចណាស់ ២០% នៃថវិកាសរុប នឹងត្រូវប្រើប្រាស់សម្រាប់សកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតចាប់ពីឆ្នាំ ២០១៤ ដល់ ២០២០។ ឯកឧត្តមក៏បានថ្លែងបន្ថែមថា EU និងដៃគូរបស់ខ្លួននឹងបន្តជួយគាំទ្រ និងសហការជាមួយប្រទេសកម្ពុជាក្នុងសកម្មភាពបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុឱ្យមានប្រសិទ្ធភាព ហើយទទូចឱ្យដៃគូអភិវឌ្ឍន៍ផ្សេងៗទៀតចូលរួមជាមួយ។

នៅថ្ងៃទី២នៃវេទិកាជាតិនេះ ការពិភាក្សាបានផ្តោតសំខាន់ កិច្ចផ្តួចផ្តើមធ្វើផែនការតាមវិស័យ ដែលអនុវត្តដោយក្រសួងពាក់ព័ន្ធនានា។ មកដល់ពេលនេះ ក្រសួងដែលពាក់ព័ន្ធទាំង ៩ បានបង្កើត CCSP តាមវិស័យ ក្រោមការសម្របសម្រួលពីនាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃក្រសួងបរិស្ថាន។ CCAP ក៏កំពុងត្រូវបានរៀបចំដោយក្រសួងពាក់ព័ន្ធដដែល ដើម្បីបង្ហាញពីកិច្ចខិតខំប្រឹងប្រែងក្នុងការបញ្ចូលការប្រែប្រួលអាកាសធាតុ ទៅក្នុងផែនការអភិវឌ្ឍទូទៅរបស់សាមីក្រសួង និងបញ្ជៀសការអនុវត្តដែលគ្មានលក្ខណៈជាប្រព័ន្ធ។ ទាំងនេះ គឺជាកិច្ចការចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវក្របខ័ណ្ឌការងារដោយពឹងផ្អែកលើភាពជាក់ស្តែង និងកញ្ចប់ថវិកាច្បាស់លាស់ រឹងមាំ និងពិតប្រាកដ ដើម្បីដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ។ ប្រធានដឹកនាំអ្នកធ្វើបទបង្ហាញ វាគ្មិន និងអ្នកចូលរួម ក៏បានលើកយកបទពិសោធន៍ទទួលបាន និងដំណើរឆ្ពោះទៅមុខនៃផែនការយុទ្ធសាស្ត្រជាតិដូចខាងក្រោម៖

## ការអប់រំការប្រែប្រួលអាកាសធាតុ ទំនាក់ទំនងនិងយេនឌ័រ៖

*ការបញ្ជ្រាបយេនឌ័រទៅក្នុងការប្រែប្រួលអាកាសធាតុ៖* ស្ត្រីមានចំនួន ៥១ % នៃប្រជាជនសរុបក្នុងប្រទេស ហើយស្ត្រីក៏រងផលប៉ះពាល់ច្រើនជាងបុរស នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ។ ការប្រែប្រួលអាកាសធាតុនាំឱ្យមានវិសមភាពយេនឌ័រកាន់តែខ្លាំង ហើយក៏អាចបណ្តាលឱ្យមានផលប៉ះពាល់ខ្លាំងដល់ស្ត្រី។ ដើម្បីឆ្លើយតបនឹងវិសមភាពនេះ MoWA ដែលជាគ្រឿងចក្រសម្រាប់លើកកម្ពស់សមភាពយេនឌ័រ និងផ្តល់អំណាចដល់ស្ត្រី បានប្តេជ្ញាចិត្តរៀបចំផែនការយុទ្ធសាស្ត្ររយៈពេល ៥ឆ្នាំ (នារីរតនៈ ៣) ដើម្បីឆ្លើយតបនឹងបញ្ហាយេនឌ័រនៅក្នុងគោលនយោបាយ និងយុទ្ធសាស្ត្រជាតិស្តីពីបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ MoWA មានយន្តការចំនួនពីរដូចជា៖ [១]ការបង្កើតគណៈកម្មាធិការយេនឌ័រ និងការប្រែប្រួលអាកាសធាតុនៅចុងឆ្នាំ២០១១ ដើម្បីដោះស្រាយបញ្ហាយេនឌ័រនៅក្នុងការប្រែប្រួលអាកាសធាតុ [២]បង្កើតក្រុមរៀបចំសកម្មភាពបញ្ជ្រាបយេនឌ័រទៅក្នុងក្រសួងពាក់ព័ន្ធនានា។

ផែនការសកម្មភាព នៅពេលខាងមុខក៏ត្រូវបានបញ្ចូលនៅក្នុងសេចក្តីព្រាងគោលនយោបាយជាតិស្តីពីយេនឌ័រ។ រាជរដ្ឋាភិបាលកម្ពុជាគួរតែផ្តោតការយកចិត្តទុកដាក់មុនគេ លើការផ្តល់អំណាចដល់ស្ត្រី ការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍបៃតង ដោយមានការចូលរួមពីស្ត្រី ប្រសិនបើគិតពីការរីកចម្រើនផ្នែកសេដ្ឋកិច្ច។ បន្ទាប់មកគួរតែមានវគ្គបណ្តុះបណ្តាល និងការអប់រំដល់ស្ត្រី និងកុមារី និងការផ្លាស់ប្តូរឥរិយាបថរបស់ពួកគេចំពោះការប្រែប្រួលអាកាសធាតុ សុខភាពស្ត្រី និងកុមារី និងកិច្ចការពារផ្លូវច្បាប់ដល់ស្ត្រី និងកុមារី ដោយផ្អែក

លើការវិនិយោគសិទ្ធិយេនឌ័រក្នុងសេវាកម្មសង្គម។ ជាចុងក្រោយ RGC គួរតែលើកទឹកចិត្តឱ្យមានការចូលរួមពីស្ត្រីក្នុងការសម្រេចចិត្តការគ្រប់គ្រងរដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុដើម្បីអភិបាលកិច្ចល្អ។

*ការអប់រំបរិស្ថាន និងការប្រែប្រួលអាកាសធាតុនៅប្រទេសកម្ពុជា៖* ការអប់រំពិតជាមានសារៈសំខាន់ណាស់ ពិសេសកុមារ និងស្ត្រីជាក្រុមដែលរងគ្រោះខ្លាំងពីការប្រែប្រួលអាកាសធាតុ។ ដើម្បីចូលរួមដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុនេះ MoEYS បានបញ្ចូលការអប់រំបរិស្ថាន និងការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីសិក្សាថ្នាក់បឋមសិក្សា និងមធ្យមសិក្សាតាំងពីឆ្នាំ ១៩៩៧ មកម្លេះ លើសពីនេះទៅទៀតតាមរយៈកិច្ចសហប្រតិបត្តិការជាមួយ MoE និង MoEYS បាន និងកំពុងរៀបចំ CCSP និង CCAP នៅក្នុងវិស័យអប់រំ។ MoEYS ប្តេជ្ញាចិត្តនឹងបន្តការអនុវត្តនូវវត្ថុបំណង និងសកម្មភាពអាទិភាពទាំងនៅក្នុង CCSP និង CCAP ដើម្បីឱ្យសិស្សមានចំណេះដឹងបន្ថែម ពីការប្រែប្រួលអាកាសធាតុ និងធានាថាពួកគេត្រៀមខ្លួនរួចជាស្រេចនឹងការប្រែប្រួលអាកាសធាតុ។ លោក **គឹម សុបិន្ត** ជាវាគ្មិននៅក្នុងវគ្គនេះ បានលើកពីសកម្មភាពបច្ចុប្បន្នរបស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA) ពាក់ព័ន្ធនឹងអាកាសធាតុ។ លោក បានបញ្ជាក់ពីសារៈសំខាន់នៃការចូលរួម និងការកសាងសមត្ថភាពនិស្សិត ដូចនេះ បានជា RUA បានស្នើទៅម្ចាស់ជំនួយនូវគម្រោង "ការបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងការមុខវិជ្ជាសិក្សាសម្រាប់ការអភិវឌ្ឍនៅកម្ពុជា"។ គម្រោងក៏បានបង្កើតមេរៀនចំនួន៩ ដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុ ទៅក្នុងកម្មវិធីសិក្សាបច្ចុប្បន្ន នៅក្នុងសាកលវិទ្យាល័យចំនួន ៧ នៅកម្ពុជា។ ក្រៅពីនេះ គម្រោងក៏នៅមានកម្មវិធីកសាងសមត្ថភាពដល់សាស្ត្រាចារ្យ ដែលចូលរួមក្នុងគម្រោងនេះផងដែរ។ បន្ថែមពីលើនេះទៀត RUA កំពុងអនុវត្តគម្រោងមួយទៀត ដែលផ្តោតលើការប្រែប្រួលអាកាសធាតុនៅតំបន់អាងទន្លេមេគង្គ កម្ពុជា ឡាវ ថៃ និងវៀតណាម) ។ ក្រុមការងាររបស់គម្រោងក៏បានស្រាវជ្រាវ ដើម្បីបង្កើតទិន្នន័យ ហើយបន្ទាប់មក គ្រោងនឹងផ្សព្វផ្សាយលទ្ធផលទៅស្ថាប័នផ្សេងៗ និងអ្នកពាក់ព័ន្ធនានា។

លោក Chris Eijkemans បានបញ្ជាក់ក្នុងចំណាប់អារម្មណ៍របស់ខ្លួន អំពីកិច្ចស្វាគមន៍ដល់ MoWA ក្នុងការដោះស្រាយបញ្ហាយេនឌ័រនៅក្នុងការប្រែប្រួលអាកាសធាតុ។ ជាការពិតណាស់ ការប្រែប្រួលអាកាសធាតុជាប់ទាក់ទងនឹងវិសមធម៌យេនឌ័រនៅកម្ពុជា។ ជាងនេះទៅទៀត ស្ត្រីមិនមែនជាជនរងគ្រោះពីការប្រែប្រួលអាកាសធាតុតែម្នាក់ឯងទេ ប៉ុន្តែស្ត្រីមានតួនាទីសំខាន់នៅក្នុងការផ្តល់ចំណេះដឹង និងជំនាញ ដូចនេះស្ត្រី និងបុរសមានសារៈសំខាន់ស្មើគ្នាក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។ មូលហេតុដែលស្ត្រីជាជនរងគ្រោះពីការប្រែប្រួលអាកាសធាតុដោយសារតែបុរសត្រូវចេញក្រៅដើម្បីរកចំណូល ចំណែកឯស្ត្រីវិញត្រូវស្នាក់នៅផ្ទះ ដើររកអុស និងធ្វើកិច្ចការផ្ទះ។ ប្រសិនបើមានទឹកជំនន់ ឬភ្លៀងធ្លាក់ខ្លាំង ស្ត្រីអាចលង់ទឹកជំនន់។ ឧទាហរណ៍៖ ប្រមាណជា៩០% នៃជនរងគ្រោះដោយសារទឹកជំនន់គឺជាស្ត្រី និងកុមារ។ ដូចនេះ RGC គួរតែបង្កើតគោលនយោបាយដែលគិតពិចារណាទាំងបុរស និងស្ត្រី។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាល គួរតែធ្វើរឿងពីរដើម្បីយកឈ្នះលើការប្រែប្រួលអាកាសធាតុ។ ទី១ គឺវិភាគ និងទី២ ត្រូវយល់ពីវិសមធម៌យេនឌ័រ។ ចុងបញ្ចប់ មានកត្តាពីរ ដើម្បីដោះស្រាយបញ្ហាយេនឌ័រ ក្នុងការប្រែប្រួលអាកាសធាតុគឺអំណាច និងការសម្រេចចិត្ត។ នៅប្រទេសកម្ពុជា មានតែបុរសទេដែលអាចធ្វើការសម្រេចចិត្តបាន។ ដូចនេះស្ត្រីគួរតែត្រូវបានបញ្ចូល និងមានសមភាព

និងគុណភាពក្នុងការចូលរួមយកឈ្នះលើការប្រែប្រួលអាកាសធាតុ។

តំណាងមកពី Oxfam រីករាយនឹងមើលឃើញ ការបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីសិក្សានៅក្នុងវិស័យអប់រំ។ ទោះបីជាយ៉ាងណាក៏ដោយការសិក្សាពីការប្រែប្រួលអាកាសធាតុនេះ គួរតែមានទាំងការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ។ ការប្រែប្រួលអាកាសធាតុ គួរតែមាននៅក្រៅសាលារៀនផងដែរ។ លើសពីនេះទៅទៀត ត្រូវតែមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាល និង CSOs។ RGC គួរតែអនុវត្តសកម្មភាពសំខាន់ៗពីរ ដែលអាចកែលម្អកម្មវិធីសិក្សាបច្ចុប្បន្ន នៃការអប់រំក្នុងប្រព័ន្ធ ដើម្បីបញ្ចូលការប្រែប្រួលអាកាសធាតុ និងបង្កើនសមត្ថភាពគ្រូបង្រៀន។ ការអប់រំក្រៅប្រព័ន្ធ មានសារៈសំខាន់ណាស់ដោយសារមានមនុស្សមួយចំនួន មិនបានចូលសាលារៀន។ RGC គួរបង្កើតភាពធន់នឹងការប្រែប្រួលអាកាសធាតុ ដោយគិតឡើងវិញពីរបៀបនៃការរស់នៅប្រកបដោយចីរភាព បង្កើនការបង្រៀនបែបបែតងបណ្តុះបណ្តាលការត្រៀមខ្លួន សម្រាប់គ្រោះមហន្តរាយ និងពង្រឹងការសម្រេចចិត្តឱ្យបានសមស្រប ចំពោះបញ្ហាទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។

អនុសាសន៍មួយចំនួន បានលើកឡើងនៅក្នុងវគ្គនេះសម្រាប់ប្រទេសកម្ពុជាមានដូចជា៖ [១] បង្កើនអ្នកអប់រំពីការប្រែប្រួលអាកាសធាតុ [២] លើកកម្ពស់ការអប់រំក្រៅប្រព័ន្ធ [៣] វៃអង្គាស និងផ្សព្វផ្សាយព័ត៌មានដែលអាចទុកចិត្តបាន និងបន្ទាប់មកត្រូវធានាថាវាត្រូវបានអនុវត្ត [៤] RGC គួរតែបណ្តាក់ទុនបង្កើតប្រព័ន្ធព័ត៌មានក្នុងប្រទេសកម្ពុជា ដែលពាក់ព័ន្ធនឹងការអប់រំក្រៅប្រព័ន្ធ [៥] ចងក្រងលទ្ធផលពីការអនុវត្តដោយជោគជ័យ ពីការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងចែករំលែកជាមួយអ្នកពាក់ព័ន្ធនានា។

ដោយផ្អែកលើរបាយការណ៍ ស្តីពីការការឃ្លាំមើលសិទ្ធិមនុស្សនៅកម្ពុជា ឆ្នាំ២០១៣ កញ្ញា **គង់ កែវសុគន្ធា** បានចែករំលែកទស្សនៈថាកម្ពុជា គឺជាប្រទេសទីពីរដែលរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុជាងគេ ហើយកម្ពុជាមិនបានចូលរួមដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ ដោយសារកង្វះខាតចំណេះដឹង ដូចនេះរាជរដ្ឋាភិបាលគួរតែព្យាយាមបន្ថែមទៀត។ មានទស្សនៈចំនួន៤ សម្រាប់ការពិចារណា៖ [១] ក្នុងកម្រិតអន្តរជាតិ កម្ពុជាគួរតែព្យាយាមបង្ហាញពីបញ្ហាដែលខ្លួនកំពុងជួបប្រទះ [២] នៅថ្នាក់ជាតិគួរតែបង្កើតវគ្គបណ្តុះបណ្តាលបន្ថែមទៀតដល់អ្នកកាសែត អាស្រ័យដោយពួកគេមានចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុតិចតួច និងលើកទឹកចិត្តឱ្យមានការប្រកួតប្រជែងក្នុងប្រធានបទការប្រែប្រួលអាកាសធាតុ [៣] នៅថ្នាក់មូលដ្ឋានគួរតែមានប្រព័ន្ធផ្តល់ព័ត៌មានជាមុន ដូចជាប្រព័ន្ធផ្តល់ព័ត៌មានទឹកជំនន់ និង [៤] បញ្ហាយេនឌ័រ។

ពាក់ព័ន្ធនឹងយេនឌ័រ លោក **ស៊ូ សុជាតិ** បានផ្តល់យោបល់ថា RGC គួរគិតពីការបញ្ចូលស្ត្រីក្នុងការប្រែប្រួលអាកាសធាតុ។ ការសិក្សាពីការប្រែប្រួលអាកាសធាតុ ត្រូវការការចូលរួមពីប្រជាជនមូលដ្ឋាន។ ការបញ្ចូលការប្រែប្រួលអាកាសធាតុ និងយេនឌ័រទៅក្នុងកម្មវិធីសិក្សាតាមសាលារៀន មានសារៈសំខាន់ណាស់ ហើយរាជរដ្ឋាភិបាលគួរតែពិចារណា។ ការចែករំលែកព័ត៌មានជាមួយអ្នកពាក់ព័ន្ធនានា ត្រូវមានយន្តការច្បាស់លាស់។ លោកក៏យល់ស្របជាមួយមតិរបស់លោក Chris ដែលបានលើកឡើងថាការអប់រំការប្រែប្រួលអាកាសធាតុ គួរតែអនុវត្តនៅក្រៅប្រព័ន្ធផងដែរ។ យន្តការនានាអាចមានដូចជា

ការបង្កើតសមាគមន៍និស្សិត ឬការរៃអង្គាសមូលនិធិ ដើម្បីដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុនៅតាមសាលារៀន។ ចំណុចចុងក្រោយ សិស្សគួរតែអាចទទួលបានព័ត៌មានពីការប្រែប្រួលអាកាសធាតុ។

សំណូមពរមួយចំនួន ត្រូវបានស្នើឡើងចំពោះដៃគូអភិវឌ្ឍនានាក្នុងការផ្តល់មូលនិធិដល់គណៈប្រតិភូឱ្យទៅចូលរួមប្រជុំ COP ព្រោះការចូលរួមនេះអាចជាឱកាសក្នុងកិច្ចចរចានិងការសម្រេចចិត្តផ្សេងៗ ហើយត្រូវបង្កើតប្រព័ន្ធផ្តល់សញ្ញាជាមុន និងនៅមានគំលាតក្នុងកិច្ចសហការជាមួយ MoWRAM និងប្រព័ន្ធផ្សព្វផ្សាយ។

ជារួម យើងត្រូវបង្កើតយន្តការដែលអាចបញ្ចូលស្ត្រីនៅក្នុងដំណើរការនៃការសម្រេចចិត្ត ធ្វើឱ្យពួកគេ ដឹងពីបញ្ហាប្រែប្រួលអាកាសធាតុ និងរៀនសូត្រពីការយកឈ្នះលើវា។ ត្រូវបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងការអប់រំទាំងក្នុង និងក្រៅប្រព័ន្ធ។

## ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម និងធារាសាស្ត្រ

ការប្រែប្រួលអាកាសធាតុ បានជះឥទ្ធិពលអវិជ្ជមានជាច្រើនដល់វិស័យធនធានទឹក និងហេដ្ឋារចនាសម្ព័ន្ធ ដោយរួមមានទាំង ប្រព័ន្ធការពារទឹកជំនន់ផងដែរ។ ជាការឆ្លើយតបទៅនឹងបញ្ហានេះ MoWRAM បានរៀបចំវិធានការចម្រុះសម្រាប់គ្រប់គ្រងធនធានទឹក និងឧតុនិយម។ MoWRAM បានរៀបចំយុទ្ធសាស្ត្រចម្រុះ ដើម្បីគ្រប់គ្រងធនធានទឹក និងឧតុនិយម។ MoRWAM ក៏បានរៀបចំផែនការសកម្មភាពតាមវិស័យរបស់ខ្លួន ដែលរួមមានវិធានការណ៍៥ចំណុចដូចជាៈ កិច្ចការស្រោចស្រពដែលធន់នឹងអាកាសធាតុ ការគ្រប់គ្រងហានិភ័យគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ព័ត៌មានពាក់ព័ន្ធនឹងជលសាស្ត្រ និងឧតុនិយម (ព័ត៌មានពីធាតុអាកាស និងប្រព័ន្ធផ្តល់សញ្ញាជាមុន) ភាពធន់នឹងអាកាសធាតុក្នុងវិស័យកសិកម្ម និងការឆ្លើយតបពីបញ្ហាយេនឌ័រ និងការគ្រប់គ្រងទឹក។

វិស័យកសិកម្មជាចលករសេដ្ឋកិច្ចជាតិដ៏សំខាន់បំផុតសម្រាប់សន្តិសុខស្បៀង និងការ-អភិវឌ្ឍសេដ្ឋកិច្ចក្នុងប្រទេស ពីព្រោះប្រជាជនប្រមាណ ៨០% នៅជនបទពឹងផ្អែកលើមុខរបរកសិកម្ម។ ប៉ុន្តែផលិតកម្មកសិកម្ម រួមមានទាំងដំណាំ ជលផល ផលិតកម្មសត្វ ដំណាំកៅស៊ូ និងព្រៃឈើ កំពុងរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុ។ វិស័យទាំងនោះក៏ជាវិស័យដែលរួមចំណែកដល់ការបញ្ចេញ GHG ដែលជាមូលហេតុនៃការប្រែប្រួលអាកាសធាតុផងដែរ។ លោកបណ្ឌិត **សរ ចិត្រា** អនុប្រធាននាយកដ្ឋានផលិតកម្ម និងបសុព្យាបាលនៃ MAFF បានសង្កត់ធ្ងន់ថា ការចិញ្ចឹមសត្វ ការដាំដំណាំស្រូវ ការដុតសំណល់កសិកម្ម និងការដុតវាលស្មៅ ក៏បានរួមចំណែកក្នុងការបញ្ចេញ GHG ក្នុងប្រទេសកម្ពុជាផងដែរ។ ការប្រែប្រួលអាកាសធាតុ អាចបណ្តាលឱ្យមានភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភ ដែលបណ្តាលមកពីព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ បណ្តាលឱ្យការដាំដុះ ផលិតកម្មចិញ្ចឹមសត្វ ជលផល និងព្រៃឈើមិនបានទទួលផល។ ការរីករាលដាលនៃជំងឺ មិនត្រឹមតែប៉ះពាល់ធ្ងន់ធ្ងរដល់ផលិតកម្មដំណាំ និងផលិតកម្មសត្វនោះទេ ប៉ុន្តែអាចប៉ះពាល់ដល់សុខភាពមនុស្សផងដែរ។ MAFF បានរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម រយៈពេល ៥ឆ្នាំ (២០១៤-២០១៨) ក្នុងកម្រិតបីផ្សេងគ្នារួមមានៈ ថ្នាក់បច្ចេកទេសតាមវិស័យ ក្នុង MAFF ថ្នាក់ជាតិ (ដោយការបញ្ចូលក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣) ថ្នាក់តំបន់ (នៅក្នុងបរិបទ UNFCCC អាស៊ាន និងមហាអនុតំបន់ទន្លេ

មេគង្គ)។ ដើម្បីអនុវត្តយុទ្ធសាស្ត្រនេះ MAFF បានរៀបចំ CCAP ក្នុងគោលបំណង៖ [១] ជំរុញផលិតភាពកសិកម្ម និងកសិឧស្សាហកម្មឱ្យបាន ១០% ដោយប្រើប្រាស់សកម្មភាពយុទ្ធសាស្ត្រចំនួន ៥ [២] បង្កើនផលិតកម្មកៅស៊ូធម្មជាតិដោយសកម្មភាពយុទ្ធសាស្ត្រចំនួន៦ និង [៣] បង្កើនផលិតកម្មសត្វប្រចាំឆ្នាំឱ្យបាន ៣% ដោយសកម្មភាពយុទ្ធសាស្ត្រចំនួន ១០។ សកម្មភាពទាំងអស់នេះឆ្លុះបញ្ចាំងពីការតាំងចិត្តរបស់ MAFF ក្នុងបន្សាំ និងការកាត់បន្ថយ GHG ពីវិស័យនេះ ដោយធានាសន្តិសុខស្បៀង និងសុខុមាលភាពសង្គម។

ទាក់ទងទៅនឹងប្រធានបទនេះ មានវាគ្មិនចំនួន៣រូបទៀត ដែលបានមកពីគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (CNMC) វេទិកានៃអង្គការក្រៅរដ្ឋាភិបាលស្តីពីកម្ពុជា និងអង្គការមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម (IFAD) និងអង្គវេទិកាទាំងមូលក៏បានយល់ស្របថា ធនធានទឹក និងព័ត៌មានឧតុនិយម មានសារៈសំខាន់ណាស់ក្នុងការដោះស្រាយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុដល់វិស័យកសិកម្ម។ ក្នុងនោះផងដែរ ឯកឧត្តម **គល់ វឌ្ឍនា** អគ្គលេខាធិការរង CNMC បានលើកឡើងថា CCAP ក្នុងការគ្រប់គ្រងធនធានទឹក និងព័ត៌មានឧតុនិយមគួរត្រូវបានយកចិត្តដាក់ឱ្យកាន់តែខ្លាំង និងឱ្យមានប្រសិទ្ធភាពខ្ពស់ ជាពិសេសចំពោះការផ្តល់ព័ត៌មានប្រកាសអាសន្នជាមុន ទាំងថ្នាក់ក្រោមជាតិ និងថ្នាក់តំបន់។ លោក **ម៉េង សក្តិភូសិទ្ធ** តំណាងមកពី IFAD ក៏ព្រួយបារម្ភចំពោះការបញ្ចូលវិស័យកសិកម្ម និងធនធានទឹក និងព័ត៌មានឧតុនិយមនេះផងដែរ។ តម្រូវការដ៏ចាំបាច់របស់កសិករគឺព័ត៌មានធាតុអាកាស និងការព្យាករណ៍ដ៏ជាក់លាក់ និងទាន់ពេលវេលា។ ព័ត៌មានទាំងអស់នេះគឺបានជួយដល់ការរៀបចំផែនការវិនិយោគក្នុងវិស័យកសិកម្ម ដើម្បីកាត់បន្ថយហានិភ័យផ្សេងៗពីអាកាសធាតុ។ ក្នុងអំឡុងពេលពិភាក្សាទាំងតំណាងរដ្ឋាភិបាល និងតំណាងពីស្ថាប័នផ្សេងៗ បានចោទជាសំណួរចំនួន៣។ សំណួរទាំងអស់នោះរួមមាន៖ តើយើងត្រូវផ្តល់ព័ត៌មានពីធាតុអាកាស និងការព្យាករណ៍ទៅកសិករឱ្យទាន់ពេលវេលាដោយវិធីណា? តើព័ត៌មានទាំងនោះត្រូវបានផ្សព្វផ្សាយដោយរបៀបណា ដើម្បីឱ្យកសិករងាយយល់? និងតើព័ត៌មានទាំងអស់នោះ បានចូលរួមចំណែកក្នុងការកាត់បន្ថយហានិភ័យអាកាសធាតុដោយវិធីណា?

ទាក់ទងទៅនឹងបញ្ហានេះផងដែរ ភាគី CSOs បានគាំទ្រដល់យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលទាក់ទងនឹងវិស័យកសិកម្ម ធនធានទឹក និងឧតុនិយមនេះបើតាមការលើកឡើងរបស់លោក **ឈិត សំអាត** នាយកប្រតិបត្តិនៃវេទិកានៃអង្គការក្រៅរដ្ឋាភិបាលស្តីពីកម្ពុជា។ លោកក៏បានផ្តល់ជាអនុសាសន៍ចំនួន ៨ ដែលមានដូចជា៖ i) ពង្រឹងការអនុវត្តបច្ចេកទេសកសិកម្មដែលធន់នឹងអាកាសធាតុ ii) ជំរុញការប្រើប្រាស់ពូជដំណាំដែលធន់នឹងអាកាសធាតុ iii) ជំរុញការដាំដំណាំសរីរាង្គក្នុងប្រព័ន្ធប្រពលវប្បកម្ម iv) បង្កើនការងារស្រោចស្រពបន្ថែម ពីការគ្រប់គ្រងធនធានទឹកក្នុងផ្ទៃទន្លេ v) ដំឡើងប្រព័ន្ធផ្តល់ព័ត៌មានជលសាស្ត្រ និងឧតុនិយម ដើម្បីផ្តល់ព័ត៌មានជាក់លាក់ទៅសហគមន៍ vi) ផ្តល់ព័ត៌មានពីការព្យាករណ៍ធាតុអាកាសឱ្យបានលឿន និងរហ័ស vii) ស្តារឡើងវិញ និងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ រួមទាំងប្រព័ន្ធធារាសាស្ត្រខ្នាតតូច viii) កៀរគរធនធានបន្ថែមដើម្បីគាំទ្រដល់កម្មវិធីស្តារហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ដើម្បីភាពធន់នឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម។

## ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

*ការកាត់បន្ថយឧស្ម័ន GHG ក្នុងវិស័យដឹកជញ្ជូន៖* ដោយយល់ឃើញពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែង ដើម្បីកៀរគរជំនួយពីដៃគូអភិវឌ្ឍបន្ថែម ដើម្បីរៀបចំផែនការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យដឹកជញ្ជូន។ នាពេលថ្មីៗនេះ ចំនួនយានយន្តនៅកម្ពុជាបានកើនឡើងគួរឱ្យកត់សម្គាល់ បណ្តាលឱ្យមានកំណើនឧស្ម័ន GHG ដែលជាបុព្វហេតុនាំឱ្យមានការប្រែប្រួលអាកាសធាតុ។ កម្ពុជាក៏បានទទួលរងឥទ្ធិពលពីខ្យល់ព្យុះកេតសាណានៅឆ្នាំ២០០៩ និងទឹកជំនន់ជាច្រើនលើកនាពេលថ្មីៗនេះ បណ្តាល ឱ្យបាត់បង់អាយុជីវិតមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ជាច្រើន។ មូលហេតុទាំងនេះ ជាកត្តាដែលជំរុញឱ្យ MoPWT បានបង្កើតនូវផែនការយុទ្ធសាស្ត្រសម្រាប់បន្សាំនឹងការប្រែប្រួលអាកាសធាតុចំនួន ៤ ចំណុចធំៗ នៅក្នុងគោលបំណង ដើម្បីធានាថាហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ធន់នឹងអាកាសធាតុ។ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រនេះ មានការប្រឈមនានាដូចជា៖ កង្វះខាតគោលនយោបាយជាតិក្នុងវិស័យដឹកជញ្ជូន និងគោលនយោបាយជាតិពាក់ព័ន្ធនឹងអាកាសធាតុក្នុងវិស័យដឹកជញ្ជូន។ នៅក្នុងពេលនេះ ក្រសួងកំពុងរៀបចំ CCAP ដើម្បីអនុវត្ត CCCSP នៅក្នុងវិស័យនេះ។

*CCAP ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈ៖* ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្នុងមនុស្សម្នាក់ប្រចាំឆ្នាំនៅប្រទេសកម្ពុជា មានតែ ០,២៩តោនប៉ុណ្ណោះ តែប្រទេសកម្ពុជា គឺជាប្រទេសដែលរងគ្រោះ ដោយសារការប្រែប្រួលអាកាសធាតុ។ កម្ពុជាហាក់ដូចជាប្រឈមនឹងកង្វះខាតទឹក និងភាពញឹកញាប់នៃគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត និងការខូចខាតផ្លូវថ្នល់តាមជនបទកាន់តែខ្លាំងឡើង ហើយដែលអាចនឹងមានតម្លៃរាប់លានដុល្លារអាមេរិក។ ក្រៅពីនេះ ក៏មានផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុលើប្រព័ន្ធស្រោចស្រពខ្នាតតូច និងការផ្គត់ផ្គង់ទឹកដែរ។ ជារៀងរាល់ឆ្នាំ នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទបានសាងសង់អណ្តូងទឹកយ៉ាងហោចណាស់ ២.០០០ ទៅ ៣.០០០អណ្តូង។ ដើម្បីឆ្លើយតបនឹងផលប៉ះពាល់នៃការប្រែប្រួល MRD បានបង្កើតផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ។ ផែនការយុទ្ធសាស្ត្រនេះមានយុទ្ធសាស្ត្រចំនួនបី ដើម្បីដោះស្រាយនូវសមត្ថភាពបន្សាំរបស់សហគមន៍ដែលងាយរងគ្រោះ ភាពធន់របស់ហេដ្ឋារចនាសម្ព័ន្ធជនបទនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដើម្បីលើកកម្ពស់ការអភិវឌ្ឍដោយចីរភាព។ ដើម្បីសម្រេចបាននូវផែនការយុទ្ធសាស្ត្រទាំងនេះ ក្រសួងបានរៀបចំនូវផែនការសកម្មភាពដែលរួមមានសកម្មភាពចម្បងៗចំនួន១០។

លោក **ចាន់ ធូ** បានពន្យល់ថា បន្សាំនឹងការប្រែប្រួលអាកាសធាតុ មានសារៈសំខាន់ណាស់ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ។ នៅពេលគិតពីបន្សាំ ត្រូវលើកយកកត្តាពីរមកពិចារណា៖ [១] កត្តាខាងក្នុង៖ គឺការបង្កើនសមត្ថភាពបន្សាំរបស់ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ និង [២] កត្តាខាងក្រៅ៖ គឺការសិក្សាពីផលប៉ះពាល់របស់ប្រទេសជិតខាង ហើយត្រៀមខ្លួនដោះស្រាយបញ្ហាទាំងនោះពេលខាងមុខ។

លោក Togo យល់ស្របនឹងយោបល់ដែលបានលើកឡើង ហើយសំណូមពរឱ្យគិតពីផលប៉ះពាល់ដែលបណ្តាលមកពីទឹកជំនន់ នៅពេលសាងសង់ស្ពាន។ ការផ្លាស់ប្តូរឥរិយាបថរបស់មនុស្សចំពោះការទុកដាក់សំណល់ក៏មាន

សារៈសំខាន់ផងដែរ ដើម្បីជៀសវាងនូវការស្ទះលូ និងនាំឱ្យមានទឹកលេចផ្លូវ។

លោកបណ្ឌិត **សុខបិល** បានរំលឹកពីកិច្ចសហប្រតិបត្តិរបស់វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ITC) កន្លងមកជាមួយ MoWRAM MRD និង MoPWT លើគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។ ITC ស្វាគមន៍រាល់កិច្ចសហប្រតិបត្តិការផ្សេងៗ ដែលពាក់ព័ន្ធនឹងវិស័យនេះ ព្រោះ ITC មានការសិក្សាស្រាវជ្រាវ និងបានបណ្តុះបណ្តាលវិស្វករជាច្រើនលើជំនាញនេះ។

កញ្ញា Nele បានចែករំលែកបទពិសោធន៍ករណីសិក្សារបស់កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដោយសារទឹកជំនន់ និងខ្យល់ព្យុះនៅតាមឆ្នេរសមុទ្រនៃប្រទេសវៀតណាម។ ព្រឹត្តិការណ៍អាកាសធាតុនេះ បណ្តាលឱ្យខូចខាតធ្ងន់ធ្ងរដល់ហេដ្ឋារចនាសម្ព័ន្ធតំបន់ឆ្នេរក្នុងតំបន់ដែលរងគ្រោះ ហើយការជួសជុល និងស្តាបនាឡើងវិញមានតម្លៃថ្លៃណាស់។ កញ្ញាក៏បានលើកឡើងវិធីសាស្ត្រចំនួនពីរ ដើម្បីវាយតម្លៃបន្សាំរបស់សហគមន៍ គឺការវាយតម្លៃសេដ្ឋកិច្ច និងសង្គម បណ្តាញហេដ្ឋារចនាសម្ព័ន្ធការពារភូមិទាំងនោះ ដូចជាទំនប់ការពារត្រូវបានខូចខាតជាបន្តបន្ទាប់ ក្នុងរយៈពេលខ្លី ហើយនៅរៀងរាល់ ២ ឬ ៣ឆ្នាំ ម្តងទាមទារឱ្យមានការជួសជុល និងស្តាបនាឡើងវិញ ដែលតម្រូវឱ្យចំណាយថវិកាយ៉ាងច្រើន។ GIZ បានរកឃើញថា ដើមកោងកាងដែលដុះនៅតាមឆ្នេរសមុទ្រ អាចការពារសហគមន៍ពីទឹកជំនន់បាន។

តំណាងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ក៏បានបង្ហាញពីបទពិសោធន៍ក្នុងកិច្ចសហការណ៍ជាមួយ អាជ្ញាធរផ្គត់ផ្គង់ទឹករាជធានីភ្នំពេញថា JICA មានគម្រោងបំពាក់បន្ទះពន្លឺព្រះអាទិត្យ ដើម្បីផ្តល់ថាមពលទៅកាន់រោងចក្រប្រព្រឹត្តកម្មទឹករបស់អាជ្ញាធរនេះ និងក៏កំពុងសិក្សាផែនការមេ ដើម្បីកាត់បន្ថយការស្ទះចរាចរនៅរាជធានីភ្នំពេញផងដែរ។ តំណាងមកពី ADB ក៏បានបង្ហាញពីបទពិសោធន៍របស់ខ្លួនក្នុងកិច្ចសហការណ៍ជាមួយមន្ត្រី MAFF ដើម្បីកសាងសមត្ថភាពមន្ត្រី អំពីការកាត់បន្ថយការបញ្ចេញ GHG នៅក្នុងវិស័យនេះ។ បន្ទាប់មកតំណាងពី GIZ ក៏បានចែករំលែកបទពិសោធន៍ករណីនៅប្រទេសម៉ិចស៊ិចកូក្នុងការកាត់បន្ថយការបញ្ចេញ GHG ពីវិស័យដឹកជញ្ជូន តាមរយៈការសាងសង់ផ្លូវ ដោយញែកកន្លែងសម្រាប់រថយន្តសាធារណៈ និងសម្រាប់រថយន្តផ្ទាល់ខ្លួន។ ការយកថ្លៃសេវាកម្មទាបពីរថយន្តសាធារណៈ ក៏ជាការលើកទឹកចិត្តដល់ការប្រើប្រាស់សេវាកម្មនេះដែរ។

តួនាទីរបស់វិស័យឯកជនទាំងនៅក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយដឹកជញ្ជូនសាធារណៈមានភាពច្បាស់លាស់ និងកត្តាបរិស្ថានសមស្រប អាចរួមចំណែកឱ្យមានការចូលរួមពីវិស័យឯកជនក្នុងការកាត់បន្ថយការបញ្ចេញ GHG និងអាចសម្រេចបាននូវគោលបំណងដែលកំណត់ក្នុង CCCSP។ សំណូមពរមួយចំនួនបានស្នើដល់ម្ចាស់ជំនួយ ជាពិសេស JICA និង GIZ ឱ្យផ្តល់មូលនិធិសម្រាប់អនុវត្តគម្រោងការពារព្រៃកោងកាងនៅតំបន់ឆ្នេរសមុទ្រនៃប្រទេសកម្ពុជា។
តំណាងមកពី MoPWT ក៏បានផ្តល់បទពិសោធន៍ពីភាពបរាជ័យ ក្នុងកិច្ចដំណើរការមធ្យោបាយដឹកជញ្ជូនសាធារណៈ នៅក្នុងរាជធានីភ្នំពេញអាស្រ័យដោយប្រជាជនគ្មានទំលាប់ដើរថ្មើរជើងក្នុងចំងាយឆ្ងាយ។ សំណូមពរក្នុងវគ្គនេះគឺ គួរសាកល្បងរៀបចំមធ្យោបាយដឹកជញ្ជូនសាធារណៈ ដោយគិតលើទិដ្ឋភាពបីដូចជា៖ មានតារាងពេលវេលាច្បាស់លាស់ មានផាសុខភាពសម្រាប់អ្នកដំណើរ និងតម្លៃសេវាកម្មអាចទទួលយកបាន។

## ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យសុខភាពអនាម័យ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ

*ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យសុខាភិបាល៖* ការប្រែប្រួលអាកាសធាតុ មានទំនាក់ទំនងជាមួយជំងឺដែលបណ្តាលមកពីភ្នាក់ងារចម្លង (ជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម) ជំងឺឆ្លងតាមទឹក និងចំណីអាហារ (ជំងឺអាសន្នរោគ ជំងឺគ្រុនពោះវៀន និងរាគរូស) អសន្តិសុខស្បៀង និងកង្វះអនាម័យ (កង្វះអាហារូបត្ថម្ភ ក្រិន ស្គមស្គាំង) និងផលវិបាលផ្នែកសុខភាព ដែលណ្តាលពីព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតី។ ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុបានរៀបចំឡើងក្នុងគោលបំណងកាត់បន្ថយអត្រាជំងឺ អត្រាបាត់បង់ជីវិតរបួស និងភាពងាយរងគ្រោះផ្នែកសុខភាព និងដោយសារវិសមរូបធាតុអាកាសធាតុ។ MoH ក៏បាននឹងកំពុងរៀបចំផែនការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ (CCAP) ដែលរួមមានយុទ្ធសាស្ត្រចម្បងៗចំនួនបី ក្នុងវិស័យសុខាភិបាល ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដូចជា យុទ្ធសាស្ត្រទី ១៖ ដើម្បីបង្កើនសមត្ថភាពធន់របស់ប្រជាពលរដ្ឋ ក្នុងការប្រយុទ្ធប្រឆាំងជំងឺបង្កដោយមេរោគ និងជំងឺឆ្លងតាមទឹកដោយសារតែការប្រែប្រួលអាកាសធាតុ។ យុទ្ធសាស្ត្រទី ២៖ កាត់បន្ថយផលប៉ះពាល់ពីធាតុអាកាស ដែលមិនប្រក្រតី និងគ្រោះមហន្តរាយតាមរយៈការត្រៀមលក្ខណៈជាមុន ចំពោះករណីអាសន្ន និងផែនការឆ្លើយតបឱ្យបានប្រសើរជាងមុន។ និងយុទ្ធសាស្ត្រ ទី ៣៖ បង្កើតចំណេះដឹងក្នុងចំណោមប្រជាពលរដ្ឋ និងបុគ្គលិកសុខាភិបាល ដើម្បីទប់ទល់នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ សកម្មភាពផ្សេងៗទៀតមានដូចជា កិច្ចសហការជាមួយភ្នាក់ងារផ្តល់ជំនួយ ដែលរួមមានដូចជា WHO និង KOICA។ MoH ស្វាគមន៍នូវរាល់កិច្ចសហប្រតិបត្តិការជាមួយម្ចាស់ជំនួយ និងអ្នកពាក់ព័ន្ធនានា ដើម្បីអនុវត្ត CCAP។

*គោលនយោបាយសន្តិសុខស្បៀង អាហារូបត្ថម្ភ និងការប្រែប្រួលអាកាសធាតុ៖* ប្រទេសកម្ពុជាងាយរងគ្រោះ ដោយសារការប្រែប្រួលអាកាសធាតុ ដោយសារសមត្ថភាពបន្សុាំ និងសេដ្ឋកិច្ចនៅទាប ហើយពឹងផ្អែកតែទៅលើវិស័យមួយចំនួន ដូចជាវិស័យកសិកម្ម ហើយនៅប្រើប្រាស់បច្ចេកវិទ្យាហួសសម័យ។ ការប្រែប្រួលអាកាសធាតុប៉ះពាល់ដល់សន្តិសុខស្បៀងនៅកម្ពុជា ដោយការថយចុះនូវផលិតកម្មស្បៀងពាណិជ្ជកម្ម និងការស្តុកទុក។ ការថយចុះទាំងនេះ នឹងនាំឱ្យមានចំណូលថយចុះ និងភាពក្រីក្រកើនឡើង។ ការប្រែប្រួលអាកាសធាតុក៏ប៉ះពាល់ដល់ស្ថានភាពសុខភាព ដូចជាគុណភាពទឹក អនាម័យផ្ទាល់ខ្លួន និងការថែទាំសុខភាព។

រដ្ឋាភិបាល បានបង្កើតយុទ្ធសាស្ត្រជាតិដើម្បីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (NSFSN) ដោយយកចិត្តទុកដាក់លើការបង្កើននូវភាពមានស្បៀង និងលទ្ធភាពរបស់គ្រួសារក្នុងការទទួលបានស្បៀងប្រកបដោយចីរភាព កែលម្អអាហារូបត្ថម្ភរបស់មាតា និងកុមារ កាត់បន្ថយភាពងាយរងគ្រោះនៃគ្រួសារពីអសន្តិសុខស្បៀង និងការពារពួកគាត់ពីហានិភ័យនានា។ NSFSN មានកម្មវិធីអាទិភាពចំនួនពីរគឺ៖ ពង្រីកកម្មវិធីសំណាញ់សុវត្ថិភាពសង្គម និងសន្តិសុខស្បៀង និងកែលម្អការត្រៀមបង្ការ សម្រាប់គ្រោះមហន្តរាយ ការកាត់បន្ថយគ្រោះភ័យ និងពង្រឹងសមត្ថភាពបន្សុាំនឹងការប្រែប្រួលអាកាសធាតុ។

NSFSN គឺជាផែនការយុទ្ធសាស្ត្រសំខាន់របស់កម្ពុជាក្នុងការដោះស្រាយបញ្ហាអសន្តិសុខស្បៀង ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។ ដូចនេះ រាជរដ្ឋាភិបាលបានសន្យានឹងអនុវត្ត NSFSN ចំពោះការប្រឈមពេលអនាគត

ដែលបណ្តាលមកពី ការប្រែប្រួលអាកាសធាតុ ដើម្បីធានានូវសន្តិសុខស្បៀង និងសហការណ៍យ៉ាងជិតស្និទ្ធជាមួយម្ចាស់ជំនួយ ដើម្បីធានាភាពជោគជ័យរបស់កម្ពុជា។

លោកស្រី **ជា អេលីយ៉ាន** តំណាងមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) បានចែករំលែកសកម្មភាពដែលបាន និងកំពុងអនុវត្តនៅស្ថាប័នរបស់ខ្លួន ហើយដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ជាពិសេសផ្តោតលើការផ្គត់ផ្គង់ទឹក និងអនាម័យ។ គោលបំណងរួមរបស់គម្រោង គឺកសាងសមត្ថភាពក្នុងការបន្សុាំនឹងប្រែប្រួលអាកាសធាតុក្នុងវិស័យទឹកស្អាត និងសុខភាព។ គម្រោងរំពឹងទុកថា សិក្ខាកាមនឹងអាចបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងការធ្វើផែនការក្នុងការផ្គត់ផ្គង់ទឹក និងអនាម័យ។ លោកស្រីបានបញ្ជាក់ថា ការបញ្ចូលការប្រែប្រួលអាកាសធាតុក្នុងការសិក្សាពីសុខភាព គឺជាកិច្ចការដ៏សំខាន់មួយដែល MoH កំពុងធ្វើ ហើយលោកស្រីសូមគាំទ្រចំពោះសកម្មភាពនេះ។

លោកបណ្ឌិត **Lean Russell** បានបង្ហាញយ៉ាងច្បាស់ថា កម្ពុជាគួរយកចិត្តទុកដាក់បន្ថែមទៀតលើវិស័យកសិកម្ម និងបរិស្ថាន។ ការអភិវឌ្ឍកសិកម្ម គឺជាវិស័យដែលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុខ្លាំងជាងគេ។ ត្រូវមានការបណ្តាក់ទុនលើការស្រាវជ្រាវ និងការអប់រំ និងយល់ពីបញ្ហាមួយចំនួនដូចជា លក្ខណៈដី ផលប៉ះពាល់នៃកំណើនកម្ពស់ទឹកសមុទ្រទៅលើជលវិទ្យា ដើម្បីត្រៀមខ្លួនចំពោះការប្រែប្រួលអាកាសធាតុ។ ការបណ្តាក់ទុន គួរតែគិតលើវគ្គបណ្តុះបណ្តាល ការកសាងសមត្ថភាព និងធានាថាក្រុមងាយរងគ្រោះត្រូវបានបញ្ចូល។ ដើម្បីធានាថាក្រុមងាយរងគ្រោះត្រូវបានរាប់បញ្ចូល កម្ពុជាត្រូវតែបញ្ចូលក្រុមទាំងអស់នោះ ទៅក្នុងដំណើរការរៀបចំគោលនយោបាយ និងការធ្វើផែនការ និងធានាថា ពួកគេបានដឹងពីការរីកចម្រើននៃដំណើរការអនុវត្ត។

លោក **ហេង សុខ** បានលើកឡើងថា ដើម្បីពង្រឹងបន្សុាំនឹងការប្រែប្រួលអាកាសធាតុ ត្រូវគិតពីសរសរស្តម្ភបី៖ [១]ការដោះស្រាយគ្រោះថ្នាក់ ឬមហន្តរាយនៃការប្រែប្រួលអាកាសធាតុដោយការសហការគ្នា ដើម្បីស្វែងរកដំណោះស្រាយរួមមួយ [២] ពង្រឹងសមត្ថភាពបន្សុាំទាំងកម្រិតសហគមន៍ និងស្ថាប័នក្រសួង [៣] បន្សុាំនឹងការប្រែប្រួលអាកាសធាតុដោយការដោះស្រាយបញ្ហាភាពគ្រីក្រ។

លោក **Steven Iddings** ក៏បានបង្ហាញពីសកម្មភាពនានារបស់ WHO ក្រោមការគាំទ្រពី KOICA ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុទាក់ទងនឹងជំងឺឆ្លងតាមទឹក។ ត្រូវបន្តការយកចិត្តទុកដាក់លើវិស័យនេះ អាស្រ័យដោយវាជាវិស័យមួយថ្មីសម្រាប់កម្ពុជា។ WHO គិតថានឹងវាយតម្លៃហានិភ័យ ពីការប្រែប្រួលអាកាសធាតុ និងសិក្សាបន្ថែមពីជំងឺទាក់ទងនឹងទឹក និងទំនាក់ទំនងនឹងការប្រែប្រួលអាកាសធាតុ។ គម្រោងនេះមានរយៈពេលតែមួយឆ្នាំ ដូចនេះវាត្រូវការការគាំទ្របន្ថែមទៀត។ លើសពីនេះទៅទៀត ការស្រាវជ្រាវតម្រូវឱ្យមានកិច្ចសហការជាមួយវិស័យផ្សេងៗ ជាពិសេសវិស័យកសិកម្ម និងបរិស្ថាន។

សិក្ខាកាមម្នាក់ បានលើកឡើងពីសក្តានុពលនៃផលប៉ះពាល់សុខភាព ពីការគ្រប់គ្រងសំណល់មិនបានត្រឹមត្រូវ និងសំណូមពរឱ្យ MoH គួរតែសហការណ៍ជាមួយ MoE ដើម្បីដោះស្រាយបញ្ហានេះ។ លោកវេជ្ជបណ្ឌិត ហៀ បានបន្ថែមថា MoH នឹងធ្វើកិច្ចការនៅក្នុងផែនការសកម្មភាព និងសកម្មភាពអាទិភាពនានាដែលមានស្រាប់។ ចំពោះទិន្នន័យសុខភាព លោកវេជ្ជ

បណ្ឌិតបានបញ្ជាក់ថា យើងមានទិន្នន័យគ្រប ដណ្តប់ប្រហែលជា ៧០% ទូទាំងប្រទេស។

## ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យព្រៃឈើ ជលផល និងស្ពានប្រព័ន្ធ

វិស័យព្រៃឈើ ជលផល និងស្ពានប្រព័ន្ធ គឺជាអាទិភាពចម្បងរបស់រាជរដ្ឋាភិបាលក្នុងការបំពេញបេសកកម្មទាំងនៅថ្នាក់ជាតិ និងអន្តរជាតិ។ សព្វថ្ងៃនេះប្រជាជនកម្ពុជាកំពុងតែពឹងផ្អែកស្ទើរទាំងស្រុងលើធនធានធម្មជាតិ ដែលកំពុងថយចុះ និងស្ពានប្រព័ន្ធសម្រាប់ចិញ្ចឹមជីវិតរបស់ពួកគេ។ ជាមួយគ្នានេះដែរ ការប្រែប្រួលអាកាសធាតុកំពុងតែធ្វើឱ្យធនធានធម្មជាតិទាំងអស់នោះថយចុះកាន់តែខ្លាំង ដែលជាមូលហេតុធ្វើឱ្យប្រជាជនមូលដ្ឋានជួបប្រទះនឹងហានិភ័យក្នុងការចិញ្ចឹមជីវិតកាន់តែធ្ងន់ធ្ងរ។

*វិស័យព្រៃឈើ៖* ប្រទេសកម្ពុជាមានឆន្ទៈនយោបាយយ៉ាងមុតមាំ ក្នុងការកាត់បន្ថយការបញ្ចេញ GHG តាមរយៈការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើឱ្យមានចីរភាព នេះបើតាមការលើកឡើងរបស់ លោក **យុន វឌ្ឍនា** អនុប្រធានទទួលបន្ទុករួមការិយាល័យឥណទានកាបូនព្រៃឈើ នៃរដ្ឋបាលព្រៃឈើ។ លោកក៏បានបន្ថែមទៀតថា MAFF បានបង្កើតយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យព្រៃឈើ ឆ្នាំ (២០១៤-២០១៨) ដើម្បីជំរុញការចូលរួមក្នុងការគ្រប់គ្រងព្រៃឈើ និងការពិភាក្សាដោយស្មើភាព ដើម្បីទទួលបានផលប្រយោជន៍ពីការលក់កាបូន ការដាំដើមឈើ និងស្តារព្រៃឈើឡើងវិញ ការកសាងសមត្ថភាពក្នុងជំនាញ REDD+ ប្រព័ន្ធគ្រប់គ្រងកាបូនព្រៃឈើ ការយល់ដឹងពីគោលនយោបាយព្រៃឈើ និងបទបញ្ញានានាពី REDD+ ទៅអ្នកពាក់ព័ន្ធ និងការកំណត់សកម្មភាពអាទិភាព សម្រាប់កិច្ចការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ។ យុទ្ធសាស្ត្រទាំងនេះសមស្របនឹងយន្តការ REDD+ ជាសកល និងលិខិតូបករណ៍ផ្សេងទៀតរបស់ UNFCCC COP១៣ (២០០៧) COP១៥ (២០០៩) និង COP១៦ (២០១០)។ ក្នុងន័យនេះ បណ្តាប្រទេសអភិវឌ្ឍន៍តម្រូវឱ្យផ្តល់ថវិកាគាំទ្រដល់ប្រទេសកំពុងអភិវឌ្ឍន៍នានា តាមរយៈយន្តការទ្វេភាគី និងពហុភាគី និងការអនុវត្ត REDD+។ លោកស្រី Sarah Sitts ប្រធានប្រចាំប្រទេសនៃអង្គការ PACT កម្ពុជា និងលោក Peter Iversen អ្នកឯកទេសផ្នែកបច្ចេកទេសនៃ UN-REDD របស់រដ្ឋបាលព្រៃឈើបានសំដែងការគាំទ្រថា យុទ្ធសាស្ត្រ REDD+ ជាយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាព សម្រាប់សហគមន៍ក្នុងការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ។ យុទ្ធសាស្ត្រនេះ ក៏មានឥទ្ធិពលផងដែរក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

*វិស័យជលផល៖* ធនធានត្រីទឹកសាប និងទឹកប្រៃកំពុងតែរងការគំរាមកំហែង ទៅនឹងការថយចុះគួរឱ្យបារម្ភ។ ហើយការថយចុះនេះបានគំរាមកំហែងដល់ការចិញ្ចឹមជីវិត ដែលពឹងអាស្រ័យលើធនធានជលផល (ប្រាក់ចំណូល សន្តិសុខស្បៀង និងអាហារូបត្ថម្ភ)។ ប្រសិនបើសីតុណ្ហភាពកើនឡើងពី (+0.៣ ដល់ +0.៦ ℃) ក្នុងឆ្នាំ២០២៥ វានឹងប៉ះពាល់ដល់អាងស្តុក និងហេដ្ឋារចនាសម្ព័ន្ធទឹក។ ម៉្យាងវិញវានឹងជះឥទ្ធិពលដល់ធនធានជីវៈចម្រុះ និងជលផល។ ព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ ដូចជា ខ្យល់ព្យុះ រលកកម្តៅ ទឹកជំនន់ គ្រោះរាំងស្ងួត និងកំណើនកម្ពស់ទឹកសមុទ្រ គឺជាមូលហេតុដែលប៉ះពាល់ដល់ការចិញ្ចឹមជីវិតរបស់ប្រជាជន និងសេដ្ឋកិច្ចជាតិទាំងមូល។ ដើម្បីឆ្លើយតបនឹងបញ្ហាទាំងអស់នេះ យុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យជលផលត្រូវបានបង្កើតឡើងជាមួយនឹងវិធានការណ៍ដូចជា៖ លើកកម្ពស់ភាពធន់នឹងអាកាសធាតុរបស់ជលវប្បកម្ម លើក

កម្ពស់ការយល់ដឹងពីឥទ្ធិពល និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើវិស័យជលផល ធានាសុវត្ថិភាពផលិតផលត្រី និងធនធានជលផល ការបង្កើតភូមិមួយ ផលិតមួយក្នុងវិស័យជលផល ការសិក្សាស្រាវជ្រាវ បង្កើត និងផ្សព្វផ្សាយបច្ចេកទេសថ្មីៗនៃការចិញ្ចឹម និងការកែច្នៃត្រីពង្រឹង និងបង្កើនសមត្ថភាពទីភ្នាក់ងារទទួលខុសត្រូវ និងអ្នកពាក់ព័ន្ធនានា ពង្រឹងការគ្រប់គ្រង និងថែរក្សាព្រៃលិចទឹក និងព្រៃកោងកាងពង្រឹងការអនុវត្តគោលនយោបាយ ច្បាប់ និងបទបញ្ញត្តិស្តីពីជលផល លើកកម្ពស់កិច្ចការពារបរិស្ថាន និងស្ថានប្រព័ន្ធ និងលើកកម្ពស់ការបន្សាំ និងការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុក្នុងវិស័យជលផល។ សកម្មភាពគន្លឹះចំនួន ៣ ដែលរដ្ឋបាលជលផលនឹងអនុវត្តនៅពេលខាងមុខដ៏ខ្លីនេះគឺ៖ ការកសាងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលនៅថ្នាក់ក្រោមជាតិពង្រីកសកម្មភាពបន្សាំ តាមរយៈការអនុវត្តគម្រោងសាកល្បង និងធ្វើការវាយតម្លៃពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងភាពងាយរងគ្រោះក្នុងវិស័យជលផល និងវារីវប្បកម្ម។

បន្សាំនឹងការប្រែប្រួលអាកាសធាតុដោយផ្អែកលើស្ថានប្រព័ន្ធ (EBA) ត្រូវបានគេចាត់ទុកជាវិធីសាស្ត្រ ដែលអាចកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ តាមរយៈការលើកកម្ពស់លក្ខខណ្ឌសេដ្ឋកិច្ចសង្គម និងការកាត់បន្ថយហានិយភ័យពីគ្រោះធម្មជាតិ។ ទ្រឹស្តី EBA ត្រូវបានគេបង្កើតជាយូរណាស់មកហើយ ប៉ុន្តែថ្មីៗនេះ UNEP បានបង្កើតនូវយុទ្ធសាស្ត្ររយៈពេលវែងមួយ ដើម្បីធ្វើឱ្យយុទ្ធសាស្ត្រនេះកាន់តែមានប្រសិទ្ធភាព ដើម្បីបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ យុទ្ធសាស្ត្រ EBA នេះមានសារៈសំខាន់ ប៉ុន្តែវានៅមានលក្ខណៈស្មុគស្មាញនៅឡើយ។ ដូចនេះ យើងត្រូវគិតតែពីរបៀបដោះស្រាយការងារដ៏ស្មុគស្មាញ ចំពោះស្ថានប្រព័ន្ធច្បាស់លាស់ ដែលរួមមាន ដូចជាតំបន់ភ្នំ តំបន់ឆ្នេរ តំបន់ស្ងួត និងតំបន់ពាក់កណ្តាលស្ងួត និងតំបន់អាងទន្លេ។ EBA ផ្តល់លទ្ធផលវិជ្ជមានដល់ DRR /ការគ្រប់គ្រងគ្រោះមហន្តរាយ (DRM) ការគ្រប់គ្រងធនធានធម្មជាតិ (NRM) និងការចិញ្ចឹមជីវិត ហើយវាគឺជាការប្រឈមរបស់អ្នកធ្វើការសម្រេចចិត្តពីព្រោះសារមួយចំនួនលម្អៀង និងធ្វើឱ្យយល់ច្រឡំ។ ទិន្នន័យវាយតម្លៃដែលទាក់ទងនឹងផលចំណេញ និងថ្លៃដើមរបស់ស្ថានប្រព័ន្ធមិនទាន់ជាក់លាក់នៅឡើយ។ ទោះបីជាមានការលំបាកយ៉ាងណាក៏ដោយក៏ប្រទេសកម្ពុជា កំពុងអនុវត្តគម្រោងដោយប្រើប្រាស់វិធីសាស្ត្រ EBA នេះដែរ តួយ៉ាងដូចជាការអនុវត្តគម្រោងនៅដែនជម្រកសត្វព្រៃបឹងពែរតំបន់ការពារសត្វព្រៃភ្នំព្រេច និងឧទ្យានជាតិភ្នំគូលេន។ គម្រោងនេះមានឈ្មោះថា "ពង្រឹងភាពធន់នឹងអាកាសធាតុ នៃសហគមន៍ជនបទដែលរស់នៅក្នុងតំបន់ការពារធម្មជាតិនៅកម្ពុជា" ដែលគម្រោងនេះ បានអនុវត្តក្នុងរយៈពេល៥ឆ្នាំ (២០១៣ ដល់២០១៧) ជាមួយនឹងកញ្ចប់ថវិកាចំនួន ៤.៩៥៤.២៧៣ ដុល្លារអាមេរិក។ គម្រោងនេះរួមមានបីផ្នែកសំខាន់ៗគឺ៖ ពិធីសារសម្រាប់អន្តរាគមន៍កសិ-អេកូឡូស៊ី អន្តរាគមន៍បន្សាំជាក់លាក់ខាងអេកូ-កសិកម្ម និងសមត្ថភាពស្ថាប័នបង្កើនការយល់ដឹង និងការពង្រីក។

លោក Micah Ingalls នាយកស្តីទីប្រចាំប្រទេសនៃអង្គការ WWF បានយល់ស្របថាតួនាទីរបស់ស្ថានប្រព័ន្ធទៅលើការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ពិតជាមានសារៈសំខាន់ខ្លាំងណាស់។ វិធីសាស្ត្រនេះ គួរត្រូវបានអនុវត្ត និងពង្រឹងនៅថ្នាក់មូលដ្ឋាន ពីព្រោះប្រជាសហគមន៍ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយស្ថានប្រព័ន្ធ។ បន្ថែមពីនេះទៅទៀត គម្រោងដែលទាក់ទងនឹងតួនាទីស្ថានប្រព័ន្ធ គួរត្រូវបានពង្រីកឱ្យកាន់តែធំ គ្របដណ្តប់ស្ថានប្រព័ន្ធទាំង

មូល។ លោកបណ្ឌិត Kien Tran Mai មន្ត្រីកម្មវិធី CCAI/MRC បានបន្ថែមថា ការវាយតម្លៃដ៏សមស្របមួយ គួរត្រូវបានអនុវត្តឱ្យបានត្រឹមត្រូវ និងប្រយ័ត្នប្រយែង ជាពិសេសទាក់ទងនឹងការសិក្សាពីសុវត្ថិភាពស្បៀង សេវាកម្មស្ថានប្រព័ន្ធទឹកជំនន់ និងគ្រោះរាំងស្ងួតជាដើម។

## ការកាត់បន្ថយការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យឧស្សាហកម្ម និងថាមពល

ការអភិវឌ្ឍឧស្សាហកម្ម និងថាមពល មានតួនាទីសំខាន់ ក្នុងការផ្តល់អត្ថប្រយោជន៍ដល់សង្គម សេដ្ឋកិច្ច និងបរិស្ថាននៅកម្ពុជា។ កន្លងមកវិស័យឧស្សាហកម្ម បានបង្កផលប៉ះពាល់ដល់បរិស្ថានយ៉ាងធ្ងន់ធ្ងរ តួយ៉ាងដូចជា ការបញ្ចេញសំណល់គីមីចូលប្រភពទឹកនានា និងការបញ្ចេញឧស្ម័នពុលទៅក្នុងបរិយាកាស ដែលបណ្តាលឱ្យមានការប្រែប្រួលអាកាសធាតុ។ MIME បានរៀបចំគោលនយោបាយជាតិ ស្តីពីប្រសិទ្ធភាពថាមពល ដោយផ្តោតលើវិស័យអាទិភាពចំនួន ៥ ដូចជា ប្រសិទ្ធភាពថាមពលក្នុងឧស្សាហកម្ម ប្រសិទ្ធភាពថាមពលនៃផលិតផលសម្រាប់អ្នកប្រើប្រាស់ផ្ទាល់ ប្រសិទ្ធភាពថាមពលក្នុងអគារ ប្រសិទ្ធភាពថាមពលនៃអគ្គិសនីកម្មជនបទ និងការចែកចាយការប្រើប្រាស់ធនធានជីវៈម៉ាសដោយប្រសិទ្ធភាព សម្រាប់តាមផ្ទះ និងឧស្សាហកម្ម។

*ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យឧស្សាហកម្ម និងថាមពល៖* ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ MIME បានរៀបចំ CCCSP សម្រាប់វិស័យឧស្សាហកម្ម និងថាមពលជាមួយនឹងផែនទីបង្ហាញផ្លូវ ដើម្បីជួយដល់វិស័យឯកជនឱ្យធ្វើផែនការក្នុងការអនុវត្ត និងដោះស្រាយបញ្ហាដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។ បេសកកម្មរួមរបស់ CCCSP គឺដើម្បីបង្កើតយុទ្ធសាស្ត្រភាពធន់សម្រាប់រយៈពេលខ្លី មធ្យម និងវែងក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ ដើម្បីទទួលបានសមិទ្ធផល និងភាពជោគជ័យ រយៈពេលវែង។ MIME ក៏មានផែនការសកម្មភាពផ្ទាល់ខ្លួន ដូចជាគម្រោងបន្ទេរបច្ចេកវិទ្យា ដែលមិនប៉ះពាល់ដល់បរិស្ថានក្នុងប្រទេសកម្ពុជា ក្នុងតំបន់អាងទន្លេមេគង្គ (TEST) និងប្រសិទ្ធភាពថាមពលនៅក្នុងវិស័យឧស្សាហកម្ម និងពានរង្វាន់បៃតង។ ផែនការនេះ មានគោលបំណងដើម្បីធានាថា វិស័យឧស្សាហកម្មអាចកាត់បន្ថយដល់កម្រិតអប្បបរមានូវផលប៉ះពាល់បរិស្ថាន។ MIME នឹងលើកកម្ពស់ដល់ការបង្កើតគោលនយោបាយក្នុងវិស័យថាមពល ដោយលើកទឹកចិត្តការប្រើប្រាស់ថាមពលជីវៈម៉ាស ថាមពលពន្លឺព្រះអាទិត្យ និងថាមពលខ្យល់ ជាជម្រើសក្នុងកិច្ចការពារបរិស្ថាន។

*CCSP សម្រាប់ផលិតកម្មថាមពល៖* MIME កំពុងផ្សព្វផ្សាយការអភិវឌ្ឍថាមពលកកើតឡើងវិញ ក៏ដូចជាប្រសិទ្ធភាពថាមពល។ MIME បានរៀបចំផែនការមេស្តីពីអគ្គិសនីកម្មជនបទ ដោយមានកិច្ចអន្តរាគមន៍បីកម្រិតផ្សេងៗគ្នាដូចជា (១)បណ្តាញអគ្គិសនីថ្នាក់ជាតិ (២)បណ្តាញចែកចាយខ្នាតតូច និង (៣)ការបំភ្លឺដោយអាគុយ។ ផែនការមេក៏បានលើកកម្ពស់ដល់ការប្រើប្រាស់ថាមពលកកើតឡើងវិញផងដែរ។ ការអនុវត្តដោយជោគជ័យនូវវិស័យអាទិភាពទាំងអស់ ត្រូវការកិច្ចសហការជាមួយអ្នកពាក់ព័ន្ធនានា និងការគាំទ្រទាំងបច្ចេកទេស និងហិរញ្ញវត្ថុ។

លោក Chuong Foeng Hinh បានប្រាប់ថាក្រុមហ៊ុន K-Cement ដុតថ្មប្រមាណ ១៥០.០០០ តោនក្នុងមួយឆ្នាំៗ ដើម្បីផលិតថាមពល ហើយដោយបញ្ចេញ GHG ប្រមាណ ៧០០-៨០០គីឡូក្រាម $CO_2$ ក្នុង១តោនស៊ីម៉ង់ត៍

ដែលផលិតបាន។ សព្វថ្ងៃនេះថាមពលចំនួន ១០ % នៃចំនួនថាមពលសរុប សម្រាប់រោងចក្រ បានមកពីអង្កាម។ ក្រុមហ៊ុនកំពុងស្វែងរកវិធីផលិតស៊ីម៉ង់ត៍បៃតង (Eco-Cement) និងប្រើប្រាស់បច្ចេកវិទ្យាថ្មី ដើម្បីកាត់បន្ថយការបញ្ចេញ GHG។ កន្លងមកក្រុមហ៊ុនបានការទទួលស្គាល់ជាអន្តរជាតិ តាមរយៈ (ISO ៩០០១:២០០៨) និង ISO ១៤០០១។

លោក Jeff Ospital បានបង្ហាញថា អង្គការរបស់លោកធ្វើកិច្ចការជាចម្បងលើការផ្តល់ជំនួយដល់ NGOs ឬសហគ្រាសនានា។ អង្គការរបស់លោកក៏បានបង្កើតគោលនយោបាយ និងសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុផងដែរ។ លោកក៏បានរៀបរាប់បន្ថែមពីបទពិសោធន៍ជាក់ស្តែងរបស់លោកក្នុងប្រទេស Kenya ជាមួយគម្រោងដែលផ្តល់មូលនិធិដោយ Nexus ចំនួន ៤០០.០០០អឺរ៉ូ ដើម្បីកែច្នៃឡើងវិញនូវសំណល់ដែលដុតឆេះក្នុងផលិតកម្មស៊ីម៉ង់ត៍។

លោក Carlo Figa បានយល់ស្របថា វិស័យឯកជនដើរតួនាទីយ៉ាងសំខាន់ ក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ អាស្រ័យដោយវិស័យនេះ គឺជាប្រភពនៃការបញ្ចេញផ្សែង និងសំណល់។ លោកបានចែករំលែកបទពិសោធន៍របស់លោក ក្នុងការផលិតធ្យូងអនាម័យពីសំណល់កែច្នៃឡើងវិញ នេះជាផ្នែកមួយនៃជម្រើសប្រសិទ្ធភាពថាមពល។ លោកបានបន្ថែមទៀតថា ជំនួញបៃតងត្រូវការដើមទុនខ្ពស់ អាស្រ័យដោយ វាត្រូវការបច្ចេកវិទ្យាប្រព្រឹត្តកម្ម ដើម្បីធានាថាគ្មាន ឬមានផលប៉ះពាល់តិចតួចដល់បរិស្ថាន។ EU បានបង្កើតគោលនយោបាយ ដើម្បីលើកទឹកចិត្តដល់ជំនួញបៃតង ដោយការផ្តល់ឧបត្ថម្ភធន ឬការលើកលែងពន្ធ ក៏ដូចជាការលើកកម្ពស់ការយល់ដឹងជាសាធារណៈ។

លោក **តូច សុវណ្ណា** បានផ្តល់ព័ត៌មានថា រាជរដ្ឋាភិបាល បានកាត់បន្ថយពន្ធនាំចូលបន្ទះពន្លឺព្រះអាទិត្យពី ៤៨ % មកត្រឹមតែ ៧ % ប៉ុណ្ណោះ។ ក្រសួងនឹងបន្តការពិភាក្សាជាមួយ MEF ដើម្បីសិក្សាពីលទ្ធភាពក្នុងការកាត់បន្ថយពន្ធនាំចូលឱ្យដល់កម្រិតសូន្យតែម្តង។ ក្រុមហ៊ុន K-cement មានរោងចក្រប្រព្រឹត្តកម្មផ្ទាល់ខ្លួន ហើយក្រុមហ៊ុន Chevron បានសុំជំនួយសម្រាប់ប្រព្រឹត្តកម្មសំណល់របស់ខ្លួនពេលខាងមុខ។

## ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងការគ្រប់គ្រងគ្រោះមហន្តរាយ

*អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ និងការប្រែប្រួលអាកាសធាតុ៖* លេខាធិការដ្ឋាន គ.ជ.អ.ប. បានអនុវត្តគម្រោងសាកល្បង នៅថ្នាក់ក្រោមជាតិក្នុងតំបន់គោលដៅមួយចំនួននៅខេត្តតាកែវ និងខេត្តបាត់ដំបង ក្រោយពីបានចងក្រងនូវផែនការយុទ្ធសាស្ត្រដំណាក់កាលទីមួយ។ គម្រោងនេះ បានអនុវត្តក្នុងគោលបំណងចំនួន ៤ ដូចជា៖ ការកសាងសមត្ថភាព និងចំណេះដឹងដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ ពង្រឹងសមត្ថភាព និងតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តសកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ កសាងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងបញ្ជ្រាបបញ្ហាការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ និងប្រព័ន្ធហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងការអនុវត្តគម្រោងនេះ ក៏នៅមានបញ្ហាប្រឈមជាច្រើន ដូចជា ការយល់ដឹងពីបន្សាំ និងការប្រែប្រួលអាកាសធាតុរបស់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋនៅមានកម្រិតទាបខ្លាំង និងគំនិតរបស់ពួកគាត់លំបាកផ្លាស់ប្តូរព្រោះគម្រោងមានរយៈពេលខ្លីពេក លំហូរថវិកាយឺតយ៉ាវពីគណនីថ្នាក់ជាតិ ទៅរដ្ឋបាលក្រោមជាតិ មូលនិធិរបស់គម្រោងតិច តែសំណើគម្រោងពីឃុំមានច្រើន

កង្វះខាតឯកសារបណ្តុះបណ្តាលពីការប្រែប្រួលអាកាសធាតុ។ ទោះបីជាយ៉ាងណាក៏ដោយ លេខាធិការដ្ឋាន គ.ជ.អ.ប. បានព្យាយាមដោះស្រាយបញ្ហាប្រឈមដូចជា ពង្រីកសកម្មភាពផ្សព្វផ្សាយ ស្តីពីការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិដោយប្រើប្រាស់ CCSP ជាគោលការណ៍ណែនាំ។ លេខាធិការដ្ឋាន គ.ជ.អ.ប. ក៏បានរៀបចំលេខកូដចំណាយសម្រាប់សកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុផងដែរ។

*ការប្រែប្រួលអាកាសធាតុ ក្នុងវិស័យគ្រប់គ្រងគ្រោះមហន្តរាយ៖* ប្រជាជនងាយរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុ ប្រហែលជា ៩០% កំពុងរស់នៅតាមជនបទ។ គ្រោះមហន្តរាយធម្មជាតិផ្សេងៗដែលបានកើតឡើង បានធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សេដ្ឋកិច្ចជាតិ និងបាត់បង់អាយុជីវិតរបស់ប្រជាពលរដ្ឋ។ លើសពីនេះទៅទៀត សមិទ្ធផលនៃកម្មវិធីអភិវឌ្ឍន៍ត្រូវរងការខូចខាត ឬបំផ្លិចបំផ្លាញ ដែលបញ្ហាទាំងអស់នេះបានក្លាយជាបន្ទុកដ៏ធ្ងន់ធ្ងរដល់រាជរដ្ឋាភិបាលកម្ពុជា។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ គ.ជ.អ.ប. បានរៀបចំ CCSP សម្រាប់វិស័យគ្រប់គ្រងគ្រោះមហន្តរាយ ដែលមានយុទ្ធសាស្ត្រចំនួន៥ ដូចជា៖ ភ្ជាប់ទំនាក់ទំនងរវាងបន្សាំនឹងការប្រែប្រួលអាកាសធាតុ និង DRR បង្កើនការទទួលបានព័ត៌មានពីប្រព័ន្ធផ្តល់ដំណឹងជាមុន ប្រើប្រាស់ចំណេះដឹងដើម្បីកសាងសមត្ថភាពធន់នឹងគ្រោះមហន្តរាយ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅគ្រប់ជាន់ថ្នាក់ និងការអភិវឌ្ឍដោយគិតពីហានិភ័យ។ លើសពីនេះទៅទៀត គ.ជ.អ.ប. ក៏បង្កើតសកម្មភាពផ្សេងៗក្នុងកិច្ចការងារ DRR ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុផងដែរ។ សកម្មភាពទាំងអស់នោះ រួមមាន ការតាក់តែងច្បាប់ និងគោលនយោបាយ ការពង្រឹងសមត្ថភាពស្ថាប័នសម្រាប់ DRM ការកសាងសមត្ថភាពដើម្បីត្រៀមខ្លួនឆ្លើយតបនឹងគ្រោះមហន្តរាយ បង្កើនការទទួលបានព័ត៌មានពីប្រព័ន្ធ ផ្តល់ព័ត៌មានជាមុន ពង្រឹងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅកម្រិតមូលដ្ឋាន បង្កើនការយល់ដឹងជាសាធារណៈអំពី DRR និងការប្រែប្រួលអាកាសធាតុ ធានានូវដំណើរការទាំងបែបវិទ្យាសាស្ត្រ និងបច្ចេកទេសសម្រាប់ DRM និងធ្វើឱ្យប្រសើរឡើងនូវការចិញ្ចឹមជីវិតរបស់សហគមន៍ដែលងាយរងគ្រោះ។ ជារួម យុទ្ធសាស្ត្របន្សាំនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ ត្រូវតែស្ថិតក្នុងក្របខ័ណ្ឌគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។ យុទ្ធសាស្ត្រនេះគួរយកចិត្តដាក់បន្ថែមលើការងារកសិកម្ម និងធនធានទឹកនៅថ្នាក់ក្រោមជាតិ ព្រោះប្រជាជនភាគច្រើនដែលរស់នៅជនបទ កំពុងពឹងផ្អែកទាំងស្រុងលើវិស័យកសិកម្ម។

វាគ្មិន ព្រមទាំងអ្នកចូលរួមទាំងអស់បានសំដែងនូវការគាំទ្រយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ នៅថ្នាក់ក្រោមជាតិនេះ។ តួយ៉ាង លោក **ហុក គឹមធួន** បានបន្ថែមថា ការអនុវត្តយុទ្ធសាស្ត្របន្សាំនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ ធ្វើឡើងក្នុងក្របខ័ណ្ឌគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។ ម្យ៉ាងទៀត ការអនុវត្តផែនការយុទ្ធសាស្ត្រនេះគួរផ្តោតសំខាន់លើការងារកសិកម្ម និងធនធានទឹកនៅថ្នាក់ក្រោមជាតិ ព្រោះប្រជាជនដែលរស់នៅតាមជនបទ កំពុងតែពឹងផ្អែកលើវិស័យទាំងពីរនេះយ៉ាងខ្លាំងសម្រាប់ការចិញ្ចឹមជីវិត។ ការពង្រឹងសមត្ថភាព និងបង្កើនការយល់ដឹងពីការប្រែប្រួលអាកាសធាតុ គឺជាតម្រូវការដ៏ចាំបាច់ផងដែរសម្រាប់ស្ត្រីតាមរយៈ MoWA។ គ្រប់ស្ថាប័នរាជរដ្ឋាភិបាល វិស័យឯកជន និងអ្នកពាក់ព័ន្ធផ្សេងៗ និងម្ចាស់ជំនួយ គួរតែសម្របសម្រួលជាមួយគ្នា ចាប់ពីតំបន់គោលដៅរបស់គម្រោង និងផែនការសកម្មភាពរបស់ពួកគេ ដើម្បីជៀសវាងការបំពេញការងារ និងការចំណាយត្រួតលើគ្នានៅ

កន្លែងតែមួយដែលនាំឱ្យមានការខ្វះខាតថវិកា។ ជាការរួមចំណែកនេះ លោកស្រី Sanna Salmela Eckstein បានយល់ស្របនឹងផែនការយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល ដែលផ្តោតសំខាន់ទៅលើថ្នាក់ក្រោមជាតិ។ លោកស្រីបានសម្តែងនូវការគាំទ្រយ៉ាងខ្លាំង ចំពោះការត្រៀមខ្លួនរបស់កម្ពុជាក្នុង COP១៩ ផងដែរ។ លោក **គឹម រតនា** ក៏បានបន្ថែមថា ការកសាងសមត្ថភាពកសិកររយៈពេលវែងក្នុងការរៀបចំផែនការវិនិយោគកសិកម្ម អាចជួយកសិករឱ្យកាត់បន្ថយហានិភ័យផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ យើងត្រូវការគោលនយោបាយដ៏ជាក់លាក់ ដើម្បីលើកទឹកចិត្តដល់ការចូលរួមពីយុវវ័យ និងជនពិការក្នុងការគ្រប់គ្រងគ្រោះមហន្តរាយពីអាកាសធាតុ។ ម៉្យាងវិញទៀត បន្សាំត្រូវការកិច្ចសហការរវាងគម្រោងនានា និងប្រទេស នេះបើតាមការលើកឡើងពីលោក Julian Abrams។ លោកក៏បានបន្ថែមទៀតថា យុទ្ធសាស្ត្រធន់នឹងអាកាសធាតុត្រូវសម្របតាមសហគមន៍ ដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់មូលដ្ឋាននៅថ្នាក់ក្រោមជាតិ និងយកចិត្តទុកដាក់នៅថ្នាក់ក្រោមជាតិ។ គ.ជ.អ.ប. គួររៀបចំកម្មវិធីគ្រប់គ្រងហានិភ័យឱ្យបានជាក់លាក់នៅថ្នាក់មូលដ្ឋាន។ ត្រូវធ្វើការពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋាន ក្នុងការកៀរគរហិរញ្ញវត្ថុបន្ថែមទៀត។

## ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ នៅក្នុងតំបន់ឆ្នេរ និងវិស័យទេសចរណ៍

*ការគ្រប់គ្រងតំបន់ឆ្នេរ៖* ក្រសួងបរិស្ថានបានបង្កើតផែនការសកម្មភាពបន្សាំ នៅទីតាំងអាទិភាពចំនួនពីរកន្លែង។ តំបន់ទាំងពីរកន្លែងនោះគឺ តំបន់ពាមក្រសោបខេត្តកោះកុង និងព្រៃនប់ ខេត្តព្រះសីហនុ។ ក្រោយពីការសិក្សា និងវាយតម្លៃយ៉ាងប្រុងប្រយ័ត្នរួចមក MoE បានដាក់ចេញនូវសកម្មភាពសាកល្បងចំនួន ៩ គឺ៖ [១] កម្មវិធីបណ្តុះបណ្តាលកសិករអំពីកសិកម្មចម្រុះដែលធន់នឹងអាកាសធាតុ [២] គម្រោងសហគមន៍នេសាទ [៣] ការសាកល្បងតាមកសិដ្ឋានសម្រាប់ពូជស្រូវ ការអនុវត្តបង្ហាញ និងការបណ្តុះបណ្តាលអំពីការជ្រើសរើសពូជ [៤] ប្រព័ន្ធស្តុកសត្វចិញ្ចឹមបែបបង្វិល [៥] ការបង្កើនការយល់ដឹងនិងការបណ្តុះបណ្តាលអំពីប្រព័ន្ធស្រោចស្រពដែលធន់នឹងការប្រែប្រួលអាកាសធាតុ [៦] ការបញ្ចូលវិធានការបន្សាំក្នុងផែនការវិនិយោគឃុំ [៧] ការស្តារទំនប់ [៨] ការពង្រីក និងការស្តារអាងជលសាស្ត្រ និង [៩] បន្សាំនឹងការប្រែប្រួលអាកាសធាតុដោយផ្អែកលើស្ថានប្រព័ន្ធ។ ជាមួយនឹងការអនុវត្តសាកល្បង នៅទីតាំងទាំងពីរកន្លែងនៃតំបន់ឆ្នេរនេះ យើងទទួលបានវិធីសាស្ត្រកាន់តែល្អ ក្នុងការអភិវឌ្ឍផែនការបន្សាំនឹងការប្រែប្រួលអាកាសធាតុកាន់តែមានប្រសិទ្ធភាព នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះដែរ ដើម្បីឱ្យយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ឆ្នេរមានចីរភាព យើងត្រូវរាប់បញ្ចូលវិស័យឯកជនឱ្យមានការចូលរួមរៀបចំផែនការ និងសកម្មភាពឱ្យកាន់តែរលូន និងចំទិសដៅ។ លើសពីនេះទៅទៀត ការបង់ថ្លៃលើសេវាកម្មបរិស្ថាន (PES) គួរត្រូវបានពិចារណា ដើម្បីកៀរគរហិរញ្ញវត្ថុបន្ថែមទៀត ដើម្បីជួយគាំទ្រដល់សហគមន៍នៅតាមតំបន់ឆ្នេររបស់ប្រទេសកម្ពុជា។

*វិស័យទេសចរណ៍ (MoT)៖* នាប៉ុន្មានឆ្នាំចុងក្រោយនេះ ចំនួនភ្ញៀវទេសចរណ៍បានកើនឡើងគួរឱ្យកត់សម្គាល់ ពីព្រោះប្រទេសកម្ពុជាមានទីកន្លែងសម្រាប់ទស្សនាជាច្រើន ជាមួយនឹងមធ្យោបាយធ្វើដំណើរដ៏សមរម្យ។ តំបន់ឆ្នេរគឺជាតំបន់ដ៏មានប្រជាប្រិយភាពមួយក្នុងចំណោមតំបន់ដទៃទៀតដែលទាក់ទាញ ទាំងភ្ញៀវជាតិ និងអន្តរជាតិ។ ភាពទាក់ទាញនេះ គឺដោយសារតំបន់ឆ្នេររបស់កម្ពុជាសម្បូរទៅដោយធនធានសមុទ្រឆ្នេរដ៏ស្រស់ស្អាត កោះដ៏ច្រើន (ចំនួន

៦៤) ព្រៃកោងកាង និងធនធានធម្មជាតិដ៏ច្រើនទៀត ដែលមាននៅតាមបណ្តោយឆ្នេរដែលមានប្រវែងសរុបចំនួន ៤៣៥ គ.ម.។ ជាអកុសល ធនធានដ៏សម្បូរបែបទាំងអស់នេះងាយនឹងរងគ្រោះពីការប្រែប្រួលអាកាសធាតុ។ គ្រោះធម្មជាតិ កំណើនកម្ពស់ទឹកសមុទ្រ ទឹកជំនន់ ការបាក់ដី ការហូរច្រោះតំបន់ឆ្នេរ គ្រោះរាំងស្ងួត និងភ្លើងឆេះព្រៃ អ័ព្ទជាបាតុភូតដែលជះឥទ្ធិពលអវិជ្ជមានដល់វិស័យទេសចរណ៍ ជីវិត និងសុខភាពរបស់មនុស្ស ស្ថានប្រព័ន្ធ និងសេដ្ឋកិច្ចជាតិ។ ដើម្បីឆ្លើយតបនឹងបញ្ហាទាំងអស់នេះ MoT បានដាក់ចេញនូវគោលនយោបាយក្នុងការអភិវឌ្ឍន៍វិស័យទេសចរណ៍ឱ្យមានចីរភាព ដោយផ្តោតសំខាន់លើភាពជាដៃគូក្នុងការកំណត់ទិសដៅទេសចរណ៍ ការផ្សព្វផ្សាយវិស័យទេសចរណ៍ និងយុទ្ធសាស្ត្រទីផ្សារ។ ម្យ៉ាងវិញទៀត ការកំណត់ដែនការពារ ក៏បានចូលរួមចំណែកក្នុងកិច្ចការពារធនធានធម្មជាតិសម្រាប់បម្រើដល់វិស័យទេសចរណ៍ផងដែរ។ ក្នុងនោះផងដែរក្រសួងទេសចរណ៍បានចុះបញ្ជីសហគមន៍អេកូទេសចរណ៍ ចំនួន ៥៦ សហគមន៍ និងសហគមន៍ទេសចរណ៍គំរូចំនួន ១១ កន្លែង ដើម្បីចូលរួមទទួលខុសត្រូវលើធនធានធម្មជាតិក្នុងតំបន់របស់ពួកគេ។ ការអភិវឌ្ឍអេកូទេសចរណ៍បានជួយជំរុញការប្រកួតប្រជែងទីក្រុងស្អាត ទេសចរណ៍ ១នាក់ដើមឈើ ១ដើម ការគ្រប់គ្រងថង់ប្លាស្ទិក ការគ្រប់គ្រងតំបន់ឆ្នេរ សណ្ឋាគារបៃតង/ផ្ទះស្នាក់បៃតង រមណីយដ្ឋានបៃតង និងភោជនីយដ្ឋានបៃតង។

លោកបណ្ឌិត **នេត បារមី** មានប្រសាសន៍ថា វិស័យទេសចរណ៍ក្នុងប្រទេសកម្ពុជាសព្វថ្ងៃកំពុងប្រឈមនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុកាន់តែធ្ងន់ធ្ងរ អាស្រ័យហេតុនេះ យើងត្រូវការវិធានការជាបន្ទាន់ ដើម្បីដោះស្រាយបញ្ហាទាំងនោះ។ លោកបណ្ឌិតក៏បានលើកយកវិធានការណ៍ចំនួនពីរ សម្រាប់ពិចារណាដោយក្នុងនោះរួមមាន៖ ទីមួយ យើងត្រូវការគោលនយោបាយដ៏ជាក់លាក់មួយ ក្នុងការកាត់បន្ថយ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការលើកកម្ពស់ការយល់ដឹងរបស់អ្នកទេសចរណ៍ ការយល់ពីសហគមន៍មូលដ្ឋានការអភិវឌ្ឍបៃតង និងកិច្ចសហការក្នុងចំណោមអ្នកពាក់ព័ន្ធនានា។ វិធានការទីពីរ គឺសកម្មភាពជាក់ស្តែងក្នុងការធ្វើឱ្យប្រសើរឡើងនូវការរស់នៅរបស់ប្រជាពលរដ្ឋ និងការគ្រប់គ្រងធនធានបរិស្ថាន ឱ្យមានចីរភាពតាមរយៈការស្រាវជ្រាវ និងការគ្រប់គ្រងប្រព័ន្ធព័ត៌មាន។ អាស្រ័យហេតុនេះ សាកលវិទ្យាល័យ និង MoT គួរសហការធ្វើការសិក្សាស្រាវជ្រាវ ដើម្បីបង្កើតប្រព័ន្ធព័ត៌មានផ្សេងៗ ដែលទាក់ទងនឹងវិស័យទេសចរណ៍ ការបញ្ជ្រាបព័ត៌មានពីការប្រែប្រួលអាកាសធាតុទៅក្នុងផែនការរបស់ MoT ការអភិវឌ្ឍជីវភាពរស់នៅរបស់ប្រជាជន ការប្រើប្រាស់យុទ្ធសាស្ត្រ ដែលមានស្រាប់ក្នុងការគ្រប់គ្រងតំបន់ឆ្នេរឱ្យមានចីរភាព និងកៀរគរវិស័យឯកជនឱ្យចូលរួមរៀបចំផែនការ និងអនុវត្តផែនការសកម្មភាពនានា។ លើសពីនេះទៅទៀត លោក **គង់ គឹមស្រេង** បានបន្ថែមថា PES គឺជាយន្តការថ្មីមួយទៀត ក្នុងការទទួលបាននូវហិរញ្ញវត្ថុបន្ថែមសម្រាប់សហគមន៍មូលដ្ឋាន។ ជាទូទៅ ចំណូលពីវិស័យទេសចរណ៍ជាចំណូលជាតិ ហើយសហគមន៍ទទួលផលប្រយោជន៍តិចតួចណាស់។ ដូច្នេះ PES គួរត្រូវបានរៀបចំដោយប្រយ័ត្នប្រយែងបំផុត ក្នុងគោលបំណងផ្តល់ផលប្រយោជន៍ដល់សហគមន៍។ ក្នុងនោះដែរ លោក **វ៉ា មឿន** បានគាំទ្រថាវិស័យទេសចរណ៍ពិតជាបានដើរតួនាទីសំខាន់ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងបរិស្ថានឱ្យមានចីរភាព។ ប្រសិនបើប្រជាសហគមន៍អាចទទួលបានផលប្រយោជន៍ដោយផ្ទាល់ពីវិស័យនេះតាមរយៈការលក់ម្ហូបអាហារ និងការផ្តល់សេវាកម្មផ្ទះស្នាក់ ពួកគាត់នឹងព្យាយាម

ការពារធនធានធម្មជាតិក្នុងតំបន់ឱ្យកាន់តែប្រសើរ និងមានប្រសិទ្ធភាព។

## វឌ្ឍនភាពរបស់កម្ពុជាក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងដំណើរឆ្ពោះទៅកាន់សកម្មភាពជាតិសមស្របសម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (NAMA)

*កិច្ចផ្តួចផ្តើមរៀបចំ NAMA៖* NAMA គឺជាយន្តការ ដើម្បីអនុវត្តការអភិវឌ្ឍដោយបញ្ចេញកាបូនតិចតាមរយៈការអភិវឌ្ឍសេដ្ឋកិច្ច។ ការប្រឈមមួយចំនួនរបស់ NAMA មានដូចជា របៀបដែលកិច្ចផ្តួចផ្តើមត្រូវបានអនុវត្ត ស្ថាប័នទទួលខុសត្រូវ និងស្ថាប័នគោលដៅ ពេលវេលាត្រូវចាប់ផ្តើមអនុវត្ត។ លើសពីនេះទៅទៀត NAMA ត្រូវការប្រទេសដែលមានលទ្ធភាពអនុវត្ត និងអាចឱ្យអ្នកពាក់ព័ន្ធនានាចូលរួមបាន។

បទបង្ហាញនៅក្នុងវគ្គនេះ បានផ្តល់ព័ត៌មានទូទៅអំពី NAMA រាប់បញ្ចូលទាំងប្រវត្តិ ប្រភេទ និងរបៀបរៀបចំ។ UNEP ព្យាយាមជួយដល់ប្រទេសដែលកំពុងរៀបចំ NAMA។ NAMA ក៏អាចដកស្រង់ចេញពី យុទ្ធសាស្ត្រអភិវឌ្ឍន៍ដោយបញ្ចេញកាបូនតិច។ ចំពោះកម្ពុជា មានជំពូកមួយនៃ CCCSP ក៏បានរៀបរាប់អំពីផែនការកាត់បន្ថយការបញ្ចេញកាបូន នៅក្នុងវិស័យទាំង ៧ ផងដែរ។ ផែនការទាំងនេះនឹងផ្តល់ជាការណែនាំដល់ការរៀបចំ NAMA។ ថ្មីៗនេះ UNEP បានជួយប្រទេសម៉ាឡេស៊ី ហើយក៏កំពុងគិតថានឹងជួយប្រទេសកម្ពុជា ឡាវ ភូមា និងវៀតណាមផងដែរ។ ការរៀបចំផែនទីបង្ហាញផ្លូវស្តីអំពីការបញ្ចេញកាបូនតិច គឺប្រើប្រាស់ការសិក្សារបស់ធនាគារពិភពលោក ដើម្បីជួយប្រទេសនានាឱ្យរៀបចំសំណើគម្រោងសុំជំនួយពី GEF ក្នុងការរៀបចំ NAMA។ មានវិធីមួយចំនួន ដើម្បីរៀបចំ NAMA ប្រកបដោយប្រសិទ្ធភាព [១] ស្វែងរកអ្នកគាំទ្រដែលអាចជាស្ថាប័ន ឬបុគ្គលដែលមានអំណាចដឹកនាំ [២] បញ្ចូលអ្នកពាក់ព័ន្ធសំខាន់ៗក្នុងការធ្វើផែនការ [៣] ការកៀរគរធនធាន។

*កិច្ចផ្តួចផ្តើមរបស់ជប៉ុនអំពីការកាត់បន្ថយការប្រែប្រួលអាកាសធាតុ៖* កញ្ញា Akiko បានណែនាំពីការចូលរួមរបស់ជប៉ុន ក្នុងកិច្ចការប្រែប្រួលអាកាសធាតុ។ ប្រទេសជប៉ុនបានគាំទ្រនូវសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (ឧទាហរណ៍ ការផ្តល់ជំនួយក្នុងការរៀបចំការអភិរក្សថាមពល ការគាំទ្រដល់គម្រោងកសាងសមត្ថភាព ជាដើម)។ នៅចុងឆ្នាំ២០១២ ទាំងវិស័យឯកជន និងសាធារណៈរបស់ជប៉ុនបានរួមចំណែកចំនួន១៨ពាន់លានដុល្លារអាមេរិក ដើម្បីជួយដល់សកម្មភាពការកាត់បន្ថយការប្រែប្រួលអាកាសធាតុនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។

ប្រទេសជប៉ុន បានពិគ្រោះយោបល់ដោយចូលរួមក្នុងយន្តការអនុវត្តរួមគ្នា (JCM) ជាមួយប្រទេសកំពុងអភិវឌ្ឍន៍ ចាប់តាំងពីឆ្នាំ ២០១១ និងបានចុះហត្ថលេខាលើឯកសារទ្វេភាគីសម្រាប់ JCM ជាមួយប្រទេសចំនួន៨។ ក្រសួងបរិស្ថានរបស់ប្រទេសជប៉ុន ក៏បានផ្តល់កម្មវិធីហិរញ្ញវត្ថុសម្រាប់គម្រោងគំរូ JCM នានាផងដែរ។

ទំហំនៃហិរញ្ញវត្ថុ គឺសមស្របសម្រួលដល់ការកាត់កាត់បន្ថយ $CO_2$ ពីការដុតឥន្ធនៈហ្វូស៊ីល ក៏ដូចជាការចំណាយក្នុងការតំឡើងឧបករណ៍។ មានម៉ាស៊ីនកិនស្រូវជាច្រើន ដំណើរការដោយថាមពលម៉ាស៊ីនភ្លើងប្រើប្រេងម៉ាស៊ូត។ ប្រព័ន្ធផលិតថាមពលដោយប្រើជីវៈម៉ាស (អង្កាម) ជាមួយនឹងម៉ាស៊ីនកូរអាចប្រើជំនួសម៉ាស៊ីនភ្លើងប្រើប្រេងម៉ាស៊ូតបាន និងអាចកាត់បន្ថយការបញ្ចេញ $CO_2$ បាន។ MoE នៃប្រទេសជប៉ុនបានអនុវត្តគម្រោងជីវៈម៉ាសខ្នាតតូច នៅក្នុងរោងចក្រម៉ាស៊ីនកិនស្រូវនៅកម្ពុជា។ នៅចុងបញ្ចប់ កញ្ញា Akiko បានបញ្ជាក់ពីការរំពឹងទុកក្នុងកិច្ចសហការរវាងកម្ពុជា និងជប៉ុនក្នុងការរៀបចំ NAMA។

# អារម្ភកថា

បន្ទាប់ពីវេទិកាជាតិលើកទី១ និងលើកទី២ បានកន្លងផុតទៅ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (គ.ជ.គ.ប.អ.) ដែលមាននាយកដ្ឋានប្រែប្រួលអាកាសធាតុ (CCD) នៃក្រសួងបរិស្ថាន (MoE) ជាលេខាធិការដ្ឋាន បានរៀបចំវេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ (3rd National Forum on Climate Change: 3rd NFCC) នៅរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី០៥ ដល់ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៣ ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹង និងចែករំលែកចំណេះដឹង ក៏ដូចជាបទពិសោធន៍អំពីការប្រែប្រួលអាកាសធាតុ ដែលជាបញ្ហាអន្តរវិស័យ ហើយតម្រូវការឱ្យមានការចូលរួមដោះស្រាយពីស្ថាប័នរាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធនានា រួមទាំង វិស័យឯកជន ស្ថាប័នសិក្សាស្រាវជ្រាវ អង្គការមិនមែនរដ្ឋាភិបាល (NGOs) និងសង្គមស៊ីវិល (CSOs)។

ភាគីពាក់ព័ន្ធជាច្រើនបានចុះឈ្មោះ និងចូលរួមនៅក្នុងវគ្គផ្សេងៗនៃវេទិកាជាតិនេះ រួមទាំងមន្ត្រីរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់នៃក្រសួង-ស្ថាប័នពាក់ព័ន្ធនានា។ វេទិកាជាតិនេះ មានកិត្តិយសដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានអញ្ជើញមកថ្លែងសុន្ទរកថាក្នុងពិធីបើក។ នៅថ្ងៃទី១ ទី២ និងទី៣ នៃអង្គវេទិកាជាតិ ឥស្សរជនជាតិ និងអន្តរជាតិសំខាន់ៗមួយចំនួន បានចូលរួមថ្លែងសុន្ទរកថាស្វាគមន៍ រួមមាន **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន **ឯកឧត្តម ខៀវ មុត** រដ្ឋលេខាធិការ ក្រសួងបរិស្ថាន លោកស្រី **Claire Van der Vaeren** មន្ត្រីសម្របសម្រួលនៃអង្គការសហប្រជាជាតិប្រចាំកម្ពុជា **ឯកឧត្តម ប៉ាន ប៊ុនធឿន** រដ្ឋលេខាធិការ ក្រសួងផែនការ **ឯកឧត្តម Jean-François Cautain** ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំកម្ពុជា **ឯកឧត្តម វស់ សីលវ៉ា** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលោក **Peter Brimble** នាយករងប្រចាំប្រទេសនៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។

វេទិកាជាតិនេះ បាននាំមកនូវលទ្ធផលជាផ្លែផ្កា តាមរយៈបទបង្ហាញ និងកិច្ចពិភាក្សា ហើយបានចែករំលែកនូវព័ត៌មាន បទពិសោធន៍ ព្រមទាំងបង្ហាញពីការប្តេជ្ញាចិត្តរបស់ភាគីពាក់ព័ន្ធទាំងអស់ក្នុងកិច្ចសហការរួមគ្នាដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។ វេទិកានេះមិនត្រឹមតែផ្តល់ការយល់ដឹងជាមូលដ្ឋានអំពីការប្រែប្រួលអាកាសធាតុ ដែលជាបញ្ហាអន្តរវិស័យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបញ្ជ្រាប និងពង្រឹងទស្សនទាននានាដល់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសបណ្តាក្រសួង-ស្ថាប័ននានា ឱ្យយកចិត្តទុកដាក់លើបញ្ហាប្រែប្រួលអាកាសធាតុ និងចាត់ទុកបញ្ហានេះជាអាទិភាពនៅក្នុងការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុប្រកបដោយប្រសិទ្ធភាព។ ព័ត៌មានពីវេទិកាជាតិនេះ មានសារៈសំខាន់ណាស់សម្រាប់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីលើកយកទៅពិភាក្សានៅក្នុងសន្និសីទបណ្តាភាគីលើកទី១៩ (COP 19) នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)។

ឯកសារនេះរួមមាន សេចក្តីសង្ខេបនៃរបាយការណ៍ពិស្តារ កិច្ចពិភាក្សាសំខាន់ៗ និងសេចក្តីសន្និដ្ឋានជាគន្លឹះ ដែលជាលទ្ធផលរបស់វេទិកាជាតិនេះ។ យើងសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា

កិច្ចពិភាក្សាដែលបានរៀបចំនៅក្នុងវេទិកាជាតិនេះ នឹងជួយជំរុញកិច្ចពិភាក្សាអំពីគោលនយោបាយ ការធ្វើសេចក្ដីសម្រេចចិត្ត និងសកម្មភាពពាក់ព័ន្ធនានា ដែលកំពុងដំណើរការ ដើម្បីឱ្យប្រទេសកម្ពុជាពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងសេដ្ឋកិច្ចដែលបញ្ចេញកាបូនតិច ហើយប្រើប្រាស់ឱកាសនិងការគាំទ្រដែលអាចទទួលបានក្នុងកិច្ចខិតខំឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់កាត់បន្ថយភាពក្រីក្រ តាមរយៈការគ្រប់គ្រងហានិភ័យអាកាសធាតុ។

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

*សក្តានុពលក្នុងការកាត់បន្ថយដំណើរការ និងដំណើរឆ្ពោះទៅមុខ៖* ប្រទេសកម្ពុជាមានសក្តានុពលក្នុងជម្រើសកាត់បន្ថយក្នុងវិស័យថាមពល និងដឹកជញ្ជូន កសិកម្ម ព្រៃឈើ និងការប្រើប្រាស់ដីធ្លី (AFOLU)។ របាយការណ៍ជាតិលើកទីពីរ (SNC) បានកំណត់នូវជម្រើសមួយចំនួនក្នុងវិស័យថាមពល ដូចជា ប្រសិទ្ធភាពថាមពល វារីអគ្គិសនី ថាមពលពន្លឺព្រះអាទិត្យ ការបម្លែងទៅជាឧស្ម័ន និងការបង្កើតអគ្គិសនីយានយន្តប្រើអគ្គិសនី ចង្ក្រានមានប្រសិទ្ធភាពថាមពល ឡជីវឧស្ម័ន និងចម្រោះទឹកសេរ៉ាមិច។ វិស័យទាំងនេះមានសក្តានុពលកាត់បន្ថយការបញ្ចេញឧស្ម័នរហូតដល់ ១៧ % នៅឆ្នាំ២០៥០។ បើតាមការប៉ាន់ស្មាន ការបញ្ចេញឧស្ម័នពី AFOLU នឹងកើនឡើង ហើយប្រទេសកម្ពុជានឹងក្លាយជាអ្នកបញ្ចេញដែរ។

ថ្មីៗនេះ ប្រទេសកម្ពុជាបាននឹងកំពុងអនុវត្តសកម្មភាពកាត់បន្ថយមួយចំនួនដូចជា៖ យន្តការអភិវឌ្ឍន៍ស្អាត (CDM) ការរៀបចំស្តង់ដាទិន្នន័យគោលសម្រាប់រោងម៉ាស៊ីនកិនស្រូវ ដើម្បីអនុវត្តសកម្មភាពកម្មវិធី។ សកម្មភាពកាត់បន្ថយសមស្របថ្នាក់ជាតិ (NAMA) គម្រោងស្នើសុំការរៀបចំយន្តការអនុវត្តរួមគ្នា ក្នុងវិស័យទឹកស្អាតក្នុងប្រទេសកម្ពុជា។ REDD ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតង ឆ្នាំ ២០១៣-២០៣០ និងកម្មវិធីភាពជាដៃគូរវាងថាមពល និងបរិស្ថាននៅតំបន់មេគង្គ។

ទាក់ទងនឹងផែនការនាពេលអនាគត ប្រទេសកម្ពុជានឹងផ្សព្វផ្សាយ CCCSP និងរៀបចំ CCAP តាមវិស័យ ធ្វើបច្ចុប្បន្នកម្មបញ្ជីសារពើភ័ណ្ឌ GHG រំកិលពីការអនុវត្តគម្រោងទៅជាការអនុវត្តកម្មវិធី និងអនុវត្តតាមកិច្ចផ្តួចផ្តើម/យន្តការកាត់បន្ថយការបញ្ចេញ GHG ថ្នាក់អន្តរជាតិ។ ថ្មីៗនេះ ក្រសួងបរិស្ថានបានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នា ជាមួយនឹង USAID ដើម្បីរៀបចំផែនការធ្វើបញ្ជីសារពើភ័ណ្ឌកសាងសមត្ថភាព និងអនុវត្តផែនការបញ្ជីសារពើភ័ណ្ឌជាតិ។ ផែនការនេះក៏មកពីសកម្មភាព JCM ដែលអនុវត្តជាមួយនឹងប្រទេសជប៉ុនដែរ។ ដើម្បីជំរុញការងារទាំងអស់ តម្រូវឱ្យអ្នកពាក់ព័ន្ធទាំងអស់សហការគ្នា និងត្រូវមានការគាំទ្រផ្នែកហិរញ្ញវត្ថុផងដែរ។

លោក **វណ្ណារិទ្ធិ** បានបង្ហាញថា គោលការណ៍អភិវឌ្ឍន៍បៃតង គឺដើម្បីកាត់ការបន្ថយភាពក្រីក្រ និងត្រូវការការចូលរួមពីអ្នកពាក់ព័ន្ធតាំងពីវិស័យឯកជនរហូតដល់វិស័យសាធារណៈ: ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។ សសរស្តម្ភទាំង ៤ នៃការអភិវឌ្ឍបៃតងគឺ សេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ក្នុងគោលបំណង ដើម្បីចីរភាពរបស់ស្ថានប្រព័ន្ធ បរិស្ថាន ខ្យល់ និងទឹក។ ការអភិវឌ្ឍបៃតង មានទស្សនៈវិស័យរយៈពេលវែងពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០៣០ ដើម្បីកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍសង្គម។

លោក **Alex Diment** បានបញ្ជាក់ពីការពិតថា រាជរដ្ឋាភិបាលធ្វើកិច្ចការជាច្រើន ដែលជាសកម្មភាពកាត់បន្ថយ ដូចនេះរចនាសម្ព័ន្ធ NAMA អាចចុះឈ្មោះដោយមានការទទួលស្គាល់ពីសហគមន៍អន្តរជាតិដែលរាជរដ្ឋាភិបាលអាចបង្ហាញពីសកម្មភាពល្អៗ នៃការប្រែប្រួលអាកាសធាតុ។ នេះជាឱកាសល្អសម្រាប់រាជរដ្ឋាភិបាលឱ្យទទួលបានការទទួលស្គាល់ថា បានធ្វើសកម្មភាពនាំមុខគេពី NAMA ព្រោះថាមានប្រទេសនៅក្នុងតំបន់តិចតួចណាស់ ដែលបានអនុវត្ត NAMA។ លោក **មៅ វិសាល** បានបញ្ជាក់ថា កម្ពុជាបានធ្វើកិច្ចការយ៉ាងល្អក្នុងការរៀបចំ CCCSP និងឯកសារផ្សេងៗទៀតទាក់ទងនឹងការប្រឈមនឹងបញ្ហាការប្រែប្រួលអាកាសធាតុ។

នៅក្នុងវគ្គពិភាក្សា មានសំណួមពរអំពីការចូលរួមកាត់បន្ថយ GHG នៃប្រទេសកម្ពុជា ដូចជា [១] អនុវត្តទីក្រុងបៃតង តាមរយៈវិស័យដឹកជញ្ជូន និងការគ្រប់គ្រងសំណល់ [២] ការកសាងសមត្ថភាពផ្នែកបច្ចេកទេស និងវិទ្យាសាស្ត្រ [៣] រដ្ឋាភិបាល គួរតែអនុវត្តនូវគោលនយោបាយដែលមានស្រាប់ ឱ្យបានជ្រួតជ្រាបដល់សហគមន៍បើទោះជា តាមរយៈគម្រោងគំរូក៏ដោយ ដែលសកម្មភាពនេះអាចផ្តល់នូវលទ្ធផលល្អៗ ឧទា-ហរណ៍ បន្ទះពន្លឺព្រះអាទិត្យ។

ជាចុងក្រោយ វេទិកាជាតិនេះបានឆ្លើយតបថា យើងមានឯកសារគោលនយោបាយ និងសកម្មភាពមួយចំនួន ដែលទាក់ទងនឹងគោលនយោបាយបៃតង ហើយកំពុងត្រូវបានអនុវត្ត។ ទោះបីជាយ៉ាងណាក៏ដោយ វឌ្ឍនភាពនៃការអនុវត្តនៅយឺតយ៉ាវ និងឧបសគ្គនៃការចែករំលែកព័ត៌មាន។ ដូចនេះ ត្រូវបង្កើនការចូលរួម និងការសម្របសម្រួលពីអ្នកពាក់ព័ន្ធ។ ការប្រែក្លាយគោលនយោបាយទៅជាសកម្មភាពនៅតែមានកម្រិត និងវាអាចជាបញ្ហាបច្ចេកទេសនៅក្នុងករណីមួយចំនួន។

## ៤.៣ កិច្ចសហប្រតិបត្តិការរបស់ប្រទេសកម្ពុជា និងអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ

ទាំងរាជរដ្ឋាភិបាល DPs និង CSOs បានទាមទារឱ្យមានការពង្រីកការសហការក្នុងការអភិវឌ្ឍកម្មវិធី ក៏ដូចជាការបែងចែកធនធាន ក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុឱ្យកាន់តែមានប្រសិទ្ធភាព។

អង្គវេទិកាជាតិនេះ ក៏បានយល់ស្របរួមគ្នាពីតម្រូវការដ៏ចាំបាច់ ក្នុងការទទួលបានហិរញ្ញវត្ថុគ្រប់គ្រាន់ពីសហគមន៍អន្តរជាតិនានា ក្នុងការជួយគាំទ្រនូវការអនុវត្តផែនការជាតិ ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ អង្គវេទិកាក៏បានគូសបញ្ជាក់ផងដែរថា សហគមន៍អន្តរជាតិមានកាតព្វកិច្ចជួយដល់ បណ្តាប្រទេសកំពុងអភិវឌ្ឍន៍នានា ដូចជាប្រទេសកម្ពុជាបន្តទៀត។ ទី១៖ សហគមន៍អន្តរជាតិជាពិសេសប្រទេសអភិវឌ្ឍន៍ត្រូវតែផ្តល់ហិរញ្ញប្បទានចំនួន ១០០ ពាន់លានដុល្លារអាមេរិក ក្នុងមួយឆ្នាំដែលជាថវិកាបន្ថែម ដើម្បីជួយគាំទ្របណ្តាប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុជាសកលរហូតដល់ឆ្នាំ២០២០។ មកដល់ពេលនេះ យើងសង្កេតឃើញថា ដំណើរការផ្តល់ថវិកាហាក់មានល្បឿនយឺតជាងការរំពឹងទុកហើយមានគំលាតថវិកាឆ្ងាយរវាងឆ្នាំ ២០១៣ និងឆ្នាំ ២០២០។ សម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួចដូចជាកម្ពុជា ហើយដែលជាប្រទេសដែលរងគ្រោះពីការប្រែប្រួលអាកាសធាតុនេះ ត្រូវការហិរញ្ញវត្ថុពីមជ្ឈដ្ឋានខាងក្រៅជាចាំបាច់។ ទី២៖ សហគមន៍អន្តរជាតិមិនគួរផ្តល់កញ្ចប់ថវិកាដែលមានលក្ខណៈស្មុគ្រស្មាញ ហើយមានប្រតិបត្តិការចំណាយខ្ពស់ ដល់ប្រទេសកំពុងអភិវឌ្ឍន៍នោះទេ។ ហិរញ្ញវត្ថុការប្រែប្រួលអាកាសធាតុ គួរត្រូវបានផ្តល់ឱ្យងាយស្រួល ទៅដល់សកម្មភាពដែលជាអាទិភាព និងប្រព័ន្ធផែនការជាតិរបស់ប្រទេសនានា ដែលកំពុងតែរងគ្រោះពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ដូចជាប្រទេសកម្ពុជាដែលជាប្រទេសមួយក្នុងចំណោមប្រទេសដែលងាយរងគ្រោះពីការប្រែប្រួអាកាសធាតុជាងគេ ក្នុងចំណោមប្រទេសទាំង១០នោះ គឺយើងត្រូវការជាចាំបាច់នូវហិរញ្ញវត្ថុសម្រាប់បន្សាំនឹងការប្រែប្រួលអាកាសធាតុជាការចាំបាច់ នេះបើតាមការលើកឡើងរបស់ឯកឧត្តម **រស់ សីលវ៉ា** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងឱកាសសុន្ទរកថាបើកនៅថ្ងៃទី

៣ នៃវេទិកាជាតិនេះ។ ឯកឧត្តមក៏បានបន្ថែមថា ក្នុងរយៈពេល៣ឆ្នាំចុងក្រោយនេះចំនួនទឹកប្រាក់ប្រហែលជា ២៥០លានដុល្លារអាមេរិក ត្រូវបានប្រើប្រាស់ដោយទទួលបានពីប្រភពផ្សេងៗ។ បេសកកម្មសំខាន់របស់ប្រទេសកម្ពុជាគឺពង្រឹងខ្ទង់ចំណាយ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីកៀរគរហិរញ្ញវត្ថុអន្តរជាតិមកបន្ថែមទៀត ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ តាមរយៈមូលនិធិសកលនៃការប្រែប្រួលអាកាសធាតុ មូលនិធិបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងមូលនិធិអាកាសធាតុបៃតង។

ម្យ៉ាងវិញទៀត ការគ្រប់គ្រងហិរញ្ញប្បទាននៃការប្រែប្រួលអាកាសធាតុ ក្នុងប្រទេសកម្ពុជាត្រូវការជាចាំបាច់ក្នុងការសហការជាមួយដៃគូអន្តរជាតិនានា ដើម្បីបំពេញការងារឱ្យកាន់តែមានប្រសិទ្ធភាព។ លើសពីនេះទៅទៀត អង្គវេទិកាជាតិបានយល់ស្របថា PES អាចជាយន្តការថ្មីមួយដែលអាចជួយកម្ពុជាឱ្យទទួលបានហិរញ្ញប្បទានបន្ថែមសម្រាប់សហគមន៍មូលដ្ឋាន។

*ក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុអន្តរជាតិ៖* ហិរញ្ញប្បទាននៃការប្រែប្រួលអាកាសធាតុត្រូវបានផ្តល់ និងស្នើឡើងក្នុងកម្រិតតំបន់ និងទ្វេភាគី។ ទោះបីជាយ៉ាងណាក៏ដោយហិរញ្ញប្បទានគឺមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ ហិរញ្ញប្បទានភាគច្រើនផ្តល់អាទិភាពលើការងារកាត់បន្ថយការប្រែប្រួលអាកាសធាតុ នៅក្នុងខណៈដែលបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅមានចំនួនតិចនៅឡើយ។ ជាមួយនឹងការប្រឈមទាំងនេះ វិស័យឯកជនបានក្លាយជាភ្នាក់ងារដ៏សំខាន់ ក្នុងការរួមចំណែកដល់ហិរញ្ញប្បទានប្រែប្រួលអាកាសធាតុក្នុងរូបភាពជា មីក្រូហិរញ្ញវត្ថុការធានារ៉ាប់រង និងការបង្កើតបច្ចេកវិទ្យាថ្មីក្នុងការកាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាជន និងសហគមន៍ពីការប្រែប្រួលអាកាសធាតុ។

ដើម្បីប្រើប្រាស់ហិរញ្ញប្បទាន ឱ្យកាន់តែមានប្រសិទ្ធភាពក្នុងការងារប្រែប្រួលអាកាសធាតុកម្ពុជា មានភារកិច្ចដ៏ចាំបាច់ក្នុងការរៀបចំផែនការហិរញ្ញវត្ថុ ឱ្យច្បាស់លាស់ជាមួយនឹងដំណើរការ MRV។

*ក្របខណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ៖* ដំណើរការនៃការប្រើប្រាស់ និងគ្រប់គ្រងហិរញ្ញវត្ថុក្នុងការងារប្រែប្រួលអាកាសធាតុមានលក្ខណៈស្មុគ្រស្មាញ នៅពេលយើងប្រើប្រាស់មូលនិធិជាតិ និងអន្តរជាតិ។ ប្រទេស កម្ពុជាកំពុងរៀបចំខ្ទង់ចំណាយយ៉ាងត្រឹមត្រូវ និងប្រយ័ត្នប្រយែងជាមួយនឹងការតាមដានយ៉ាងទៀងទាត់ផងដែរ។ ក្នុងនោះ កិច្ចសហការជាមួយដៃគូអន្តរជាតិ គួរត្រូវពង្រឹងបន្ថែម ដើម្បីទទួលបាននូវហិរញ្ញប្បទានអាកាសធាតុ។ លើសពីនេះ រាល់គម្រោងថវិកា នឹងត្រូវបែងចែកឱ្យបានត្រឹមត្រូវបំផុត និងជាលក្ខណៈប្រព័ន្ធក្នុងការសម្រេចឱ្យបាននូវគោលបំណង នៃការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

*កិច្ចសហប្រតិបត្តិការអន្តរជាតិ ទស្សនវិស័យរបស់ MRC៖* ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ ពិតជាមានសារៈសំខាន់។ ការឆ្លើយតបនេះ នឹងកាន់តែមានប្រសិទ្ធភាព ប្រសិនបើកិច្ចសហការរវាងរដ្ឋាភិបាល និងម្ចាស់ជំនួយ NGOs និងវិស័យឯកជនត្រូវបានពង្រឹង និងពង្រីក។ ការពង្រីកកិច្ចសហការរបស់គម្រោង ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុទៅដល់ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ គឺជាជំហានបន្ទាប់ដែលត្រូវតែអនុវត្តក្នុងការសិក្សាពីគ្នាទៅវិញទៅមក ដើម្បីកាត់បន្ថយ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុឱ្យកាន់តែមានប្រសិទ្ធភាព។ លើសពីនេះទៅទៀត ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ ទៅក្រសួងពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធដទៃទៀតពិតមានសារៈ

សំខាន់ខ្លាំងណាស់ ក្នុងការលើកកម្ពស់ការយល់ដឹងជាសាធារណៈ។ ការផ្តល់ព័ត៌មានពីការប្រែប្រួលអាកាសធាតុ អាចប្រព្រឹត្តទៅក្នុងសិក្ខាសាលា និងរាល់ព្រឹត្តិការណ៍នានា ដើម្បីឱ្យប្រជាពលរដ្ឋបានដឹងតួនាទីរបស់ខ្លួនក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ តាមរយៈការបញ្ជ្រាបការប្រែប្រួលអាកាសធាតុនេះ នឹងធ្វើឱ្យវិស័យសាធារណៈវិស័យឯកជន សហគមន៍ និងម្ចាស់ជំនួយ មានឱកាសធ្វើការរួមគ្នា ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

*ការចរចាក្នុង UNFCCC និងគោលជំហររបស់ប្រទេសកម្ពុជាក្នុង COP ១៩ ៖* កម្ពុជាគាំទ្រយ៉ាងពេញទំហឹងដល់ហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុថ្មី និងបន្ថែមពីប្រភពសាធារណៈជាមួយនឹងផែនទីបង្ហាញផ្លូវដ៏ច្បាស់លាស់។ ប្រទេសអភិវឌ្ឍន៍នានា គួរបន្ថែមខ្នង់ចំណាយរបស់ពួកគេ ដើម្បីផ្តល់ឱ្យប្រទេសដែលកំពុងតែរងគ្រោះពីការប្រែប្រួលអាកាសធាតុ។ ជាការរំពឹងទុកនៅឆ្នាំ២០២០ បណ្តាប្រទេសអភិវឌ្ឍន៍នានាត្រូវផ្តល់ថវិកាដល់ប្រទេស ដែលងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុយ៉ាងតិចណាស់ ១០០ ពាន់លានដុល្លារអាមេរិក ដែលយន្តការនេះបានកំណត់ក្នុងកិច្ចព្រមព្រៀងនៅទីក្រុងCopenhagen។ ក្រៅពីការគាំទ្រហិរញ្ញវត្ថុ កម្ពុជាក៏អំពាវនាវរកជំនួយផ្នែកវាយតម្លៃតម្រូវការបច្ចេកវិទ្យាថ្មីៗ និងមិនប៉ះពាល់បរិស្ថាន។ សម្រាប់ការងារពង្រឹងសមត្ថភាពឱ្យមានប្រសិទ្ធភាព យើងត្រូវការការចូលរួមយ៉ាងពេញលេញពីអ្នកពាក់ព័ន្ធ។ ការកសាងសមត្ថភាព ត្រូវការភាពរឹងមាំ និងអាចរស់រវែងបាន ដើម្បីដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុនៅក្នុងការងារទំនាក់ទំនងថ្នាក់ជាតិ។

វេទិកាជាតិលើកទី៣នេះ បានបញ្ចប់ក្រោមអធិបតីភាព ឯកឧត្តម **សាបូ អូហ្សាណ្ណ** រដ្ឋលេខាធិការ ក្រសួងបរិស្ថាន។ ឯកឧត្តម បានមានប្រសាសន៍ក្នុងសុន្ទរកថាបិទនេះថា រាជរដ្ឋាភិបាល មានឆន្ទៈយ៉ាងមោះមុតបំផុត ក្នុងការធ្វើការងារជាមួយដៃគូនានា ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុឱ្យមានប្រសិទ្ធភាព។ ការចូលរួមចំណែករបស់យើងទាំងអស់គ្នា គឺជាការរួមចំណែកដោះស្រាយរាល់បញ្ហាជាប្រវត្តិសាស្ត្រ និងសម្រាប់មនុស្សជំនាន់ក្រោយ។ ប្រទេសកម្ពុជា គឺជាជនរងគ្រោះពីការប្រែប្រួលអាកាសធាតុ ពោល គឺយើងមិនមែនជាប្រទេសដែលធ្វើឱ្យកើតឡើងនូវការប្រែប្រួលអាកាសធាតុនេះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងនាមជារាជរដ្ឋាភិបាលកម្ពុជា យើងនឹងចូលរួមរកដំណោះស្រាយបញ្ហានានាក្នុងគ្រប់កម្រិត រួមទាំងកម្រិតនយោបាយផងដែរ។

វេទិកាជាតិនេះ ត្រូវបានផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់បំផុតពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នាឱកាសបើកវេទិកាជាតិ និងការប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុកម្ពុជា។ ផែនការយុទ្ធសាស្ត្រជាតិនេះ នឹងក្លាយជាផែនទីបង្ហាញផ្លូវ សម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជាលើគ្រប់វិស័យ។ រាល់គំនិត និងអនុសាសន៍ពីវេទិកាជាតិនេះ នឹងត្រូវបានចងក្រង និងប្រើប្រាស់សម្រាប់គោលជំហររបស់កម្ពុជាក្នុង COP ១៩ នៅទីក្រុងវ៉ាសូវី ប្រទេសប៉ូឡូញ។ កម្ពុជានឹងធ្វើការរួមគ្នាជាមួយនឹងប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀត ដៃគូអភិវឌ្ឍន៍ អង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិផ្សេងទៀត ដើម្បីទាមទារឱ្យប្រទេសអភិវឌ្ឍន៍បន្តផ្តល់ការគាំទ្រទាំងបច្ចេកទេស និងថវិកាបន្ថែមទៀត ដើម្បីយើងអាចយកមករៀបចំផែនការបន្សាំថ្នាក់ជាតិបន្តទៀត។

# ៥. សេចក្តីសន្និដ្ឋាន

វេទិកាជាតិលើកទី៣ស្តីពីការប្រែប្រួលអាកាសធាតុនេះ បានស្វាគមន៍ចំពោះការប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ CCCSP។ CCCSP គឺជាឯកសារគោលនយោបាយដំបូងរបស់កម្ពុជាសម្រាប់ឱ្យក្រសួងពាក់ព័ន្ធទាំងអស់ រួមទាំង ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងសហគមន៍ បញ្ជ្រាបបញ្ហាបប្រែប្រួលទៅក្នុងផែនការសកម្មភាពរបស់ខ្លួន ។

អង្គវេទិកាទាំងមូល បានឯកភាពថា នៅសល់ការងារជាច្រើនទៀតដែលយើងត្រូវបំពេញទាំងអស់គ្នា ដើម្បីសម្រេចឱ្យបាននូវទស្សនវិស័យ និងគោលបំណងនៃការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ក្នុងនោះមានសេចក្តីថ្លែងការណ៍មួយចំនួនត្រូវបានដាក់ចេញដូចខាងក្រោម៖

- ជំរុញឱ្យអនុវត្តផែនការសកម្មភាពនានា និងពង្រីកពីការអនុវត្តគម្រោងគំរូទៅតំបន់ដែលធំជាងនេះ ក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។
- ជំរុញឱ្យមានការកសាងសមត្ថភាពបន្ថែមទៀតទាំងការងារបច្ចេកទេស និងការគ្រប់គ្រងហិរញ្ញវត្ថុតាមបណ្តាសាមីក្រសួង ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។
- លើកទឹកចិត្តវិស័យឯកជនឱ្យជួយដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ ដោយកាត់បន្ថយហានិភ័យអាកាសធាតុ និងលើកកម្ពស់ការអភិវឌ្ឍបៃតងតាមរយៈបង្កើតបរិយាកាសសមស្របសម្រាប់ការវិនិយោគនៅកម្ពុជា។
- រាល់ផែនការបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុត្រូវស្របនឹង CCCSP។
- ជំរុញឱ្យមានយន្តការសម្របសម្រួលសមស្របមួយ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកាជាតិក្នុងសាមីក្រសួង និងស្ថាប័ននានាក្នុងសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។
- ជំរុញឱ្យស្ថាប័នថ្នាក់ក្រោមជាតិរៀបចំផែនការការប្រែប្រួលអាកាសធាតុ និងចាត់វិធានការជាបន្ទាន់ក្នុងការឆ្លើយតបនឹងតម្រូវការពិតប្រាកដនៅសហគមន៍។ ការកសាងសមត្ថភាពនៅថ្នាក់ក្រោមជាតិគឺជាតម្រូវការដ៏ចាំបាច់មួយ។
- បង្កើតការសហការនៅថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ដើម្បីពង្រឹងសមត្ថភាព និងទទួលបាននូវហិរញ្ញវត្ថុបន្ថែមក្នុងការបំពេញកិច្ចការបន្សាំនឹងការប្រែប្រួលអាកាសធាតុឱ្យកាន់តែប្រសើរ។
- ទំនាក់ទំនងជាមួយម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍនានា ដើម្បីទទួលបានការគាំទ្រហិរញ្ញវត្ថុបន្ថែមលើសកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។

# ឧបសម្ព័ន្ធទី ១៖ របៀបវារៈ

| ថ្ងៃទី ១៖ | ថ្ងៃអង្គារ ទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៣ |
|---|---|
| | **ពិធីបើកវេទិកា** |
| ០៧:៣០-៨:០០ | -ការអញ្ជើញដល់របស់ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា សមាជិក សមាជិកា ភ្ញៀវជាតិ និងអន្តរជាតិ |
| ០៨:០០ | -ការអញ្ជើញដល់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា |
| | **ចាប់ផ្តើមកម្មវិធី** |
| ០៨:០០ | ប្រកាសរបៀបវារៈនៃពិធីបើក |
| | គោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា |
| | សុន្ទរកថាស្វាគមន៍របស់ **ឯកឧត្តមសាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (គ.ជ.គ.ប.អ.) |
| | សុន្ទរកថាបើកវេទិកាជាតិរបស់**សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា |
| | ពិធីប្រគល់ផែនការយុទ្ធសាស្រ្តឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា២០១៤-២០២៣ ដោយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធាន គ.ជ.គ.ប.អ. |
| | ការអញ្ជើញនិវត្តរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា |
| ៩:៣០ | - បិទពិធីបើកវេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ |
| | **កម្មវិធីពេលរសៀល** |
| ១២:៣០ - ១៣:៣០ | ការចុះឈ្មោះ<br>ទីកន្លែង៖ សណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា រាជធានីភ្នំពេញ |
| ១៣:៣០ - ១៣:៤០ | ប្រកាសរបៀបវារៈ |
| ១៣:៤០ - ១៣:៥៥ | សុន្ទរកថាស្វាគមន៍របស់ **លោកស្រី Claire Van der Vaeren** មន្ត្រីសម្របសម្រួលនៃអង្គការសហប្រជាជាតិប្រចាំកម្ពុជា |
| ១៣:៥៥ - ១៤:១០ | សុន្ទរកថាបើករបស់ **ឯកឧត្តម ខៀវ មុត** រដ្ឋលេខាធិការក្រសួងបរិស្ថាន |
| | **១ វគ្គចាប់ផ្តើម៖ ព័ត៌មានវិទ្យាសាស្រ្តអំពីការប្រែប្រួលអាកាសធាតុ វឌ្ឍនភាពនៃការអនុវត្ត និងផែនការយុទ្ធសាស្រ្តឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (ផ.យ.ប.អ.ក.)** |

| | |
|---|---|
| | ប្រធានដឹកនាំះឯ.ឧ. ខៀវ មុត រដ្ឋលេខាធិការក្រសួងបរិស្ថាន |
| ១៤:១០-១៤:៣០ | **១១. បច្ចុប្បន្នភាពនៃព័ត៌មានវិទ្យាសាស្ត្រប្រែប្រួលអាកាសធាតុះ មូលហេតុ និងផលប៉ះពាល់**<br>គោលបំណងះ ផ្តល់នូវព័ត៌មានថ្មីបំផុតអំពីវិទ្យាសាស្ត្រ ផលប៉ះពាល់ និង កាលានុវត្តភាព នៃការប្រែប្រួលអាកាសធាតុ ដោយផ្អែកលើរបាយការណ៍ចុងក្រោយរបស់ក្រុមប្រឹក្សាអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC)<br>អ្នកធ្វើបទបង្ហាញះ លោក Mozaharul Alam អ្នកសម្របសម្រួលការងារប្រែប្រួលអាកាសធាតុប្រចាំតំបន់របស់ UNEP (២០នាទី) |
| ១៤:៣០ - ១៥:០០ | សំណួរ ចម្លើយ (នាទី៣០) |
| ១៥:០០ - ១៥:២០ | សម្រាកពិសាអាហារសម្រន់ |
| ១៥:២០ - ១៥:៤០ | **១.២ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅកម្ពុជា និងតំបន់អាស៊ីអាគ្នេយ៍**<br><br>គោលបំណងះ ធ្វើបច្ចុប្បន្នភាពចុងក្រោយអំពីលទ្ធផលនៃការសិក្សា ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅកម្ពុជា និងតំបន់អាស៊ីអាគ្នេយ៍<br>អ្នកធ្វើបទបង្ហាញះ<br>១. បណ្ឌិត ប៊ិច សុខេម ប្រធានក្រុម និងជាអ្នកឯកទេសធនធានទឹក និង ការប្រែប្រួលអាកាសធាតុនៃក្រុមហ៊ុន Hatfield/SPCR (១០នាទី)<br>២. លោក Hans Guttman នាយកប្រតិបត្តិគណៈកម្មាធិការទន្លេមេគង្គ (MRC) (១០នាទី) |
| ១៥:៤០ - ១៦:១០ | សំណួរ ចម្លើយ (នាទី៣០) |
| ១៦:១០ - ១៦:៣០ | **១.៣ បច្ចុប្បន្នភាពការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា ដោយផ្តោតលើសកម្មភាពបន្តនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ**<br>គោលបំណងះ រាយការណ៍ពីវឌ្ឍនភាពរបស់ប្រទេសកម្ពុជាក្នុងការ កសាង សមត្ថភាពស្ថាប័ន ការបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុទៅ ក្នុងផែន ការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុថ្នាក់ជាតិ និងតាមវិស័យ និងការអនុវត្តគំនិតផ្តួចផ្តើមការងារប្រែប្រួលអាកាសធាតុសំខាន់ៗ។<br>អ្នកធ្វើបទបង្ហាញះ លោក ម៉ា ច័ន្ទសុទ្ធា អនុប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុក្រសួងបរិស្ថាន (២០នាទី) |
| ១៦:៣០ - ១៧:០០ | សំណួរ ចម្លើយ(នាទី ៣០) |
| ១៧:០០ - ១៧:២០ | **១.៤ ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា**<br>គោលបំណងះ បង្ហាញពីដំណើរការរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (ផ.យ.ប.អ.ក.) មាតិកាសំខាន់ៗ និង ដំណើរឆ្ពោះទៅមុខ។<br>អ្នកធ្វើបទបង្ហាញះ លោក ស៊ុំ ធី ប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ |

| | |
|---|---|
| | ក្រសួងបរិស្ថាន (២០នាទី) |
| ១៧:២០ - ១៧:៥០ | សំណួរ ចម្លើយ (នាទី៣០) |
| ១៧:៥០ - ១៨:១០ | ការសង្ខេបសកម្មភាពថ្ងៃទី១ |
| ១៨:១៥ - ២០:៣០ | ពិធីជប់លៀងភេសជ្ជៈពេលល្ងាច<br>ទីកន្លែង៖ បន្ទប់ Pre-Function នៃសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា |
| **ថ្ងៃទី ២** | **ថ្ងៃពុធ ទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៣** |
| ០៧:៣០ -០៨:៤៥ | ការចុះឈ្មោះ<br>ទីកន្លែង៖ សណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា |
| ០៨:៤៥ - ០៩:១៥ | ការចាប់ផ្តើមកម្មវិធី<br>សុន្ទរកថាស្វាគមន៍របស់ **ឯកឧត្តម ប៉ាន ប៊ុនធឿន** រដ្ឋលេខាធិការក្រសួងផែនការ<br>សុន្ទរកថាស្វាគមន៍របស់ **ឯកឧត្តម Jean-François Cautain** ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំកម្ពុជា |
| ០៩:១៥ - ០៩:៣០ | សេចក្តីសង្ខេបលទ្ធផលថ្ងៃទី១<br>ប្រកាសរបៀបវារៈថ្ងៃទី២<br>ការណែនាំកិច្ចពិភាក្សាវគ្គស្របគ្នា |
| ០៩:៣០ - ១០:០០ | សម្រាកពិសាអាហារសម្រន់ |
| ១០:០០ - ១១:៣០ | វគ្គស្របគ្នា៖ ការរៀបចំផែនការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុស្តីពីមេរៀនទទួលបាន និងដំណើរឆ្ពោះទៅមុខ |

**វគ្គស្របគ្នាផ្នែកទី១៖ ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ (ផ.យ.ប.អ. តាមវិស័យ) និងផែនការសកម្មភាព**

| **ក្រុមទី១៖ ការអប់រំការប្រែប្រួលអាកាសធាតុ ទំនាក់ទំនង និងយេនឌ័រ** | **ក្រុមទី២៖ ការឆ្លើយតបការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម និងធារាសាស្ត្រ** | **ក្រុមទី៣៖ ការឆ្លើយតបការប្រែប្រួលអាកាសធាតុក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត** |
|---|---|---|
| ទីកន្លែង៖ បន្ទប់ Fuluzu | ទីកន្លែង៖ សាលប្រជុំភូគីត្រា Grand Ballroom 2 | ទីកន្លែង៖ សាលប្រជុំភូគីត្រា១ ជាន់ទី២ |
| **ប្រធានដឹកនាំ៖ លោកជំទាវ ប្រាក់ ច័ន្ទណយ** រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគនាគមន៍ | **ប្រធានដឹកនាំ៖ លោក ប្រាក់ ថាវអាមិដា** អគ្គលេខាធិការរង MAFF | **ប្រធានដឹកនាំ៖ ឯ.ឧ. ឡេង ធនយុទ្ធា** អនុរដ្ឋលេខាធិការ MoPWT |
| អ្នកធ្វើបទបង្ហាញ៖ (២ x ១៥ នាទី) | អ្នកធ្វើបទបង្ហាញ៖ (២ x ១៥ នាទី) | អ្នកធ្វើបទបង្ហាញ៖ (២ x ១៥ នាទី) |
| ១. លោកស្រី ចេង ចិនណេត MoWA៖ ការបញ្ជ្រាបយេនឌ័រ | ១. លោក អ៊ុំ រីណា ប្រធានស្តីទី នាយកដ្ឋានឧតុនិយម | ១. លោក ច្រៀង ផល័គ្គ ប្រធាននាយកដ្ឋានផែនការ និងវិនិយោគ |

| | | |
|---|---|---|
| ទៅក្នុងការប្រែប្រួលអាកាសធាតុ<br>២. លោក ជួន វណ្ណា អនុប្រធានការិយាល័យកម្មវិធីសិក្សាវិទ្យាសាស្ត្រ MoEYS៖ ការអប់រំបរិស្ថាន និងការប្រែប្រួលអាកាសធាតុនៅកម្ពុជា | MoWRAM៖ ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យធនធានទឹក និង ឧតុនិយម<br>២. លោកបណ្ឌិត សរ ចិត្រា អនុប្រធាននាយកដ្ឋានផលិតកម្ម និងបសុព្យាបាល MAFF | MoPWT៖ ផែនការយុទ្ធសាស្ត្រជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ក្នុងវិស័យដឹកជញ្ជូន<br>២. លោក ស្រ៊ុន ពិទូ អនុប្រធាននាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ MRD៖ ផែនការសកម្មភាពប្រែប្រួលអាកាសធាតុក្នុងវិស័យដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ |
| **វាគ្មិន៖** | **វាគ្មិន៖** | **វាគ្មិន៖** |
| ១. កញ្ញា គង់ កែវសុគន្ធា មជ្ឈមណ្ឌលព័ត៌មានឯករាជ្យកម្ពុជា )CCIM(<br>២. លោក ស៊ូ សុជាតិ អ្នកសម្របសម្រួលបណ្តាញប្រែប្រួលអាកាសធាតុកម្ពុជា<br>៣. លោក គឹម សុបិន្ត ប្រធានមជ្ឈមណ្ឌលសិក្សាកសិកម្ម និងបរិស្ថាន នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម<br>៤. លោក Chris Eijkemans នាយកប្រចាំប្រទេសនៃអង្គការ Oxfam | ១. ឯ.ឧ. គល់ វឌ្ឍនា អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា<br>២. លោក ឈិត សំអាត នាយកប្រតិបត្តិនៃអង្គការ NGO Forum on Cambodia<br>៣. លោក Sakphouseth Meng មន្ត្រីតំណាងប្រចាំប្រទេសនៃមូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម (IFAD) | ១. លោក ហែម ចន្ទ មន្ត្រីគម្រោងជាន់ខ្ពស់ នៃធនាគារអភិវឌ្ឍន៍អាស៊ី )ADB(<br>២. លោក Uchida Togo ទីប្រឹក្សាគម្រោងផ្នែកបរិស្ថាន និងការប្រែប្រួលអាកាសធាតុនៃ JICA<br>៣. លោកបណ្ឌិត ហេង សុខបិល អ្នកស្រាវជ្រាវនៃដេប៉ាតឺម៉ង់សំណង់ស៊ីវិល សាស្ត្រាចារ្យ និងប្រធានផ្នែកស្ថាបត្យកម្មនៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា )ITC(<br>៤. លោកស្រី Nele Bünner តំណាងអង្គការ GIZ ទទួលបន្ទុកកម្មវិធីការពារអាកាសធាតុសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ |
| សំណួរ ចម្លើយ | សំណួរ ចម្លើយ | សំណួរ ចម្លើយ |
| ១១:៣០ - ១៣:៣០ | អាហារថ្ងៃត្រង់<br>ទីកន្លែង៖ La Coupole Restaurant នៃសណ្ឋាគារសូហ្វីតែល ភ្នំពេញភូគីត្រា | |
| ១៣:៣០ - ១៥:០០ | វគ្គស្របគ្នា (បន្ត) | |
| **វគ្គស្របគ្នាផ្នែកទី ២៖ ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ តាមវិស័យ** | | |

| | | |
|---|---|---|
| (ផ.យ.ប.អ. តាមវិស័យ) និងផែនការសកម្មភាព | | |
| **ក្រុមទី១៖ ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យសុខាភិបាល អនាម័យ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ** | **ក្រុមទី២៖ ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យព្រៃឈើ ជលផល និងប្រព័ន្ធអេកូឡូស៊ី** | **ក្រុមទី៣៖ ការកាត់បន្ថយការប្រែប្រួលអាកាសធាតុក្នុងវិស័យឧស្សាហកម្ម និងថាមពល** |
| ទីកន្លែង៖ បន្ទប់ Fuluzu | ទីកន្លែង៖ សាលប្រជុំភ្ញូគីត្រា Grand Ballroom 2 | ទីកន្លែង៖ សាលប្រជុំភ្ញូគីត្រា ១ ជាន់ទី២ |
| **ប្រធានដឹកនាំ៖ ឯ.ឧ.បណ្ឌិត ឡុញ ហ៊ាល** អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស MoE | **ប្រធានដឹកនាំ៖ ឯ.ឧ. ចាយ សាមិត្ត** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ MoE | **ប្រធានដឹកនាំ៖ ឯ.ឧ. សាត សាមី** រដ្ឋលេខាធិការ MIME |
| **អ្នកធ្វើបទបង្ហាញ៖ (២ x ១៥ នាទី)** | **អ្នកធ្វើបទបង្ហាញ៖ (៣ x ១០ នាទី)** | **អ្នកធ្វើបទបង្ហាញ៖ (២ x ១៥ នាទី)** |
| ១. វេជ្ជបណ្ឌិត កុល ហ៊ៅ អនុប្រធាននាយកដ្ឋាននៃ MoH៖ ផែនការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យសុខាភិបាល<br>២. ឯ.ឧ. វ័ត្ន វិរៈ សមាជិកក្រុមប្រឹក្សាអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ៖ គោលនយោបាយសន្តិសុខស្បៀង អាហារូបត្ថម្ភ និងការប្រែប្រួលអាកាសធាតុ | ១. លោក យុន វឌ្ឍនា (អនុប្រធានទទួលបន្ទុករូមការិយាល័យតណទានកាបូនព្រៃឈើ រដ្ឋបាលព្រៃឈើ៖ ការឆ្លើយតបការប្រែប្រួលអាកាសធាតុក្នុងវិស័យព្រៃឈើ<br>២. លោកស្រីបណ្ឌិត កៅ សុជីវី អនុប្រធានរដ្ឋបាលជលផល៖ ផែនការឆ្លើយតបការប្រែប្រួលអាកាសធាតុក្នុងវិស័យជលផល<br>៣. លោក អ៊ុក ណាវ៉ាន់ អគ្គនាយករងរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ៖ ការឆ្លើយតបការប្រែប្រួលអាកាសធាតុក្នុងប្រព័ន្ធអេកូឡូស៊ី | ១. ឯ.ឧ. ទឹង ស៊ីនី អនុរដ្ឋលេខាធិការ MIME៖ ផែនការប្រែប្រួលអាកាសធាតុក្នុងវិស័យឧស្សាហកម្ម និងថាមពល<br>២. លោក តូច សុវណ្ណា ប្រធាននាយកដ្ឋាន បច្ចេកទេសថាមពល៖ ផែនការប្រែប្រួលអាកាសធាតុក្នុងដំណើរការផលិតកម្មថាមពល |
| **វាគ្មិន៖** | **វាគ្មិន៖** | **វាគ្មិន៖** |
| ១. លោកបណ្ឌិត Iean Russell ប្រធានគម្រោង MALIS, FAO<br>២. លោក Steven Iddings ប្រធានក្រុមសុខភាពបរិស្ថាន | ១. លោកស្រី Sarah Sitts ប្រធានប្រចាំប្រទេសនៃអង្គការ PACT កម្ពុជា<br>២. លោក Peter Iversen អ្នក | ១. លោក ឈួង ហ៊្វឹងហ៊ិញ ក្រុមហ៊ុនខេ ស៊ីមែន<br>២. លោក Jeff Ospital នាយកប្រតិបត្តិនៃអង្គការ Nexus Carbon |

| | | |
|---|---|---|
| WHO<br>៣. លោកស្រី ជា អេលីយ៉ាន អនុប្រធានដេប៉ាតឺម៉ង់បរិស្ថាន RUPP<br>៤. លោក ហេង សុខ អ្នកឯកទេសអភិបាលកិច្ច និងកាត់បន្ថយគ្រោះមហន្តរាយនៃអង្គការ Plan International | ឯកទេសផ្នែកបច្ចេកទេសនៃ UN-REDD, FA<br>៣. លោកបណ្ឌិត Kien Tran-Mai មន្ត្រីកម្មវិធីគំនិតផ្តួចផ្តើមបន្សាំនឹងការប្រែប្រួលអាកាសធាតុ (CCAI/MRC)<br>៤. លោក Micah Ingalls នាយកស្តីទីប្រចាំប្រទេស នៃអង្គការ WWF | Development<br>៣. លោក Carlo Figa Talamanca នាយក SGFE និងជាប្រធាន EuroCham Green Business Committee |
| សំណួរ ចម្លើយ | សំណួរ ចម្លើយ | សំណួរ ចម្លើយ |
| ១៥:០០ - ១៥:២០ | សម្រាកពិសាអាហារសម្រន់ | |
| ១៥:២០ - ១៦:៥០ | វគ្គស្របគ្នា (បន្ត) | |
| **វគ្គស្របគ្នាផ្នែកទី ៣៖ ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ (ផ.យ.ប.អ. តាមវិស័យ) និងផែនការសកម្មភាព (បន្ត)** | | |
| **ក្រុមទី១៖ ការឆ្លើយតបការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងការគ្រប់គ្រងគ្រោះមហន្តរាយ** | **ក្រុមទី២៖ ការឆ្លើយតបការប្រែប្រួលអាកាសធាតុនៅតំបន់ឆ្នេរ និងទេសចរណ៍** | **ក្រុមទី៣៖ វឌ្ឍនភាពរបស់កម្ពុជាក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងដំណើរឆ្ពោះទៅកាន់សកម្មភាពជាតិសមស្របសម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (NAMA)** |
| ទីកន្លែង៖ សាលប្រជុំភ្នំគីត្រា Grand Ballroom 2 | ទីកន្លែង៖ សាលប្រជុំភ្នំគីត្រា១ ជាន់ទី២ | ទីកន្លែង៖ បន្ទប់ Fuluzu |
| **ប្រធានដឹកនាំ៖ ឯ.ឧ. សក់ សេដ្ឋា** រដ្ឋលេខាធិការ និងជាប្រធានលេខាធិការដ្ឋាន គ.ជ.ប.អ. MoI | **ប្រធានដឹកនាំ៖ ឯ.ឧ. ប៊ិន សម្បត្តិថាវ័ត្ន** រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | **ប្រធានដឹកនាំ៖ ឯ.ឧ. ជា សំអាង** អនុប្រធានរដ្ឋបាលព្រៃឈើ |
| អ្នកធ្វើបទបង្ហាញ៖ (២ x ១៥ នាទី) | អ្នកធ្វើបទបង្ហាញ៖ (២ x ១៥ នាទី) | អ្នកធ្វើបទបង្ហាញ៖ (៣ x ១០ នាទី) |
| ១. លោក គង់ ចាន់ថន ទីប្រឹក្សាផែនការប្រែប្រួលអាកាសធាតុនៃគ.ជ.អ.ប.៖ ការអនុវត្តផែនការសកម្មភាពប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិតាមរយៈអភិបាល | ១. លោក ប៊ូ ច័ន្ទសិរី អនុប្រធាននាយកដ្ឋានផែនការ និងអភិវឌ្ឍន៍ទេសចរណ៍ នៃក្រសួងទេសចរណ៍៖ បទពិសោធន៍ និងការរៀបចំផែនការប្រែប្រួលអាកាសធាតុក្នុងវិស័យ | ១. លោក Conrado Heruela ប្រធានគ្រប់គ្រងកិច្ចការសម្រាប់គម្រោងប្រែប្រួលអាកាសធាតុរបស់GEF នៃនាយកដ្ឋានបច្ចេកវិទ្យា ឧស្សាហកម្ម និងសេដ្ឋកិច្ច |

| | | |
|---|---|---|
| កិច្ចមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុ<br>២. លោក សុទ្ធ គឹមកុលមុនី អនុប្រធាននាយកដ្ឋានត្រៀមរៀបចំ និងបណ្តុះបណ្តាលនៃ CNMC៖ ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុសម្រាប់គ្រប់គ្រងគ្រោះមហន្តរាយ | ទេសចរណ៍<br>២. ឯ.ឧ. បណ្ឌិត វ៉ាន់ មុនីនាថ អគ្គនាយករងនៃអគ្គនាយកដ្ឋានបច្ចេកទេសនៃ MoE និងជាអគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិសម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ឆ្នេរ៖ បទពិសោធន៍ និងផែនការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់គ្រប់គ្រងតំបន់ឆ្នេរ | ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិកនៃអង្គការ UNEP៖ គំនិតផ្តួចផ្តើមសម្រាប់ការរៀបចំផែនការ NAMA<br>២. លោកស្រី Akiko Fukui ជំនួយការអ្នកស្រាវជ្រាវក្រុមយន្តការទីផ្សារកាបូនរបស់ IGES<br>៣. លោក អ៊ុយ កាម៉ាល អនុប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ MoE ៖ មេរៀនទទួលបានរបស់កម្ពុជា និងដំណើរឆ្ពោះទៅកាន់ NAMA |
| **វាគ្មិន៖** | **វាគ្មិន៖** | **វាគ្មិន៖** |
| ១. លោក ហុក គឹមធូន ប្រធានគ្រប់គ្រងគម្រោងថ្នាក់ជាតិនៃ NAPA Follow-Up<br>២. លោកស្រី Sanna Salmela-Eckstein, Regional DM Delegate, Asia, Finnish Red Cross<br>៣. លោក គឹម រតនា នាយកប្រតិបត្តិអង្គការការីតាសកម្ពុជា<br>៤. លោក Julian Abrams អ្នកសម្របសម្រួលបច្ចេកទេសនៃអង្គការ UNCDF-LoCAL | ១. លោកបណ្ឌិត នេត បារមី ប្រធានដេប៉ាតឺម៉ង់ទេសចរណ៍នៃ RUPP<br>២. លោក គង់ គឹមស្រេង មន្ត្រីកម្មវិធីជាន់ខ្ពស់នៃអង្គការ IUCN កម្ពុជា<br>៣. លោក វ៉ា មឿន នាយកប្រតិបត្តិអង្គការម្លប់បៃតង | ១. លោក វន់ វណ្ណារិទ្ធ ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍បៃតង MoE<br>២. លោក Alex Diment ទីប្រឹក្សាបច្ចេកទេសជាន់ខ្ពស់នៃអង្គការ WCS<br>៣. លោក មៅ វិសាល ប្រធានការិយាល័យសង្គមបរិស្ថាន និងទំនាក់ទំនងសាធារណៈ នៃអគ្គិសនីកម្ពុជា |
| សំណួរ ចម្លើយ | សំណួរ ចម្លើយ | សំណួរ ចម្លើយ |
| ១៦:៤០ - ១៦:៥០ សង្ខេប និងបិទកិច្ចពិភាក្សា | ១៦:៤០ - ១៦:៥០ សង្ខេប និងបិទកិច្ចពិភាក្សា | ១៦:៤០ - ១៦:៥០ សង្ខេប និងបិទកិច្ចពិភាក្សា |

| **ថ្ងៃទី ៣** | **ថ្ងៃព្រហស្បតិ៍ ទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៣** |
|---|---|
| ០៧:៣០ - ០៨:៣០ | ការចុះឈ្មោះ<br>ទីកន្លែង៖ សណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា |
| ០៨:៣០ - ០៨:៥០ | ចាប់ផ្តើមកម្មវិធី<br>សុន្ទរកថាស្វាគមន៍របស់ ឯកឧត្តម រស់ សីលវ៉ា អនុរដ្ឋលេខាធិការក្រសួង |

| | |
|---|---|
| | សេដ្ឋកិច្ច និងហិរញ្ញវត្ថុសុន្ទរកថាស្វាគមន៍របស់លោក Peter Brimble នាយករងប្រចាំប្រទេស នៃធនាគារអភិវឌ្ឍន៍អាស៊ី )ADB) |
| ០៨:៥០ - ០៩:០០ | សេចក្តីសង្ខេបលទ្ធផលថ្ងៃទី២<br>ប្រកាសរបៀបវារៈថ្ងៃទី៣ |
| ០៩:០០ - ១២:១៥ | ប្រធានដឹកនាំ៖ ឯ.ឧ. សុខ ចិន្តាសោភា រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| ០៩:០០ - ៩:២០ | **ក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុអន្តរជាតិ**<br>គោលបំណង៖ ធ្វើសេចក្តីសង្ខេបអំពីការអភិវឌ្ឍចុងក្រោយនៃយន្តការផ្តល់ហិរញ្ញប្បទានសាកល។<br>អ្នកធ្វើបទបង្ហាញ៖ លោកស្រី Joanne Manda អ្នកឯកទេសហិរញ្ញប្បទានប្រែប្រួលអាកាសធាតុនៃអង្គការ UNDP ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក (២០ នាទី) |
| ០៩:២០ - ៩:៤០ | សម្រាកពិសាអាហារសម្រន់ |
| ៩:៤០ - ១០:៥០ | **ក្របខ័ណ្ឌហិរញ្ញប្បទានជាតិការប្រែប្រួលអាកាសធាតុ**<br>គោលបំណង៖ ធ្វើការវិភាគលើស្ថានភាពហិរញ្ញប្បទាននាពេលបច្ចុប្បន្ន មេរៀនទទួលបានពីមូលនិធិ CCCA កម្ពុជា និងផ្តល់អនុសាសន៍សម្រាប់យន្តការហិរញ្ញប្បទាននាពេលអនាគត។<br>អ្នកធ្វើបទបង្ហាញ៖ លោកបណ្ឌិត តូច ច័ន្ទក្រឹស្នា ប្រធានការិយាល័យធនាគារពិភពលោកនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០នាទី) |
| វាគ្មិន៖ | ១. លោក Koen Everaert មន្ត្រីទំនាក់ទំនងសហប្រតិបត្តិការនៃតំណាងសហភាពអឺរ៉ុបប្រចាំកម្ពុជា<br>២. លោក Julien Chevillard មន្ត្រីរដ្ឋបាលមូលនិធិ CCCA នៃលេខាធិការដ្ឋានមូលនិធិ CCCA/UNDP<br>៣. លោកបណ្ឌិត ទិន ពន្លក អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ និងជាប្រធានលេខាធិការដ្ឋានមូលនិធិ CCCA នៃក្រសួងបរិស្ថាន |
| សំណួរ ចម្លើយ (៣០ នាទី) | |
| ១០:៥០ - ១២:០០ | ប្រធានដឹកនាំ៖ ឯ.ឧ. សុខ ចិន្តាសោភា រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>ការឆ្លើយតបការប្រែប្រួលអាកាសធាតុថ្នាក់តំបន់ផ្តោតលើទិដ្ឋភាពទូទៅនៃគម្រោងគំនិតផ្តួចផ្តើមបន្សាំនឹងការប្រែប្រួលអាកាសធាតុ (CCAI)<br>**វគ្គពេញអង្គ៖ កិច្ចសហប្រតិបត្តិការអន្តរជាតិ** |
| | **ការឆ្លើយតបការប្រែប្រួលអាកាសធាតុថ្នាក់តំបន់ផ្តោតលើទិដ្ឋភាពទូទៅនៃគម្រោងគំនិតផ្តួចផ្តើមបន្សាំនឹងការប្រែប្រួលអាកាសធាតុ (CCAI)**<br>គោលបំណង៖ បង្ហាញពីគំរូនៃសកម្មភាពដែលបានផ្តួចផ្តើមក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុអន្តរប្រទេស នៅក្នុងតំបន់អាងទន្លេ |

| | |
|---|---|
| | មេគង្គ។<br>អ្នកធ្វើបទបង្ហាញ៖ លោក នួន វណ្ណា មន្ត្រីបច្ចេកទេសគម្រោង CCAI នាយកដ្ឋានបរិស្ថាននៃគណៈកម្មការទន្លេមេគង្គ (២០នាទី) |
| វាគ្មិន៖ | ១. លោកបណ្ឌិត Pradeep Kurukulasuriya ទីប្រឹក្សាបច្ចេកទេសជាន់ខ្ពស់ ផ្នែកបន្សាំនឹងការប្រែប្រួលអាកាសធាតុ នៃអង្គការ UNDP ប្រចាំតំបន់ អាស៊ីប៉ាស៊ីហ្វិក<br>២. លោក Conrado Heruela ប្រធានគ្រប់គ្រងកិច្ចការសម្រាប់គម្រោងប្រែប្រួលអាកាសធាតុរបស់ GEF នៃនាយកដ្ឋានបច្ចេកវិទ្យា ឧស្សាហកម្ម និងសេដ្ឋកិច្ចថ្នាក់តំបន់នៅអាស៊ី និងប៉ាស៊ីហ្វិក នៃអង្គការ UNEP<br>៣. លោក Peter Brimble នាយករងប្រចាំប្រទេស ADB |
| សំណួរចម្លើយ (៣០ នាទី) | |
| ១២:០០ - ១៣:៣០ | អាហារថ្ងៃត្រង់<br><u>ទីកន្លែង៖</u> La Coupole Restaurant សណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា |
| ១៣:៣០ -១៤:៣០ | ប្រធានដឹកនាំ៖ លោកបណ្ឌិត ទិន ពន្លក អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ និងជាប្រធានលេខាធិការដ្ឋានមូលនិធិ CCCA នៃក្រសួងបរិស្ថាន<br>វគ្គពេញអង្គ៖ គោលជំហររបស់ប្រទេសកម្ពុជា ក្នុងសន្និសីទកំពូលលើកទី ១៩ នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |
| | **បច្ចុប្បន្នភាពចុងក្រោយនៃកិច្ចចរចា UNFCCC**<br>គោលបំណង៖ បង្ហាញជូននូវការវិវឌ្ឍចុងក្រោយនៃកិច្ចចរចាការប្រែប្រួលអាកាសធាតុ បញ្ហាចម្បងៗ ដែលនឹងត្រូវលើកយកមកពិភាក្សាក្នុងសន្និសីទកំពូលលើកទី១៩ នៅទីក្រុងវ៉ាស្សូវី ប្រទេសប៉ូឡូញ។<br>អ្នកធ្វើបទបង្ហាញ៖ លោក ស៊ុំ ធី ប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ ក្រសួងបរិស្ថាន (២០នាទី) |
| | **សេចក្តីព្រាងគោលជំហររបស់ប្រទេសកម្ពុជា និងដំណើរឆ្ពោះទៅមុខ**<br>គោលបំណង៖ សង្ខេបអំពីគោលជំហររបស់ប្រទេសកម្ពុជាសម្រាប់សន្និសីទកំពូលលើកទី១៩ និងប្រមូលមតិយោបល់ពីអង្គវេទិកាទាំងមូល។<br>អ្នកធ្វើបទបង្ហាញ៖ លោក ជា ចន្ទន៍ធូ អនុប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ ក្រសួងបរិស្ថាន (២០នាទី) |
| | **សំណួរ ចម្លើយ (៣០នាទី)** |
| ១៤:៣០ - ១៥:០០ | សម្រាកពិសាអាហារសម្រន់ |
| ១៥:០០ - ១៥:៣០ | សេចក្តីសង្ខេបដំណើរការវេទិការយៈពេល២ ថ្ងៃ |
| ១៥:៣០ - ១៥:៤៥ | សុន្ទរកថាបិទរបស់ ឯកឧត្តម សាបូ អូហ្សាណា រដ្ឋលេខាធិការ ក្រសួងបរិស្ថាន<br>គោរពភ្លេងជាតិ៕ |

# ឧបសម្ព័ន្ធទី២៖ សុន្ទរកថាបិទ និងបើកវេទិកា

## ថ្ងៃទី១៖ ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៣

## សុន្ទរកថាបើកវេទិកា

ថ្លែងដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិជាទីមេត្រី!**

ថ្ងៃនេះខ្ញុំមានសេចក្តីរីករាយ ដោយបានមកចូលរួមនៅក្នុងពិធីបើក «***វេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ***» នាឱកាសនេះ។ វេទិកាជាតិនេះបានប្រារព្ធឡើងតែមួយសប្តាហ៍មុនសម័យប្រជុំលើកទី១៩ នៃសន្និសីទភាគីជាសមាជិកអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងសម័យប្រជុំលើកទី៩ របស់ភាគីជាសមាជិក **ពិធីសារក្យូតូ** ដែលនឹងប្រព្រឹត្តទៅនៅ **ទីក្រុងវ៉ាសូវី ប្រទេសប៉ូឡូញ**។ ក្នុងន័យនេះពិតជាមិនអាចប្រកែកបានទេថា វេទិកាដែលបានរៀបចំឡើងនាពេលនេះនឹងក្លាយជាធាតុចូលមួយយ៉ាងសំខាន់ ដល់កិច្ចប្រជុំដែលនឹងត្រូវប្រារព្ធឡើងនាពេលខាងមុខ។ ទន្ទឹមនេះ យើងទាំងអស់គ្នាក៏ចាំបាច់ត្រូវបន្តយល់បន្ថែមទៀតពីបញ្ហានានាដែលកំពុងកើតមានឡើង ដោយសារការប្រែប្រួលគុណភាពបរិស្ថានជាអាទិ៍រួមមាន: ការកើនឡើងកម្តៅភពផែនដី, បាតុភូតគ្រោះធម្មជាតិ, គ្រោះរាំងស្ងួត, គ្រោះទឹកជំនន់, ខ្យល់ព្យុះសង្ឃរា, ការខូចខាតប្រពន្ធ័អេកូឡូស៊ី, ការបាត់បង់ជីវៈចម្រុះ, ការកើនឡើងជំងឺដង្កាត់ប្លែកៗ បំផ្លាញជីវិតមនុស្ស សត្វ ដែលបញ្ហាទាំងនេះមិនត្រឹមតែជះឥទ្ធិពលជាអវិជ្ជមានដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ះពាល់ដល់សុវត្ថិភាព និងសុខុមាលភាពសាធារណៈទៀតផង។

ឆ្លៀតឱកាសនេះ ក្នុងនាមរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងបរិស្ថាន, ក្រសួង-ស្ថាប័ន, អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់, អង្គការជាតិ-អន្តរជាតិ, វិស័យឯកជន, ព្រះសង្ឃ, ប្រជាពលរដ្ឋ និងសិស្សានុសិស្ស និស្សិតគ្រប់ភូមិសិក្សាដែលបានខិតខំប្រឹងប្រែងបំពេញការងារយ៉ាងសស្រាក់សស្រាំ, ពុះពាររួមគ្នាយ៉ាងសកម្មនៅក្នុងយុទ្ធនាការ និងសកម្មភាពទាំងឡាយដើម្បីគោលដៅនៃការការពារបរិស្ថានក្នុងរយៈពេលកន្លងមក ហើយខ្ញុំសង្ឃឹមថា យើងនឹងបន្តកិច្ចខិតខំប្រឹងប្រែងលើការងារនេះទៀត សម្រាប់ពេលអនាគតខាងមុខនេះ។ ជាការពិត កិច្ចខិតខំប្រឹងប្រែងនេះនឹងបន្តរួមចំណែកពង្រឹងថែមទៀតនូវឆន្ទះរបស់យើង និងប្រជាជននៅលើភពផែនដីទាំងមូលក្នុងបុព្វហេតុចូលរួមបង្ការ និងទប់ស្កាត់ព្រោះមហន្តរាយនានាឱ្យប្រកបដោយប្រសិទ្ធភាពខ្ពស់ និងធានានូវភាពសុខដុមរមនានៃការរស់នៅរបស់មនុស្សជាមួយនឹងបរិស្ថានបានយ៉ាងប្រសើរ។

ក្នុងឱកាសនេះ ខ្ញុំក៏សូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះអ្នកចូលរួមទាំងអស់ ទាំងភ្ញៀវជាតិ និងអន្តរជាតិដែលជាតំណាងក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ តំណាងអង្គទូតនានា ប្រចាំ

នៅព្រះរាជាណាចក្រកម្ពុជា, វិស័យឯកជន, គ្រឹះស្ថានសិក្សា, អង្គការសង្គមស៊ីវិល និងអ្នកចូលរួមទាំងអស់នៅក្នុង **«វេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ»** នេះ។

ជារួម **«វេទិកាជាតិស្តីពីការប្រែប្រួលអាសកាសធាតុ»** ត្រូវបានរៀបចំឡើងដោយទៀងទាត់ និងក្លាយជាព្រឹត្តិការណ៍សំខាន់ដែលផ្តល់ឱកាសឱ្យអ្នករៀបចំគោលនយោបាយ, អ្នកវិទ្យាសាស្ត្រ, ដៃគូអភិវឌ្ឍន៍ និងប្រតិបត្តិករនានាមកជួបជុំគ្នា ដើម្បីបង្ហាញពីចំណេះដឹងថ្មីៗបំផុតអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅកម្ពុជា ហើយចែករំលែកបទពិសោធន៍នៃផលប៉ះពាល់ទាំងនោះក្នុងគោលបំណងរួមចំណែកដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ដើម្បីសម្រេចគោលដៅអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់យើងនៅក្នុងបរិការណ៍នៃការប្រែប្រួលអាកាធាតុនេះ។ ជាក់ស្តែង វេទិកានេះនឹងផ្តល់លទ្ធភាពឱ្យយើងរួមគ្នាបន្តពិនិត្យមើលវឌ្ឍនភាព ដែលយើងសម្រេចបានចាប់តាំងពីវេទិកាជាតិលើកទី២ កាលពីឆ្នាំ ២០១១ មកទល់បច្ចុប្បន្ននេះ និងដើម្បីរួមចំណែកក្នុងការពិភាក្សាអំពីកិច្ចការជាអាទិភាពលើការប្រែប្រួលអាកាសធាតុនៅកម្ពុជាសម្រាប់រយៈពេលពី ៥ទៅ ១០ ឆ្នាំខាងមុខទៀត។

ជាការពិតការប្រែប្រួលអាកាសធាតុលែងជាអ្វីដែលស្ថិតនៅឆ្ងាយពីយើងទៀតហើយ ហើយកំពុងបន្តឥទ្ធិពលមកលើយើងទាំងអស់គ្នាក្នុងពេលបច្ចុប្បន្ន និងជាបញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាធំៗបំផុតដែលមនុស្សជាតិត្រូវប្រឈមនៅក្នុងសតវត្សរ៍ទី២១នេះ ដោយសារតែផលប៉ះពាល់កាន់តែធ្ងន់ធ្ងរឡើង ហើយមានវិសាលភាពកាន់តែធំជាងមុន។ បើពិនិត្យតាមរបបគំហើញពីការស្រាវជ្រាវថ្មីៗ បានអះអាងយ៉ាងច្បាស់លាស់អំពីកំណើននៃផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុគឺកាន់តែខ្លាំងក្លា និងញឹកញាប់ជាងមុន ខណៈដែលកំណើននៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់បានបន្តធ្វើអោយសីតុណ្ហភាពមធ្យមលើពិភពលោកកើនឡើងជាខ្លាំង។ ជាក់ស្តែងក្នុងឆ្នាំនេះ ពិភពលោកត្រូវបានគេសង្កេតឃើញថា កំហាប់ឧស្ម័នកាបូនិចក្នុងបរិយាកាសកើនដល់ **៤០០ភាគលាន** ដែលជាកម្រិតខ្ពស់បំផុតលើកដំបូង គិតចាប់តាំងពីពេលមានការវាស់ដោយប្រើប្រាស់ឧបករណ៍ទំនើបមក។ នៅចំពោះមុខកំហាប់ឧស្ម័នកាបូនិចក្នុងបរិយាកាសកម្រិតខ្ពស់បំផុតជាប្រវត្តិសាស្ត្រនេះបានបង្ហាញថា យើងកំពុងឈានចូលទៅក្នុងស្ថានភាពមួយប្រកបដោយគ្រោះថ្នាក់។ ក្នុងនោះ តំបន់អាស៊ីប៉ាស៊ីហ្វិចបានពើបប្រទះនូវនិន្នាការដែលត្រូវប្រកាសអាសន្ននៃទឹកជំនន់, គ្រោះរាំងស្ងួត និងព្រឹត្តិការណ៍អាកាសធាតុមិនប្រក្រតី ដែលកើតមានកាន់តែញឹកញាប់ និងធ្ងន់ធ្ងរជាងមុន ជាពិសេសក្នុងអំឡុងពេលនៃទសវត្សរ៍ចុងក្រោយនេះ។ លើសពីនេះទៀត ភាពងាយរងគ្រោះនៃទឹកជំនន់នៅអាស៊ីនឹងបន្តកើនឡើង ហើយរហូតដល់ឆ្នាំ២០២៥ ប្រជាជនច្រើនជាង៤១០លាននាក់ ដែលតំណាងឱ្យលើសពី ៨៥% នៃសេដ្ឋកិច្ចពិភពលោកត្រូវប្រឈមនឹងហានិភ័យនៃការជន់លិចនៅតាមតំបន់ឆ្នេរ ដោយសារប្រឈមនឹងផលប៉ះពាល់នៃព្យុះស៊ីក្លូន និងតំបន់ទំនាបលិចទឹកដែលងាយពើបប្រទះនឹងព្យុះទីហ្វុង។ គ្រោះមហន្តរាយជាញឹកញាប់ទាំងនេះរួមផ្សំជាមួយឥទ្ធិពលដទៃទៀត ដែលបណ្តាលពីការប្រែប្រួលអាកាសធាតុដូចជា ការជ្រាបចូលនៃទឹកប្រៃនៅតាមតំបន់ឆ្នេរ ឬផលប៉ះពាល់បណ្តាលពីសត្វចង្រៃ និងការរាតត្បាតនៃជំងឺបានធ្វើឱ្យការប្រែប្រួលអាកាសធាតុក្លាយជាបញ្ហាប្រឈម ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ជាបន្ទាន់។ ទន្ទឹមនេះ ទឹកជំនន់នាពេលថ្មីៗនេះនៅកម្ពុជាក៏បានបង្កឱ្យមានការបាត់បង់អាយុជីវិតមនុស្ស, ផលប៉ះពាល់ដល់ដំណាំកសិកម្ម, ហេដ្ឋារចនាសម្ព័ន្ធ និងការចិញ្ចឹម

ជីវិតរបស់ប្រជាជននៅសហគមន៍ ដែលបញ្ហានេះជាភស្តុតាងថ្មីបន្ថែមទៀតបង្ហាញពីសញ្ញាបន្ទាន់ និងភាពធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុនេះ។

ដោយសារផលប៉ះពាល់ទាំងនេះ យើងអាចនិយាយបានមួយបែបទៀតថា **"ការប្រែប្រួលអាកាសធាតុបានក្លាយជាបញ្ហាប្រឈមជាយុទ្ធសាស្ត្រមួយក្នុងការអភិវឌ្ឍ ហើយទាមទារឱ្យមានការយកចិត្តទុកដាក់រួមគ្នាជាបន្ទាន់"**។ ហើយរឹតតែសំខាន់ជាងនេះទៅទៀត **"បញ្ហានេះ តម្រូវអោយយើងត្រូវរួមគ្នាធ្វើសកម្មភាពជាបន្ទាន់ ក្នុងការកសាងគោលនយោបាយអាកាសធាតុសមស្របមួយ សម្រាប់ឆ្លើយតបទាំងក្នុងកម្រិតមូលដ្ឋាន កម្រិតតំបន់ និងកម្រិតពិភពលោក"**។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី!**

ជារួម យើងទាំងអស់គ្នាបានដឹងហើយថា ការប្រែប្រួលបរិស្ថានភពផែនដី ជាបញ្ហាដែលកើតមានយ៉ាងពិតប្រាកដ ហើយយើងមិនអាចបដិសេធ ឬនៅតែធ្វើមិនដឹងមិនឮ និងមិនអើពើបានទេ។ ជាក់ស្តែង ការគ្រប់គ្រងបរិស្ថាន និងការប្រែប្រួលអាកាសធាតុបានក្លាយជាបញ្ហាប្រឈមមួយទៀតសម្រាប់ចីរភាពនៃកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គមកម្ពុជា ក្នុងនោះមានការបញ្ចេញចោលយ៉ាងសន្ធឹកសន្ធាប់នូវឧស្ម័នផ្ទះកញ្ចក់ ជាពិសេសឧស្ម័នកាបូនិចដោយសារសម្ពាធពីកំណើនប្រជាជន, ចរន្តនគរូបនីយកម្ម, វិបុលកម្ម និងប្រពលកម្មកសិកម្ម ក៏ដូចជាការអភិវឌ្ឍវិស័យដឹកជញ្ជូន, ថាមពល និងវិស័យដទៃទៀត។ ជាការពិតបញ្ហានេះមិនមែនយើងទើបតែយកចិត្តក្នុងពេលនេះនោះទេ ជាក់ស្តែងយើងបានធ្វើកិច្ចការច្រើនណាស់ហើយនាពេលនេះ។ ក្នុងពេលនោះយើងបានអនុវត្តនូវអនុសាស្ត្រនានាពីវេទិកាជាតិលើកទី២ ស្តីពីការប្រែប្រួលអាកាសធាតុដែលបានរៀបចំឡើងកាលពីឆ្នាំ ២០១១ ដែលសកម្មភាពនេះគឺជាភស្តុតាងបញ្ជាក់ពីការប្តេជ្ញារបស់កម្ពុជាក្នុងការដោះស្រាយបញ្ហាប្រឈមនានា ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។

តាមរយៈនេះ កម្ពុជាក៏បានកសាងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុដែលជាកិច្ចការសំខាន់បំផុត ក្នុងការពង្រឹងសមត្ថភាពស្ថាប័ន និងសមត្ថភាពបច្ចេកទេសអន្តរវិស័យ ព្រមទាំងពហុជំនាញចាំបាច់ សម្រាប់កំណត់វិធានការក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ទន្ទឹមនេះកម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងការចរចារអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុនៅគ្រប់លំដាប់ថ្នាក់ ហើយបានរួមចំណែកយ៉ាងសកម្មនៅក្នុងកិច្ចប្រឹងប្រែងទាំងនៅក្នុងថ្នាក់តំបន់ និងអន្តរជាតិសម្រាប់ដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុនេះ។ ជាមួយគ្នានេះ យើងបានបង្កើតស្ថាប័ន និងវិធានការនានា រួមមានការបង្កើតគណៈកម្មការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ, ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិជាដើម។ កិច្ចការទាំងនេះជាជំហានដ៏សំខាន់មួយ ហើយកម្ពុជានឹងបន្តដាក់បញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** និងក្នុង**គោលដៅអភិវឌ្ឍន៍សហវត្សរ៍នៅកម្ពុជាក្រោយឆ្នាំ២០១៥** ព្រមទាំងសមាហរណកម្មការងារនេះទៅក្នុងផែនការអភិវឌ្ឍន៍តាមវិស័យរបស់ក្រសួងនានាផងដែរ។

ចំពោះមុខនេះ កម្ពុជាក៏បានដាក់ចេញវិធានការ និងសកម្មភាពជាក់លាក់ដែលទាក់ទងនឹងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ, ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការ

អភិវឌ្ឍបៃតង ដែលការងារនេះបានឆ្លុះបញ្ចាំងក្នុង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៣** របស់រាជរដ្ឋាភិបាល។ ជាក់ស្តែងយើងបាន និងកំពុងជំរុញអនុវត្តកិច្ចសហប្រតិបត្តិការជាមួយតួអង្គអភិវឌ្ឍន៍ពាក់ពន្ធ័ក្នុងក្របខណ្ឌ **"គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង"** និង **"ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ ២០១៣-២០៣០"** តាមរយៈការអភិវឌ្ឍក្របខណ្ឌគតិយុត្ត និងយន្តការសម្រាប់ការធ្វើពាណិជ្ជកម្មកាបូន, ការពង្រឹងសមត្ថភាព, ការរៀបចំ និងអនុវត្តវិធានការសម្រាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ, ការសិក្សាពីលទ្ធភាពក្នុងការប្រើប្រាស់យន្តការហិរញ្ញប្បទានផ្នែកបរិស្ថានដូចជា ការទូទាត់កម្រៃបរិស្ថាន និងមូលនិធិបរិស្ថាន, ការពង្រឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិរួមទាំងជីវៈចម្រុះ, តំបន់ផ្ទៃរងទឹកភ្លៀង និងតំបន់ដីសើម ព្រមទាំងការពង្រឹងយន្តការតាមដាន និងត្រួតពិនិត្យបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ីទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ក្នុងស្មារតីលើកកម្ពស់អនុវត្តការងារនេះឱ្យកាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងកាន់តែស៊ីជម្រៅ ខ្ញុំសូមជំរុញឱ្យក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ទាំងអស់ ធ្វើការពិចារណាជាលក្ខណៈប្រពន្ធ័អំពីការងារប្រែប្រួលអាកាសធាតុនៅពេលលើកផែនការអន្តរាគមន៍លើការងារអភិវឌ្ឍ ដើម្បីធានាថាការចំណាយវិនិយោគនានាមានប្រសិទ្ធភាព និងផ្តល់ផលក្នុងបរិការណ៍នៃការប្រែប្រួលអាកាសធាតុនេះ។ ក្នុងនោះយើងត្រូវផ្តោតការយកចិត្តទុកដាក់ឱ្យខ្លាំងថែមទៀតលើការប្រើប្រាស់ប្រភពថាមពលកកើតឡើងវិញ ដូចជាថាមពលវារីអគ្គិសនី, សំណល់កម្តៅពីឧស្សាហកម្ម, សំណល់ពីកសិកម្ម និងសំណល់ពីការចញ្ចឹមសត្វជាដើម។ ទន្ទឹមនេះ យើងក៏ត្រូវបន្តអនុវត្តនូវគំនិតផ្តួចផ្តើមការអភិវឌ្ឍបៃតងជាតិនៅកម្ពុជា ដើម្បីគាំទ្របន្ថែមទៀតដល់ការអភិវឌ្ឍប្រកបដោយចីរភាព។ ក្នុងនោះដែរ យើងត្រូវបន្តយកចិត្តទុកដាក់លើការអនុវត្តបណ្តាគម្រោងយន្តការអភិវឌ្ឍស្អាត, ការជំរុញយុទ្ធនាការសន្សំសំចៃថាមពលអគ្គិសនី និងប្រេងឥន្ធនៈ, សកម្មភាពការពារ និងអភិរក្សព្រៃឈើនៅក្នុងតំបន់ការពារធម្មជាតិ, ព្រៃបម្រុង និងព្រៃការពារជាដើម។

ម្យ៉ាងទៀតខ្ញុំយល់ថា ការអនុវត្តកម្មវិធីយល់ដឹងជាសាធារណៈអំពីការប្រែប្រួលអាកាសធាតុ និងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ក៏មានសារៈសំខាន់ណាស់ដែរ ដើម្បីលើកទឹកចិត្តឱ្យមានការរួមចំណែកទាំងអស់គ្នា។ ដូច្នេះ ដើម្បីសម្រេចការងារនេះបាន ទាមទារឱ្យមានកិច្ចសហការជិតស្និទ្ធរវាងសាកលវិទ្យាល័យ, មជ្ឈមណ្ឌលស្រាវជ្រាវ, ក្រសួង-ស្ថាប័ននានានៃរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ក្នុងការដាក់បញ្ច្រាបការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីសិក្សា និងកម្មវិធីស្រាវជ្រាវ ហើយបង្កើតនូវយន្តការនានាសម្រាប់ផ្លាស់ប្តូរចំណេះដឹងទាំងអស់នោះ ដែលជាមូលដ្ឋានសំខាន់ដល់ការរៀបចំគោលនយោបាយ។ ប្រការនេះនឹងជួយធានាបានថា គោលនយោបាយ និងផែនការការងារប្រែប្រួលអាកាសធាតុរបស់យើងនឹងត្រូវបានកសាងឡើង និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់ដោយផ្អែកលើចំណេះដឹងដែលមាន និងលទ្ធផលនៃការស្រាវជ្រាវមួយដែលអាចទុកចិត្តបាន។

ក្នុងន័យនេះខ្ញុំសូមស្នើឱ្យក្រសួងអប់រំ យុវជន និងកីឡា គួរពិនិត្យពិចារណាដាក់បញ្ចូលមុខវិជ្ជាការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីអប់រំ និងបណ្តុះបណ្តាលនានា ទាំងកម្មវិធីសិក្សាក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងបន្តបង្កើតបរិយាកាសអំណោយផល និងលើកទឹកចិត្តសម្រាប់ការចូលរួមរបស់វិស័យឯកជន នៅក្នុងការវិនិយោគដែលនឹងជួយដោះស្រាយ

ដល់ការងារប្រែប្រួលអាកាសធាតុទាំងលើវិធានការបន្សាំ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ជាដើម។

ប្រការសំខាន់មួយទៀត ដែលត្រូវផ្ដោតការយកចិត្តទុកដាក់ គឺនៅពេលដែលកម្រិតហិរញ្ញប្បទានកើនឡើង ចំនួនច្រើននៃវិធីសាស្ត្រ និងមធ្យោបាយផ្ដល់ខុសៗគ្នានឹងបង្កើតឱ្យមានចំណាយពាក់ព័ន្ធខ្ពស់ ក៏ដូចជាភាពខ្វះចន្លោះ និងភាពត្រួតលើគ្នា ដែលធ្វើឱ្យកិច្ចខិតខំប្រឹងប្រែងរបស់យើងក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ មានប្រសិទ្ធភាពទាប និងផ្ដល់ផលកម្រិតទាប។ ដូច្នេះ ដើម្បីឱ្យវិធានការរបស់យើងក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុផ្ដល់លទ្ធផលជាទ្រង់ទ្រាយធំទៅតាមការរំពឹងទុកនោះ ចាំបាច់ត្រូវឈានជាបណ្ដើរៗចេញពីគំរូនៃការអនុវត្តគម្រោងដាច់ដោយឡែកពីគ្នា ទៅរកអភិក្រមកម្មវិធី, ការប្រមូលផ្ដុំមូលនិធិ និងទីបំផុតគឺការគាំទ្រថវិកា។ ក្នុងស្មារតីនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ត្រូវសហការគ្នាជិតស្និទ្ធជាមួយគណៈកម្មការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ដើម្បីរៀបចំនូវវិធានការដែលងាកចេញពីគម្រោងដែលមានលក្ខណៈដាច់ពីគ្នា និងការកសាងផែនការប្រែប្រួលអាកាសធាតុដាច់ដោយឡែកពីគ្នា ទៅរកសមាហរណកម្មការងារប្រែប្រួលអាកាសធាតុ ក្នុងដំណើរការថវិកា និងការកសាងផែនការជាទៀងទាត់របស់យើង។ ជាមួយនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក៏មានតួនាទីគន្លឹះក្នុងការចរចារជាមួយម្ចាស់ជំនួយនីមួយៗ ដើម្បីធានាថាកម្មវិធីរបស់ដៃគូអភិវឌ្ឍន៍នានាត្រូវបានពិនិត្យជាលក្ខណៈប្រព័ន្ធនៅក្នុងក្របខ័ណ្ឌនៃការប្រែប្រួលអាកាសធាតុ ហើយការពិចារណាអំពីការប្រែប្រួលអាកាសធាតុត្រូវតែបានដាក់បញ្ចូលទៅក្នុងកម្មវិធីទាំងនោះ នៅក្នុងករណីដែលមានការពាក់ព័ន្ធ។

ជាមួយគ្នានេះ គណៈកម្មធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងលេខាធិការនៃគណៈកម្មធិការនេះត្រូវមានភារកិច្ចកៀរគរ និងសម្របសម្រួលភាពជាដៃគូសម្រាប់ការអនុវត្តវិធានការឆ្លើយតបនឹងប្រែប្រួលអាកាសធាតុនេះឱ្យកាន់តែសកម្មភ្លៀវក្លាថែមទៀត។ ជារួម គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ មិនត្រឹមតែដើរតួជាអ្នកផ្ដល់យោបល់លើការងារអន្តរវិស័យក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែគឺជាអ្នកសម្របសម្រួលភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធពីខាងក្រៅ និងពិនិត្យ តាមដាន និងវាយតម្លៃអំពីការប្រែប្រួលអាកាសធាតុទៀតផង។ ក្នុងអនាគតដ៏ខ្លីខាងមុខនេះ សម្រាប់លេខាធិការដ្ឋាននៃគណៈគម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការចុះបញ្ជី និងបានការទទួលស្គាល់ជាអង្គភាពអនុវត្តនៅថ្នាក់ជាតិ នៅក្នុងប្របខណ្ឌមូលនិធិបន្សាំ និងបន្ទាប់មកមូលនិធិអាកាសធាតុបៃតង ដើម្បីឱ្យកម្ពុជាអាចមានសិទ្ធទទួលបានហិរញ្ញវត្ថុអាកាសធាតុពិភពលោកដោយផ្ទាល់។ ទន្ទឹមនេះ យើងត្រូវផ្ដល់ការគាំទ្រដល់ក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ ជនបង្គោលបច្ចេកទេស និងក្រុមការងារប្រែប្រួលអាកាសធាតុនៅតាមក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីឱ្យពួកគេអាចបំពេញតួនាទីជាអ្នកជំនាញខាងការប្រែប្រួលអាកាសធាតុនៅក្នុងក្រសួង-ស្ថាប័នរបស់ខ្លួន និងផ្ដល់យោបល់បច្ចេកទេស ដល់សមាជិកនានានៃគណៈកម្មការធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

ជារួម កម្ពុជាគាំទ្រទាំងស្រុងនូវការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិដោយផ្អែកលើគោលការណ៍សំខាន់ៗជាមូលដ្ឋានគឺ **ទទួលខុសត្រូវរួមគ្នា ប៉ុន្តែក្នុងកម្រិតផ្សេងគ្នា** តាមសមត្ថភាពរៀងៗខ្លួន និងតម្រូវការដោយឡែកចំពោះស្ថានភាពនៃបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសដែលងាយរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុ ក្នុងការជំរុញការអភិវឌ្ឍប្រកបដោយចីរភាព។ ពិតមែនតែសមត្ថភាព និងធនធានមានកម្រិត ក៏ប៉ុន្តែកម្ពុជាបានប្តេជ្ញាក្នុងឆន្ទៈនយោបាយខ្ពស់ ក្នុងការត្រៀមខ្លួន និងរួមចំណែកជានិច្ចក្នុងកិច្ចខិតខំប្រឹងប្រែងជាសកលក្នុងការទទួលខុសត្រូវចំពោះជោគវាសនានៃមនុស្សជាតិ ក្នុងការរួមចំណែកដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ដោយឈរលើស្មារតីនៃគោលការណ៍ចម្បងៗ របស់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។

ក្នុងស្មារតីនេះ ខ្ញុំយល់ថា **វេទិកាជាតិលើកទី៣ ស្តីពីប្រែប្រួលអាកាសធាតុ** នេះនឹងផ្តល់នូវកាលានុវត្តភាពដ៏កម្រ សម្រាប់ការពិភាក្សាលើបញ្ហាជាច្រើន ដូចជាវិទ្យាសាស្ត្រប្រែប្រួលអាកាសធាតុ ការចរចាអន្តរជាតិ មេរៀននានាដែលទទួលបានមកទល់បច្ចុប្បន្ន យុទ្ធសាស្ត្ររបស់យើងសម្រាប់អនាគត ការគ្រប់គ្រងចំណេះដឹង ការស្រាវជ្រាវ និងការចាត់ចែងហិរញ្ញប្បទានលើការងារគ្រប់គ្រងប្រែប្រួលអាកាសធាតុ។ ខ្ញុំសង្ឃឹមថា ឯកឧត្តម លោកជំទាវ លោក លោកស្រី ពិតជាទទួលបានអត្ថប្រយោជន៍ពីការពិភាក្សានានាជាមួយប្រតិបត្តិករទាំងឡាយនៅក្នុងរយៈពេលប៉ុន្មានថ្ងៃខាងមុខនេះ ហើយខ្ញុំរំពឹងថា យើងនឹងទទួលបានអនុសាសន៍ជាច្រើនផងដែរពីវេទិកានេះ ដើម្បីជាប្រយោជន៍សម្រាប់គាំទ្រកម្ពុជាក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ឆ្ពោះទៅការកសាងសង្គមមួយដែលបៃតង បញ្ចេញកាបូនតិច ធន់នឹងការប្រែប្រួលអាកាសធាតុ មានសមធម៌ និងមានភាពសុខដុមរវាងការរស់នៅរបស់មនុស្ស និងបរិស្ថាន។

ជាថ្មីម្តងទៀត ខ្ញុំសូមបញ្ជាក់ថែមទៀតថា នៅក្នុងអាណត្តិថ្មីនេះ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តយកចិត្តទុកដាក់ខ្ពស់បន្ថែមទៀតលើកិច្ចការពារបរិស្ថាន ដែលជាវិធានការដ៏ចាំបាច់បំផុត ហើយចាត់ទុកនិរន្តរភាពបរិស្ថានជាអាទិភាពនាំផ្លូវដ៏ត្រឹមត្រូវ សម្រាប់យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព និងការលុបបំបាត់ភាពក្រីក្រ។ រាជរដ្ឋាភិបាលនឹងប្រឹងប្រែងអនុវត្តគំនិតផ្តួចផ្តើមនៃការអភិវឌ្ឍបៃតងជាតិដែលអាចពង្រឹងនូវកំណើនសេដ្ឋកិច្ច, ការប្រើប្រាស់, ការផលិត និងធុរកិច្ចដែលមានលក្ខណៈបៃតង ដើម្បីរក្សាតុល្យភាពនៃការអភិវឌ្ឍឱ្យប្រកបដោយចីរភាពលើទិដ្ឋភាពធំទាំងបួន គឺ **សង្គម វប្បធម៌ បរិស្ថាន និងសេដ្ឋកិច្ច** ។

ជាទីបញ្ចប់នេះ ជាមួយនឹងការប្រកាសបើក **"វេទិកាជាតិស្តីលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ និងប្រកាសឱ្យប្រើប្រាស់ជាផ្លូវការ នូវផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា"** នៅពេលនេះ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គវេទិកាទាំងមូល សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

*សូមអរគុណ!*

# ការចាប់ផ្តើមនៃការបើកវេទិកាជាតិនាថ្ងៃទី ១

## សុន្ទរកថាស្វាគមន៍

## ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ថ្លែងក្នុងពិធីបើកវេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ ក្រោមប្រធានបទ "ធ្វើសកម្មភាពឆ្ពោះទៅរកការអភិវឌ្ឍដោយចីរភាពក្នុងបរិបទប្រែប្រួលអាកាសធាតុ" នៅវិមានសន្តិភាព ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៣

- ជាបឋម ខ្ញុំបាទសូមគោរពសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- សូមគោរព ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃព្រឹទ្ធសភា និងរដ្ឋសភា
- សូមគោរព ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី សមាជិក សមាជិកានៃរាជរដ្ឋាភិបាល
- ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត តំណាងអង្គទូត ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល
- អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន
- ឯកឧត្តម លោកឧកញ៉ា លោកជំទាវ អស់លោក លោកស្រី ភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិ និងប្អូនៗយុវជន
- សមាជិក សមាជិកានៃអង្គវេទិកា ទាំងមូលជាទីមេត្រី!

ក្នុងនាមក្រសួងបរិស្ថាន គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំបាទសូមគោរពស្វាគមន៍យ៉ាងកក់ក្តៅ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមានដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានកិត្តិយសនៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ដែលបានឆ្លៀតពេលដ៏មមាញឹកអញ្ជើញជាអធិបតី ក្នុងពិធីបើកវេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុក្រោមប្រធានបទ "ធ្វើសកម្មភាពឆ្ពោះទៅរកការអភិវឌ្ឍដោយចីរភាពក្នុងបរិបទប្រែប្រួលអាកាសធាតុ" នាពេលនេះ។ ជាមួយគ្នានេះដែរ ខ្ញុំក៏សូមថ្លែងអំណរគុណជាអនេកចំពោះ ឯកឧត្តម លោកឧកញ៉ា លោកជំទាវ អស់លោក លោកស្រី ភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិ ប្អូនៗយុវជន និងនិស្សិតទាំងអស់ដែលបានអញ្ជើញចូលរួមក្នុងវេទិកាដ៏មានសារៈសំខាន់នេះ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំបាទសូមគោរពជម្រាបជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** និងអង្គវេទិកាទាំងមូលមេត្តាជ្រាបថា ការប្រែប្រួលអាកាសធាតុ គឺជាលទ្ធផលនៃសកម្មភាពរបស់មនុស្ស ដែលបញ្ហានេះត្រូវបានពិភពលោកទទួលស្គាល់ជាបញ្ហាសកល។ កំណើនកំហាប់ឧស្ម័នផ្ទះកញ្ចក់នៅក្នុងបរិយាកាស បានធ្វើឱ្យកើនកម្តៅនៅលើផែនដី ដែលជាមូលហេតុចម្បងនៃការប្រែប្រួលអាកាសធាតុ

ជារួមរបស់ភពផែនដី។ ការប្រែប្រួលរបបអាកាសធាតុនេះ អាចនឹងជះឥទ្ធិពលជាអវិជ្ជមានដល់កំណើនសេដ្ឋកិច្ចនិងជីវៈចម្រុះ ជាពិសេសក្នុងបណ្តាប្រទេសអភិវឌ្ឍន៍តិចតួចដូចជាប្រទេសកម្ពុជាជាដើម។

តាមការព្យាករណ៍បានឱ្យដឹងថា កម្តៅភពផែនដីនឹងកើនឡើងពី១,៥°C ដល់ ២°C នៅចុងសតវត្សរ៍ទី២១ បើធៀបនឹងសីតុណ្ហភាពនៅចុងសតវត្សរ៍ទី១៩។ ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុនៃអង្គការសហប្រជាជាតិបានអះអាងថា សកម្មភាពរបស់មនុស្សបានជះឥទ្ធិពលទៅលើការប្រែប្រួលអាកាសធាតុយ៉ាងពិតប្រាកដ។ គិតចាប់តាំងពីសម័យបដិវត្តន៍ឧស្សាហកម្មមកទល់ពេលនេះ កំហាប់ឧស្ម័នកាបូនិកនៅក្នុងបរិយាកាសបានកើនឡើងដល់៤០% ដោយសារទង្វើរបស់មនុស្ស ជាពិសេសការបញ្ចេញពីការដុតឥន្ធនៈហ្វូស៊ីល និងការប្រែប្រួលនៃការប្រើប្រាស់ដី។

ក្នុងនាមជាប្រទេសអភិវឌ្ឍន៍តិចតួច កម្ពុជាអាចនឹងងាយរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ដោយសារមូលដ្ឋានសេដ្ឋកិច្ចរបស់ប្រទេសយើងមានភាពអាស្រ័យយ៉ាងផ្ទាល់លើវិស័យកសិកម្ម ហើយធនធានមនុស្ស និងហិរញ្ញវត្ថុក៏នៅមានកម្រិត ហេដ្ឋារចនាសម្ព័ន្ធរូបវន្តក៏នៅមិនទាន់ឆ្លើយតបតាមតម្រូវការ ជាពិសេសយើងក៏នៅខ្វះខាតបច្ចេកវិទ្យាសមស្របសម្រាប់ដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុនៅឡើយ។

**- សម្តេច ឯកឧត្តម លោកឧកញ៉ា លោកជំទាវ អស់លោក លោកស្រីជាទីគោរព!**

ការជួបជុំគ្នានៅថ្ងៃនេះ គឺជាសក្ខីភាពបញ្ជាក់ឱ្យឃើញអំពីការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់រាជរដ្ឋាភិបាលចំពោះបញ្ហាប្រែប្រួលអាកាសធាតុ ក៏ដូចជា កិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ដើម្បីធានាបាននូវតុល្យភាពរវាងការអភិវឌ្ឍ និងការអភិរក្ស។ បញ្ហាប្រែប្រួលអាកាសធាតុត្រូវបានដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដោយផ្តោតជាសំខាន់លើការកសាងភាពធន់ទ្រាំរបស់យើងចំពោះការប្រែប្រួលអាកាសធាតុ និងការលើកកម្ពស់ការអភិវឌ្ឍ ដែលបញ្ចេញកាបូនតិច។ ជាងនេះទៅទៀត ការប្រែប្រួលអាកាសធាតុក៏បានក្លាយជាកត្តាអាទិភាពនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ហើយបញ្ហានេះក៏ត្រូវបានរំពឹងទុកថាជាកិច្ចការដ៏ចម្បងមួយនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ សម្រាប់រយៈពេលខាងមុខបន្តទៀត។ វត្តមានរបស់យើងទាំងអស់គ្នានៅទីនេះគឺជាសាក្សីនៃការប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ **ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា** ដែលផែនការនេះនឹងក្លាយជាឯកសារយោងដ៏ពិស្តារសម្រាប់វិធានការរបស់យើងទៅអនាគត ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

ជាការឆ្លើយតបទៅនឹងអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់រាជរដ្ឋាភិបាល នៅក្នុងវេទិកាជាតិលើកទី២ ស្តីពីការប្រែប្រួលអាកាសធាតុកាលពីខែតុលា ឆ្នាំ២០១១ កន្លងមក និងដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ បានបំពេញកិច្ចការសំខាន់ៗ ដោយសម្រេចបានសមិទ្ធផលគួរឱ្យកត់សម្គាល់ដូចខាងក្រោម៖

១. ការរៀបចំគោលនយោបាយនិងផែនការយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុៈ

គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ បានសម្របសម្រួលដំណើរការរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា និងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធសំខាន់ៗមួយចំនួន។ ផែនការយុទ្ធសាស្ត្រទាំងនេះជាឯកសារផែនការជាតិ និងជាផែនការតាមវិស័យដំបូងបង្អស់សម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុយ៉ាងទូលំទូលាយនៅកម្ពុជា ដែលនឹងតម្រង់ទិសការបញ្ជ្រាបបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងកិច្ចខិតខំប្រឹងប្រែងនៅថ្នាក់ជាតិថ្នាក់ក្រោមជាតិ និងតាមវិស័យ ដើម្បីសម្រេចឱ្យបានការអភិវឌ្ឍដែលធន់ទ្រាំនឹងអាកាសធាតុនិងបញ្ចេញកាបូនតិច។

២.ការពង្រឹងការសម្របសម្រួលស្ថាប័ននិងបច្ចេកទេសៈ

បច្ចុប្បន្ន នាយកដ្ឋានប្រែប្រួលអាកាសធាតុ ដែលជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុបាន និងកំពុងដើរតួនាទីជាអ្នកជួយគ្រប់សកម្មភាពការងារទាំងនៅថ្នាក់ជាតិនិងអន្តរជាតិ។ ក្រសួងស្ថាប័នពាក់ព័ន្ធសំខាន់ៗបានបង្កើតក្រុមការងារប្រែប្រួលអាកាសធាតុរបស់ខ្លួន និងតែងតាំងជនបង្គោល ដើម្បីសម្របសម្រួលវិធានការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ តាមវិស័យ រួមមាន ការបង្កើតផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា និងផែនការសកម្មភាពនៅតាមវិស័យទាំងនោះ។ អនុក្រុមហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុក៏ត្រូវបានបង្កើតឡើង ដើម្បីគាំទ្រដល់ការបង្កើតក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ។ សំណើសុំបង្កើតអនុក្រុមឯកទេសអន្តរក្រសួងនៅក្រោមក្រុមបច្ចេកទេសប្រែប្រួលអាកាសធាតុ កំពុងស្ថិតក្នុងការរៀបចំ ដើម្បីដោះស្រាយបញ្ហាបច្ចេកទេសដែលទាក់ទងនឹងការកាត់បន្ថយនិងការបន្សាំ។ ដើម្បីពង្រឹងបន្ថែមនូវសមត្ថភាពសម្របសម្រួល ក្រសួងបរិស្ថាន បាន និងកំពុងបន្តដឹកនាំកិច្ចពិភាក្សាស្វែងរកវិធីកែលម្អស្ថាប័នប្រែប្រួលអាកាសធាតុដែលមានស្រាប់។

៣.ការអនុវត្តគម្រោងឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុៈ

ក្នុងរយៈពេល២ឆ្នាំចុងក្រោយនេះ យើងឃើញមានគម្រោងទាក់ទងនឹងការប្រែប្រួលអាកាសធាតុកាន់តែច្រើន ដែលត្រូវបានអនុវត្តដោយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធដទៃទៀតនៅកម្ពុជា។ ក្រសួងបរិស្ថានបានដើរតួនាទីយ៉ាងសកម្មជាអ្នកសម្របសម្រួល ក្នុងការកៀរគរធនធាន និងការអនុវត្តគម្រោងប្រែប្រួលអាកាសធាតុជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា។ គម្រោងទាំងនេះមានជាអាទ៍ (១) សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ដែលមានទឹកប្រាក់សរុបចំនួន ១១ លានដុល្លារ ផ្តល់ដោយសហភាពអឺរ៉ុប អង្គការ UNDP ប្រទេសស៊ុយអែដ និងដាណឺម៉ាក (២) កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់ទ្រាំនឹងអាកាសធាតុ អនុវត្តដោយក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួន ដែលមានទឹកប្រាក់សរុបចំនួន ៩១ លានដុល្លារ ផ្តល់ដោយមូលនិធិវិនិយោគអាកាសធាតុ និង (៣) គម្រោងគាំទ្រសហគមន៍តំបន់ការពារធម្មជាតិមួយចំនួន ដើម្បីបន្សាំទៅនឹងអាកាសធាតុផ្អែកលើប្រព័ន្ធអេកូឡូស៊ីដែលមានទឹកប្រាក់សរុបចំនួន ៥ លានដុល្លារ ផ្តល់ដោយមូលនិធិបន្សាំ។ លើសពីនេះ យើងនៅមានគម្រោងប្រែប្រួលអាកាសធាតុមួយចំនួនទៀត ដែលគាំទ្រមូលនិធិដោយ USAID JICA KOICA មូលនិធិបរិស្ថានពិភពលោក និងភ្នាក់ងារអង្គការសហប្រជាជាតិនានា ហើយគម្រោងទាំង

នេះកំពុងត្រូវបានអនុវត្តដោយក្រសួង និងស្ថាប័នពាក់ព័ន្ធ។ ទន្ទឹមនឹងនេះគំនិតផ្តួចផ្តើមអាកាសធាតុថ្មីៗមួយចំនួនកំពុងស្ថិតក្នុងដំណាក់កាលរៀបចំ ហើយមានគោលដៅពង្រឹងប្រព័ន្ធផ្តល់ព័ត៌មានជាមុនភាពធន់ទ្រាំនៃការប្រកបមុខរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋនៅតាមជនបទ និងប្រព័ន្ធអេកូឡូស៊ី និងការលើកកម្ពស់សន្តិសុខថាមពលរបស់ប្រទេសកម្ពុជា។ ពាក់ព័ន្ធនឹងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ក្រសួងបរិស្ថាន ក្នុងនាមជាស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាត បានអនុម័តគម្រោងចំនួន ១០ ដែលក្នុងនោះមានគម្រោងចំនួន ៩ ត្រូវបានគណៈកម្មាធិការប្រតិបត្តិនៃអង្គការសហប្រជាជាតិចុះបញ្ជីរួចហើយ។ គម្រោងទាំង ១០ នេះ នឹងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់បានប្រមាណ ២ លានតោន ក្នុងមួយឆ្នាំៗ គិតជាសមមូលឧស្ម័នកាបូនិក ហើយនឹងនាំមកនូវផលប្រយោជន៍យ៉ាងច្រើនដល់សេដ្ឋកិច្ចសង្គម និងបរិស្ថាន តាមរយៈការផលិតអគ្គិសនី និងកម្តៅពីប្រភពថាមពលកកើតឡើងវិញ សំណល់កម្តៅពីឧស្សាហកម្ម សំណល់ពីកសិកម្ម និងពីការចិញ្ចឹមសត្វ។

៤.ការកៀរគរហិរញ្ញវត្ថុ៖

ក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ទឹកប្រាក់ប្រមាណ ២៥០ លានដុល្លារ ត្រូវបានកៀរគរសម្រាប់គាំទ្រដល់ការអនុវត្តគម្រោងប្រែប្រួលអាកាសធាតុនានា។ ក្រសួងបរិស្ថានបានផ្តួចផ្តើមអនុវត្តមូលនិធិប្រែប្រួលអាកាសធាតុសាកល្បង ក្រោមកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ហើយក៏បានសិក្សាអំពីស្ថាប័ន និងការចំណាយសាធារណៈ ដោយមានកិច្ចសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងគោលបំណងស្វែងរកបទពិសោធសម្រាប់ឈានទៅបង្កើតក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ ក៏ដូចជា តម្រង់ទិសឱ្យឆាកចេញពីអភិក្រមកម្រិតអនុវត្តគម្រោងដោយឡែកៗ ឈានឆ្ពោះទៅរកអភិក្រមដោយផ្អែកលើកម្មវិធីជាលក្ខណៈប្រព័ន្ធ ដោយរាប់បញ្ចូលទាំងរបៀបប្រើប្រាស់មូលនិធិប្រមូលផ្តុំ និងការផ្តល់ថវិកាសម្រាប់គាំទ្រការងារតាមវិស័យ។

៥.ការអប់រំ និងការលើកកម្ពស់ការយល់ដឹង៖

ដោយមានការគាំទ្រពីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ សម្រាប់វិស័យអប់រំ ដើម្បីលើកកម្ពស់សមាហរណកម្មបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងប្រព័ន្ធអប់រំ ទាំងក្នុង និងក្រៅប្រព័ន្ធ។ លើសពីនេះទៀត ក្រសួងបរិស្ថានបានបង្កើតគោលការណ៍ណែនាំយុទ្ធសាស្ត្រ ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការអប់រំអំពីការប្រែប្រួលអាកាសធាតុ។ ក្រសួងបរិស្ថាន បានរៀបចំសម្ភារឧបទ្ទេសមួយចំនួន មានជាអាទិ៍ ផ្ទាំងព័ត៌មាន កូនសៀវភៅកម្មវិធីខ្លីៗ សម្រាប់ការចាក់ផ្សាយតាមវិទ្យុ និងទូរទស្សន៍ ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការប្រែប្រួលអាកាសធាតុ។ នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធផ្សេងទៀត រួមទាំងអង្គការមិនមែនរដ្ឋាភិបាល បានរៀបចំសិក្ខាសាលា និងការបណ្តុះបណ្តាលមួយចំនួន ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ក្រសួងបរិស្ថាននឹងបន្តពង្រីកសកម្មភាពរបស់ខ្លួនលើការអប់រំការស្រាវជ្រាវ និងការបង្កើនការយល់ដឹងក្នុងភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធនានា ដើម្បីធានាឱ្យមានការយល់ដឹងកាន់តែប្រសើរជាមុន ក្នុងចំណោមសាធារណជន ក៏ដូចជា ការចូលរួមពីអ្នកពាក់ព័ន្ធក្នុងការឆ្លើយតបការធ្វើសេចក្តីសម្រេចចិត្ត ដើម្បីឈានទៅទទួលបានសង្គមមួយ ដែលផ្អែកលើចំណេះដឹងជាគោល។

៦.ការចរចាកម្រិតអន្តរជាតិដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ៖

ក្នុងនាមគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុក្រសួងបរិស្ថាន បានដើរតួនាទីយ៉ាងសកម្ម ក្នុងការដឹកនាំដំណើរការចរចាអំពីការប្រែប្រួលអាកាសធាតុ ក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។ ក្រសួងជានិច្ចកាល បានរៀបចំកិច្ចប្រជុំពិភាក្សាដាក់ចេញនូវឯកសារបញ្ជាក់អំពីជំហររបស់កម្ពុជា ដោយមានការឯកភាពពីសំណាក់ក្រុមអ្នកពាក់ព័ន្ធនៅថ្នាក់ជាតិមុននឹងដាក់ជូនសហគមន៍អន្តរជាតិ នៅក្នុងសន្និសីទប្រចាំឆ្នាំនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។

**- សម្តេច ឯកឧត្តម លោកឧកញ៉ា លោកជំទាវ អស់លោក លោកស្រីជាទីគោរព!**

សមិទ្ធផលដូចបានរៀបរាប់ជម្រាបជូនខាងលើ គឺជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរួមគ្នារវាងថ្នាក់ដឹកនាំ និងសមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ដោយមានការដឹកនាំ ចង្អុលបង្ហាញ និងតម្រង់ទិសជាប្រចាំ ពីសំណាក់សម្តេចតេជោនាយករដ្ឋមន្ត្រី។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉េត** អតីតរដ្ឋមន្ត្រីក្រសួងបរិស្ថាន ដែលបានដឹកនាំគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ដោយទទួលបាននូវសមិទ្ធផលគួរជាទីមោទនៈទាំងនេះ។

ជាទីបញ្ចប់ ខ្ញុំបាទសូមគោរពជូនពរសម្តេចតេជោនាយករដ្ឋមន្ត្រី ឯកឧត្តម លោកឧកញ៉ា លោកជំទាវ អស់លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ប្អូនៗយុវជន និងនិស្សិត សមាជិក សមាជិកាអង្គវេទិកាទាំងមូល សូមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ដើម្បីផ្តល់ជាគោលគំនិត និងអនុសាសន៍ណែនាំ សម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ក៏ដូចជាដើម្បីជាមូលដ្ឋានគំនិតសម្រាប់ការពិភាក្សានៅក្នុងរយៈពេលបីថ្ងៃនេះ ខ្ញុំបាទសូមអនុញ្ញាតគោរពអញ្ជើញសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ថ្លែងសុន្ទរកថាបើកវេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ ក្រោមប្រធានបទ «**ធ្វើសកម្មភាពឆ្ពោះទៅការអភិវឌ្ឍដោយចីរភាពក្នុងបរិបទប្រែប្រួលអាកាសធាតុ**» ដោយក្តីអនុគ្រោះបំផុត។

***សូមអរគុណ!***

# សុន្ទរកថាស្វាគមន៍របស់

## លោកស្រី CLAIRE VAN DER VAEREN

## អ្នកសម្របសម្រួលអង្គការសហប្រជាជាតិ ប្រចាំនៅកម្ពុជា

សូមគោរព៖

ឯកឧត្តម ខៀវ មុត រដ្ឋលេខាធិការក្រសួងបរិស្ថាន

ឯកឧត្តម ដៃគូអភិវឌ្ឍន៍ ភ្ញៀវកិត្តិយស លោក លោកស្រីជាទីមេត្រី!

ក្នុងនាមក្រុមទីភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ខ្ញុំមានកិត្តិយសក្នុងការស្វាគមន៍ឯកឧត្តម លោកលោកស្រី នៅក្នុងវគ្គនេះនៃវេទិកាជាតិលើកទី ៣ ស្តីពីការប្រែប្រួលអាកាសធាតុ។

ជាការចាប់ផ្តើម ខ្ញុំសូមអបអរសាទរគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុដែលបានដឹក នាំការចាត់ចែងព្រឹត្តិការណ៍ដ៏មានសារៈសំខាន់នេះ។ ការប្រកាសជាផ្លូវការនូវ*ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា* ដោយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បង្ហាញពីចំណុចគោលដ៏សំខាន់មួយដែលបញ្ជាក់ពីការប្តេជ្ញាមុតមាំរបស់រដ្ឋាភិបាលក្នុងការដោះស្រាយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

ការចេញផ្សាយថ្មីៗនេះនៃ*របាយការណ៍វាយតម្លៃលើកទី៥ របស់ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ* សន្និដ្ឋានថាការឡើងកម្តៅផែនដីក្នុងរយៈពេលហាសិបឆ្នាំកន្លងមកនេះ ភាគច្រើន លើសលុបបង្កដោយសកម្មភាពរបស់មនុស្ស។ ការធ្លាក់ភ្លៀង និងរបបសីតុណ្ហភាពនឹងបន្តប្រែប្រួលនៅក្នុងបណ្តាទសវត្សរ៍ខាងមុខនេះ ដែលបង្កជាការគំរាមកំហែងមកលើកិច្ចប្រឹងប្រែងលុបបំបាត់ភាពក្រីក្រ។ គ្រោះមហន្តរាយធម្មជាតិដែលបង្កដោយអាកាសធាតុដែលកើតចេញពីព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតី ដូចជា ទឹកជំនន់ និងគ្រោះរាំងស្ងួត កាន់តែមានញឹកញាប់ជាងមុនរួចទៅហើយ និងកាន់តែខ្លាំងផងដែរ។និន្នាការនេះត្រូវបានគេរំពឹងថានឹងបន្តបង្កជាការប្រឈមសំខាន់ៗមកលើការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងការទ្រទ្រង់កំណើននៃសមិទ្ធផលនេះ។

កម្ពុជាស្ថិតនៅក្នុងចំណោមប្រទេសចំនួនដប់ ដែលមានភាពងាយរងគ្រោះបំផុត ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ សេចក្តីព្រាងរបាយការណ៍ជាតិលើកទី២ សម្រាប់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) បង្ហាញថា សីតុណ្ហភាពជាមធ្យមក្នុងប្រទេសកម្ពុជាបាន កើនឡើង០,៨ អង្សាសេ តាំងពីឆ្នាំ១៩៦០មក។ ការប្រែប្រួលលក្ខខណ្ឌអាកាសធាតុ នឹងកាន់តែធ្វើឱ្យកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ ការផ្គត់ផ្គង់ទឹក ប្រព័ន្ធអេកូឡូស៊ី និងសុខភាព និងសុវត្ថិភាពរបស់មនុស្សប្រឈមនឹងហានិភ័យ។ ប្រជាជនដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ និងក្រុមដទៃទៀត ដូចជា គ្រួសារដែលមានស្រីជាមេគ្រួសារ កុមារ មនុស្សចាស់ ជនពិការ និងសហគមន៍ជនជាតិដើមភាគតិច គឺជាក្រុមដែលមានភាពងាយរងគ្រោះជាពិសេស។

ភាពងាយរងគ្រោះរបស់កម្ពុជានៅចំពោះមុខការប្រែប្រួលអាកាសធាតុ មិនមែនដោយសារតែហានិភ័យអាកាសធាតុប៉ុណ្ណោះទេ ប៉ុន្តែដោយសារតែប្រទេសនេះនៅមានសមត្ថភាពបន្សាំក្នុងកម្រិតកំណត់ផងដែរ។ ប្រជាជន៨០% រស់នៅជនបទ ដែលភាគច្រើនធ្វើកសិកម្ម មានសមត្ថភាពបន្សាំ និងហេដ្ឋារចនាសម្ព័ន្ធកម្រិតទាប។ សេចក្តីព្រាងរបាយការណ៍ជាតិលើកទី ២ សម្រាប់ UNFCCC ក៏បង្ហាញផងដែរថាជិត ៥០% នៃឃុំនៅកម្ពុជា ត្រូវបានចាត់ទុកថាស្ថិតក្នុងចន្លោះស្ថានភាពងាយរងគ្រោះ ងាយរងគ្រោះបំផុតនៅចំពោះមុខវិសមរូបអាកាសធាតុ។ លើសពីនេះ ការអង្កេតអំពីការយល់ឃើញរបស់សាធារណជនអំពីការប្រែប្រួលអាកាសធាតុ ដែលបានធ្វើឡើងនៅឆ្នាំ ២០១០ បានរកឃើញថា អ្នកឆ្លើយច្រើនជាង ៥០% មានអារម្មណ៍ថា ពុំមានព័ត៌មានដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុឡើយ និង៦០% មានអារម្មណ៍ថាពួកគេពុំដឹងពី របៀបឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុឡើយ។

ការប្រែប្រួលអាកាសធាតុ ត្រូវគេដឹងថាជាការគំរាមកំហែងធំជាងគេមួយចំពោះការអភិវឌ្ឍដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ។ ប៉ុន្តែជាញឹកញាប់បំផុត ប្រការសំខាន់មួយត្រូវគេបំភ្លេចៈ *ការដោះស្រាយការប្រែប្រួលអាកាសធាតុគឺជាឱកាសមួយក្នុងចំណោមឱកាសធំបំផុតចំនួនបួនរបស់យើង។* ជំនាញខាងបច្ចេកវិទ្យាបញ្ចេញកាបូនកម្រិតទាប និងការបន្សាំគឺជាអ្វីដែលត្រូវការជាខ្លាំង។ ប្រទេសនានាដែលវិនិយោគក្នុងដំណាក់កាលដើមដំបូងលើវិស័យទាំងនេះ នឹងស្ថិតក្នុងស្ថានភាពរឹងមាំនៅក្នុងទីផ្សារថ្មីនេះ។ ប្រការសំខាន់បំផុតគឺ ការរួមបញ្ចូលការប្រែប្រួលអាកាសធាតុនៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផ្តល់នូវឱកាស ដើម្បីបង្កើតគំរូនៃកំណើនសេដ្ឋកិច្ចដោយចីរភាពសម្រាប់កម្ពុជាស្របជាមួយតុល្យភាពដែលត្រូវការជាចាំបាច់រវាងអត្ថប្រយោជន៍ខាងសង្គម សេដ្ឋកិច្ច និងបរិស្ថាន។

ឯកឧត្តម លោក លោកស្រីជាទីមេត្រី!

សូមអនុញ្ញាតឱ្យខ្ញុំបង្ហាញអំពីវិធាននានា ដែលអាចពង្រឹងសមត្ថភាពដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

ទីមួយការរួមបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការកសាងផែនការ និងការលើកថវិកាអភិវឌ្ឍន៍ជាតិ និងនៅមូលដ្ឋាន គឺជាគន្លឹះក្នុងការបន្សាំ និងការវិនិយោគដែលធន់នឹងអាកាសធាតុ។ ការប្រែប្រួលអាកាសធាតុនិងការអភិវឌ្ឍបៃតងមានឆ្លុះបញ្ចាំងរួចមកហើយនៅក្នុងដំណាក់កាលនានានៃយុទ្ធសាស្ត្រចតុកោណជំហានទីបី។ ប្រការសំខាន់គឺវាត្រូវតែជាអាទិភាពទាំងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិថ្មី ក៏ដូចជានៅក្នុងដំណើរការកសាងផែនការសម្រាប់អង្គភាពនានានៅថ្នាក់ក្រោមជាតិផងដែរ។ ក្រុមទីភ្នាក់ងារសហប្រជាជាតិ បានចូលរួមជាមួយដៃគូនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិរបស់យើង ដើម្បីធ្វើឱ្យការប្រែប្រួលអាកាសធាតុក្លាយជាទិដ្ឋភាពស្តង់ដារមួយនៃការកសាងផែនការអភិវឌ្ឍន៍ និងការលើកថវិកា។

ទីពីរ ដូចមានចែងនៅក្នុង *ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា* "កម្ពុជាត្រូវអភិវឌ្ឍន៍ទៅរកសង្គមមួយ ដែលបៃតងជាងមុន បញ្ចេញកាបូនកម្រិតទាប ធន់នឹងអាកាសធាតុ មានសមធម៌ និរន្តរភាព និងដែលផ្អែកលើចំណេះដឹង។" ដើម្បីសម្រេចចក្ខុវិស័យនេះបាន ប្រការសំខាន់គឺថា *ត្រូវបង្កើតក្របខ័ណ្ឌជាតិដ៏មានប្រសិទ្ធិភាព និងតម្លាភាព* ដើម្បីពិនិត្យតាមដានសកម្មភាពដែលទាក់ទង

នឹងការប្រែប្រួលអាកាសធាតុ និងពិនិត្យមើលវិភាជន៍ហិរញ្ញវត្ថុអាកាសធាតុ ស្របជាមួយអាទិភាពរបស់ជាតិ។

ទីបីនៅក្នុងបរិបទនេះ*កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូកាន់តែធំធេងរវាងអ្នកពាក់ព័ន្ធទាំងអស់ នឹងនាំមកនូវអនុភាពកាន់តែខ្លាំង*។ កិច្ចប្រឹងប្រែងដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនឹងមិនអាចសម្រេចទៅបានដោយរដ្ឋាភិបាលតែឯងឡើយ។ សង្គមស៊ីវិល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ត្រូវតែផ្តល់ការប្តេជ្ញាឱ្យបានពេញលេញ និងគាំទ្រដល់អាទិភាពជាតិទាំងនេះ។

ទីបួនផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមានឥទ្ធិពលមិនត្រឹមតែមកលើបរិស្ថាននោះទេ។ ដូច្នេះវិធានចម្រុះក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុ មានសារៈសំខាន់ណាស់ ជាពិសេស ដើម្បីកសាងភាពធន់នៅចំពោះមុខហានិភ័យអាកាសធាតុនៅថ្នាក់មូលដ្ឋាន។ ការគាំទ្រ និងពង្រីកការអនុវត្តជាបន្ថែមគឺជាតម្រូវការចាំបាច់។ មេរៀនមួយក្នុងចំណោមមេរៀនដែលទទួលបានពីគម្រោងកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគឺថា ភាពធន់របស់សហគមន៍មានភាពប្រសើរជាងមុន នៅពេលដែលពួកគេអាចកំណត់អាទិភាពរបស់ខ្លួន និងលើកស្នើដំណោះស្រាយចំពោះភាពងាយរងគ្រោះនៅចំពោះមុខការប្រែប្រួលអាកាសធាតុតាមវិធីចម្រុះ។

ទីប្រាំក្នុងពេលដែលការយកចិត្តទុកដាក់លើកកម្ពស់ភាពធន់មានទំនោរផ្តោតច្រើនលើអ្នកក្រីក្រនៅជនបទ កំណើនចំណាកស្រុកទៅទីក្រុងនានា ដោយសារតែការប្រែប្រួលអាកាសធាតុធ្វើឱ្យភាពធន់នៅទីក្រុងក៏ជាបញ្ហាមួយមានសារៈសំខាន់ផងដែរ។ យើងត្រូវធានាថា ទីក្រុងនានាទៅអនាគតត្រូវបានគ្រោងឡើងត្រឹមត្រូវ មាននិរន្តរភាព និងអាចឱ្យមនុស្សទាំងអស់ប្រើប្រាស់បាន។

នៅទីបញ្ចប់ ខ្ញុំសូមស្នើថា យើង*ពិនិត្យបញ្ហាការប្រែប្រួលអាកាសធាតុពីជ្រុងទស្សនៈយេនឌ័រផង។* ឥទ្ធិពលនៃហានិភ័យពីការប្រែប្រួលអាកាសធាតុនឹងបង្កើនវិសមភាពដែលមានស្រាប់ បង្កការគំរាមកំហែងមកលើរបរចិញ្ចឹមជីវិត និងសន្តិសុខរបស់ស្ត្រី។ *ប៉ុន្តែ ស្ត្រីនៅក្នុងសហគមន៍ក៏អាចជាភ្នាក់ងារនាំមកនូវការប្រែប្រួលវិជ្ជមានផងដែរ និងជាអ្នកផ្តល់វិភាគទានដ៏សំខាន់នៅក្នុងយុទ្ធសាស្ត្រនៃការបន្ស៊ាំសម្រាប់ការចិញ្ចឹមជីវិត ប្រសិនបើ* ពួកគេមានឱកាសចូលរួមនៅក្នុងការស្វែងរកដំណោះស្រាយ និងធ្វើសេចក្តីសម្រេច ទាំងក្នុងការកំណត់គោលនយោបាយ និងការអនុវត្ត។

ឯកឧត្តម លោក លោកស្រីជាទីមេត្រី!

អង្គការសហប្រជាជាតិ បានដាក់ការប្រែប្រួលអាកាសធាតុនៅក្នុងរបៀបវារៈខ្ពស់មួយនៃការអភិវឌ្ឍពិភពលោក។ យើងមានការប្តេជ្ញា ដើម្បីបន្តធ្វើជាដៃគូជាមួយវិស័យនានា ដើម្បីគាំទ្រដល់កិច្ចប្រឹងប្រែងរបស់ រដ្ឋាភិបាល ក្នុងការកែលម្អការសម្របសម្រួល ពង្រឹងការយល់ដឹង និងចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុ និងកៀងគរការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍន៍សមត្ថភាព និងដោះស្រាយគម្លាតខាងគោល នយោបាយនិងស្ថាប័ន។

យើងមកជួបជុំគ្នានៅក្នុងបន្ទប់នេះនាថ្ងៃនេះ ក្នុងនាមជាអ្នកឯកទេសប្រែប្រួលអាកាសធាតុ៖ ដែលរួមមានអ្នកវិទ្យាសាស្ត្រ រហូតដល់ប្រតិបត្តិករ អ្នកកសាងគោលនយោបាយរហូតដល់វិស័យឯក

ជន អ្នកស្រាវជ្រាវដល់ តំណាងពីសង្គមស៊ីវិល និងមេដឹកនាំសហគមន៍។ រួមជាមួយគ្នា យើងបានចាប់ផ្តើមចាត់ចែង វិធានការរបស់កម្ពុជាដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ រយៈពេលពីរថ្ងៃកន្លះខាងមុខនឹងផ្តល់ឱកាសយ៉ាងច្រើនដើម្បីចែករម្លែកបទពិសោធន៍ដ៏សំបូរបែបនេះ។ ប៉ុន្តែវេទិកានេះក៏ស្តីអំពី ការបញ្ចេញ សកម្មភាព ជាក់ស្តែងផងដែរ។ សូមឱ្យយើងបង្កើត និងពង្រឹងភាពជាដៃគូដែលមានជាក់លាក់នៅទីនេះ ដែលយើងត្រូវការ ដើម្បីអនុវត្តចក្ខុវិស័យនៃគំរូអភិវឌ្ឍន៍ដែលបញ្ចេញកាបូនតិច និងដែលធន់នឹងអាកាសធាតុសម្រាប់កម្ពុជា!

សូមអរគុណ!

# សុន្ទរកថាបើកសម្រាប់វគ្គបច្ចេកទេស

## ដោយ **ឯកឧត្តម ខៀវ មុត** រដ្ឋលេខាធិការ ក្រសួងបរិស្ថាន

**សូមគោរព ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ!**

ជាបឋម ក្នុងនាមក្រសួងបរិស្ថាន និងជាអ្នកសម្របសម្រួលការរៀបចំកម្មវិធីនៃវេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ ខ្ញុំមានកិត្តិយស និងសេចក្តីរីករាយជាអតិបរមាដែលបានមកចូលរួមថ្លែង សុន្ទរកថាបើកវគ្គបច្ចេកទេសពេញអង្គទី១ នៃវេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ ដ៏ឱឡារិកនេះ។ នៅក្នុងឱកាសវិសាលនេះ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ សមាជិក សមាជិកា អង្គវេទិកា ទាំងមូលដែលបានចំណាយពេលដ៏មានតម្លៃ មកចូលរួមក្នុងព្រឹត្តិការណ៍ដ៏សំខាន់នេះ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី!**

ការប្រែប្រួលអាកាសធាតុគឺជាបញ្ហាប្រឈមដ៏ចម្បងមួយដែលពិភពលោកកំពុងតែជួបប្រទះនាពេលបច្ចុប្បន្ន ហើយដែលតម្រូវឱ្យយើងចូលរួមដោះស្រាយ។ប្រទេសទាំងអស់ទូទាំងពិភពលោកកំពុងរង ផលប៉ះពាល់ធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុដោយសារតែ គ្រោះរាំងស្ងួត ខ្យល់ព្យុះ និងរលកកម្តៅ ដែលធ្វើឱ្យបាត់បង់ធ្ងន់ធ្ងរនូវអាយុជីវិត និងទ្រព្យសម្បត្តិ។របកគំហើញថ្មីៗនេះរបស់ក្រុមការងារ អន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុបានអះអាងឡើងវិញប្រកបដោយទំនុកចិត្តកម្រិតខ្ពស់ថា កំណើនការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីសកម្មភាពមនុស្ស គឺជាមូលហេតុចម្បងនៃការប្រែប្រួលអាកាសធាតុ។ ប្រទេសនានានៅក្នុងតំបន់មេគង្គងាយរងគ្រោះនៅចំពោះមុខការប្រែប្រួលអាកាសធាតុ ដោយសារតែ ការប្រែប្រួលរបបជលសាស្ត្រទន្លេមេគង្គ ការថយចុះនៃកសិផល និងផលនេសាទ ការជ្រាបចូលនៃទឹកប្រៃ កំណើនចំនួនប្រជាជន ធនធានហិរញ្ញវត្ថុ និងបច្ចេកទេសមានកម្រិត ហេដ្ឋារចនាសម្ព័ន្ធរូបវន្តមិនសមស្រប និងសមត្ថភាពបន្សាំកម្រិតទាប។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពុជាបានឆ្លងកាត់ គ្រោះទឹកជំនន់ គ្រោះរាំងស្ងួត និងខ្យល់ព្យុះកាន់តែធ្ងន់ធ្ងរ និងញឹកញាប់ជាងមុន ដែលបានបង្កការប៉ះពាល់ ធ្ងន់ធ្ងរមកលើសន្តិសុខស្បៀង របរចិញ្ចឹមជីវិតរបស់ប្រជាជន ហេដ្ឋារចនាសម្ព័ន្ធ និងសេដ្ឋកិច្ចសង្គមរបស់ ជាតិជារួម។ ទឹកជំនន់ដ៏ធ្ងន់ធ្ងរនាពេលថ្មីៗនេះ បានបង្កការប៉ះពាល់មកលើខេត្ត ក្រុងស្ទើរទាំងអស់នៅក្នុង ប្រទេសយើង ហើយបង្កឱ្យបាត់បង់អាយុជីវិតមនុស្ស និងការខូចខាតធ្ងន់ធ្ងរមកលើទ្រព្យសម្បត្តិ ផលដំណាំ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងរបរចិញ្ចឹមជីវិតរបស់សហគមន៍។ ទាំងនេះជាភស្តុតាងកាន់តែច្បាស់បន្ថែមទៀត ដែលបង្ហាញពីភាពធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុ ហើយតម្រូវឱ្យចាត់វិធានការបន្ទាន់ដើម្បីឆ្លើយតប។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី!**

របាយការណ៍ជាតិលើកទី២របស់កម្ពុជា ក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួល អាកាសធាតុបានសន្និដ្ឋានថា សីតុណ្ហភាព និងកម្ពស់ទឹកភ្លៀងនៅកម្ពុជាបានប្រែប្រួលរួចមកហើយ តាំងពីពាក់កណ្តាលចុងក្រោយនៃសតវត្សរ៍ទី២០មក។ ការព្យាករណ៍សម្រាប់រយៈពេល ៨០ ឆ្នាំ ខាងមុខបាន បង្ហាញថាប្រសិនបើពុំមានចាត់វិធានការជាដុំកំភួនណាមួយសម្រាប់កាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះ កញ្ចក់ទេ នោះសីតុណ្ហភាពនៅកម្ពុជាទៅអនាគតនឹងបន្តកើនឡើង ចំណែករដូវវស្សានឹងកាន់តែមាន ភ្លៀងធ្លាក់ច្រើន តែក្នុងរយៈពេលខ្លីជាងមុន ហើយរដូវប្រាំងនឹងមានរយៈពេលកាន់តែវែង ហើយកាន់តែស្ងួត ហែងជាងមុន។ នេះមានន័យថា កិច្ចប្រឹងប្រែងពីសំណាក់ សហគមន៍អន្តរជាតិក្នុងការកាត់បន្ថយ ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នឹងមានឥទ្ធិពលដោយផ្ទាល់មកលើអាកាសធាតុនៅកម្ពុជាទៅអនាគត។ កាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំនេះ ពិភពលោកបានឃើញនូវកំហាប់ឧស្ម័នកាបូនិច ក្នុងបរិយាកាសកើនដល់ ៤០០ភាគលានជាលើកដំបូង គិតចាប់តាំងពីពេលមនុស្សចាប់ ផ្តើមកត់ត្រាជាលក្ខណៈប្រព័ន្ធដោយ ប្រើប្រាស់បរិក្ខារទំនើប។ នៅពេលដែលកំណើនឧស្ម័នផ្ទះកញ្ចក់ឈានដល់ចំណុចកំពូលជាប្រវត្តិសាស្ត្រនេះ យើងកំពុងតែឈានចូលក្នុងកម្រិតគ្រោះថ្នាក់ថ្មីមួយនៃកំណើនសីតុណ្ហភាពខ្ពស់ជាង២°C។ កំណើន សីតុណ្ហភាពបែបនេះនឹងនាំមកនូវផលវិបាកធំធេងមកលើវិស័យជាច្រើននៃសង្គមរបស់យើង និងបង្កឱ្យមាន ផលប៉ះពាល់ដែលបណ្តាលមកពីទឹកជំនន់ គ្រោះរាំងស្ងួត និងខ្យល់ព្យុះធ្ងន់ធ្ងរ ហើយញឹកញាប់ជាងមុន។ អាស្រ័យហេតុនេះ មានការអំពាវនាវជាច្រើនលើសលប់ដើម្បីឱ្យចាត់វិធានការជាបន្ទាន់ សំដៅកាត់បន្ថយ ហានិភ័យ និងកាត់បន្ថយកម្រិតធ្ងន់ធ្ងរនៃផលប៉ះពាល់ ជាពិសេសផលប៉ះពាល់មកលើរបរចិញ្ចឹមជីវិតរបស់ ប្រជាពលរដ្ឋភាគច្រើនរបស់យើងដែលរស់នៅតាមជនបទ និងដែលងាយរងគ្រោះបំផុត។

**ឯកឧត្តម លោកជំទាវ លោក លោកស្រីជាទីមេត្រី!**

កម្ពុជាបាន និងកំពុងចូលរួមយ៉ាងសកម្មនៅក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុទាំង នៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ។ នៅថ្នាក់ជាតិ យើងបានបន្តពង្រឹងសមត្ថភាពគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុដែលមានអាណត្តិសម្របសម្រួលវិធានការជាតិ សម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ គឺជាអាទិភាពចម្បងនៅក្នុងរបៀបវារៈរបស់រាជរដ្ឋាភិបាល។ ការបង្កើតផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជាដែល **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានប្រកាសដាក់ឱ្យប្រើប្រាស់កាលពីព្រឹកមិញនេះគឺជាជំហានដ៏សំខាន់មួយ ឆ្ពោះទៅរកការបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជានៅក្រោយឆ្នាំ ២០១៥ និងការរួមបញ្ចូលសមាហរណកម្ម បញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍តាមវិស័យរបស់ក្រសួងពាក់ព័ន្ធ។ ផែនការយុទ្ធសាស្ត្រ ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជាសម្រាប់រយៈពេល១០ឆ្នាំ ២០១៤-២០២៣ កំណត់ចក្ខុវិស័យ យ៉ាងច្បាស់លាស់មួយសម្រាប់រយៈពេលវែង ពោលគឺ **"កម្ពុជាអភិវឌ្ឍន៍ទៅរកសង្គមមួយដែលបៃតង បញ្ចេញកាបូនតិច ធន់នឹងការប្រែប្រួលអាកាសធាតុ សមធម៌ ចីរភាព និងពឹងផ្អែកលើចំណេះដឹងជាគោល"** ។ ផែនការនេះនឹងផ្តល់នូវក្របខ័ណ្ឌគោលនយោបាយជាយុទ្ធសាស្ត្រមួយសម្រាប់តម្រង់ទិស និងគាំទ្រស្ថាប័នជាតិ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ក្នុងការគិតគូរអំពីវិធានការជាក់លាក់ និងសមស្រប ដែលទាក់ទងនឹងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយការបញ្ចេញឧស្ម័ន ផ្ទះកញ្ចក់

ការអភិវឌ្ឍបៃតង និងការអភិវឌ្ឍដែលបញ្ចេញកាបូនតិចដែលគាំទ្រដល់សមិទ្ធិផលនៃ យុទ្ធសាស្ត្រចតុកោណ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។

ព្រឹកមិញនេះ នៅក្នុងពិធីបើកវេទិកា ដែលប្រព្រឹត្តិទៅនៅវិមានសន្តិភាព **សម្តេចអគ្គមហាសេនាបតិតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានបកស្រាយ គោលការណ៍នាំមុខសំខាន់ៗចំនួនបីសម្រាប់វិធានការរបស់យើងដើម្បីឆ្លើយតបនឹង ការប្រែប្រួលអាកាសធាតុនៅរយៈពេល៥ឆ្នាំខាងមុខ នៅក្នុងអាណត្តិទី៥ នៃរាជរដ្ឋាភិបាលកម្ពុជា និងបណ្តាឆ្នាំក្រោយៗទៀត ជាអាទិ៍៖

- ភាពចាំបាច់នៃការប្រើប្រាស់វិធីសាស្ត្រពហុជំនាញ និងកិច្ចសហការជាមួយស្ថាប័ននានា នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា និងផែនការសកម្មភាព។
- សារសំខាន់នៃការគិតគូរជាលក្ខណៈប្រព័ន្ធពីសំណាក់ក្រសួងនានា និងដៃគូអភិវឌ្ឍន៍អំពីបញ្ហាប្រែប្រួលអាកាសធាតុនៅពេលបង្កើតអន្តរាគមន៍អភិវឌ្ឍន៍ថ្មីៗ ដើម្បីធានាថា យើងនៅតែសម្រេចគោលដៅអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចរបស់យើងនៅក្នុងបរិការណ៍នៃការប្រែប្រួលអាកាសធាតុ។
- ការតម្រូវឱ្យអ្នកពាក់ព័ន្ធទាំងអស់ធ្វើការជិតស្និទ្ធជាមួយគ្នាក្នុងការស្រាវជ្រាវ និងអភិវឌ្ឍន៍តាមបែបវិទ្យាសាស្ត្រ និងការផ្លោះប្តូរចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុ ដើម្បីកសាងធនធានមនុស្ស និងគាំទ្រដល់ការធ្វើសេចក្តីសម្រេចដែលផ្អែកលើចំណេះដឹង។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី!**

ខ្ញុំមានសេចក្តីរីករាយណាស់ចំពោះការចូលរួមរបស់អ្នកជំនាញការជាតិ និងអន្តរជាតិទាំងអស់ ដែលនឹងធ្វើបទបង្ហាញចែករំលែកបទពិសោធន៍ និងចូលរួមនៅក្នុងការពិភាក្សាលើប្រធានបទធំៗ ដូចជា វិទ្យាសាស្ត្រប្រែប្រួលអាកាសធាតុ ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ គោលនយោបាយប្រែប្រួលអាកាសធាតុ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ និងប្រធានបទ អន្តរវិស័យនានាជាច្រើនផ្សេងទៀត។ ខ្ញុំក៏មានសេចក្តីរីករាយផងដែរ ដែលបានឃើញការចូលរួមយ៉ាងសកម្មភាពពីសំណាក់វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងការតាំងបង្ហាញផលិតផល មេត្រីភាពអាកាសធាតុរបស់ខ្លួន។ នេះជាសញ្ញាវិជ្ជមានមួយដែលបង្ហាញថា វិស័យឯកជននៅកម្ពុជា មានការយល់ដឹងកាន់តែច្រើនឡើងអំពីឱកាសខាងទីផ្សារ និងតួនាទីមិនអាចខ្វះបានរបស់វិស័យឯកជននៅក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ហើយភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន គឺជាមូលដ្ឋានគ្រឹះដើម្បីធានាប្រសិទ្ធភាព និងភាពផ្តល់ផលនៃវិធានការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

ខ្ញុំជឿជាក់យ៉ាងមុតមាំថា ក្នុងរយៈពេលពីរថ្ងៃកន្លះខាងមុខនេះ អ្នកចូលរួមទាំងអស់ នឹងមានឱកាស ដើម្បីទទួលបានចំណេះដឹងជាក់ស្តែង ជំនាញ ព័ត៌មាន និងបទពិសោធន៍នានា កាន់តែច្រើនជាងមុន និងអាចចូលរួមយ៉ាងសកម្មនៅក្នុងការពិភាក្សាលើប្រធានបទសំខាន់ៗ ដើម្បីរួមចំណែក

ពង្រឹងវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ ការចូលរួមយ៉ាងសកម្មភាពរបស់ឯកឧត្តម ជំទាវ លោក លោកស្រី នៅទីនេះ ឆ្លុះបញ្ចាំងអំពីការប្តេជ្ញាមោះមុត ក្នុងការដោះស្រាយបញ្ហាប្រឈមនានាបង្ក ដោយការប្រែប្រួលអាកាសធាតុ។ ខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថា យើងនឹងរួបរួមគ្នាដើម្បីអភិវឌ្ឍកម្ពុជា ឆ្ពោះទៅរកសង្គមមួយដែលបៃតង បញ្ចេញកាបូនតិច ធន់នឹងការប្រែប្រួលអាកាសធាតុ សមធម៌ ចីរភាព និងពឹងផ្អែកលើចំណេះដឹងជាគោល។

នៅទីបញ្ចប់ ក្នុងនាមក្រសួងបរិស្ថាន និងក្រុមការងាររៀបចំវេទិការនេះ ខ្ញុំសូមជូនពរឯកឧត្តម លោកជំទាវ លោក លោកស្រី បានប្រកបតែនឹងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមឱ្យវេទិកានេះប្រព្រឹត្តទៅប្រកបដោយផ្លែផ្កា និងការស្ថាបនា។

**សូមអរគុណ!**

# សុន្ទរកថាក្នុងពិធីជប់លៀងភេសជ្ជៈ

## ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ

គណៈប្រតិភូ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ជាទីមេត្រី!

ជាបឋម ខ្ញុំសូមថ្លែងអំណរគុណដល់ភ្ញៀវកត្តិយសទាំងអស់ ដែលបានអញ្ជើញមកចូលរួមក្នុងពិធីជប់លៀងភេសជ្ជៈជាមួយយើងខ្ញុំនៅក្នុងឱកាសដ៏ត្រកាលនេះ។ រូបខ្ញុំផ្ទាល់ទើបតែបានមកកាន់តំណែងក្នុងរយៈពេលជាងមួយខែតែប៉ុណ្ណោះ ហើយខ្ញុំក៏ជារដ្ឋមន្ត្រីដែលមានវ័យក្មេងជាងគេនៅក្នុងជួររាជរដ្ឋាភិបាលបច្ចុប្បន្ន។ ប៉ុន្តែទោះបីជាយ៉ាងនេះក្តី ខ្ញុំបាន និងកំពុងតែខិតខំបំពេញតួនាទីយ៉ាងសស្រាក់សស្រាំ ដើម្បីធានានូវជោគជ័យនៃព្រឹត្តិការណ៍ដ៏សំខាន់នេះ។ ខ្ញុំដឹងច្បាស់ថា ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់គ្នាពិតជាមានការនឿយហត់ច្រើន បន្ទាប់ពីបានខិតខំបំពេញការងារយ៉ាងសកម្ម អស់ពីកម្លាំងកាយចិត្ត។ ហេតុដូច្នេះ ខ្ញុំយល់ឃើញថា ឥឡូវនេះជាពេលវេលាដ៏ស័ក្តិសម សម្រាប់ពិធីជប់លៀងជួបជុំពិសាភេសជ្ជៈ និងអាហារ សម្រាកពីការងារ និងបំពេញបន្ថែមនូវថាមពល ដើម្បីបន្តភារកិច្ចរបស់យើងនៅថ្ងៃស្អែក។ ខ្ញុំសង្ឃឹមថា ថាមពលដែលយើងផ្តល់ជូននៅទីនេះមានកម្រិតកាបូនទាប និងបញ្ចេញឧស្ម័នផ្ទះកញ្ចក់តិចតួចបំផុត។ ព្រោះខ្ញុំយល់ថា យើងមិនគួរជួបជុំគ្នាដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ តាមរយៈការបង្កើតបញ្ហាថ្មីមួយទៀតឡើយ។

ខ្ញុំបានស្នងតំណែងជាមេដឹកនាំក្នុងបេសកកម្មការពារបរិស្ថាន និងដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុរបស់កម្ពុជា នៅក្នុងកាលទេសៈដ៏ប្រឈមបំផុត៖ តើយើងត្រូវធ្វើយ៉ាងណា ដើម្បីទ្រទ្រង់និរន្តរភាពនៃកំណើនសេដ្ឋកិច្ចសង្គម ដោយជាមួយគ្នានោះរក្សាឱ្យបាននូវគុណភាពបរិស្ថាន និងសុខភាពនៃប្រព័ន្ធអេកូឡូស៊ីចម្បងៗរបស់យើង? តើយើងត្រូវប្រើវិធីបែបណា ដែលអាចធានាបាននូវតុល្យភាពរវាងការអភិវឌ្ឍជាតិ និងគុណភាពបរិស្ថាន មិនត្រឹមតែសម្រាប់ជាផលប្រយោជន៍របស់យើងនាពេលបច្ចុប្បន្នទេ ប៉ុន្តែក៏សម្រាប់អនាគតកូនចៅជំនាន់ក្រោយៗ នៅក្នុងស្ថានភាពមួយដែលការប្រែប្រួលអាកាសធាតុបានក្លាយទៅជាកត្តាមិនអាចកាត់ផ្តាច់បានពីការអភិវឌ្ឍរបស់យើង? ជាការពិត ខ្ញុំពុំមានការស្រមើស្រម៉ៃរបស់ជនឧត្តមគតិនិយមថា ទ្រឹស្តីបរិស្ថានទាំងអស់ដែលខ្លួនបានសិក្សារៀនសូត្រនៅឯសាកលវិទ្យាល័យ សុទ្ធតែអាចទាញយកទៅអនុវត្តបាននៅគ្រប់ពេល គ្រប់ស្ថានភាពនោះទេ។ តថភាពសង្គម គឺពិតជាមិនផ្តល់ភាពងាយស្រួលបែបនេះឡើយ។ ទោះជាយ៉ាងណាក្តី ក្នុងនាមខ្ញុំជារដ្ឋមន្ត្រីក្រសួងបរិស្ថាននៃអាណត្តិនេះ សូមបញ្ជាក់ថា យ៉ាងហោចណាស់អ្វីដែលខ្ញុំចង់សម្រេចឱ្យបាននៅក្នុងរយៈពេលប្រាំឆ្នាំខាងមុខ គឺការធានាថារាល់មន្ត្រីស៊ីវិលក្រសួងបរិស្ថានទាំងអស់ នឹងឈានជើងឆ្ពោះទៅមុខប្រកបដោយមោទនភាពជាមួយនឹងតួនាទីរបស់ខ្លួនក្នុងក្រសួងនេះ ទទួលបាននូវការគោរព និងមានការប្តេជ្ញាចិត្តខ្ពស់ក្នុងបុព្វហេតុការពារ និងថែរក្សាបរិស្ថានជាតិ។ ខ្ញុំសូមសង្កត់ធ្ងន់លើពាក្យថា "មន្ត្រីស៊ីវិល" ជំនួសឱ្យពាក្យ "មន្ត្រីរាជការ" ឬបុគ្គលិករាជរដ្ឋាភិបាល ដោយសារតែខ្ញុំមានជំនឿដោយសុទ្ធចិត្តថា យើងមានតួនាទីជាអ្នកបម្រើសាធារណជន មិនមែនជាការបញ្ជាសមកវិញនោះទេ។ យើងចាំបាច់ត្រូវមាន គោលនយោបាយ ផែនការ និងសកម្មភាព

ច្បាស់លាស់ និងទូលំទូលាយ ដើម្បីអាចឱ្យយើងសម្រេចបានលទ្ធផលជាក់ស្តែង និងពិតៗ។ យើងចាំបាច់ទាមទារនូវការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសគឺយុវជនដែលជាកម្លាំងចលករគន្លឹះនៃវឌ្ឍនភាពសង្គមរបស់យើង។

បើក្រឡេកមើលលើកិច្ចខិតខំប្រឹងប្រែងរបស់យើង ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុវិញ ខ្ញុំគិតថាទាំងអស់គ្នាបានដឹងរួចហើយអំពីសមិទ្ធផលគួរឱ្យកត់សម្គាល់ ដែលកម្ពុជាសម្រេចបានកន្លងមក។ ប្រាកដណាស់ថាយើងត្រូវប្តេជ្ញាខិតខំយ៉ាងពេញទំហឹងតាមដែលអាចធ្វើទៅបាន ដើម្បីឱ្យកម្ពុជានៅតែឈានមុខគេលើការដោះស្រាយបញ្ហាអាកាសធាតុ។ ជាការពិតក្នុងនាមជាប្រទេសអភិវឌ្ឍតិចតួច សមត្ថភាព និងធនធានហិរញ្ញវត្ថុរបស់កម្ពុជានៅមានកម្រិត ដូច្នេះភាពជាដៃគូ និងការគាំទ្រពីសំណាក់ភាគីពាក់ព័ន្ធទាំងអស់គឺជាកត្តាចាំបាច់ ដើម្បីសម្រេចបាននូវគោលបំណងនេះ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា វេទិកាជាតិនេះ រួមទាំងម្ហូបអាហារ និងភេសជ្ជៈនៅទីនេះនឹងផ្តល់នូវលក្ខខណ្ឌអំណោយផល សម្រាប់ការពង្រឹងភាពជាដៃគូ និងការសម្រេចបាននូវគោលដៅរួមរបស់យើង។

ឥឡូវនេះ ខ្ញុំសូមអញ្ជើញភ្ញៀវកិត្តិយសទាំងអស់ចូលរួមពិសារភេសជ្ជៈ និងអាហារ ហើយជជែកពិភាក្សាគ្នាដោយរីករាយ និងដោយចំហ នាវេលារាត្រីដ៏សែនមនោរម្យនេះ។ ខ្ញុំសូមអញ្ជើញអ្នកទាំងអស់គ្នាលើកកែវឡើង ដើម្បីជោគជ័យរបស់ដំណើរការវេទិកាជាតិលើកទី៣ ដ៏សំខាន់នេះ និងដើម្បីភាពរីកចម្រើនលូតលាស់នៃប្រទេសកម្ពុជាឆ្ពោះទៅរកសង្គមមួយដែលបៃតង បញ្ចេញកាបូនតិច ធន់នឹងការប្រែប្រួលអាកាសធាតុ ប្រកបដោយសមធម៌ មានចីរភាព និងផ្អែកលើចំណេះដឹង។

សូមអរគុណ។

# ថ្ងៃទី ២៖ ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៣

## សុន្ទរកថាស្វាគមន៍

### ដោយ ឯកឧត្តម ប៉ាន ប៊ុនធឿន រដ្ឋលេខាធិការក្រសួងផែនការ

**សូមគោរពឯកឧត្តម លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ!**

១. ខ្ញុំមានកិត្តិយសបំផុតដែលបានអញ្ជើញមកថ្លែងសុន្ទរកថាស្វាគមន៍នៅថ្ងៃទី២ នៃវេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ បន្ទាប់ពីពិធីបើកវេទិកានេះជាផ្លូវការកាលពីម្សិលមិញនេះដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

២. ដូចដែលយើងបានឮកាលពីម្សិលមិញស្រាប់ក្នុងសុន្ទរកថាសម្តេចតេជោនាយករដ្ឋមន្ត្រីដែលខ្ញុំ សូមដកស្រង់ខ្លឹមសារដើមទាំងស្រុង "ការប្រែប្រួលអាកាសធាតុលែងជាអ្វីដែលស្ថិតនៅឆ្ងាយពីយើងទៀតហើយ។ ការប្រែប្រួលអាកាសធាតុកំពុងបង្កឥទ្ធិពលមកលើយើងទាំងអស់គ្នាក្នុងពេលបច្ចុប្បន្ន..."។ ប្រទេស យើងបន្តប្រឈមការលំបាកចម្បងៗបណ្តាលពីហានិភ័យដែលបង្កដោយការប្រែប្រួលអាកាសធាតុ ហើយជាការគួរឱ្យស្តាយ ផលប៉ះពាល់ខ្លាំងនឹងកើតមានមកលើសហគមន៍ក្រីក្របំផុត ដែលងាយរងគ្រោះបំផុត ជាពិសេសសហគមន៍ជនបទ និងតំបន់ដាច់ស្រយាល។
សម្តេចនាយករដ្ឋមន្ត្រី បានរំលឹកអំពីទឹកជំនន់ កន្លងទៅថ្មីៗនេះនៅទូទាំងប្រទេស។ យោងតាមគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ខេត្តចំនួន ២០ បានរងឥទ្ធិពលពីទឹកជំនន់នេះដោយមិនប្រជាជនជិត ២លាននាក់ រងការប៉ះពាល់ដោយផ្ទាល់។ ជំនន់នេះបានធ្វើឱ្យមនុស្សច្រើនជាង ១៥០នាក់បាត់បង់ជីវិត និងការខូចខាតធ្ងន់ធ្ងរចំពោះវិស័យកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធដូចជា ផ្លូវថ្នល់ ស្ពាន និងទំនប់។ បញ្ហានេះបានបង្កឱ្យមានការខូចខាតធំធេង ចំពោះរបរចិញ្ចឹមជីវិតរបស់ប្រជាជន កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍជាតិ។

៣. សម្តេចតេជោបានរម្លឹកនៅក្នុងសុន្ទរកថាកាលពីម្សិលមិញថា "វិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ មានការពាក់ព័ន្ធជិតស្និទ្ធជាមួយគោលដៅអភិវឌ្ឍន៍ សេដ្ឋកិច្ច និងសង្គមរបស់យើង និងមិនមែនជាអ្វីមួយដែលអាចអនុវត្តជាសកម្មភាពបន្ទាប់បន្សំដែលគ្រាន់តែជាការបន្ថែមនោះឡើយ។ វាត្រូវតែរួមបញ្ចូលយ៉ាងជិតស្និទ្ធតាមវិធីដែលអាចគ្រប់គ្រងកម្មវិធីអភិវឌ្ឍន៍ និងការវិនិយោគដែល មានស្រាប់របស់យើង។" ដូច្នេះយើងត្រូវការចេមានផែនការសមាហរណកម្មកម្រិតខ្ពស់ជាងមុនសម្រាប់ ការអភិវឌ្ឍរបស់យើង ដោយផ្អែកលើចក្ខុវិស័យអំពីអាកាសធាតុ។ ជាពិសេស យើងត្រូវប្រឹងប្រែងឈានទៅ ប្រើប្រាស់ការប្រែប្រួលអាកាសធាតុជាលក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសយករាល់ការវិនិយោគ និងដំណើរការកសាងផែនការ ដូចជាយេនឌ័រដូច្នោះដែរ។

៤. ប្រសិនបើយើងសង្កេតមើលគោលដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់យើង ការគិតគូរ អំពីការប្រែប្រួលអាកាសធាតុគឺជាលក្ខខណ្ឌមួយ ដើម្បីធានាឱ្យមានជោគជ័យ។ ផ្អែកលើកំណើនសេដ្ឋកិច្ច នៅទសវត្សរ៍កន្លងទៅ កម្ពុជាទំនងនឹងសម្រេចបានឋានៈជាប្រទេសដែលមានប្រាក់

ចំណុចកម្រិតកណ្ដាល។ ដូចគ្នានេះដែរកម្ពុជា កំពុងស្ថិតក្នុងស្ថានភាពល្អ ក្នុងការសម្រេចចំណុចដៅសំខាន់ៗនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ដូចជា កាត់បន្ថយភាពក្រីក្រពាក់កណ្ដាលការថែទាំសុខភាពមាតា និងការអប់រំជាសកល។ រាជរដ្ឋាភិបាល កម្ពុជានៅតែប្ដេជ្ញាមោះមុតបន្តអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ដូចមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណថ្មីដំណាក់កាលទី៣។ ទោះជាយ៉ាងណាក៏ដោយ កំណើនដែលសម្រេចបានកន្លងមកអាចនឹងបាត់បង់ទៅវិញដោយងាយ ដោយសារតែការប្រែប្រួលអាកាសធាតុ ហើយ កិច្ចប្រឹងប្រែងទៅអនាគតអាចជួបការលំបាកលើកលែងតែបានបញ្ចូលបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការកសាងផែនការរបស់យើង។

៥. នៅក្នុងការដាក់បញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ របស់ជាតិ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តជំហានសំខាន់ៗមួយចំនួនរួចមកហើយ។ ដូចដែលសម្ដេចតេជោ នាយករដ្ឋមន្ត្រីមានប្រសាសន៍ពីម្សិលមិញ *"ការប្រែប្រួលអាកាសធាតុបានក្លាយជាផ្នែកសំខាន់មួយនៃ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមបច្ចុប្បន្នកម្ម ២០០៩-២០១៣ របស់យើង ហើយឥឡូវនេះបានក្លាយ ជាផ្នែកមួយនៃយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាល ហើយវានឹងក្លាយជា ជាបញ្ហាអន្តរវិស័យផ្លូវការនៅ ក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមថ្មី ឆ្នាំ២០១៤-២០១៨ របស់ជាតិយើង។ ការដោះស្រាយបញ្ហា ប្រែប្រួលអាកាសធាតុ ក៏ជាសមាធាតុគន្លឹះមួយនៃគោលនយោបាយ នឹងផែនការសកម្មភាពអភិវឌ្ឍន៍បៃតង របស់យើងផងដែរ។"*

៦. ក្រសួងផែនការនឹងបន្តធានាឱ្យមានការដាក់បញ្ចូលសូចនាករពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ទៅក្នុងក្របខ័ណ្ឌពិនិត្យតាមដែនផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ដោយសហការជាមួយ ក្រសួងបរិស្ថាន យើងនឹងផ្ដល់ការគាំទ្រដល់ក្រសួងពាក់ព័ន្ធដើម្បីរួមបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុង ឯកសារធាតុចូលរបស់ក្រសួងទាំងនោះ សម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ នៅកម្រិតវិស័យថ្ងៃនេះ យើងនឹងមានការពិភាក្សាអំពីការងារដែលក្រសួងពាក់ព័ន្ធចំនួនដប់បានអនុវត្ត ដើម្បីបង្កើតផែនការ យុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងផែនការសកម្មភាពប្រែប្រួលអាកាសធាតុរបស់ខ្លួន ដែលជាការបង្ហាញពីកិច្ចប្រឹងប្រែងអនុវត្តដើម្បីដាក់បញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការ កសាងផែនការជាប្រក្រតីរបស់ខ្លួននិងបញ្ចៀសការចាត់ទុកការប្រែប្រួលអាកាសធាតុថាជាផ្នែកមួយនៅដាច់តែឯង។ ការងារនេះជំរុញឱ្យមានវិធីសាស្ត្រហ្មត់ចត់ ដោយផ្អែកលើសេណារីយ៉ូហិរញ្ញប្បទានប្រាកដនិយម ដើម្បីចៀសវាងការបង្កើត "តារាងសកម្មភាពដែលគ្រាន់តែជាការចង់បាន"ប៉ុន្តែត្រូវដាក់ចុះនូវកម្មវិធីជាក់លាក់ មានភាពស៊ីសង្វាក់គ្នា និងប្រាកដនិយម។

៧. ឯកឧត្ដម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកាអង្គវេទិកាទាំងអស់ជាទីមេត្រី! ទោះជាយ៉ាងណាក៏ យើងនៅមានកិច្ចការជាច្រើនដែលត្រូវសម្រេចឱ្យបាន។ ការកសាងសមត្ថភាព គឺជាតម្រូវការបន្ទាន់ ដើម្បីអាចរួមបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការអភិវឌ្ឍន៍ជាតិ ក៏ដូចជាការបង្កើតក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃដែលនឹងជួយតាមដានជោគជ័យនៅក្នុងការវិនិយោគលើការងារប្រែប្រួលអាកាសធាតុ និងផ្ដល់ជាមាគ៌ាសម្រាប់ការរៀនសូត្រ សំដៅតែលម្អមូលដ្ឋានចំណេះដឹងរបស់យើង។ យើងនៅមានកិច្ចការជាច្រើនទៀតដែលត្រូវសម្រេចឱ្យបាន

នៅក្នុងការស្រង់យកមេរៀនដែលទទួលបានពីបទពិសោធន៍ក្នុងគម្រោងសាកល្បង ដែលមានស្រាប់ សម្រាប់បញ្ចូលការប្រែប្រួលអាកាសធាតុ ទៅក្នុងការកសាងផែនការនៅថ្នាក់ក្រោមជាតិ និងការបង្កើតគោលការណ៍ណែនាំ ផ្លូវការ និងគាំទ្រដល់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ។

៨. ក្នុងពេលដែលការបន្សាំ គឺជាអាទិភាពបន្ទាន់បំផុតរបស់យើង ការកសាងផែនកាអភិវឌ្ឍន៍ជាតិ ទាមទារឱ្យសម្លឹងវែងឆ្ងាយទៅអនាគត ដើម្បីប្រែក្លាយសង្គមរបស់យើង ទៅរកការអភិវឌ្ឍដែលបញ្ចេញកាបូនតិច និងធន់ទ្រាំនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុទៅអនាគត។ ដូចដែលសម្តេចតេជោនាយករដ្ឋមន្ត្រីបានគូសបញ្ជាក់"*កាបន្សុីគ្នាឡើងវិញនូវការអភិវឌ្ឍរបស់យើងឆ្ពោះទៅសង្គមមួយ ដែលមានភាពធន់ និងការអភិវឌ្ឍដែលបញ្ចេញកាបូនតិច។*" ក្រៅពីការបន្សាំ យើងកំពុងចាត់វិធានការ ដើម្បីរួមចំណែកក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ តាមរយៈដំណោះស្រាយឈ្នះ-ឈ្នះ។ យើងបានខិតខំអភិវឌ្ឍថាមពលកកើតឡើងវិញនៅក្នុងការពង្រីកការផលិតថាមពល និងពង្រីកការផ្តល់សេវាថាមពលដល់ទីជនបទ ប្រជាជននៅតាមទីក្រុងដែលមានកំណើនយ៉ាងឆាប់រហ័ស វិស័យឧស្សាហកម្ម និងសេវាកម្ម។ យើងក៏ជំរុញឱ្យមានទម្លាប់បង្កើនប្រសិទ្ធភាពថាមពលផងដែរ ដោយសារវាផ្តល់អត្ថប្រយោជន៍សម្រាប់ធុរកិច្ចនានាក្នុងការបង្កើនផលចំណេញរបស់ខ្លួន ដោយជាមួយគ្នានោះរួមចំណែកក្នុង កិច្ចប្រឹងប្រែងកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

៩. អនុសាសន៍ដែលយើងនឹងទទួលបានពីការពិភាក្សានាថ្ងៃនេះ ស្របពេលសម្រាប់ដាក់បញ្ចូល ទៅក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិសម្រាប់រយៈពេល៥ឆ្នាំខាងមុខ។ ខ្ញុំសូមលើកទឹកចិត្តដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រើប្រាស់ឱកាសនេះ ដើម្បីស្វែងយល់បន្ថែមទៀត ពីការងារប្រែប្រួលអាកាសធាតុ និងសូមចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការពិភាក្សា។ ជាមួយដំណើរការពិស្តារនៃការកសាងផែនការយុទ្ធសាស្ត្រ យើងសង្ឃឹមថានឹងសម្រេចបានវិធានការឆ្លើយតបរបស់ជាតិ ក្នុងកម្រិតធំគ្រប់គ្រាន់ បានឆាប់រហ័ស និងចំគោលដៅជាយុទ្ធសាស្ត្រ។

១០. ខ្ញុំសូមឯកឧត្តម លោក លោកស្រី ទទួលបានពុទ្ធពរទាំងបួនប្រការ និងការពិភាក្សាប្រកបដោយផ្លែផ្កា។

# សុន្ទរកថាស្វាគមន៍របស់

## ដោយ ឯកឧត្តម JEAN-FRANÇOIS CAUTAIN ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំកម្ពុជា

សូមគោរពឯកឧត្តម ប៉ាន ប៊ុនធឿន រដ្ឋលេខាធិការក្រសួងផែនការ និង ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់!

កាលពីពីរថ្ងៃមុនខ្ញុំបានពិភាក្សាការងារជាមួយសហគមន៍នេសាទនៅបឹងទន្លេសាប។ នៅពេលនោះ ខ្ញុំបានសួរក្រុមអ្នកនេសាទទាំងអស់នោះពីបញ្ហាប្រឈមរបស់ពួកគាត់ក្នុងការរស់នៅ ខ្ញុំបានទទួលចម្លើយថា គឺការនេសាទលើសកំណត់ និងបន្ទាប់មកគឺការប្រែប្រួលអាកាសធាតុ។ ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុបានកើតឡើងកាន់តែច្បាស់។ ប៉ុន្តែសកម្មភាពដែលឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅមានប្រសិទ្ធភាពតិចតួចនៅឡើយ។ ប្រសិនបើគ្មានដោយសកម្មភាពសមស្របទាន់ពេលវេលាទេ ពិភពលោកនឹងកើនកម្តៅ ពី 3-4°C នៅចុងសតវត្សរ៍នេះ។

អាស្រ័យហេតុនេះ ការកាត់បន្ថយការប្រែប្រួលអាកាសធាតុនៅមុនឆ្នាំ ២០២០ មានភាពចាំបាច់បំផុត ក្នុងទិសដៅបញ្ចុះកម្តៅ២°C។ សកម្មភាពកាត់បន្ថយនេះរួមមានសកម្មភាពជំរុញឱ្យបណ្តាប្រទេសនានា កាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដូចដែលបានសន្យារួមគ្នា និងលើកទឹកចិត្ត ដល់បណ្តាប្រទេសដែលមិនទាន់បានសន្យាឱ្យចុះកិច្ចសន្យាកាត់បន្ថយការបញ្ចេញ ក៏ដូចជាកិច្ចផ្តួចផ្តើមកម្រិត អន្តរជាតិថ្មីនៅក្នុងវិស័យជាក់លាក់ដើម្បីបង្កើនសកម្មភាពកាត់បន្ថយ។

នៅក្នុងកិច្ចប្រជុំបណ្តាប្រទេសជាភាគីលើកទី១៩ នៅក្នុងទីក្រុងវ៉ាស្សូវី សហភាពអឺរ៉ុប ចង់ឃើញវឌ្ឍនភាពនៃការរៀបចំ និងរចនាសម្ព័ន្ធផ្លូវច្បាប់នៃកិច្ចព្រមព្រៀងអន្តរជាតិ ហើយដែលគ្រោងនឹងបញ្ចប់នៅឆ្នាំ ២០១៥។ ការងារនេះរួមបញ្ចូលនូវការកំណត់ព័ត៌មានចាំបាច់ក្នុងការធានានូវតម្លាភាព គុណវឌ្ឍ និងការប្តេជ្ញាចិត្តខ្ពស់។ ដើម្បីសម្រេចបាននូវការងារនេះ យើងត្រូវការក្របខ័ណ្ឌ ពេលវេលាសម្រាប់បណ្តាប្រទេសនានា ស្នើឡើងជាមុននូវការប្តេជ្ញាចិត្ត កាត់បន្ថយនៅក្នុងប្រទេសរបស់ខ្លួនក្នុងកិច្ចព្រមព្រៀងឆ្នាំ២០១៥។

សហភាពអឺរ៉ុបមានការប្តេជ្ញាចិត្តខ្ពស់ និងកំពុងបំពេញកិច្ចការនេះដើម្បីដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុដោយមោទនភាពបំផុត។

សហភាពអឺរ៉ុបបានបង្ហាញនូវទិន្នន័យថ្មីៗ ដែលទាក់ទងនឹងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ឆ្នាំ ២០១១ ទៅបណ្តាប្រទេសជាសមាជិក ដែលប្រទេសទាំងនោះបានកាត់បន្ថយនូវការបញ្ចេញឧស្ម័នឱ្យបាន ១៨.៤% ធៀបនឹងឆ្នាំ១៩៩០ ខណៈដែល GDP មានកំណើនច្រើនជាង ៤០%។

នៅសហភាពអឺរ៉ុប យើងមានច្បាប់កំណត់ដែលធានាថា បណ្តាប្រទេសក្នុងសហភាពអឺរ៉ុបទាំងអស់ នឹងអាចសម្រេចនូវទិសដៅរបស់ខ្លួនទៅតាមពិធីសារក្យូតូ។ បើយោងតាមច្បាប់នេះ យើងកំពុងអនុវត្តការប្តេជ្ញាចិត្តផ្លូវច្បាប់ ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នរហូតដល់ ២០% នៅឆ្នាំ ២០២០ បើធៀបទៅនឹងកម្រិតឆ្នាំ ១៩៩០។ លើសពីនេះទៅទៀត សហភាពអឺរ៉ុបកំពុងជំរុញការកាត់បន្ថយឱ្យបាន ៣០% ប្រសិនបើប្រទេសផ្សេងៗមានមហិច្ឆតាដូចគ្នា។

នៅប្រទេសកម្ពុជា ការប្រើប្រាស់ថាមពលដែលបញ្ចេញនូវឧស្ម័នកាបូនិចមានការកើនឡើងទ្វេដង ក្នុងរយៈពេលដប់ឆ្នាំចុងក្រោយនេះ ដែលនេះជាការប្រឈមធំរបស់គោលនយោបាយជាតិស្តីពីថាមពល។ ស្របជាមួយគ្នានេះដែរ ខ្ញុំមានសេចក្តីរីករាយខ្លាំងណាស់ដែលកម្ពុជា មានសេចក្តីព្រាងគោលនយោបាយជាតិ ផែនការយុទ្ធសាស្រ្ត និងផែនការសកម្មភាពស្តីពីប្រសិទ្ធភាពថាមពលរួចហើយក្រោមការជួយឧបត្ថម្ភពីសហភាពអឺរ៉ុប។ កិច្ចប្រឹងប្រែងនេះបានបង្ហាញពីឆន្ទៈដ៏ពិតប្រាកដរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានធ្ងន់ធ្ងរទៅលើបរិស្ថាន ដែលបណ្តាលមកពីការប្រើប្រាស់ថាមពល និងដើម្បីរួមចំណែកដល់ការកាត់បន្ថយការប្រែប្រួលអាកាសធាតុជាសកល។

ឯកឧត្តម លោក លោកស្រី ភ្ញៀវកិត្តិយសជាទីមេត្រី!

សហភាពអឺរ៉ុប មានកំណត់ត្រាទិន្នន័យច្បាស់លាស់ក្នុងហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ។ សហភាពអឺរ៉ុបបានត្រៀមថវិកាប្រមាណ ៧.៣ពាន់លានដុល្លាអាមេរិច ក្នុងរយៈពេលពីឆ្នាំ ២០១០ ដល់ ឆ្នាំ២០១២ ដើម្បីកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

សហភាពអឺរ៉ុបមានឆន្ទៈក្នុងការចាត់ចែងធនធានហិរញ្ញវត្ថុប្រមាណជា ១០០ ពាន់លានដុល្លាសហរដ្ឋអាមេរិចក្នុងមួយឆ្នាំនៅឆ្នាំ២០២០ ដែលមកពីប្រភពផ្សេងៗ។ សហភាពអឺរ៉ុប និងប្រទេសសមាជិក នឹងបន្តគាំទ្រក្នុងសកម្មភាពការប្រែប្រួលអាកាសធាតុនៅបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដោយផ្តល់ហិរញ្ញប្បទានតាមរយៈរដ្ឋាភិបាល និងវិស័យឯកជន។ យើងក៏មានកម្មវិធីបញ្ចូលហិរញ្ញប្បទានអាកាសធាតុប្រមាណ ២០% នៃហិរញ្ញប្បទានសរុបចាប់ពីឆ្នាំ ២០១៤ ដល់ឆ្នាំ ២០២០ ដល់សកម្មភាពទាំងឡាយណាដែលទាក់ទងនឹងអាកាសធាតុ។

ការពង្រីកហិរញ្ញប្បទានអាកាសធាតុនៅឆ្នាំ ២០២០ គឺជាដំណើរការអាទិភាព។ ការរៀបចំគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ស្តីពីអាកាសធាតុថ្នាក់ជាតិនឹងត្រូវអនុវត្តដោយទទួលការគាំទ្រពីដៃគូអន្តរជាតិ។ អាស្រ័យហេតុនេះ ការពង្រីកហិរញ្ញប្បទានអាកាសធាតុតម្រូវឱ្យមានការចូលរួមធ្វើការជាមួយគ្នានៅបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។

នៅក្នុងបុព្វហេតុនេះ ខ្ញុំមានអារម្មណ៍រីករាយខ្លាំងណាស់ដែលសហភាពអឺរ៉ុបរួមជាមួយនឹងរដ្ឋាភិបាលប្រទេសដាណឺម៉ាក ប្រទេសស៊ុយអែដ និងអង្គការ UNDP បានគាំទ្ររដ្ឋាភិបាលកម្ពុជាក្នុងការបង្កើតនូវកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា។ សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជាគឺជាការរួមបញ្ចូលនូវកិច្ចការរួមគ្នា ដើម្បីគាំទ្រដល់ផែនការសកម្មភាពថ្នាក់សាមីក្រសួង ដើម្បីបញ្ជ្រាបការធ្វើផែនការ ការចំណាយ និងការអនុវត្តនៅថ្នាក់ក្រសួង។

សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា បានរួមចំណែកយ៉ាងសំខាន់ក្នុងការរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុជាតិនៃការប្រែប្រួលអាកាសធាតុ ដើម្បីផ្តល់ព័ត៌មានជាក់លាក់ក្នុងការកសាងសេណារីយ៉ូហិរញ្ញវត្ថុ ខ្ទង់ចំណាយ ផលប្រយោជន៍រំពឹងទុក និងអនុសាសន៍នានា សម្រាប់យន្តការហិរញ្ញប្បទានអាកាសធាតុ និងការសម្របសម្រួល។

ខ្ញុំសូមសង្ខេបនូវសុន្ទរកថារបស់ខ្ញុំថា វេទិកាជាតិ ស្ដីពីការប្រែប្រួលអាកាសធាតុដែលរៀបចំឡើងពីរឆ្នាំម្ដងនេះ បានទទួលនូវការតាំងចិត្តខ្ពស់ពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពុះពារក្នុងការដោះស្រាយនូវរាល់ឧបសគ្គនានាពីការប្រែប្រួលអាកាសធាតុ។ យើងមានសេចក្ដីរីករាយយ៉ាងក្រៃលែង ហើយតាងនាមឱ្យសហភាពអឺរ៉ុប យើងនឹងបន្តជួយគាំទ្រប្រទេសកម្ពុជាក្នុងការតាក់តែង និងរៀបចំគោលនយោបាយថ្នាក់ជាតិ និងក្របខ័ណ្ឌបទបញ្ញានានា ហើយសូមស្វាគមន៍ជានិច្ចនូវដៃគូអភិវឌ្ឍន៍នានាក្នុងធ្វើការងារលើការប្រែប្រួលអាកាសធាតុនេះរួមគ្នា។

នៅព្រឹកមិញនេះ ខ្ញុំបានអានព័ត៌មានក្នុងកាសែត Reuters ខ្ញុំសូមដកស្រង់ដូចខាងក្រោម "ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នឹងកើនពីដល់ ៨ ទៅ ១២ ពាន់លានតោនឆ្នាំ២០២០ ហើយបរិមាណនេះខ្ពស់ជាងបរិមាណដែលធ្វើឱ្យផែនដីកើនកម្ដៅ ២°C ទៅទៀត"។

ជាបញ្ចប់ខ្ញុំសង្ឃឹមថា ការពិភាក្សា និងអនុសាសន៍ដែលទទួលបានពីអង្គវេទិកានេះនឹងអាចជួយធ្វើឱ្យការប៉ាន់ប្រមាណខាងលើនោះ ក្លាយជារឿងមិនពិត និងធ្វើឱ្យផែនដីរបស់យើងក្លាយជាពិភពបៃតង។

សូមអរគុណចំពោះការយកចិត្តទុកដាក់របស់លោកអ្នក។

## ថ្ងៃទី ៣៖ ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៣

# សុន្ទរកថាស្វាគមន៍

## ដោយ ឯកឧត្តម រស់ លីលវ៉ា អនុរដ្ឋលខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយស ជាទីគោរព

ខ្ញុំមានសេចក្តីសោមនស្សរីករាយជាខ្លាំង ដែលបានចូលរួមក្នុងពិធីបើកវគ្គនៃថ្ងៃចុងក្រោយរបស់វេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុនេះ។

ដំណើរការវេទិការយៈពេលពីរថ្ងៃកន្លងមក បានផ្តល់ឱកាសឱ្យយើងធ្វើការពិភាក្សាលម្អិតពីការងារ ដែលក្រសួងពាក់ព័ន្ធ ក្រសួងបរិស្ថាន និងដៃគូរបស់ខ្លួន បានអនុវត្តក្នុងអំឡុងពេលពីរឆ្នាំកន្លងមកដើម្បីរៀបចំនូវផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដ៏សមស្របមួយសម្រាប់កម្ពុជា។ គម្រោងជាច្រើនទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ដែលត្រូវបានអនុវត្តរហូតមកដល់បច្ចុប្បន្ន បានជួយឱ្យយើងមានការយល់ដឹងកាន់តែប្រសើរឡើងពីវិធីសាស្ត្រដែលមានប្រសិទ្ធភាពសម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ នៅក្នុងបរិបទនៃប្រទេសកម្ពុជា។ ឥឡូវនេះ ជាមួយនឹងការប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា យើងមានមូលដ្ឋានរឹងមាំច្បាស់លាស់ ដើម្បីអនុវត្តកម្មវិធីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុជាទ្រង់ទ្រាយធំ។ ប៉ុន្តែ ដូចដែលយើងទាំងអស់គ្នាបានដឹងហើយថា កម្មវិធីនេះអាចដំណើរការទៅបានលុះត្រាណាតែយើងអាចកៀរគរធនធានហិរញ្ញវត្ថុបានគ្រប់គ្រាន់ជាមុន។

នៅថ្នាក់ពិភពលោក ទឹកប្រាក់ចំណាយទៅលើសកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុត្រូវបានគេប៉ាន់ស្មានថា មានប្រមាណពី ៤០ ទៅ៥០០ ពាន់លានដុល្លារអាមេរិក ក្នុងមួយឆ្នាំៗ។ បើទោះបីជាបណ្តាប្រទេសអភិវឌ្ឍន៍ធ្វើតាមការសន្យា ដែលខ្លួនបានប្រកាសនៅក្នុងសន្និសិទលើកទី១៦នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុនៅឆ្នាំ២០១០ក្តី ក៏កង្វះខាតថវិកានៅតែជាបញ្ហាចោទ ព្រោះថាទឹកប្រាក់សរុបដែលអាចកៀរគរបានសម្រាប់ទ្រទ្រង់ការចំណាយក្នុងមួយឆ្នាំៗរហូតដល់ឆ្នាំ២០២០ គឺមានតិចជាង១០០ពាន់លានដុល្លារអាមេរិក ហើយក្នុងនោះ ទឹកប្រាក់មួយភាគធំនឹងត្រូវយកទៅប្រើប្រាស់ក្នុងគម្រោងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ជាជាងលើការងារបន្សាំ។ សម្រាប់ប្រទេសកំពុងអភិវឌ្ឍ ដូចជាប្រទេសកម្ពុជា ដែលថ្មីៗនេះត្រូវបានគេចាត់ចូលក្នុងចំណោមប្រទេសចំនួន១០ ដែលងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុបំផុតនោះ ការធានាឱ្យមានគ្រប់គ្រាន់នូវថវិកាសម្រាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ គឺជាការចាំបាច់បំផុត។ នេះមានន័យថា គម្លាតរវាងតម្រូវការ និងការផ្គត់ផ្គង់ហិរញ្ញប្បទាននៅតែមានទំហំធំ ដែលតម្រូវឱ្យកម្ពុជាមានជាចាំបាច់នូវសមត្ថភាពគ្រប់គ្រាន់ក្នុងការទាក់ទាញហិរញ្ញប្បទាន សំដៅធានាឱ្យបាននូវទីតាំងដ៏រឹងមាំក្នុងការប្រកួតប្រជែងយកធនធានដែលមានកំរិតនៅថ្នាក់អន្តរជាតិ ដើម្បីបំពេញតាមតម្រូវការរបស់ខ្លួនក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

កម្ពុជាត្រូវការយន្តការដែលគួរឱ្យជឿទុកចិត្ត និងមានភាពទាក់ទាញសម្រាប់ហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ ដើម្បីធានាប្រសិទ្ធភាពនៃការកៀរគរធនធានដែលមាន។ យើងបានបង្ហាញឱ្យឃើញរួចមកហើយ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ពីសមត្ថភាពរបស់យើងក្នុងការកៀរគរ និងគ្រប់គ្រងហិរញ្ញប្បទានពីប្រភពផ្សេងៗ រួមមានថវិកាពីមូលនិធិបន្សាំ មូលនិធិសម្រាប់ប្រទេសមានការអភិវឌ្ឍតិចតួច មូលនិធិវិនិយោគប្រែប្រួលអាកាសធាតុ ក៏ដូចជាមូលនិធិសម្រាប់ការងារប្រែប្រួលអាកាសធាតុពីសហភាពអឺរ៉ុប សហរដ្ឋអាមេរិក ជប៉ុន ស៊ុយអែត កូរ៉េខាងត្បូង និងបណ្តាប្រទេសផ្សេងៗទៀត។ ជារួមទឹកប្រាក់ប្រមាណ ២៥០ លានដុល្លារអាមេរិក ត្រូវបានកៀរគរយកមកប្រើប្រាស់ក្នុងរយៈពេលបីឆ្នាំកន្លងមក។ ក្នុងពេលជាមួយគ្នានោះ ការពិនិត្យទៅលើចំណាយសាធារណៈពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ដែលត្រូវបានធ្វើឡើងក្នុងឆ្នាំ២០១២ បានបង្ហាញឱ្យឃើញថាប្រហែល១៦% នៃការចំណាយសរុបគឺបានមកពីថវិកាជាតិ ឧទាហរណ៍ដូចជាតាមរយៈការវិនិយោគទៅលើការឆ្លើយតបនឹងគ្រោះមហន្តរាយ ឬហេដ្ឋារចនាសម្ព័ន្ធជនបទ។

នៅពេលដែលលំហូរធនធានហិរញ្ញវត្ថុ សម្រាប់គ្រប់គ្រងបញ្ហាអាកាសធាតុ កាន់តែរីកធំឡើង យើងត្រូវបង្កើតយន្តការសម្រាប់ពង្រីកការងារឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ឱ្យស្របទៅនឹងថវិកាដែលទទួលបាន។ រហូតដល់ឆ្នាំ២០២០ គេរំពឹងថា ហិរញ្ញប្បទានអាកាសធាតុ នឹងកើនឡើងប្រហាក់ប្រហែលទៅនឹងថវិកាសរុបរបស់ជំនួយអភិវឌ្ឍន៍ផ្លូវការ ដែលកំពុងត្រូវបានចំណាយនាពេលបច្ចុប្បន្ននៅទូទាំងពិភពលោក។ ដូច្នេះជាប្រការសំខាន់បំផុតក្នុងការធានាឱ្យបាននូវការគ្រប់គ្រងធនធានប្រកបដោយប្រសិទ្ធភាព ស្របតាមគោលការណ៍នៃសេចក្តីប្រកាសទីក្រុងប៉ារីស ស្តីពីប្រសិទ្ធភាពជំនួយ។ ខ្ញុំរំពឹងថា ក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ ដែលបច្ចុប្បន្នកំពុងត្រូវបានអភិវឌ្ឍនឹងដើរតួជាមគ្គុទេសន៍ ដឹកនាំឱ្យសម្រេចបាននូវគោលបំណងនេះ ប៉ុន្តែខ្ញុំក៏មានបំណងចង់ចែករំលែកជាគោលគំនិតមួយចំនួនទាក់ទង នឹងតួនាទីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការរួមចំណែកគ្រប់គ្រងហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ នាពេលអនាគត។

ដើម្បីធានាបាននូវភាពជាម្ចាស់របស់ជាតិ ការបែងចែកធនធានយកទៅប្រើប្រាស់គួរតែធ្វើឡើងឱ្យស្រប ទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ជាពិសេសស្របជាមួយនឹងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹង ការប្រែប្រួលអាកាសធាតុកម្ពុជា។

បច្ចុប្បន្ន ហិរញ្ញប្បទានាភាគច្រើនត្រូវបានផ្តល់មកសម្រាប់តែដំណើរការគម្រោងមួយៗ ដាច់ដោយឡែកពីគ្នា។ នៅរយៈពេលពីរបីឆ្នាំទៅមុខទៀត យើងចង់ឱ្យមានការវិវត្ត ដោយធ្វើការផ្លាស់ប្តូរបន្តិច ម្តងៗ ពីវិធីសាស្ត្រដែលមានមូលដ្ឋានផ្អែកលើគម្រោងមួយៗ ទៅជាវិធីសាស្ត្រដែលផ្តោតលើកម្មវិធី។ ចាំបាច់ត្រូវជំរុញយន្តការមូលនិធិបែបប្រមូលផ្តុំ ក៏ដូចជាការគាំទ្រថវិកាតាមវិស័យ។ តាមរបៀបនេះ វានឹងជួយយើងក្នុងការគ្រប់គ្រងកំណើននៃលំហូរធនធាន ដោយបញ្ចៀសការចំណាយប្រតិបត្តិការហួសកំណត់ដែលកើតឡើង ដោយសារកំណើនយ៉ាងឆាប់រហ័សនៃចំនួនគម្រោង។

លើសពីនេះ វិធីនេះក៏នឹងជួយយើងក្នុងការដាក់បញ្ចូលការងារប្រែប្រួលអាកាសធាតុទៅក្នុងការធ្វើផែនការ និងការឡើងថវិកាដើម្បីអភិវឌ្ឍន៍។ យើងគួរកំណត់គោលដៅថា នៅក្នុងថេរវេលា១០ឆ្នាំទៅមុខ យើងនឹងលែងមានយន្តការហិរញ្ញប្បទាន ឬគម្រោងការប្រែប្រួលអាកាសធាតុដាច់ដោយ

ឡែកៗពីគ្នាទាំងស្រុង។ មានន័យថា ការប្រែប្រួលអាកាសធាតុគួរតែត្រូវបានប្រើជាលក្ខណៈវិនិច្ឆ័យស្តង់ដារនៅក្នុងរាល់សកម្មភាពធ្វើផែនការវិនិយោគ ទាំងសាធារណៈនិងឯកជន និងទៅក្នុងការរៀបចំថវិការបស់យើង។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងសហការជាមួយគ្រប់ក្រសួងពាក់ព័ន្ធ និងជាមួយក្រសួងបរិស្ថាន ដើម្បីធានាឱ្យបានថា យើងមានការយល់ដឹងគ្រប់ជ្រុងជ្រោយអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើការវិនិយោគតាមផែនការ និងអំពីវិធានការបច្ចេកទេស ដើម្បីដោះស្រាយផលប៉ះពាល់ទាំងនេះ។ ប្រការនេះនឹងជួយតម្រង់ទិសដៅការប្រើប្រាស់ធនធានដែលមានក្នុងស្រុក និងដែលទទួលបានពីម្ចាស់ជំនួយ សម្រាប់អនុវត្តតែការងារវិនិយោគណាដែលផ្តល់នូវអត្ថប្រយោជន៍ច្រើនបំផុតដល់សេដ្ឋកិច្ច និងសង្គមកម្ពុជានៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ។ ជាមួយគ្នានេះ យើងក៏ត្រូវធ្វើការពង្រឹងសមត្ថភាពក្នុងការតាមដានហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ និងប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានទាំងនោះ ដើម្បីឱ្យដៃគូអភិវឌ្ឍន៍មានទំនុកចិត្ត និងបន្តផ្តល់ជំនួយតាមរយៈប្រព័ន្ធជាតិរបស់យើង។

គោលដៅចម្បងសម្រាប់ប្រទេសកម្ពុជានាពេលរយៈពេលពីរទៅបីឆ្នាំបន្ទាប់នេះ គឺទទួលបាននូវហិរញ្ញប្បទានផ្ទាល់ពីមូលនិធិអាកាសធាតុសកល ដូចជា មូលនិធិបន្សាំ និងមូលនិធិអាកាសធាតុបៃតង តាមរយៈការជំរុញឱ្យមានការទទួលស្គាល់ជាផ្លូវការនូវអង្គភាពអនុវត្តន៍ជាតិ។

សម្រាប់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បញ្ហាគន្លឹះមួយផ្សេងទៀត គឺការរក្សាឱ្យបាននូវការពិភាក្សាប្រកបដោយលទ្ធផលផ្លែផ្កា ជាមួយវិស័យឯកជន លើការលើកកម្ពស់បរិយាកាសវិនិយោគមួយដែលមានអំណោយផលដល់អាជីវកម្មបៃតង។ វិស័យឯកជនដើរតួនាទីយ៉ាងសំខាន់នៅស្ទើរតែគ្រប់ផ្នែកទាំងអស់នៃផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា។ ឧទាហរណ៍ខ្លះៗ ដូចជាការអភិវឌ្ឍថាមពលកកើតឡើងវិញ ប្រសិទ្ធភាពថាមពលនៅក្នុងឧស្សាហកម្មនិងកសិឧស្សាហកម្ម ប្រសិទ្ធភាពថាមពល ក្នុងវិស័យសាងសង់ ហេដ្ឋារចនាសម្ព័ន្ធធន់នឹងអាកាសធាតុ និងផ្នែកផ្សេងៗទៀតជាច្រើន។ យើងមានកាតព្វកិច្ចក្នុងការធានាថា ប្រទេសកម្ពុជាផ្តល់នូវបរិស្ថានអំណោយផល មានស្ថេរភាព និងសន្តិសុខ សម្រាប់ការវិនិយោគបៃតង ដើម្បីឱ្យយើងអាចបង្កើនហិរញ្ញវត្ថុពីប្រភពឯកជនដើម្បីជួយដល់ការសម្រេចគោលដៅចម្បងរបស់យើង ក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់ជាទីគោរព

ដូចដែលយើងទាំងអស់គ្នាបានឃើញក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ ហើយក៏ដូចជាគ្រោះទឹកជំនន់ ដែលទើបនឹងកើតឡើងនៅប៉ុន្មានសប្តាហ៍ថ្មីៗនេះ ប្រទេសកម្ពុជាបានទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងររួចទៅហើយពីការប្រែប្រួលអាកាសធាតុ ដែលកើតមានកាន់តែញឹកញាប់ និងធ្ងន់ធ្ងរជាងមុន។ រាជរដ្ឋាភិបាល កម្ពុជាបានធ្វើវិភាជន៍ថវិកាយ៉ាងច្រើនសម្រាប់ទ្រទ្រង់ដល់កិច្ចខិតខំប្រឹងប្រែងគ្រប់គ្រងគ្រោះមហន្តរាយទាក់ទងនឹងអាកាសធាតុ ហើយក៏បានធ្វើការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការគាំទ្រដល់ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅពេលអនាគត។

ទោះជាយ៉ាងនេះក្តី ក្នុងនាមជាប្រទេសអភិវឌ្ឍតិចតួច និងជាប្រទេសមួយដែលងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុកម្ពុជាប្រឈមមុខនឹងបញ្ហាចោទជាច្រើន រួមទាំង កង្វះសមត្ថភាព

ផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ។ ដូច្នេះ ការអនុវត្តនូវផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុជាអ្វីដែលយើង បានពិភាក្សាអស់រយៈពេលពីរថ្ងៃកន្លងមកនេះ នឹងតម្រូវឱ្យមាននូវភាពជាដៃគូដ៏រឹងមាំជាមួយភាគីពាក់ព័ន្ធ ខាងក្រៅ។

ខ្ញុំសង្ឃឹមថា ថ្ងៃចុងក្រោយនៃវេទិកានេះនឹងផ្តល់នូវឱកាសឱ្យយើងធ្វើការពិភាក្សាអំពីថា តើយើងត្រូវការភាពជាដៃគូបែបណា តើយើងត្រូវរៀបចំផែនការកៀរគរធនធានចាំបាច់បែបណា និងតើគួរគ្រប់គ្រងធនធានទាំងនោះឱ្យមានប្រសិទ្ធភាព និងប្រកបដោយការសម្របសម្រួលបែបណា។ ខ្ញុំមានជំនឿជឿជាក់ថា ដៃគូអភិវឌ្ឍន៍យើង និងភាគីពាក់ព័ន្ធទាំងអស់នឹងគាំទ្រ ហើយចូលរួមសហការពេញទំហឹងក្នុងកិច្ចស្វែងរកដំណោះស្រាយបញ្ហាប្រឈមដ៏ចម្បងនៃយុគសម័យកាលយើងនេះ។

សូមអរគុណ។

# សុន្ទរកថាស្វាគមន៍

## ដោយ លោក PETER BRIMBLE, នាយករងប្រចាំប្រទេសនៃធនាគារអភិវឌ្ឍន៍អាស៊ី

អរុណសួស្តី! និងសូមគោរព ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ!

តាងនាមឱ្យធនាគារអភិវឌ្ឍន៍អាស៊ី ខ្ញុំបាទមានកិត្តិយសខ្លាំងណាស់ដែលមានឱកាសមកចូលរួមក្នុងវេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុក្រោមប្រធានបទ "ធ្វើសកម្មភាពឆ្ពោះទៅការអភិវឌ្ឍដោយចីរភាពក្នុងបរិបទប្រែប្រួលអាកាសធាតុ"។ ខ្ញុំនៅចងចាំសុន្ទរកថារបស់ខ្ញុំកាលពីវេទិកាជាតិលើកទី២ ក្នុងខែតុលា ឆ្នាំ២០១១ ហើយវាហាក់មានការប្រែប្រួលបន្តិចបន្តួចបើធៀបនឹងពេលនេះ។

១. ដូចយើងទាំងអស់គ្នាបានដឹងហើយថា ការប្រែប្រួលអាកាសធាតុបានក្លាយជាក្តីកង្វល់ដ៏ធំធេងដល់មនុស្សគ្រប់គ្នា។ ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុនេះក៏បានជះឥទ្ធិពលអាក្រក់ដល់បណ្តាប្រទេសនានា ជាពិសេសប្រទេសដែលមានលទ្ធភាពឆ្លើយតបតិចតួចទៅនឹងការប្រែប្រួលអាកាសធាតុ។ នៅក្នុងប្រទេសកម្ពុជា ក៏ដូចជាបណ្តាប្រទេសដែលស្ថិតក្នុងតំបន់អាស៊ី ការកើនឡើងកម្តៅផែនដី និងការប្រែប្រួលអាកាសធាតុបង្កឱ្យមានហានិភ័យ ដូចជា គ្រោះមហន្តរាយធម្មជាតិដែលគំរាមកំហែងដល់ផលិតកម្មដំណាំ ប្រជាជនដែលរស់នៅតំបន់ឆ្នេរ និងទីក្រុងភាគច្រើន។

២. ធនាគារអភិវឌ្ឍន៍អាស៊ីបានដើរតួនាទីយ៉ាងសកម្មក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិច ដើម្បីចូលរួមដោះស្រាយរាល់បញ្ហាដែលកើតឡើងពីការប្រែប្រួលអាកាសធាតុ។ យុទ្ធសាស្ត្រឆ្នាំ២០២០ ដែលស្ថិតនៅក្រោមយុទ្ធសាស្ត្ររយៈពេលវែងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី បានដាក់បញ្ចូលការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងរបៀបវារៈនៃការលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាពបរិស្ថានក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិច។ យុទ្ធសាស្ត្រនេះបានបញ្ជាក់ថា មានតែការអភិវឌ្ឍដែលមានចីរភាពបរិស្ថានទេ ទើបអាចលុបបំបាត់ភាពក្រីក្របាន ពីព្រោះប្រជាជនក្រីក្រភាគច្រើនពឹងផ្អែកលើធនធានធម្មជាតិសម្រាប់ការចិញ្ចឹមជីវិតរបស់ពួកគេ។

៣. ទន្ទឹមគ្នានេះ ធនាគារអភិវឌ្ឍន៍អាស៊ី បានអនុម័តនូវយុទ្ធសាស្ត្រចម្រុះសម្រាប់ការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដោយផ្តោតសំខាន់លើវិស័យអាទិភាពមួយចំនួនដូចជា៖ (i) ការពង្រីកការប្រើប្រាស់ថាមពលស្អាត (ii) ការលើកទឹកចិត្តដល់ការដឹកជញ្ជូនប្រកបដោយចីរភាព និងការអភិវឌ្ឍទីក្រុង (iii) ការគ្រប់គ្រងការប្រើប្រាស់ដីធ្លី និងព្រៃឈើក្នុងការចាប់យកកាបូនតាមរយៈការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ (REDD+) និង (iv) ការជំរុញការអភិវឌ្ឍដែលធន់នឹងអាកាសធាតុ។

៤. នៅក្នុងការពិនិត្យឡើងវិញនូវផែនការយុទ្ធសាស្ត្ររបស់ធនាគារអភិវឌ្ឍន៍អាស៊ីឆ្នាំ ២០២០ នៅពាក់កណ្តាលត្រីមាសបានកត់សម្គាល់ថា ហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ីសម្រាប់ការកាត់បន្ថយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុបានកើនឡើងរហូតដល់ ៣.៣ ពាន់លាន

ដុល្លារអាមេរិកក្នុងឆ្នាំ ២០១២ ដោយក្នុងនោះ ២.៨៣ពាន់លានដុល្លាអាមេរិកសម្រាប់ការកាត់បន្ថយ និង ៨៩៦លានដុល្លាអាមេរិកសម្រាប់ការងារបន្សាំ។ ផែនការហិរញ្ញប្បទានក្នុងការងារបន្សាំនឹងត្រូវបានកើនឡើងក្នុងរយៈពេល៧ឆ្នាំចុងក្រោយរហូតដល់ឆ្នាំ២០២០។

៥. នៅក្នុងកម្រិតមហាអនុតំបន់ទន្លេមេគង្គវិញ ដើម្បីឆ្លើយតបនឹងក្តីកង្វល់ជាច្រើនទាក់ទងនឹងផលប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សេដ្ឋកិច្ច ធនាគារអភិវឌ្ឍន៍អាស៊ីបានសម្រេចជួយគាំទ្រប្រទេសជាសមាជិកទាំង៦ ក្នុងការផ្តួចផ្តើមបង្កើតកម្មវិធីបរិស្ថាន និងការអភិរក្សជីវចម្រុះនៅច្រករបៀង (CEP-BCI) តាំងពីឆ្នាំ ២០០៥ មកម្លេះ។ CEP-BCI មានសមាសភាគចំនួន៤សំខាន់ៗ និងផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍដែលធន់នឹងអាកាសធាតុ និងការកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនិចពីការផ្លាស់ប្តូរការប្រើប្រាស់ដីធ្លី។ កម្មវិធីនេះបានបញ្ចូលជាមួយដំណើរការរៀបចំផែនការសម្រាប់មហាអនុតំបន់ទន្លេមេគង្គក្នុងវិស័យអាទិភាពមួយចំនួនដូចជា៖ វិស័យដឹកជញ្ជូន វិស័យកសិកម្ម វិស័យថាមពល និងវិស័យទេសចរណ៍ ដើម្បីធានាពីការពិចារណាអំពីបរិស្ថាន និងការប្រែប្រួលអាកាសធាតុ។

៦. ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តោតទៅលើពាក្យ "ការបញ្ជ្រាប" ចីរភាពបរិស្ថានទៅក្នុងកម្រិតប្រទេស - ការកសាងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុទៅក្នុងយុទ្ធសាស្ត្រជាតិនៃភាពជាដៃគូ ផែនការប្រតិបត្តិការធុរកិច្ចជាតិ និងការវាយតម្លៃតាមវិស័យ និងផែនទីបង្ហាញផ្លូវ។ ឯកសារទាំងនោះណែនាំដល់កិច្ចអន្តរាគមន៍របស់ធនាគារអភិវឌ្ឍន៍អាស៊ីពីតម្រូវការជាអាទិភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលជាសមាជិករបស់ខ្លួន និងស្របពេលជាមួយគ្នានោះ ដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុតាមវិស័យជាក់លាក់។

៧. ក្នុងវិស័យនានានៃការប្រែប្រួលអាកាសធាតុ ធនាគារអភិវឌ្ឍន៍អាស៊ីបានស្វែងរកជំនួយហិរញ្ញវត្ថុ ដើម្បីសហការជាមួយដៃគូអភិវឌ្ឍន៍ដទៃទៀត។ ប្រភពធនធានចម្បងៗមានដូចជា ភាពជាដៃគូក្នុងការផ្តល់ហិរញ្ញប្បទានថាមពលស្អាត មូលនិធិវិនិយោគអាកាសធាតុ (មូលនិធិបច្ចេកវិទ្យាស្អាត និងមូលនិធិផែនការយុទ្ធសាស្ត្រអាកាសធាតុ) ភ្នាក់ងារកិច្ចសហប្រតិបត្តិការ និងអភិឌ្ឍន៍អន្តរជាតិស៊ុយអែត (SIDA) មូលនិធិអភិវឌ្ឍន៍ Nordic រដ្ឋាភិបាលប្រទេសហ្វាំងឡង់ និងមូលនិធិកិច្ចសហប្រតិបត្តិការលើការប្រែប្រួលអាកាសធាតុប្រទេសកាណាដា និងមូលនិធិដទៃទៀតជាដើម។

៨. លោក លោកស្រីភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិទាំងអស់ជាទីមេត្រី ធនាគារអភិវឌ្ឍន៍អាស៊ី មានបេសកកម្មជាក់លាក់ទាក់ទងនឹងការប្រែប្រួលអាកាសធាតុនៅប្រទេសកម្ពុជា ដែលស្របទៅនឹងយុទ្ធសាស្ត្រជាតិនៃភាពជាដៃគូឆ្នាំ២០១១ ដល់ ២០១៣ ដែលបានរៀបចំឡើងដោយមានការប្រឹក្សាយោបល់ជាមួយរាជរដ្ឋាភិបាលកម្ពុជា ហើយស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣ និងបានធ្វើបដិលេខដោយក្រុមប្រឹក្សារបស់ធនាគារអភិវឌ្ឍន៍អាស៊ីកាលពីថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១១ មកម្លេះ។

៩. ផែនការយុទ្ធសាស្ត្រជាតិនៃភាពជាដៃគូបានគូសបញ្ជាក់ថា បញ្ហាបរិស្ថាន និងការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាប្រឈមអន្តរវិស័យរបស់កម្ពុជា។ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងធ្វើកិច្ចការមួយចំនួនក្នុងប្រទេសកម្ពុជាដូចជា៖ (ii) បញ្ជ្រាបការប្រឈមនឹងការប្រែប្រួលអាកាសធាតុនៅក្នុងការ

វិភាគ ការធ្វើផែនការ និងការរៀបចំគម្រោងទៅតាមវិស័យនានាដែលពាក់ព័ន្ធ (ii) បន្តអនុវត្តយន្តការអភិរក្សធនធានឱ្យកាន់តែប្រសើរឡើង (iii) សម្របសម្រួលជាមួយកម្មវិធីថ្នាក់ជាតិ និងថ្នាក់អនុតំបន់ពីការប្រែប្រួលអាកាសធាតុ និងបរិស្ថាន និង (iv) ការកៀរគរធនធានហិរញ្ញវត្ថុពីក្នុង និងក្រៅប្រទេសដើម្បីគាំទ្រសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅក្នុងគម្រោងថ្មី និងគម្រោងដែលកំពុងអនុវត្ត។

១០. ខ្ញុំសុំឆ្លៀតឱកាសនេះពន្យល់ពីឧទាហរណ៍មួយដែលធនាគារអភិវឌ្ឍន៍អាស៊ីបានជួយរដ្ឋាភិបាលកម្ពុជានៅក្នុងឆ្នាំ២០១០-២០១១ ក្នុងការរៀបចំកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងការប្រែប្រួលអាកាសធាតុ (SPCR) តាមរយៈការទទួលបាននូវមូលនិធិវិនិយោគអាកាសធាតុពីធនាគារពិភពលោក។ ធនធានដែលបានប្រើប្រាស់ក្នុងកម្មវិធី SPCR មានចំនួនប្រមាណ ៣៩០ លានដុល្លាសហរដ្ឋអាមេរិច ដោយក្នុងនោះ ៩១លានដុល្លាអាមេរិចសម្រាប់មូលនិធិវិនិយោគអាកាសធាតុ និង ២៩៩លានដុល្លាអាមេរិកទៀតបានមកពីការផ្តល់ជំនួយរួមគ្នារវាងធនាគារអភិវឌ្ឍន៍អាស៊ី និងដៃគូអភិវឌ្ឍន៍ដទៃទៀត។ SPCR បានបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងគម្រោងវិនិយោគចំនួន៧ ដោយរួមមាន ការកសាងផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធជនបទ និងជីវៈចម្រុះ និងផ្តល់ជាជំនួយបច្ចេកទេស និងធនធានផ្សេងៗដើម្បីពង្រឹងការតាមដានពីកិច្ចការប្រែប្រួលអាកាសធាតុ ផ្សារភ្ជាប់ជាមួយសង្គមស៊ីវិល និងការបង្កើតជាវេទិកាចំណេះដឹង។

១១. មុននឹងបូកសរុបនូវសុន្ទរកថារបស់ខ្ញុំនាព្រឹកនេះ អនុញ្ញាតិឱ្យខ្ញុំបានលើកយកនូវចំណុចផ្ទាល់ខ្លួនមួយចំនួនដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុដូចខាងក្រោម៖

(i) ការយកចិត្តទុកដាក់ទៅលើផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមាន សារៈសំខាន់ខ្លាំងណាស់ក្នុងការធានានូវការវិនិយោគនានា ដើម្បីស្តារឡើងវិញពីគ្រោះទឹកជំនន់តាមរយៈការវិនិយោគទៅលើការគ្រប់គ្រង និងត្រួតពិនិត្យទឹកជំនន់។
(ii) យើងត្រូវការការរួមបញ្ចូលគ្នានៃទស្សនាទាននៃការប្រែប្រួលអាកាសធាតុ និងកិច្ចផ្តួចផ្តើមពីការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យពីគ្រោះមហន្តរាយ។
(iii) យើងត្រូវការការយល់ដឹងឱ្យកាន់តែច្បាស់ពីវិធី និងមធ្យោបាយក្នុងការណែនាំ "ការប្រែប្រួលអាកាសធាតុ និងការកសាងភាពធន់" ក្នុងគណនីជាតិដើម្បីចីរភាពនៃមូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធជាតិ។

ជាចុងក្រោយ ខ្ញុំសូមជូនពរឱ្យការពិភាក្សាក្នុងវេទិកាជាតិស្តីពីការប្រែប្រួលអាកាសធាតុលើកនេះឱ្យទទួលបានជោគជ័យជាទីមោទនៈ។

# សុន្ទរកថាបិទវេទិកា

## ដោយ ឯកឧត្តម សាបូ អូហ្សាណូ រដ្ឋលេខាធិការ ក្រសួងបរិស្ថាន

ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាព្រឹទ្ធសភារាជរដ្ឋាភិបាលកម្ពុជា ជាទីគោរព

ឯកឧត្តម លោកជំទាវ ឯកអគ្គរដ្ឋទូត តំណាងអង្គទូត ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន គ្រឹះស្ថានសិក្សា និងប្អូនៗយុវជន សិស្ស និស្សិតទាំងអស់ជាទីមេត្រី!

ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ សមាជិក សមាជិកានៃអង្គវេទិកាទាំងមូលជាទីមេត្រី!

ជាបឋម ជូនសមុខឱ្យឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន និងគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ខ្ញុំសូមថ្លែងអំណរគុណដោយស្មោះអស់ពីដួងចិត្តដល់សមាជិក សមាជិកានៃអង្គវេទិកាទាំងមូល ចំពោះការចូលរួមយ៉ាងសកម្ម និងការខិតខំប្រឹងប្រែងសម្រេចបានលទ្ធផលជាផ្លែផ្កា ក្នុងអំឡុងពេលដំណើរការវេទិកាជាតិអស់រយៈពេលបីថ្ងៃកន្លងមកនេះ។ អនុសាសន៍ប្រកបទៅដោយខ្លឹមសារសំខាន់ៗ ដែលយើងបានទទួលពីវេទិកានេះ គឺជាត្រីវិស័យតម្រង់ទិស និងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់យើងនៅក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ នាពេលខាងមុខ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរព

យើងទាំងអស់គ្នាបានយល់យ៉ាងច្បាស់ថា វេទិកាជាតិលើកទី៣ ដែលកំពុងតែឈានទៅរកទីបញ្ចប់នាពេលនេះ បានផ្តល់ឱកាសឱ្យយើងពង្រឹងការយល់ដឹង និងចំណេះដឹងអំពីវិទ្យាសាស្ត្រនៃការប្រែប្រួលអាកាសធាតុ រួមទាំងមូលហេតុ និងផលប៉ះពាល់របស់វាផងដែរ។ យើងបានយល់ដឹងកាន់តែប្រសើរឡើងថា ការឆ្លើយតបទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុ ដែលជាបញ្ហាអភិវឌ្ឍន៍អន្តរវិស័យ ទាមទារនូវវិធីសាស្ត្រដោះស្រាយ ដែលមានលក្ខណៈយុទ្ធសាស្ត្រ សមាហរណកម្ម ការសម្របសម្រួល និងមានការចូលរួមពីគ្រប់ជាន់ថ្នាក់ក្នុងការរៀបចំផែនការនៅគ្រប់លំដាប់ថ្នាក់។ គោលនយោបាយ និងបរិធានច្បាប់សមស្របក៏មានសារៈសំខាន់ដូចគ្នាដែរ។ យើងក៏បានយល់ទៀតថា កត្តាផ្សេងៗទៀត ដូចជា ស្ថាប័នពាក់ព័ន្ធ ធនធានហិរញ្ញវត្ថុ ការសម្របសម្រួលល្អ សមត្ថភាពខ្ពស់ និងកិច្ចសហប្រតិបត្តិការក្នុងនិងក្រៅតំបន់ គឺជាលក្ខខណ្ឌចាំបាច់ដែលតម្រូវឱ្យមានជាមុន សម្រាប់គាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្ររបស់យើង ឱ្យទៅជាសកម្មភាពជាក់ស្តែង ហើយនាំមកនូវលទ្ធផលពិតប្រាកដ ដែលនឹងជួយជំរុញដំណើរឈានឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាពនៅក្រោមលក្ខខណ្ឌនៃអាកាសធាតុដែលកំពុងតែប្រែប្រួល។

ក្នុងអំឡុងពេលនៃពិធីបើកសម្ពោធវេទិកា សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានកិត្តិយស នៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ បានលើកសរសើរពីសមិទ្ធផលដែលយើងសម្រេចបានក្នុងកិច្ចខិតខំប្រឹង

ប្រែងរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ដែលត្រូវបានសម្តេចបានចាត់ជាឯកសារផែនការថ្នាក់ជាតិ សម្រាប់តម្រង់ទិសការងារឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅប្រទេសកម្ពុជា។ សម្តេចក៏បានផ្តល់ជាអនុសាសន៍ជាយុទ្ធសាស្ត្រ គន្លឹះបន្ថែមទៀត សម្រាប់គាំទ្រដល់ដំណើរការដាក់ឱ្យប្រតិបត្តិការនៃផែនការនេះ ដោយផ្តោតជាពិសេសលើការកៀរគរធនធាន ការស្រាវជ្រាវនិងអភិវឌ្ឍន៍ ការផ្ទេរបច្ចេកវិទ្យា ការកសាងសមត្ថភាព និងការបង្កើនការយល់ដឹងជាសាធារណៈ។ អនុសាសន៍របស់សម្តេចទាំងប៉ុន្មាន រួមផ្សំជាមួយនឹងសមិទ្ធផលដែលយើងសម្រេចបានពីវេទិកាជាតិ រយៈពេល៣ថ្ងៃនេះ នឹងបង្កើតបានជាមូលដ្ឋានគ្រឹះដ៏រឹងមាំ សម្រាប់គាំទ្ររាល់គ្រប់សកម្មភាពរបស់យើង ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅប្រទេសកម្ពុជា។ រូបភាពនៃជនរងគ្រោះទឹកជំនន់ថ្មីៗនេះ ដែលបានចាក់ស្រេះនៅក្នុងអារម្មណ៍យើងគ្រប់គ្នានៅឡើយ ក៏ដូចជាការខូចខាតដែលគ្រោះអាកាសធាតុនេះបានបង្កដល់សង្គមរបស់យើង គឺច្រើនលើសពីគ្រប់គ្រាន់សម្រាប់ឱ្យយើងទាំងអស់គ្នាធ្វើសកម្មភាពដោះស្រាយជាបន្ទាន់ភ្លាមៗ នៅគ្រប់កម្រិត និងគ្រប់ជាន់ថ្នាក់។

ចាប់តាំងពីវេទិកាជាតិលើកទី២ ស្តីពីការប្រែប្រួលអាកាសធាតុនៅចុងឆ្នាំ២០១១ មក កម្ពុជាសម្រេចបានលទ្ធផលគួរឱ្យកត់សម្គាល់ នៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ការប្រែប្រួលអាកាសធាតុបានក្លាយទៅជាប្រធានបទមួយដ៏សំខាន់មួយនៃរបៀបវារៈអភិវឌ្ឍន៍ជាតិ ដែលត្រូវបានដាក់បញ្ចូលជាបន្តបន្ទាប់ ទៅក្នុងកម្រិតថ្នាក់ក្រោមជាតិ និងថ្នាក់សហគមន៍ តាមរយៈវិធីសាស្ត្រផ្សេងៗគ្នា។ កម្ពុជាបានកៀរគរថវិកាបានប្រមាណ ២៥០ លានដុល្លារអាមេរិក សម្រាប់ប្រើប្រាស់ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ របាយការណ៍អំពីកិច្ចដំណើរការរបស់វេទិកា បង្ហាញឱ្យឃើញថា ក្នុងរយៈពេលបីថ្ងៃកន្លងមកនេះ យើងបានសម្រេចនូវលទ្ធផលគួរជាទីគាប់ចិត្ត អាស្រ័យដោយមានការចូលរួមយ៉ាងសកម្មពីសំណាកសមាជិកសមាជិកាទាំងអស់មកពីស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានសិក្សា និងវិស័យឯកជន ជាពិសេសការរួមចំណែកប្រកបដោយអត្ថន័យរបស់សហប្រធាន អ្នកជំនាញការ និងអ្នកធ្វើបទបង្ហាញជាតិនិងអន្តរជាតិ ដែលបានទទួលយកដោយកក់ក្តៅនូវសេចក្តីអញ្ជើញរបស់យើងឱ្យមកចូលរួមចែករំលែកចំណេះដឹង និងបទពិសោធន៍ ញ៉ាំងឱ្យវេទិកានេះមានភាពរស់រវើក និងសម្បូរបែប។ ទាំងអស់នេះគឺជាវិភាគទានរួមចំណែកក្នុងជំហានបន្ទាប់របស់យើង ដើម្បីដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុនាពេលអនាគត ជាពិសេសការអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា ដែលជាឯកសារផែនការយោងថ្នាក់ជាតិ សម្រាប់ណែនាំតម្រង់ទិសការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុរបស់ភាគីពាក់ព័ន្ធទាំងអស់។

ភារកិច្ចចំពោះមុខរបស់យើងគឺនៅមានច្រើនទៀត៖ ការអភិវឌ្ឍគោលនយោបាយប្រែប្រួលអាកាសធាតុ ការពង្រឹងសមត្ថភាពបច្ចេកទេស និងស្ថាប័ន ការស្រាវជ្រាវនិងអភិវឌ្ឍន៍ ការពង្រឹងកិច្ចសម្របសម្រួល និងភាពជាដៃគូ ការអនុវត្តជាក់ស្តែងនូវវិធានការអាទិភាព និងការពង្រីកសកម្មភាពនៅទីតាំងផ្សេងៗ ការកៀរគរធនធាន ការលើកកម្ពស់ការអប់រំនិងការយល់ដឹង និងការចរចាថ្នាក់អន្តរជាតិអំពីការប្រែប្រួលអាកាសធាតុ ជាពិសេសការត្រៀមរៀបចំជំហររបស់កម្ពុជាសម្រាប់ចូលរួមក្នុងសន្និសីទលើកទី១៩ នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ នៅទីក្រុង

វ៉ាសូវី ប្រទេសប៉ូឡូញ ដែលនឹងចាប់ផ្តើមនាសប្តាហ៍ក្រោយនេះ។ ជាការពិតណាស់ យើងមិនត្រូវចាត់ទុកវេទិកាជាតិលើកទី៣ នេះ ឬវេទិកាជាបន្តបន្ទាប់ ថាជាលទ្ធផលសម្រេច ឬជាព្រឹត្តិការណ៍មួយដាច់ ដោយឡែកតែឯងនោះទេ ប៉ុន្តែត្រូវតែចាត់ទុកថា វាជាសមាសធាតុមួយដែលមិនអាចខ្វះបាននៃកិច្ចខិតខំប្រឹងប្រែងរបស់យើង ដើម្បីឆ្លើយតបនឹងបញ្ហាប្រែប្រួលអាកាសធាតុ។ យើងត្រូវតែយល់ថា វេទិកានេះជាទីកន្លែងសម្រាប់ចែក រំលែកព័ត៌មាននិងបទពិសោធថ្មីៗ ពិនិត្យឡើងវិញនូវវឌ្ឍនភាព និងបរាជ័យរបស់យើង ពិភាក្សាអំពីជំហានទៅមុខព្រមទាំងលើកកម្ពស់ការសម្របសម្រួលនិងភាពជាដៃគូរបស់យើង។ នៅក្នុងស្ថានភាពដែលធនធានមានកម្រិត តែតម្រូវការមានខ្ពស់ ការសម្របសម្រួលប្រកបដោយគុណភាព គឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ធានា ឱ្យបាននូវការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុប្រកបដោយប្រសិទ្ធភាពក្នុងចំណោមស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល គ្រឹះស្ថានសិក្សាស្រាវជ្រាវ និងវិស័យឯកជន។ សុខដុមរម្យនីយកម្មក្នុងចំណោមដៃគូអភិវឌ្ឍន៍ដែលជាគោលការណ៍ស្នូលនៃប្រសិទ្ធភាពជំនួយ គួរត្រូវបានអនុវត្តផងដែរ ក្នុងកិច្ចសហប្រតិបត្តិលើការងារប្រែប្រួលអាកាសធាតុ។ លើសពីនេះទៀត ខ្ញុំសូមសង្កត់ធ្ងន់ពីតួនាទីដ៏សំខាន់នៃភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជន នៅក្នុងការអនុវត្តវិធានការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ ដោយហេតុនេះ រាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការបង្កើតនូវបរិស្ថានប្រកបមួយ ដែលអនុញ្ញាតឱ្យមានការចូលរួមពេញលេញ ពីសំណាក់វិស័យឯកជននៅក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ទាំងក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ទាំងការចាត់វិធានការបន្សាំ។

ខ្ញុំសូមបញ្ជាក់ជាថ្មីម្តងទៀតអំពីការប្តេជ្ញាចិត្តរបស់យើង ដើម្បីធ្វើការជាមួយដៃគូទាំងអស់ ក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។ គឺដោយសារតែកម្ពុជាគឺជាប្រទេសអភិវឌ្ឍតិចតួចនេះហើយ ដែលសបញ្ជាក់ថា យើងពុំអាចព្រងើយកន្តើយមិនយកចិត្តទុកដាក់នឹងការប្រែប្រួលអាកាសធាតុបានទេ ពីព្រោះការខាតបង់ដោយសារបញ្ហានេះក្នុងករណីមិនធ្វើអ្វីសោះ និងមានច្រើនលើសពីបរិមាណនៃការចំណាយលើការចាត់វិធានការទប់ស្កាត់នាពេលបច្ចុប្បន្ន។ នេះគឺជាគតិបណ្ឌិតនៃ "គោលការណ៍បង្ការជាមុន" ដែលសមស្របបំផុតនៅក្នុងបរិបទសង្គមរបស់យើង។ ជាការពិតណាស់ ពិភពលោកគឺមិនមានយុត្តិធម៌ប៉ុន្មានទេចំពោះប្រទេសយើង ដោយហេតុថា ការរួមចំណែករបស់យើងនៅក្នុងការបង្កបញ្ហានេះគឺមានស្តួចស្តើងតិចតួចបំផុត ទាំងក្នុងអតីតកាល និងពេលអនាគត។ ដោយពិតទៅ យើងគឺជាជនរងគ្រោះរបស់បញ្ហាមួយ ដែលយើងមិនមែនជាមូលហេតុផងនោះទេ។ ទោះជាយ៉ាងណាក្តី យើងមានបំណងចង់ជាផ្នែកមួយនៃដំណោះស្រាយបញ្ហាសកលនេះ។ ព្រោះថា ការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ មិនមែនគ្រាន់ជាជម្រើសមួយនោះទេ តែគឺជាផ្លូវតែមួយគត់ដើម្បីធានាដល់ការរស់រានមានជីវិត និងការរីកចម្រើនរុងរឿង។ ពីព្រោះយើងជឿជាក់ថា ការចូលរួមដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុនឹងផ្តល់នូវប្រយោជន៍ ទាំងផ្នែកនយោបាយ សេដ្ឋកិច្ច បរិស្ថាន និងបច្ចេកវិទ្យា។ សំខាន់បំផុត ដោយសារយើងជឿជាក់ថា យើងអាចបង្វែរវិបត្តិនៃការប្រែប្រួលអាកាសធាតុនេះ ឱ្យទៅជាឱកាសថ្មី សម្រាប់ការអភិវឌ្ឍមួយដែលបៃតងបញ្ចេញកាបូនតិច ធន់នឹងការប្រែប្រួលអាកាសធាតុ សមធម៌ ចីរភាព និងពឹងផ្អែកលើចំណេះដឹង។

ជាមួយនឹងអាណត្តិផ្លូវច្បាប់ដែលរាជរដ្ឋាភិបាលបានប្រគល់ឱ្យ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ដែលមានក្រសួងបរិស្ថានជាប្រធាន ត្រៀមខ្លួនជាស្រេច ដើម្បីបន្តបំពេញ

បេសកកម្មរបស់ខ្លួន ប្រកបដោយការទទួលខុសត្រូវក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ ការសម្របសម្រួល និងជំរុញភាពជាដៃគូ ដោយសមធម៌ តម្លាភាព ប្រសិទ្ធភាព និងអាចទុកចិត្តបាន។ យើងប្តេជ្ញាលើកកម្ពស់ និងធានាឱ្យមានបរិស្ថានប្រកបមួយ ដែលតួអង្គប្រែប្រួលអាកាសធាតុទាំងអស់អាចមានឱកាសស្មើគ្នា ក្នុងការរួមចំណែកដោយពេញលេញនៅក្នុងកិច្ចខិតខំប្រឹងប្រែងដោះស្រាយបញ្ហាជាអាយុជីវិតនេះ។

ជាទីបញ្ចប់ ជូសមុខឱ្យគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ថ្នាក់ដឹកនាំព្រមទាំងមន្ត្រីរាជការរបស់ក្រសួងបរិស្ថាន ខ្ញុំសូមថ្លែងអំណរគុណដល់សមាជិក សមាជិកានៃអង្គវេទិកាទាំងមូល ជាពិសេសចំពោះសហប្រធានដឹកនាំ វាគ្មិន និងអ្នកជំនាញការនានា ដែលបានចំណាយពេលវេលាដ៏មានតម្លៃ មកចូលរួមក្នុងវេទិកាថ្នាក់ជាតិនេះ ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធរបស់ពួកគេ ហើយចូលរួមចំណែកយ៉ាងសកម្មនៅក្នុងការពិភាក្សា និងការផ្តល់នូវយោបល់ដ៏មានតម្លៃ។ ខ្ញុំសូមអរគុណជាពិសេសដល់តំណាងវិស័យឯកជន អង្គការជាតិ និងអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានមកចូលរួមនៅក្នុងការតាំងពិព័រណ៌ការប្រែប្រួលអាកាសធាតុនេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសមាជិក សមាជិកា នៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ក៏ដូចជាគណៈកម្មាការរៀបចំវេទិកាជាតិលើកទី៣ នេះចំពោះការខិតខំបំពេញភារៈកិច្ចរបស់ពួកគេ ក្នុងការរៀបចំដំណើរការវេទិកាជាតិនេះ ឱ្យប្រព្រឹត្តិទៅដោយជោគជ័យ។ ជាចុងក្រោយ ខ្ញុំសូមអរគុណជាពិសេសដល់អ្នកឧបត្ថម្ភរបស់យើង រួមមាន សហភាពអឺរ៉ុប កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ (Sida) ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិដាណឺម៉ាក(DANIDA) កម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP) វេទិកាអង្គការក្រៅរដ្ឋាភិបាល DanChurchAid និង CCCN ចំពោះការគាំទ្រឧបត្ថម្ភផ្នែកហិរញ្ញវត្ថុ សម្រាប់ដំណើរការវេទិកាជាតិទី៣ នេះ។

ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងភ្ញៀវកិត្តិយសទាំងអស់ សូមជួបតែពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ។ សូមប្រកាសបិទវេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ ចាប់ពីពេលនេះតទៅ។ សូមអរគុណ។

# ឧបសម្ព័ន្ធទី៣៖ ប្រវត្តិរូបសង្ខេប

## ថ្ងៃទី១៖ ទី៥ ខែវិច្ឆិកា ឆ្នាំ២០១៣

## ១. វគ្គចាប់ផ្តើម

### ១.១ បច្ចុប្បន្នភាពនៃព័ត៌មានវិទ្យាសាស្ត្រប្រែប្រួលអាកាសធាតុ៖ មូលហេតុ និងផលប៉ះពាល់

**អ្នកធ្វើបទបង្ហាញ៖**

លោក Mozaharul Alam ជាអ្នកសម្របសម្រួលកម្មវិធីប្រែប្រួលអាកាសធាតុថ្នាក់តំបន់អាស៊ី និងប៉ាស៊ីហ្វិកនៃកម្មវិធីបរិស្ថានសហប្រជាជាតិ ដែលមានទីតាំងក្នុងទីក្រុងបាងកក។ ចាប់តាំងពីខែសីហា ឆ្នាំ២០០៩ មក លោកទទួលខុសត្រូវក្នុងការត្រួតពិនិត្យ និងផ្តល់យោបល់ផ្នែកគោលនយោបាយ និងបច្ចេកទេស សម្រាប់អនុវត្តអនុកម្មវិធីប្រែប្រួលអាកាសធាតុរបស់កម្មវិធីបរិស្ថានសហប្រជាជាតិ នៅតំបន់អាស៊ី និងប៉ាស៊ីហ្វិច។ មុនពេលបម្រើការនៅកម្មវិធីបរិស្ថានសហប្រជាជាតិ លោកបានរៀបចំ និងសម្របសម្រួលការងារស្រាវជ្រាវជាច្រើនពាក់ព័ន្ធនឹងផលប៉ះពាល់ ភាពងាយរងគ្រោះ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ ថ្នាក់តំបន់ និងសាកល។ នាពេលបច្ចុប្បន្ន លោកជាអ្នកនិពន្ធឈានមុខសម្រាប់ក្រុមការងារទី២ នៃរបាយការណ៍វាយតំលៃលើកទី៥ របស់ក្រុមការងារអន្តររដ្ឋាភិបាល ស្តីពីការប្រែប្រួលអាកាសធាតុ។ ជាមួយគ្នានេះ ចាប់តាំងពីឆ្នាំ២០០០ មក លោកបានចូលរួមជាប្រចាំក្នុងការចរចាការប្រែប្រួលអាកាសធាតុ ហើយប៉ុន្មានឆ្នាំចុងក្រោយ លោកគឺជាសមាជិកនៃគណៈប្រតិភូរបស់ប្រទេសបង់ក្លាដេស្ស ចូលរួមក្នុងការចរចាការប្រែប្រួលអាកាសធាតុ។

### ១.២ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ នៅកម្ពុជា និងតំបន់អាស៊ីអាគ្នេយ៍

**អ្នកធ្វើបទបង្ហាញ៖**

បណ្ឌិត ប៉ិច សុខែម មានបទពិសោធន៍ការងារគ្រប់គ្រងជាន់ខ្ពស់ ជាមួយនឹងរដ្ឋាភិបាលថ្នាក់ជាតិ អង្គការអន្តររដ្ឋាភិបាលអន្តរជាតិ ពហុវិន័យសម័្ពន្ធស្រាវជ្រាវ និងក្រុមហ៊ុនពិគ្រោះយោបល់នៅក្នុងតំបន់អាស៊ី និងអាមេរិកខាងជើង ជាង ២៩ឆ្នាំ។ លោកបណ្ឌិតជាអ្នកគ្រប់គ្រងជាន់ខ្ពស់ប្រឹក្សាយោបល់នៃក្រុមអភិវឌ្ឍអន្តរជាតិនៅក្នុងក្រុមហ៊ុន Hatfield ដែលមានមូលដ្ឋាននៅក្រុង Vancouver, British Columbia ប្រទេសកាណាដា។ លោកបណ្ឌិត ជាអ្នកដឹកនាំក្រុមនៅក្នុងកម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ (PPCR) ទទួលការឧបត្ថម្ភថវិកាគម្រោងតាមរយៈធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) (ការរៀបចំផែនការប្រែប្រួលអាកាសធាតុផ្អែកលើវិទ្យាសាស្ត្រ) នៅប្រទេសកម្ពុជា។ លោកបណ្ឌិត ជាប្រធានក្រុម និងជាអ្នកឯកទេសបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងធនធនទឹកអន្តរជាតិសម្រាប់ PPCR ដំណាក់កាលទី ២ នៃការអនុវត្តកម្មវិធីសាកល្បងភាពធន់នឹងការប្រែប្រួលអាកាសធាតុ ដែលឧបត្ថម្ភថវិកាដោយមូលនិធិវិនិយោគអាកាសធាតុតាមរយៈធនាគារអភិវឌ្ឍន៍អាស៊ី។

លោក Guttman មានសញ្ជាតិស៊ុយអែដ ដែលបានចំណាយពេលភាគច្រើននៃអាជីពលើជំនាញវិជ្ជាជីវៈរបស់គាត់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ លោកបានបញ្ចប់ផ្នែកជីវសាស្ត្រសមុទ្រពីសា

កលវិទ្យាល័យ James Cook ក្នុងប្រទេសអូស្ត្រាលី ។ លោក ហាន បានចំណាយពេលច្រើននៃជីវិតយុវវ័យរបស់គាត់ ហើយគាត់ទទួលបានសញ្ញាប័ត្រថ្នាក់អនុបណ្ឌិតពីសាកលវិទ្យាល័យបច្ចេកវិទ្យាអាស៊ី នៅប្រទេសថៃ និងបានធ្វើការ 10 ឆ្នាំមកហើយ ជាមួយកម្មវិធី AIT Aqua ការផ្សព្វផ្សាយ ការលើកកម្ពស់ ការគ្រប់គ្រងធនធានទឹក និងការអភិវឌ្ឍ ជនបទនអាស៊ីអាគ្នេយ៍។ នៅឆ្នាំ ២០០១ លោក ហាន បានចូលបម្រើការងារជាប្រធានប្រតិបត្តិ នៃលេខាធិការដ្ឋាននៃគណៈ កម្មាការទន្លេមេគង្គ ដែលមាន ការិយាល័យនៅទីក្រុង វៀងច័ន្ទ ប្រទេសឡាវ និងទីក្រុងភ្នំពេញប្រទេសកម្ពុជា។

## ១.៣ បច្ចុប្បន្នភាពការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជាដោយផ្តោតលើសកម្មភាពបន្តនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

**អ្នកធ្វើបទបង្ហាញ៖**

លោក ម៉ា ច័ន្ទសទ្ធា អនុប្រធាននាយដ្ឋានប្រែប្រួលអាកាសធាតុកម្ពុជា ក្រសួងបរិស្ថាន

## ១.៤ ផែនការយុទ្ធសាស្រ្តឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា

**អ្នកធ្វើបទបង្ហាញ៖**

បច្ចុប្បន្ននេះ លោក ស៊ុំ ធី ជាប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ និងជាអ្នកសម្របសម្រួលគម្រោងអភិវឌ្ឍន៍គោលនយោបាយ និងការគ្រប់គ្រងចំណេះដឹងប្រែប្រួលអាកាសធាតុ នៃកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា។ លោកបានទទួលសញ្ញាប័ត្រអនុបណ្ឌិតផ្នែកគ្រប់គ្រងការអភិវឌ្ឍន៍។

ចាប់តាំងពីឆ្នាំ១៩៩៩ លោក ស៊ុំ ធី បានចូលរួមធ្វើគម្រោងជាច្រើន ដែលទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុ មានដូចជា ការរៀបចំរបាយការណ៍ជាតិលើកទី១ នៅក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ ការកសាងសមត្ថភាពសម្រាប់យន្តការអភិវឌ្ឍន៍ស្អាត កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាស ធាតុ និងរបាយការណ៍ជាតិលើកទី២។

ជាមួយគ្នានេះ លោកក៏បានចូលរួមយ៉ាងសកម្មក្នុងការបង្កើត និងរៀបចំស្ថាប័នប្រែប្រួលអាកាសធាតុជាតិ ដែលរួមមានគណៈកម្មាធិការប្រែប្រួលអាកាសធាតុជាតិ ក្រុមបច្ចេកទេសប្រែប្រួលអាកាសធាតុ និងនាយកដ្ឋានប្រែប្រួលអាកាសធាតុ។ លោកក៏ជាសមាជិកនៃប្រតិភូកម្ពុជាដែលចូលរួមចរចាលើបញ្ហាប្រែប្រួលអាកាសធាតុរបស់អង្គការសហប្រជាជាតិ។

# ថ្ងៃទី២៖ ទី៦ ខែវិច្ឆិកា ឆ្នាំ២០១៣

## វគ្គស្របគ្នាផ្នែកទី១៖ ផែនការយុទ្ធសាស្រ្តឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ (ផ.យ.ប.អ. តាមវិស័យ) និងផែនការសកម្មភាព

### ក្រុមទី១៖ ការអប់រំការប្រែប្រួលអាកាសធាតុ ទំនាក់ទំនង និងយេនឌ័រ

*ទីកន្លែង៖ បន្ទប់ Fuluzu*

**អ្នកធ្វើបទបង្ហាញ៖**

១. នៅឆ្នាំ ២០១២ លោកស្រី ចេង ចិនណៃត ត្រូវបានតម្លើងជាអនុប្រធាននាយកដ្ឋានសមភាពយេនឌ័រ ទទួលបន្ទុកការបញ្ជ្រាបយេនឌ័រទៅក្នុងវិមជ្ឈការ និងសហវិមជ្ឈការ នៃក្រសួងកិច្ចការ នារី។ មុននេះ គាត់ជាសមាជិកមួយរូបនៃគណៈកម្មាធិការយេនឌ័រ និងការប្រែប្រួលអាកាសធាតុនៃក្រសួងកិច្ចការនារី ហើយនៅពេលថ្មីៗនេះ គាត់ក៏បានក្លាយជាសមាជិកនៃក្រុមបច្ចេកទេសប្រែប្រួលអាកាសធាតុនៃគណៈកម្មាធិការជាតិស្ដីពីការប្រែប្រួលអាកាសធាតុផងដែរ។

២. លោក ជួន វណ្ណា អនុការិយាល័យកម្មវិធីវិទ្យាសាស្ត្រ ទទួលបន្ទុកផ្នែកអប់រំបរិស្ថាន និងការប្រែប្រួលអាកាសធាតុនៃក្រសួងអប់រំ យុវជន និងកីឡា

## វាគ្មិនៈ

១. កញ្ញា គង់ កែវសុគន្ធា ដែលបច្ចុប្បន្នជាទីប្រឹក្សាឯករាជ្យ ជាពិសេស ខាងការងារប្រែប្រួលអាកាសធាតុ និងយុទ្ធសាស្ត្រព័ត៌មាន។ កញ្ញាធ្លាប់ត្រូវបានជ្រើសតាំងជាក្រុមប្រឹក្សានាយកនៃបណ្ដាញប្រែប្រួលអាកាសធាតុកម្ពុជា (CCCN) និងជានាយកអភិវឌ្ឍន៍ធុរកិច្ចព័ត៌មាននៃមជ្ឈមណ្ឌលកម្ពុជាសម្រាប់ព័ត៌មានឯករាជ្យ (CCIM)។ កញ្ញា មានបទពិសោធន៍រយៈពេល ៦ឆ្នាំ ខាងអភិវឌ្ឍន៍ និងគ្រប់គ្រងព័ត៌មាន និងគម្រោង ជាពិសេស ការស្វែងរកមូលនិធិ។ កាលពីឆ្នាំទៅ កញ្ញា ត្រូវបានជ្រើសរើសដើម្បី ចូលរួមនៅក្នុង COP 18 នៅទីក្រុងដូហា ប្រទេសកាតា ស្ដីពីការប្រែប្រួលអាកាសធាតុ និងបានចូលរួមជាសមាជិកបណ្ដាញសកម្មភាពអាកាសធាតុ *(CAN អន្តរជាតិ)* នៅក្នុងក្រុមកសាងសមត្ថភាព។

២. លោក ស៊ូ សុជាតិ បម្រើការងារជាអ្នកសម្របសម្រួល នៃបណ្ដាញប្រែប្រួលអាកាសធាតុកម្ពុជា

៣. លោក គឹម សុបិន ជាប្រធានមជ្ឈមណ្ឌលសិក្សាកសិកម្មនិងបរិស្ថាន និងជាអ្នកសម្របសម្រួលកម្មវិធីថ្នាក់អនុបណ្ឌិតវិទ្យាសាស្ត្រ (MSc) នៃសកលវិទ្យាល័យភូមិន្ទកសិកម្ម។ លោកមានបទពិសោធន៍រយៈពេលច្រើន ជាង ១៥ឆ្នាំ លើការងារស្រាវជ្រាវ និងបង្រៀនអំពីការគ្រប់គ្រងធនធានធម្មជាតិ។ លោកជាអ្នកសម្របសម្រួលបណ្ដាញសកលវិទ្យាល័យប្រចាំប្រទេសកម្ពុជា អំពីអេកូឡូស៊ីតំបន់ដីសើមក្នុងអាងទន្លេមេគង្គក្រោម។ លោកធ្វើការជាអ្នកសម្របសម្រួលគម្រោងប្រែប្រួលអាកាសធាតុនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងជាគ្រូបង្ហាត់ក្នុងកម្មវិធីនានាដែលទាក់ទងនឹង "វិធីស្រាវជ្រាវក្នុងការប៉ាន់ប្រមាណផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងយុទ្ធសាស្ត្របន្សាំ" និង "អេកូឡូស៊ី និងការគ្រប់គ្រងតំបន់ដីសើមក្នុងអាងទន្លេមេគង្គក្រោម" ផងដែរ។ លោកមានសញ្ញាបត្រ ថ្នាក់អនុបណ្ឌិតវិទ្យាសាស្ត្រ ជីវិត និងបរិស្ថានពីសកលវិទ្យាល័យត្សឹគូបានៃប្រទេសជប៉ុន និងអនុបណ្ឌិតខាងការគ្រប់គ្រងធនធានធម្មជាតិកកើតឡើងវិញ ពីសកលវិទ្យាល័យភូមិន្ទកសិកម្មនៃប្រទេសកម្ពុជា។

៤. លោក Chris Eijkemans ជានាយកថ្មីនៃអង្គការអុកស្វាមសម្រាប់កម្ពុជា។ គាត់បានចាប់ផ្ដើមការងារនេះនៅ ខែមិថុនា ឆ្នាំនេះ និងស្ថិតក្នុងចំណោមអ្នកដែលរៀនសូត្រអំពីកម្ពុជា។ មុនមកកម្ពុជា គាត់បានធ្វើការនៅលេខាធិការដ្ឋាននៃអង្គការអុកស្វាមអន្តរជាតិ ដែលពិនិត្យមើលការិយាល័យចំនួន ១៧នៃសហព័ន្ធអុកស្វាម ក្នុងនាមជាប្រធានអភិវឌ្ឍន៍សហព័ន្ធ។ តំណែងនេះពាក់

ព័ន្ធនឹងសកម្មភាពក្នុងវិស័យពីរខុសគ្នា៖ ទទួលខុសត្រូវលើការិយាល័យដែលជាសមាជិក ថ្មីរបស់អុកស្វាម និងពិនិត្យមើលសកម្មភាពកៀងគរមូលនិធិសម្រាប់អុកស្វាមទាំងមូល។

## ក្រុមទី២៖ ការឆ្លើយតបការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម និងធារាសាស្ត្រ

*ទីកន្លែង៖ សាលប្រជុំភូគីត្រា Grand Ballroom 2*

**អ្នកធ្វើបទបង្ហាញ៖**

១. លោក អ៊ុំ រីណា មានសញ្ញាប័ត្រថ្នាក់អនុបណ្ឌិតវិទ្យាសាស្ត្រឧតុនិយម (ការព្យាករណ៍) (១៩៨៦-១៩៩២) ពីវិទ្យាស្ថានជលសាស្ត្រ-ឧតុនិយម នៅទីក្រុងអូដេសា នៃសាធារណរដ្ឋអ៊ុយក្រែន។ លោក រីណា ជាប្រធានស្តីទី នាយកដ្ឋានឧតុនិយម នៃក្រសួងធនធានទឹក និងឧតុនិយម។

២. លោក សរ ចិត្រា អនុប្រធាននាយកដ្ឋានផលិតកម្ម និងបសុសត្វ

**វាគ្មិន៖**

១. ឯកឧត្តម គល់ វឌ្ឍនា អគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

២. លោក ឈិត សំអាត នាយកប្រតិបត្តិនៃវេទិកាមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា

៣. ម៉េង សាកភូសេត ជាមន្ត្រីបច្ចុប្បន្នកម្មវិធីប្រទេសសម្រាប់ប្រទេសកម្ពុជាមូលនិធិអន្តរជាតិសម្រាប់ការ អភិវឌ្ឍកសិកម្ម (IFAD)។ មុនពេលទៅថាគាត់ជាទីប្រឹក្សាជាន់ខ្ពស់កម្មវិធីថ្នាក់ខេត្តសម្រាប់គម្រោងអង្គការ UNDP PLG ដែលមានមូលដ្ឋាននៅក្នុងខេត្តកំពង់ធំ។ លោកបានគាំទ្រដល់កម្មវិធី IFAD នៅក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ 2001។ គាត់មានវិសាលភាពផលប័ត្ររបស់គាត់ដើម្បីគាំទ្រដល់ប្រតិបត្តិការនៅក្នុងប្រទេសឥណ្ឌូនេស៊ី IFAD និងមីយ៉ាន់ម៉ា ហើយគាត់គឺជាអតីតសាស្ត្រាចារ្យនៅសាកលវិទ្យាល័យជាច្រើននៅក្នុងប្រទេសកម្ពុជា។ លោកបានទទួលសញ្ញាប័ត្រមួយនៅក្នុងសេដ្ឋកិច្ចនិងសញ្ញាប័ត្រមួយរបស់ MS នៅក្នុងការគ្រប់គ្រងអាជីវកម្ម។ សេតមានចំណាប់អារម្មណ៍ប្រាស់និងជាបទពិសោធដ៏រឹងមាំនៅក្នុងការអនុវត្តន៍គម្រោង ដើម្បីគាំទ្រដល់សកម្មភាពរបស់របរចិញ្ចឹមជីវិតនៅជនបទក្រីក្រ។

## ក្រុមទី៣៖ ការឆ្លើយតបការប្រែប្រួលអាកាសធាតុក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

*កន្លែង៖ សាលប្រជុំភូគីត្រា១ ជាន់ទី២*

**អ្នកធ្វើបទបង្ហាញ៖**

១. លោក ច្រៀង ផល័ក្ខ ប្រធាននាយដ្ឋានផែនការ និងវិនិយោគ នៃក្រសួងសាធារណការនិងដឹកជញ្ជូន។ លោក ផល័ក្ខ នឹងធ្វើបទបង្ហាញស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រជាតិសម្រាប់បន្សុាំ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ក្នុងវិស័យ ដឹកជញ្ជូន

២. លោក ស្រ៊ុន ពិទូ អនុប្រធាន នាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ នៃក្រសួងអភិវឌ្ឍន៍ជនបទ។ បទបង្ហាញរបស់លោកគឺ ការរៀបចំផែនការប្រែប្រួលអាកាសធាតុសម្រាប់វិស័យដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ

**វាគ្មិនៈ**

១. លោក ហែម ចន្ទ បាន នឹងកំពុងធ្វើការនៅការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំនៅកម្ពុជា តាំងពីខែឧសភា ឆ្នាំ ២០០៩មក ក្នុងនាមជាមន្ត្រីជាន់ខ្ពស់គម្រោង។ លោកទទួលបន្ទុកកិច្ចការកសិកម្ម ការគ្រប់គ្រងធនធានធម្មជាតិ និង ការប្រែប្រួលអាកាសធាតុ។ លោកបានទទួលសញ្ញាប័ត្រថ្នាក់អនុបណ្ឌិតគ្រប់គ្រងធនធានធម្មជាតិ ពីសកលវិទ្យាល័យ ភូមិន្ទកសិកម្មនៅ ឆ្នាំ២០១៣ និងអនុបណ្ឌិតរដ្ឋបាលធុរកិច្ច ពីសកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជានៅឆ្នាំ ២០០៦។

២. លោក Togo Uchida ទីប្រឹក្សាកសាងគម្រោងនៃការិយាល័យ JICA នៅកម្ពុជា ទទួលបន្ទុកហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងការប្រែប្រួលអាកាសធាតុ។ គម្រោងបច្ចុប្បន្នរបស់គាត់ផ្តោតលើហេដ្ឋារចនាសម្ព័ន្ធទីក្រុង ដូចជា ប្រព័ន្ធលូ និងប្រព័ន្ធដោះទឹក និងគម្រោងប្រែប្រួលអាកាសធាតុផងដែរ ជាពិសេស នៅក្នុងផ្នែក REDD+។ កាលពីមុន លោក ធ្លាប់ធ្វើការជាទីប្រឹក្សាភាពជាដៃគូនៅធនាគារជប៉ុនសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ (JBIC) និងនៅការិយាល័យ JICA ក្នុងប្រទេសថៃផងដែរខាងផ្នែកបរិស្ថាន និងការប្រែប្រួលអាកាសធាតុ។

៣. លោក ហេង សុខបិល Heng Sokbil មានអាយុ៣៩ឆ្នាំ បានបញ្ចប់ថ្នាក់បណ្ឌិតវិស្វកម្មអភិវឌ្ឍន៍អន្តរជាតិ ជំនាញវិស្វកម្មបច្ចេកទេសភូមិសាស្ត្រ និងស៊ីវិល ពីវិទ្យាស្ថានបច្ចេកវិទ្យាតូក្យូ។ លោកបានត្រឡប់មកប្រទេសកម្ពុជាក្នុងខែមីនា ឆ្នាំ២០១១ និងបន្តការងាររបស់គាត់នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ គាត់បានទទួលពានរង្វាន់ Golden Green Award សម្រាប់កម្ពុជាពីបណ្ឌិតសភាអាស៊ាននៃវិស្វកម្ម និងបច្ចេកវិទ្យា) AAET ២០១១ក្នុងឆ្នាំ ((នៅប្រទេសម៉ាឡេស៊ីនិង ( ក្លាយជាសមាជិកនៃបណ្ឌិតសភាអាស៊ាននៃវិស្វកម្ម និងបច្ចេកវិទ្យាក្នុងឆ្នាំ២០១២។ ក្នុងខែឧសភា ឆ្នាំ២០១២ គាត់បានទទួលការតែងតាំងពីសម្តេចនាយករដ្ឋមន្ត្រី ជាសមាជិកនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិជាន់ខ្ពស់បន្ថែមលើមុខងារបច្ចុប្បន្ន។ បច្ចុប្បន្ន គាត់កំពុងធ្វើការជាមួយក្រុមការងារស្រាវជ្រាវលើផ្នែកវិទ្យាសាស្ត្របច្ចេកវិទ្យា និង អភិវឌ្ឍគោលនយោបាយ (STI) នៃក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិជាន់ខ្ពស់។

៤. លោកស្រី Nele Bünner ជាអ្នកកសិកម្ម និងសេដ្ឋកិច្ច។ បច្ចុប្បន្ននេះ Bünner បម្រើការងារនៅមជ្ឈមណ្ឌលប្រែប្រួលអាកាសធាតុ ដែលទីស្នាក់ការនៅទីក្រុង Frankfurt ប្រទេសអាល្លឺម៉ង់។ ការងារគន្លិៈរបស់គាត់គឺការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដោយផ្តោតសំខាន់លើការវាយតម្លៃភាពងាយរងគ្រោះ និងផែនការបន្សាំ។ មុនពេលលោកស្រី ចូលរួមការងារជាមួយ GIZ លោកស្រីបានបម្រើការងារនៅវិទ្យាស្ថានគោលនយោបាយបរិស្ថានអឺរ៉ុប នៅទីក្រុង Brussels លើប្រធានបទកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

## វគ្គស្របគ្នាផ្នែកទី ២៖ ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ (ផ.យ.ប.អ. តាមវិស័យ) និងផែនការសកម្មភាព

### ក្រុមទី១៖ ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យសុខាភិបាល អនាម័យ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ

*ទីកន្លែង៖ បន្ទប់ Fuluzu*

**អ្នកធ្វើបទបង្ហាញ៖**

១. លោកបណ្ឌិត កុល ហៅរ៉ូ មានតួនាទីជាអនុប្រធាននាយកដ្ឋាន នៃក្រសួងសុខាភិបាល។ លោកបណ្ឌិត ជាអ្នករៀបចំយុទ្ធសាស្រ្ត ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យសុខាភិបាល

២. ឯកឧត្តម វ័ន្ត វិរៈ ជាសមាជិកនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ។ គាត់ជាអ្នករៀបចំគោលនយោបាយស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនិងការផ្លាស់ប្តូរអាកាសធាតុ។

**វាគ្មិន៖**

១. លោកបណ្ឌិត Iean Russell ជានាយកគម្រោងនៃអង្គការម្លឹះ ដែលជាគម្រោងសន្តិសុខស្បៀងសម្រាប់កសិករតូចតាចនៅភាគពាយព្យនៃប្រទេសកម្ពុជា ដែលទទួលមូលនិធិពីសហភាពអឺរ៉ុប។ កាលពីមុន លោកបានធ្វើការជាមួយ FAO ជាទីប្រឹក្សាកម្មវិធីសម្រាប់គម្រោងមូលនិធិស្បៀងអាហារនៃ FAO EU ដែលរួមទាំង ការទទួលខុសត្រូវលើវេទិកាជាតិសម្រាប់ការប្រែប្រួលអាកាសធាតុ និងកសិកម្ម ដែលបានធ្វើឡើងនៅភ្នំពេញកាលពីឆ្នាំ ២០១១។ មុនពេលចូលធ្វើ ការជាមួយ FAO បណ្ឌិត Russell បានធ្វើការអស់រយៈពេលជាង ២០ឆ្នាំ ជាអ្នកសិក្សាស្រាវជ្រាវនៅសកល វិទ្យាល័យឃ្វីនលែន នៃប្រទេសអូស្រ្តាលី។ លោកមានបទពិសោធន៍ខាងការងារអភិវឌ្ឍន៍នៅទូទាំងតំបន់អាស៊ី-ប៉ាស៊ីហ្វិក។

២. លោក Steven Iddings ជាវិស្វករស៊ីវិលនិងបរិស្ថាន សញ្ជាតិអាមេរិកដែលធ្វើការនៅការិយាល័យ WHO ប្រចាំនៅកម្ពុជា។ លោកដឹកនាំក្រុមការងារខាងជំងឺមិនឆ្លង (NCD) និងសុខភាពបរិស្ថាននៃអង្គការ WHO និងគ្រប់គ្រងកម្មវិធីសុខភាពបរិស្ថាននៃអង្គការ WHO ប្រចាំនៅកម្ពុជា ដែលរួមទាំង ការប្រែប្រួលអាកាសធាតុ និងសកម្មភាពក្នុងផ្នែកសុខភាព។ អតីតភាពការងាររយៈពេលសាមសិបប្រាំឆ្នាំរបស់លោកភាគច្រើនគឺជាមួយអង្គការ WHO និងរួមទាំងតំណែងការងារនៅប្រទេសហ្វីជី សាម៉ៅ ហាវ៉ៃ ប៉ាពួញូហ្គីនេ ឡាវ និងវៀតណាម ដែលរួមទាំង ការងារចំនួនពីរនៅកម្ពុជាផងដែរ។

៣. លោកស្រី ជា អេលីយ៉ាន ជាប្រធានដេប៉ាតឺម៉ង់វិទ្យាសាស្រ្តបរិស្ថាន នៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ។ លោកស្រីបានចូលរួមក្នុងការសិក្សាស្រាវជ្រាវ និងការអនុវត្តគម្រោងជាច្រើន ជាពិសេស នៅក្នុងវិស័យផ្គត់ផ្គង់ទឹក និងអនាម័យ។ បច្ចុប្បន្ននេះ លោកស្រីជានាយកគម្រោងកសាងសមត្ថភាពអំពីការប្រែប្រួលអាកាសធាតុ ភាពងាយរងគ្រោះ និងការបន្សុាំនៅក្នុងគម្រោងទឹក និងវិស័យសុខភាព ដែលទទួលហិរញ្ញវត្ថុគាំទ្រពី CCCA-TF។

៤ .លោក ហេង សុក មានសញ្ញាបត្រថ្នាក់អនុបណ្ឌិតខាងគោលនយោបាយសាធារណៈនៅសកលវិទ្យាល័យជាតិសឹង្ហបូរី។ លោកមានបទពិសោធន៍ក្នុងការងារអភិវឌ្ឍន៍រយៈពេលច្រើនជាង១០ឆ្នាំ។ បច្ចុប្បន្ន លោកធ្វើការជាមួយអង្គការភ្លែនអន្តរជាតិជាអ្នកឯកទេសគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ។ ភ្លែនអន្តរជាតិបាន និងកំពុងអនុវត្តគម្រោងស្តីពីការពង្រឹងភាពធន់នឹងអាកាសធាតុ និងកសិកម្មដែលធន់នឹងអាកាសធាតុផងដែរ។

## ក្រុមទី២៖ ការឆ្លើយតបការប្រែប្រួលក្នុងវិស័យព្រៃឈើ ជលផល និងប្រព័ន្ធអេកូឡូស៊ី

*ទីកន្លែង៖ សាលប្រជុំភូគីត្រា Grand Ballroom 2*

## អ្នកធ្វើបទបង្ហាញ៖

១. Mr. Khun Vathana ប្រធានលេខាធិការដ្ឋានក្រុមការងារ **REDD+** កម្ពុជា និងជាប្រធានស្តីទីការិយាល័យប្រែប្រួលអាកាសធាតុ, និងឥណទានកាបូន នៃរដ្ឋបាលព្រៃឈើ: ការរៀបចំផែនការប្រែប្រួលអាកាសធាតុ សម្រាប់វិស័យព្រៃឈើ

២. លោកស្រីបណ្ឌិត កៅ សុជីវី បានទទួលបរិញ្ញាបត្រវិទ្យាសាស្ត្រជលផល នៃសាកលវិទ្យាល័យភូមិន្ទ កសិកម្ម នៅឆ្នាំ ១៩៩៤។ នៅឆ្នាំ ១៩៩៩ លោកស្រី បានទទួលបរិញ្ញាប័ត្រជាន់ខ្ពស់គ្រប់គ្រង នៅសាកលវិទ្យាល័យ នៃ ប្រទេសហ្វីលីពីន ទីក្រុង Los Banos ក្នុងឆ្នាំ ២០០២។ ក្នុងឆ្នាំ ២០០៣ លោកស្រីបានទទួលអាហារូបករណ៍ SEARCA ម្តងទៀតដើម្បីបន្ត ថ្នាក់បណ្ឌិត ផ្នែកអភិវឌ្ឍន៍សហគមន៍នៅឆ្នាំ ២០០៥។ នៅក្នុងឆ្នាំ ២០០៧ លោកស្រីបណ្ឌិត កៅ សុជីវី ត្រូវបានតែងតាំង ជាអនុប្រធាន វិទ្យាស្ថានការប្រមូលផល នេសាទ និងបច្ចេកវិទ្យា នៃរដ្ឋបាលជលផល។ នៅឆ្នាំ ២០០៩ រហូតដល់ បច្ចុប្បន្ន លោកស្រីបណ្ឌិត ត្រូវបានតែងតាំងជា អគ្គនាយករង នៃ រដ្ឋបាលជលផល។ លោកស្រីបណ្ឌិត ទទួលខុសត្រូវដ៏សំខាន់លើវិទ្យាស្ថានស្រាវជ្រាវការនេសាទ ទឹក និងអភិវឌ្ឍន៍ ) IFReDI ) និងនាយកដ្ឋានបច្ចេកវិទ្យាប្រមូលផលនេសាទ ព្រមទាំងការប្រែប្រួលអាកាសធាតុ ក្នុងវិស័យជលផល។

៣ .លោក អ៊ុក ណាវ៉ាន់ អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ក្រសួងបរិស្ថាន: ការឆ្លើយតបការប្រែប្រួលអាកាសធាតុ ក្នុងវិធីសាស្ត្រដែលមានមូលដ្ឋានលើប្រព័ន្ធអេកូ

## វាគ្មិន៖

១. Sarah Sitts បានបម្រើការជាអ្នកគ្រប់គ្រងអង្គការផែកប្រចាំនៅប្រទេសកម្ពុជា ចាប់តាំងពីខែ មិថុនា ឆ្នាំ ២០១២មក។ Sarah ដឹកនាំការងារក្នុងកម្មវិធីនៃគម្រោងគ្រប់គ្រងធនធានធម្មជាតិ របរចិញ្ចឹមជិវិតនិងអភិបាលកិច្ចនៅកម្ពុជា ដែលរួមបញ្ចូល គម្រោងសហគមន៍ព្រៃឈើ REDD+ នៅ ឧត្តរមានជ័យផងដែរ។ នៅក្នុងអង្គការផែក Sarah បានដើរតួសំខាន់មួយនៅក្នុងការបង្កើត និងគ្រប់គ្រងគម្រោងនៅប្រទេសមីយ៉ាន់ម៉ា និងបានធ្វើការគ្រប់គ្រងគម្រោង និងធ្វើការក្នុងតំណែងអភិវឌ្ឍន៍ធុរកិច្ចពីការិយាល័យនៅវ៉ាស៊ីនតោន ឌីស៊ី។ កាលពីមុនមក Sarah ធ្លាប់បានធ្វើការក្នុងកម្មវិធីសិទ្ធិសមធម៌ មូលនិធិសត្វព្រៃអាហ្វ្រិក DAI និង John Snow។ Sarah មានសញ្ញាបត្រថ្នាក់ អនុបណ្ឌិតខាងការអភិវឌ្ឍអន្តរជាតិពីមហាវិទ្យាល័យ Fletcher ខាងកិច្ចការច្បាប់ និងកិច្ចការទូត នៃសកលវិទ្យាល័យ Tufts ហើយសារណាស្រាវជ្រាវរបស់គាត់បានពិនិត្យមើលខ្សែចង្វាក់តម្លៃ នៅក្នុងឧស្សាហកម្មអេកូទេសចរណ៍។

២. Peter Iversen ជាអ្នកឯកទេសខាងបច្ចេកទេសក្នុងកម្មវិធី UN-REDD ដែលជាកម្មវិធីមួយជួយកម្ពុជាកសាងសមត្ថភាពដើម្បីចូលរួមនៅក្នុងយន្តការអន្តរជាតិសម្រាប់ UNFCCC REDD+ ពោលគឺការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ។ Peter បានធ្វើជាតំណាងប្រទេសកម្ពុជានៅក្នុងការចរចាក្នុងអនុសញ្ញា UNFCCC លើការ ប្រើប្រាស់ដី ដែលរួមទាំង REDD+ និងកសិកម្ម ចាប់តាំងពី COP9 (2003) ដល់ COP18 (2012) និងបានធ្វើជាប្រធាននៅក្នុងការចរចាអំពីការប្រើប្រាស់ដី ការប្រែប្រួលលើការប្រើប្រាស់ដីនិងព្រៃឈើ នៅក្រោមពិធីសារក្យូតូ ពី COP16 ដល់ COP18។

៣ .បណ្ឌិត Kien Tran-Mai (MRC/CCAI) ៖មានបទពិសោធន៍រយៈពេល ១៧ឆ្នាំក្នុងការងារស្រាវជ្រាវ និងបទពិសោធន៍ការងារជាក់ស្តែងនៅក្នុងផ្នែកប្រែប្រួលបរិស្ថានពិភពលោក និងការប្រែប្រួលអាកាសធាតុ។ បណ្ឌិត កៀន កំពុងកាន់តំណែងជា មន្ត្រីជាន់ខ្ពស់កម្មវិធីប្រែប្រួលអាកាសធាតុនៃលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ (MRC-S), កិច្ចផ្តួចផ្តើមប្រែប្រួលអាកាសធាតុ និងការបន្សុំា (CCAI)។ ជំនាញរបស់គាត់មានរាប់ចាប់ពីការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយ គោលនយោបាយអាកាសធាតុ និងការកសាងផែនការយុទ្ធសាស្រ្ត កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សុំាផ្អែកតាមសហគមន៍ តាមរយៈសុខភាពបរិស្ថាន និងសុខភាពសាធារណៈ។

បណ្ឌិត កៀន មានសញ្ញាប័ត្រថ្នាក់អនុបណ្ឌិតខាងវិទ្យាសាស្រ្តសុខាភិបាល និងសុខភាពសាធារណៈ និងបានបញ្ចប់ថ្នាក់ បណ្ឌិតខាងការប្រែប្រួលបរិស្ថានពិភពលោក និងផលប៉ះពាល់មកលើសុខភាពសាធារណៈនៅក្រុងម៉ូស្គូ សហព័ន្ធរុស្ស៊ី នៅឆ្នាំ ២០០០។ លោកបានបញ្ចប់ការស្រាវជ្រាវថ្នាក់ក្រោយបណ្ឌិតស្តីពីផលប៉ះពាល់ នៃការប្រែប្រួលអាកាសធាតុមកលើសុខភាពសាធារណៈ និងបានបោះពុម្ពអត្ថបទដៃឡមានការពិនិត្យជាក្រុម និងជំពូកក្នុងសៀវភៅ នានានៅក្នុងទិនានុប្បវត្តិអន្តរជាតិ និងសៀវភៅនានាស្តីពីការប្រែប្រួលអាកាសធាតុ និងសុខភាពសាធារណៈ។ បណ្ឌិត កៀន បានបង្រៀននៅសកលវិទ្យាល័យវៀតណាម បានបម្រើការជាវាគ្មិនកិត្តិយស អ្នកជំនាញ ឬ វាគ្មិន នៅក្នុងសន្និសីទអន្តរជាតិ សិក្ខាសាលាជាច្រើនផងដែរ។ មុនចូលធ្វើការនៅ MRC ក្នុងឆ្នាំ ២០០៨ បណ្ឌិត កៀន បាន ធ្វើការជាអ្នកស្រាវជ្រាវជាន់ខ្ពស់ និងអនុប្រធានដេប៉ាតឺម៉ង់នៅក្នុងវិទ្យាស្ថានឧតុនិយម ជលសាស្រ្ត និងបរិស្ថាន (IMHEN) ជាតិវៀតណាម និងបានរួមចំណែកក្នុងការបង្កើត និងរៀបចំ "កម្មវិធីជាតិដើម្បីឆ្លើយតបនឹងការប្រែប្រួល អាកាសធាតុ"(NTP.RCC) និង "យុទ្ធសាស្រ្តជាតិវៀតណាមស្តីពីយន្តការអភិវឌ្ឍស្អាត"។

៤. Micah Ingalls បម្រើការក្នុងតំណែងពីរ ជាប្រធានកម្មវិធីអភិរក្សនៃអង្គការ WWF ប្រចាំនៅប្រទេសឡាវ និងជា នាយកអង្គការ WWF ប្រចាំនៅប្រទេសកម្ពុជា។ លោកបានធ្វើការនៅអាស៊ីតាំងពីឆ្នាំ ២០០១ ក្នុងការគ្រប់គ្រងប្រព័ន្ធ អេកូឡូស៊ី-សង្គម និងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុជាមួយអង្គការនានា ដូចជា គណៈកម្មការទន្លេ មេគង្គ, GiZ, DAI និងអង្គការទស្សនៈពិភពលោក។ លោកគឺជាកូនប្រុសជំនាន់ទីប្រាំបួននៃកសិករអាមេរិក ដែលមាន កម្រិតសិក្សាជាន់ខ្ពស់ខាងកៀរគ្របរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ មកពីមហាវិទ្យាល័យ Wheaton និង សកលវិទ្យាល័យ Cornell។

## ក្រុមទី៣៖ ការកាត់បន្ថយការប្រែប្រួលអាកាសធាតុក្នុងវិស័យឧស្សាហកម្ម និងថាមពល

*កន្លែង៖ សាលប្រជុំភូគីត្រា១ ជាន់ទី២*

### អ្នកធ្វើបទបង្ហាញ៖

១. ឯកឧត្តមបណ្ឌិត ទឹង ស៊ីនី អនុរដ្ឋលេខាធិការ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។ បទបង្ហាញរបស់ ឯកឧត្តមបណ្ឌិតគឺការរៀបចំផែនការយុទ្ធសាស្រ្តប្រែប្រួលអាកាសធាតុសម្រាប់វិស័យឧស្សាហកម្ម។

២. លោក គួច សុវណ្ណា ប្រធាន នាយកដ្ឋានបច្ចេកទេសថាមពល នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។ បទបង្ហាញរបស់លោក សុវណ្ណា គឺ ការរៀបចំផែនការប្រែប្រួលអាកាសធាតុសម្រាប់ផលិតកម្មថាមពល។

## វាគ្មិនៈ

១. លោក ឈួង ហ៊ឹងហិញ ជាវិស្វករត្រួតពិនិត្យគុណភាព។ គាត់ទទួលបន្ទុកផ្នែក ធានាគុណភាពផលិតកម្មស៊ីម៉ង់ និងតាមដានត្រួតពិនិត្យស្តង់ដាគុណភាព ISO 9001 និង 14001។ គាត់មានបទពិសោធន៍ការងាររយៈពេល ១០ឆ្នាំ។

២. លោក Jeff Ospital គឺជានាយកប្រតិបត្តិស្តីទីនៃ កាបូនេកសឹសដើម្បីអភិវឌ្ឍន៍។ អស់រយៈពេល ២៥ឆ្នាំមកហើយ លោកបានគ្រប់គ្រងអង្គការខុសៗគ្នា ដែលរួមទាំង អង្គការមិនមែនរដ្ឋាភិបាលធំៗនៅអាហ្វ្រិកខាងត្បូង ដែលធ្វើការផ្តោតជាសំខាន់លើការអភិវឌ្ឍជនបទ ភាពធន់របស់សហគមន៍ សកម្មភាពបង្កើនប្រាក់ចំណូល ប្រសិទ្ធភាពថាមពល និងគម្រោងថាមពលកកើតឡើងវិញនៅតំបន់ដែលគ្មានបណ្តាញចែកចាយអគ្គិសនី។ Jeff ធ្វើការក្នុងគណៈកម្មាធិការជាន់ខ្ពស់ជាច្រើនដែលដឹកនាំគម្រោងសាធារណៈនានា ក្នុងនាមជាអ្នកផ្តល់ការប្រឹក្សា និងបានចូលរួមនៅក្នុងការសរសេរគោលនយោបាយថាមពលកកើតឡើងវិញជាដំបូងនៅប្រទេសអាហ្វ្រិកខាងត្បូង។ លោកមានចំការឈើទំហំ ២៨០អេយ៉រ និងនិច្ចវប្បកម្មនៅប្រទេសប៉ូឡូញផងដែរ។

៣. Carlo Figà Talamanca គឺជានាយកប្រតិបត្តិ និងជាម្ចាស់សហគ្រាសនិរន្តរភាពឥន្ធនៈបៃតង (SGFE) និងជាប្រធានគណៈកម្មាធិការធុរកិច្ចបៃតងនៃសភាពាណិជ្ជកម្មអឺរ៉ុបប្រចាំនៅកម្ពុជា។ លោកបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យរ៉ូម ខាងវិស្វកម្មឧស្សាហកម្មនៅឆ្នាំ ២០០២។ លោកបានចាប់ផ្តើមអាជីពក្នុងជំនួញពិគ្រោះយោបល់ ដោយចូលរួមក្រុមផ្ទេរបច្ចេកវិទ្យាអន្តរជាតិអ៊ីណូវ៉ា (INNOVA S.p.A.) (អ៊ីតាលី)។ នៅឆ្នាំ ២០០៥ លោកត្រូវបានតែងតាំងជានាយកប្រតិបត្តិនៃសាខា INNOVA ប្រចាំនៅស.រ.អា ដែលនៅទីនោះលោកដឹកនាំគម្រោងផ្ទេរបច្ចេកវិទ្យាអន្តរជាតិជាមួយអឺរ៉ុប ស.រ.អា និងអាមេរិកឡាទីន។ ចាប់ពីឆ្នាំ ២០១០មក លោកធ្វើការនៅកម្ពុជា ដែលក្រៅពីក្នុងជំនួញផ្ទាល់ខ្លួន លោកក៏ធ្វើការជាទីប្រឹក្សាសម្រាប់គម្រោងដែលទាក់ទងនឹងថាមពលផងដែរ។

## វគ្គស្របគ្នាផ្នែកទី ៣៖ ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ (ផ.យ.ប.អ. តាមវិស័យ) និងផែនការសកម្មភាព (បន្ត)

---

## ក្រុមទី១៖ ការឆ្លើយតបការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងការគ្រប់គ្រងគ្រោះមហន្តរាយ

*ទីកន្លែង៖ សាលប្រជុំភ្ញូគីត្រា Grand Ballroom 2*

## អ្នកធ្វើបទបង្ហាញ៖

១. លោក គង់ ចាន់ថន ទីប្រឹក្សាការប្រែប្រួលអាកាសធាតុជាតិ នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

២. លោកវេជ្ជបណ្ឌិត សុទ្ធ គីមកុលមុនី អនុប្រធាននាយកដ្ឋានត្រៀមរៀបចំ និងបណ្តុះបណ្តាល នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។ លោកវេជ្ជបណ្ឌិត ជាអ្នករៀបចំផែនការយុទ្ធសាស្រ្តប្រែប្រួលអាកាសធាតុសម្រាប់គ្រប់គ្រងហានិភ័យ នៃគ្រោះមហន្តរាយ។

**វាគ្មិនៈ**

១. លោក ហុក គីមធួន ប្រធានគម្រោងថ្នាក់ជាតិ អង្គភាពគាំទ្រគម្រោង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

២. Ms. Sanna Salmela Eckstein ប្រតិភូកាកបាទក្រហម ប្រចាំតំបន់អាស៊ី និងហ្វាំងឡង់

៣ .លោក គីម រតនា ប្រធានប្រតិបត្តិអង្គការ Caritas កម្ពុជា

៤. Julian Abrams ជាអ្នកជំនាញឯកទេសខាងការអភិវឌ្ឍមូលដ្ឋាន។ គាត់បានធ្វើការនៅក្នុងកម្មវិធីកំណែទម្រង់ វិមជ្ឈការនៅកម្ពុជាតាំងពីឆ្នាំ១៩៩៧មក។ ក្នុងនាមជាអ្នកសម្របសម្រួលកម្មវិធីរស់នៅ បន្សាំនឹងអាកាសធាតុ នៅ មូលដ្ឋាន (LoCAL) នៃUNCDF លោកជួយនៅក្នុងការវិនិយោគលើភាពធន់នឹងអាកាសធាតុ តាមរយៈរដ្ឋាភិបាលមូលដ្ឋាននៅក្នុងប្រទេសមួយចំនួនក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក

## ក្រុមទី២៖ ការឆ្លើយតបការប្រែប្រួលអាកាសធាតុនៅតំបន់ឆ្នេរ និងទេសចរណ៍

*ទីកន្លែង៖ សាលប្រជុំភូគីត្រា១ ជាន់ទី២*

**អ្នកធ្វើបទបង្ហាញ៖**

១. លោក ប៊ូ ចាន់សេរី អនុប្រធាន នាយកដ្ឋានផែនការ និងអភិវឌ្ឍន៍វិស័យទេសចរណ៍ នៃក្រសួងទេសចរណ៍។ លោក សេរី មានបទពិសោធន៍ ក្នុងការរៀបចំផែនការប្រែប្រួលអាកាសធាតុក្នុងវិស័យទេសចរណ៍

២. លោកបណ្ឌិត វ៉ាន់ មុនិនាថ អគ្គនាយករងបច្ចេកទេស នៃក្រសួងបរិស្ថាន

**វាគ្មិនៈ**

១. បណ្ឌិត នេត បារមី មានសញ្ញាបត្រថ្នាក់បណ្ឌិត (PhD) ខាងវិទ្យាសាស្រ្តកសិកម្មដើម្បីអភិវឌ្ឍន៍ជនបទ និងសហគមន៍ នៅឆ្នាំ ២០០៨ ពីសកលវិទ្យាល័យ កាសសែល និងបទពិសោធន៍ការងារស្រាវជ្រាវក្រោយបានបញ្ចប់ថ្នាក់បណ្ឌិត (ឆ្នាំ២០០៩-២០១១)ជាមួយសកលវិទ្យាល័យ Georg-August នៅកូទីនកេន ប្រទេសអាល្លឺម៉ង់។ បណ្ឌិតជាប្រធានដេប៉ាតឺម៉ង់ ទេសចរណ៍ និង ជាបុគ្គលសំខាន់ម្នាក់នៅក្នុងកម្មវិធីថ្នាក់ក្រោយបរិញ្ញាបត្រខាងការសិក្សាអភិវឌ្ឍន៍នៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ។

២. បច្ចុប្បន្ន លោក គង់ គីមស្រេង មាននាទីជាមន្ត្រីកម្មវិធីជាន់ខ្ពស់នៃអង្គការ IUCN នៅកម្ពុជា ដែលក៏ជាអ្នកសម្របសម្រួលប្រចាំកម្ពុជាផងដែរ សម្រាប់គម្រោងកសាងភាពធន់នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ នៅតំបន់ ឆ្នេរអាស៊ីអាគ្នេយ៍ (BCR) សម្រាប់កម្ពុជា និងការសន្ទនាអំពីទឹកនៅតំបន់មេគង្គសម្រាប់កម្ពុជា។ លោក គីមស្រេង មានសញ្ញាប័ត្រអនុបណ្ឌិតគ្រប់គ្រងធនធានធម្មជាតិនៅឆ្នាំ ២០០៨ និងបរិញ្ញាបត្រវិទ្យាសាស្ត្រព្រៃឈើ នៅឆ្នាំ ១៩៩៨ ពីសកលវិទ្យាល័យភូមិន្ទកសិកម្ម។ លោកមានបទពិសោធន៍ធ្វើការជាមួយស្ថាប័នរដ្ឋាភិបាល និង NGOs អស់រយៈ

ពេលជិត ១៣ឆ្នាំក្នុងការងារអភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិ បញ្ហាប្រែប្រួលអាកាសធាតុនៅក្នុងតំបន់ ឆ្នេរកម្ពុជា ជាពិសេស ការស្រាវជ្រាវជីវៈចម្រុះ និងតំបន់ដីសើម នៅក្នុងតំបន់ការពារធម្មជាតិភាគច្រើន ដែលរួមទាំង តំបន់រ៉ាមសារនៅកម្ពុជា (ស្ទឹងត្រែង បឹងឆ្មារ និងកោះកាពិ)។

៣ .លោក វ៉ា មឿន មានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រខាងគណិតវិទ្យា ពីសកលវិទ្យាល័យភូមិន្ទភ្នំពេញ និងវិញ្ញាបនបត្រឌីប្លូម៉ា ខាងការរៀបចំផែនការអប់រំ ពី IIEP នៅក្រុងប៉ារីស ប្រទេសបារាំង។ ក្រោយបានបម្រើការងារក្នុងវិស័យអប់រំនៅក្នុងក្របខ័ណ្ឌរដ្ឋាភិបាលកម្ពុជាអស់រយៈពេល ២៣ឆ្នាំ នៅឆ្នាំ២០០២ លោកបានសម្រេចចិត្តចូលធ្វើការនៅអង្គការម្លប់បៃតង ក្នុងនាមជានាយកប្រតិបត្តិ។ លោកបានប្រែក្លាយអង្គការម្លប់បៃតងពីអង្គការតូចមួយ ទៅជាអង្គការដ៏ធំមួយដែលមានភាពល្បីល្បាញ និងមានបុគ្គលិកច្រើនជាង ៦០នាក់។

## ក្រុមទី៣៖ វឌ្ឍនភាពរបស់កម្ពុជាក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងដំណើរឆ្ពោះទៅកាន់សកម្មភាពជាតិសមស្របសម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (NAMA)

*ទីកន្លែង៖ បន្ទប់ Fuluzu*

### អ្នកធ្វើបទបង្ហាញ៖

១. លោក Conrado Heruela អ្នកគ្រប់គ្រង គម្រោងប្រែប្រួលអាកាសធាតុនៃកម្មវិធីបរិស្ថានសហប្រជាជាតិបានផ្តោតសំខាន់លើវិស័យថាមពល ដែលទទួលបានថវិកាពីមូលនិធិបរិស្ថានសកល។ លោក Conrado Heruela បម្រើការងារនៅផ្នែកបច្ចេកវិទ្យា ឧស្សាហកម្ម និងសេដ្ឋកិច្ច នៃការិយាល័យប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក។ កម្មវិធីបរិស្ថានសហប្រជាជាតិ កំពុងផ្តួចផ្តើមគំនិតរៀបចំផែនការសកម្មភាពកាត់បន្ថយសមស្របថ្នាក់ជាតិ។

២. លោកស្រីAkiko Fukui ជាជំនួយការស្រាវជ្រាវ នៃក្រុមយន្តការទីផ្សារកាបូន វិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានសកល។ Akiko Fukui ជាអ្នកស្រាវជ្រាវពីវិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានពិភពលោក (IGES)។ លោកស្រីធ្វើការលើការកសាងសមត្ថភាពសម្រាប់យន្តការអភិវឌ្ឍន៍ស្អាត (CDM) ក៏ដូចជា យន្តការផ្តល់ឥណទានរួមនៃកិច្ចផ្តួចផ្តើមជប៉ុនក្នុងបណ្តាប្រទេសនៅអាស៊ីផងដែរ។ លោកស្រីបង្កើតកម្រងទិន្នន័យ និងប័ណ្ណព័ត៌មានសម្រាប់គណនាការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សម្រាប់គម្រោង CDM និងគាំទ្រដល់នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថានកម្ពុជា ក្នុងការបង្កើតសំណើលក្ខខណ្ឌគោលស្តង់ដារ និងគណនាមេគុណបញ្ចេញឧស្ម័នពីបណ្តាញអគ្គិសនីនៅកម្ពុជាផងដែរ។

៣. លោក អ៊ុយ កាម៉ាល់ អនុប្រធាន នាយកដ្ឋានប្រែប្រួលអាកាសធាតុ ក្រសួងបរិស្ថាន។ លោក និងធ្វើបទបង្ហាញស្តីពីដំណើរការសកម្មភាពកាត់បន្ថយសមស្របថ្នាក់ជាតិនៅកម្ពុជា ដែលផ្តោតសំខាន់លើ ដំណើរឆ្ពោះទៅមុខ បទពិសោធន៍ និងជំហានបន្ទាប់

### វាគ្មិន៖

១. លោក វន់ វណ្ណារិទ្ធ ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ក្រសួងបរិស្ថាន

២. លោកបណ្ឌិត Alex ជាអ្នកជីវអភិរក្សមួយរូប ដែលមានបទពិសោធន៍ជាមួយនឹងគម្រោងបរិស្ថាននៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ ២០០០។ លោកបណ្ឌិត Diment ជាទីប្រឹក្សាជាន់ខ្ពស់បច្ចេកទេស សម្រាប់ការ WCS ដោយគាំទ្រលើ ការគ្រប់គ្រងព្រៃឈើ និងអភិរក្សសត្វព្រៃ ជាពិសេសការងារដែលពាក់ព័ន្ធនឹងពារព្រៃឈើសីម៉ា នៅក្នុងខេត្ត មណ្ឌលគិរី។

៣. លោក ម៉ៅ វិសាល ប្រធានការិយាល័យសង្គម បរិស្ថាន និងទំនាក់ទំនងសាធារណៈ នៃ EAC។

# ថ្ងៃទី៣៖ ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៣

## វគ្គពេញអង្គ៖ ហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ

### ១. ក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុអន្តរជាតិ

**អ្នកធ្វើបទបង្ហាញ៖**

Joanne Manda អ្នកឯកទេសហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុ នៅពេលថ្មីៗនេះ បានចូលរួមជាមួយ UNDP APRC នៅក្នុងក្រុមការងារប្រជាធិបតេយ្យនិងអភិបាលកិច្ច ជាអ្នកឯកទេសទទួលខុសត្រូវក្នុងការជួយបង្កើតឧបករណ៍ និងប្រព័ន្ធនានាសម្រាប់អភិបាលកិច្ចប្រសើរជាងមុនខាងហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុ និងប្រសិទ្ធភាពនៃការអភិវឌ្ឍ។ គាត់នឹងមានតួនាទីគាំទ្រដល់កិច្ចផ្តួចផ្តើមហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុថ្នាក់តំបន់ ដោយធានាថា ហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុត្រូវបានផ្តល់ជាប្រយោជន៍សម្រាប់អ្នកក្រីក្រ និងងាយរងគ្រោះ។ គាត់ចូលរួមជាមួយ UNDP APRC ក្រោយពីបានធ្វើការរយៈពេល ១២ឆ្នាំនៅក្នុង DFID ដែលក្នុងនោះតំណែងចុងក្រោយបំផុតរបស់គាត់គឺទីប្រឹក្សាខាងការប្រែប្រួលអាកាសធាតុនិងបរិស្ថាននៅប្រទេសបង់ក្លាដែស។

### ២. ក្របខ័ណ្ឌហិរញ្ញប្បទានជាតិការប្រែប្រួលអាកាសធាតុ

**អ្នកធ្វើបទបង្ហាញ៖**

លោកបណ្ឌិត តូច ច័ន្ទក្រឹស្នា ជាប្រធានការិយាល័យធនាគារពិភពលោក នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លោកបណ្ឌិត បានធ្វើការក្នុងគម្រោងសាកល្បងសម្រាប់ភាពធន់នឹងការប្រែប្រួលអាកាសធាតុ(PPCR) ចាប់តាំងពីឆ្នាំ២០០៩។ លោកជាជនបង្គោលរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគម្រោង PPCR និងជាសមាជិកក្រុមបច្ចេកទេស ការងារប្រែប្រួលអាកាសធាតុនៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ។

**វាគ្មិន៖**

១. លោក Koen Everaert មានកម្រិតសិក្សាថ្នាក់អនុបណ្ឌិតវិទ្យាសាស្ត្រខាងការគ្រប់គ្រងធនធានធម្មជាតិ មកពី សកលវិទ្យាល័យ Ghent ប្រទេសបែលហ្សិក និងអនុបណ្ឌិតវិទ្យាសាស្ត្រគោលនយោបាយសាធារណៈ និងការគ្រប់ គ្រង ពីសកលវិទ្យាល័យ នៃទីក្រុងឡុង ចក្រភពអង់គ្លេស។ លោកបានធ្វើការនៅអាស៊ី អស់រយៈពេល ១៧ឆ្នាំ ភាគ ច្រើនលើការគ្រប់គ្រងធនធានធម្មជាតិ។ បច្ចុប្បន្ននេះ លោកជាមន្ត្រីគ្រប់គ្រងធនធានធម្មជាតិ និងប្រែប្រួលអាកាស ធាតុនៃប្រតិភូសហភាពអឺរ៉ុបប្រចាំនៅព្រះរាជា ណាចក្រកម្ពុជា និងជាប្រធានសម្របសម្រួលក្រុមការងារបច្ចេកទេស កំណែទម្រង់វិស័យព្រៃឈើ។

២. លោក Julien Chevillard, ជាបុគ្គលិករដ្ឋបាល នៃលេខាធិការដ្ឋានមូលនិធិប្រែប្រួលអាកាសធាតុ/កម្មវិធីអភិវឌ្ឍន៍ សហប្រជាជាតិ

៣. លោកបណ្ឌិត ទិន ពន្លក អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ និងជាប្រធានលេខាធិការដ្ឋានមូលនិធិប្រែប្រួលអាកាសធាតុ ក្រសួងបរិស្ថាន

## វគ្គពេញអង្គ៖ កិច្ចសហប្រតិបត្តិការអន្តរជាតិ

## ការឆ្លើយតបការប្រែប្រួលអាកាសធាតុថ្នាក់តំបន់ផ្តោតលើទិដ្ឋភាពទូទៅនៃគម្រោងគំនិតផ្តួចផ្តើមបន្សុំាំនឹងការប្រែប្រួលអាកាសធាតុ (CCAI)

### អ្នកធ្វើបទបង្ហាញ៖

លោក នួន វណ្ណា មន្ត្រីបច្ចេកទេសប្រែប្រួលអាកាសធាតុ និងគំនិតផ្តួចផ្តើមបន្សុំាំ នៃលេខាធិការដ្ឋានគណកម្មាការទន្លេមេគង្គ

### វាគ្មិន៖

១. បណ្ឌិត Pradeep Kurukulasuriya ដឹកនាំកម្មវិធីទាំងអស់របស់ UNDP/GEF ដែលទាក់ទងនឹងការ បន្សុំាំទៅនឹងការប្រែប្រួល អាកាសធាតុ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍បញ្ចេញកាបូនតិចដែលធន់នឹងអាកាសធាតុ។ បណ្ឌិតត្រូវបានចាត់តាំងពី ការិយាល័យកណ្តាលនៃ UNDP ឱ្យប្រចាំការនៅមជ្ឈមណ្ឌលប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលនៅទីនោះបណ្ឌិតបាន ដឹកនាំកិច្ចប្រឹងប្រែងនានានៅជុំវិញពិភពលោកដើម្បីជួយប្រទេសនានា ដាក់ពាក្យសុំ រួមបញ្ចូល និងចាត់ចែងកិច្ចការ ជាបន្តបន្ទាប់ពាក់ព័ន្ធនឹងហិរញ្ញប្បទានពីមូលនិធិអាកាសធាតុពិភពលោកខុសៗគ្នា។ បណ្ឌិតKurukulasuriya មានសញ្ញាបត្រថ្នាក់បណ្ឌិត(PhD)ខាងសេដ្ឋកិច្ចបរិស្ថាន មកពីសកលវិទ្យាល័យយេល នៅស.រ.អា និងថ្នាក់ អនុបណ្ឌិតពីសកលវិទ្យាល័យខេមប្រ៊ីជ នៅចក្រភពអង់គ្លេស។

២. លោក Conrado Heruela អ្នកគ្រប់គ្រងការងារគម្រោងប្រែប្រួលអាកាសធាតុ ផ្តោតសំខាន់លើវិស័យថាមពល ដែលទទួលបានថវិកាពីមូលនិធិបរិស្ថានសកល។ លោក Conrado Heruela បម្រើការងារនៅផ្នែកបច្ចេកវិទ្យា ឧស្សាហកម្ម និងសេដ្ឋកិច្ច នៃការិយាល័យប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក។ កម្មវិធីបរិស្ថានសកល កំពុងផ្តួចផ្តើមគំនិតរៀបចំផែនការសកម្មភាពកាត់បន្ថយសមស្របថ្នាក់ជាតិ

៣. Mr. Peter Brimble អនុប្រធាន ធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំប្រទេសកម្ពុជា

## វគ្គពេញអង្គ៖ គោលជំហររបស់ប្រទេសកម្ពុជា ក្នុងសន្និសីទកំពូលលើកទី១៩ នៃអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ

## បច្ចុប្បន្នភាពចុងក្រោយនៃកិច្ចចរចា UNFCCC

### អ្នកធ្វើបទបង្ហាញ៖

បច្ចុប្បន្ននេះ លោក **ស៊ុំ ធី** ជាប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ និងជាអ្នកសម្របសម្រួលគំរោង អភិវឌ្ឍន៍គោល នយោបាយ និងការគ្រប់គ្រងចំណេះដឹងប្រែប្រួលអាកាសធាតុ នៃ

កម្មវិធីសម្ព័ន្ធភាពប្រែប្រួល អាកាសធាតុកម្ពុជា។ លោកបានទទួលសញ្ញាប័ត្រអនុបណ្ឌិត ផ្នែកគ្រប់គ្រងការអភិវឌ្ឍន៍។

ចាប់តាំងពីឆ្នាំ១៩៩៩ លោក **ស៊ុំ ធី** បានចូលរួមធ្វើគំរោងជាច្រើន ដែលទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុ មានដូចជា ការរៀបចំរបាយការណ៍ជាតិលើកទី១ នៅក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ ការកសាងសមត្ថភាពសម្រាប់យន្តការអភិវឌ្ឍន៍ស្អាត កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងរបាយការណ៍ជាតិលើកទី២។

ជាមួយគ្នានេះ លោកក៏បានចូលរួមយ៉ាងសកម្មក្នុងការបង្កើត និងរៀបចំស្ថាប័នប្រែប្រួលអាកាសធាតុជាតិ ដែល រួមមាន គណៈកម្មាធិការប្រែប្រួលអាកាសធាតុជាតិ ក្រុមបច្ចេកទេសប្រែប្រួលអាកាសធាតុ និងនាយកដ្ឋាន ប្រែប្រួល អាកាសធាតុ។ លោកក៏ជាសមាជិកនៃប្រតិភូកម្ពុជាដែលចូលរួមចរចាលើបញ្ហាប្រែប្រួលអាកាសធាតុ របស់អង្គការ សហប្រជាជាតិ។

## សេចក្តីព្រាងគោលជំហររបស់ប្រទេសកម្ពុជា និងដំណើរឆ្ពោះទៅមុខ

### អ្នកធ្វើបទបង្ហាញ៖

លោក ជា ច័ន្ទធូ មានបទពិសោធន៍ការងារ ២៤ឆ្នាំ ជាមួយស្ថាប័នរដ្ឋាភិបាល នៅក្នុងវិស័យកសិកម្ម ការរៀបចំផែនការបរិស្ថាន និងការប្រែប្រួលអាកាសធាតុ បន្ទាប់ពីលោកបានបញ្ចប់ការសិក្សាជាវិស្វករបច្ចេកវិទ្យាសម្រាប់វិស័យកសិកម្មពីប្រទេសអាល្លឺម៉ង់ក្នុងឆ្នាំ ១៩៩៨ ហើយគាត់បានទទួលអនុបណ្ឌិតរដ្ឋបាលសាធារណៈនៅក្នុង ឆ្នាំ ២០០៩។ បច្ចុប្បន្ន លោក ជា ច័ន្ទធូ ជាអនុប្រធាន នាយកដ្ឋានប្រែប្រួលអាកាសធាតុ ក្រសួងបរិស្ថាន និងបានចូលរួមនៅក្នុងសកម្មភាពដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ ១៩៩៩ រួមទាំងគោលនយោបាយយុទ្ធសាស្រ្ត សម្របសម្រួល ការកាត់បន្ថយ និងសារពើភ័ណ្ឌ GHG។ លោក ច័ន្ទធូ ជាសមាជិក ក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ និងបានដឹកនាំក្រុមជម្រើសសម្រាប់ការអភិវឌ្ឍនៃ NAPA SNC និង CCCSP នេះ។

# ឧបសម្ព័ន្ធទី ៥៖ បញ្ជីរាយនាមអ្នកចូលរួម

| ល.រ | នាម និងគោត្តនាម | តួនាទី | ស្ថាប័ន |
|---|---|---|---|
| | | **គណៈអធិបតី** | |
| 1. | ឯកឧត្តម សាយ សំអាល់ | រដ្ឋមន្ត្រី | MoE |
| 2. | ឯកឧត្តម ខៀវ មុត | រដ្ឋលេខាធិការ | MoE |
| 3. | ឯកឧត្តម រស់ សីលវ៉ា | អនុរដ្ឋលេខាធិការ | MEF |
| 4. | ឯកឧត្តម ប៉ាន ប៊ុនធឿន | រដ្ឋលេខាធិការ | MoP |
| 5. | ឯកឧត្តម Jean-François Cautain | ឯកអគ្គរដ្ឋទូតប្រចាំកម្ពុជា | EU |
| 6. | លោក Peter J. Brimble | នាយករងប្រចាំប្រទេស | ADB |
| 7. | លោកស្រី Claire Van der Vaeren | មន្ត្រីសម្របសម្រួលនៃអង្គការសហប្រជាជាតិប្រចាំកម្ពុជា | UNDP |
| 8. | ឯកឧត្តម សាបូ អូហ្សាណ្ណា | រដ្ឋលេខាធិការ | MoE |
| | | **ប្រធានដឹកនាំ និងវាគ្មិន** | |
| 9. | លោកជំទាវ ប្រាក់ ច័ន្ទណាយ | រដ្ឋលេខាធិការ | ក្រសួងប្រៃសនីយ៍ និងទូរគមនាគមន៍ |
| 10. | ឯកឧត្តម សាត សាមី | រដ្ឋលេខាធិការ | MIME |
| 11. | ឯកឧត្តម សក់ សេដ្ឋា | រដ្ឋលេខាធិការ | MoI |
| 12. | ឯកឧត្តម ឡេង ធនយុទ្ធា | អនុរដ្ឋលេខាធិការ | MoPWT |
| 13. | ឯកឧត្តម ប៊ិន សម្បត្តិថាវ័ត្ន | អនុរដ្ឋលេខាធិការ | MLMUPC |
| 14. | ឯកឧត្តម ជា សំអាង | អគ្គនាយករង | រដ្ឋបាលព្រៃឈើ |
| 15. | ឯកឧត្តម ឡុញ ហ៊ាល | អគ្គនាយក | MoE |
| 16. | ឯកឧត្តម សុខ ចិន្តាសោភា | អគ្គលេខាធិការ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| 17. | ឯកឧត្តម ចាយ សាមិត្ត | ប្រតិភូអមរាជរដ្ឋាភិបាល និងអគ្គនាយក | MoE |
| 18. | លោក ប្រាក់ ថាវអាមិដា | អគ្គលេខាធិការរង | MAFF |
| 19. | លោកបណ្ឌិត ទិន ពន្លក | អគ្គនាយករង | MoE |
| 20. | ឯកឧត្តម គល់ វឌ្ឍនា | អគ្គលេខាធិការរង | CNMC |
| 21. | លោក Julian Abrams | អ្នកសម្របសម្រួលបច្ចេកទេស/ UNCDF-LoCAL | UNCDF p/a UNDP |
| 22. | បណ្ឌិត នេត បារមី | ប្រធានដេប៉ាតឺម៉ង់ទេសចរណ៍ | RUPP |
| 23. | លោក Peter J. Brimble | នាយករងប្រចាំប្រទេស | ADB |

| ល.រ | នាម និងគោត្តនាម | តួនាទី | ស្ថាប័ន |
|---|---|---|---|
| 24. | លោកស្រី Nele Bunner | មន្ត្រីទទួលបន្ទុកកម្មវិធីការពារអាកាសធាតុសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ | GIZ |
| 25. | លោកស្រី ជា អេលីយ៉ាន | អនុប្រធានដេប៉ាតឺម៉ង់វិទ្យាសាស្ត្របរិស្ថាន | RUPP |
| 26. | លោក Julien Chevillard | អ្នកគ្រប់គ្រងរដ្ឋបាលនៃលេខាធិការដ្ឋាន CCCA/UNDP | MoE |
| 27. | លោក Alex Diment | ទីប្រឹក្សាបច្ចេកទេសជាន់ខ្ពស់ | អង្គការអភិរក្សសត្វព្រៃ |
| 28. | លោកស្រី Sanna Salmela-Eckstein | Regional DM Delegate | Asia Finnish Red Cross |
| 29. | លោក Chris Fijkemans | នាយកប្រចាំប្រទេសកម្ពុជា | Oxfam |
| 30. | លោក Koen Everaert | មន្ត្រីទំនាក់ទំនងសហប្រតិបត្តិការនៃតំណាងសហភាពអឺរ៉ុបប្រចាំកម្ពុជា | EU |
| 31. | លោក ហែម ចន្ទន៍ធូ | មន្ត្រីគម្រោងជាន់ខ្ពស់ | CARM |
